

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
### អគ្គលេខាធិការដ្ឋានគណៈកម្មាធិការ
### សម្បទានដីសង្គមកិច្ចថ្នាក់ជាតិ

# សៀវភៅណែនាំប្រតិបត្តិ
# ស្តីពីការអនុវត្ត
# កម្រោងបែងចែកដីដើម្បីសង្គមកិច្ច
# និងការអភិវឌ្ឍសេដ្ឋកិច្ច

រៀបចំដោយកម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច
( ឥណទានលេខ 4441-KH, ជំនួយឥតសំណងលេខ H386-KH )

ខែកញ្ញា ឆ្នាំ២០១០

# សៀវភៅណែនាំប្រតិបត្តិ
# ស្ដីពីការអនុវត្ត
# គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

**ខែ កញ្ញា ឆ្នាំ ២០១០**

# មាតិកា


ក. គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ច ...... ១៤
ក.១ តើគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចជាគម្រោងអ្វី? ...... ១៤
ក.២ គោលបំណងរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច... ១៤
ក.៣ "គោលការណ៍" របស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ...... ១៤
ក.៤ ក្របខ័ណ្ឌច្បាប់ ...... ១៤
ក.៥ សមាសភាគគម្រោង ...... ១៤
ក.៦ រចនាសម្ព័ន្ធគ្រប់គ្រង ...... ១៥
ក.៧ ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ...... ១៥
ក.៨ ការបញ្ជ្រាបយេនឌ័រនៅក្នុងគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ...... ១៦
ក.៩ ដៃគូគម្រោង ...... ១៦
ក.១០ តើនរណាខ្លះជាអ្នកទទួលផលពីគម្រោងនេះ? ...... ១៦
ក.១១ តើនរណាខ្លះដែលមានលក្ខណសម្បត្តិសក្តិសមនឹងទទួល បានដីក្រោមកម្មវិធីសម្បទានដីសង្គមកិច្ចនេះ? ...... ១៦
ក.១២ ប្រភេទដីផ្សេងៗគ្នាដែលបែងចែក ...... ១៧
ខ. ដំណើរការគម្រោងការបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច និងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោង ...... ១៨
ខ.១ តើសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងជាអ្វី? ...... ១៨
ខ.២ ខ្លឹមសារនៃសៀវភៅណែនាំនេះ ...... ១៨
ខ.៣ តើនរណាប្រើប្រាស់សៀវភៅណែនាំនេះ ហើយប្រើប្រាស់របៀបណា? ...... ១៨
ខ.៤ សទ្ទានុក្រម: ការយល់ដឹងពីភាសារបស់គម្រោង ...... ១៨
ខ.៥ វិធីឆ្លើយតបទៅនឹងតម្រូវការព័ត៌មានរបស់គម្រោង ...... ១៩
ខ.៦ តើនណាមានសំណួរអំពីគម្រោងនេះ ...... ១៩
គ. ដំណើរការសម្បទានដីសង្គមកិច្ចដែលមានមូលដ្ឋាននៅតាមឃុំ ...... ២០
ដំណាក់កាលទាំង ១០ នៃដំណើរការសម្បទានដីសង្គមកិច្ច ...... ២០
ពេលវេលាដែលត្រូវការសម្រាប់អនុវត្តន៍ការសម្បទានដីសង្គមកិច្ច ...... ២១
ជំហានទី ១: ផ្តួចផ្តើម ត្រួតពិនិត្យឡើងវិញ និងពិនិត្យកម្មវិធីសម្បទានដីសង្គមកិច្ច ...... ២១
គ.១.១ សំណើសុំសម្បទានដីសង្គមកិច្ច ...... ២១

| | | |
|---|---|---|
| គ.១.២ | ការរៀបចំសំណើសុំជំនួយរៀបចំសម្បទានដីសង្គមកិច្ចដាក់ជូនគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត | ២២ |
| គ.១.៣ | កិច្ចប្រជុំថ្នាក់ខេត្តដើម្បីពិនិត្យសំណើសុំសម្បទានដីសង្គមកិច្ច | ២២ |
| គ ១.៤ | ឃុំចុះទស្សនកិច្ចដើម្បីពិនិត្យសំណើសុំសម្បទានដីសង្គមកិច្ច | ២៤ |
| គ ១.៥ | ការសម្រេចរបស់អភិបាលខេត្តឲ្យបន្តដំណើរការចំណាត់ថ្នាក់ដីរដ្ឋ | ២៤ |
| ជំហានទី ២: | ការរៀបចំឲ្យមានការសិក្សាតាមបច្ចេកទេស | ២៥ |
| ជំហានទី ៣: | ព័ត៌មាន ការលើកកម្ពស់ការយល់ដឹង ការចូលរួម និងការជ្រើសរើសមុខសញ្ញាអ្នកទទួលដី | ២៦ |
| គ ៣.១ | យុទ្ធនាការផ្សព្វផ្សាយព័ត៌មាន | ២៦ |
| គ ៣.២ | ការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រជាមុន | ២៨ |
| គ ៣.៣ | ការវិភាគយេនឌ័រ | ២៨ |
| គ ៣.៤ | កំណត់ដំណើរការ និងលក្ខណវិនិច្ឆ័យសម្រាប់ការជ្រើសរើសមុខសញ្ញាអ្នកទទួលដី | ២៨ |
| ជំហានទី ៤: | ការកំណត់អត្តសញ្ញាណកម្មដីរដ្ឋ ការធ្វើផែនទី ការចាត់ជាប្រភេទ និងការចុះបញ្ជី | ២៩ |
| គ ៤.១ | រៀបចំផែនទីតំបន់សម្បទានដីសង្គមកិច្ច | ២៩ |
| គ ៤.២ | អនុវត្តការស្ទង់មតិទាក់ទងដី ទឹក និងព្រៃ | ៣០ |
| គ ៤.៣ | ស្ទង់មតិលម្អិត និងធ្វើផែនទីតំបន់សម្បទានដែលបានស្នើសុំ | ៣០ |
| គ ៤.៤ | ការបង្ហាញផែនទីព្រាងជាសាធារណៈរយៈពេល ៣០ ថ្ងៃ | ៣១ |
| គ ៤.៥ | ក្រុមការងារថ្នាក់ស្រុករៀបចំរបាយការណ៍ និងអនុសាសន៍សម្រាប់ការធ្វើចំណាត់ថ្នាក់ដីឯកជនរបស់រដ្ឋ | ៣១ |
| គ ៤.៦ | កិច្ចប្រជុំថ្នាក់ខេត្តធ្វើការធ្វើចំណាត់ថ្នាក់ដីឯកជនរបស់រដ្ឋដែលប្រើប្រាស់សម្រាប់សម្បទានដីសង្គមកិច្ច | ៣២ |
| គ ៤.៧ | គណៈកម្មាធិការគ្រប់គ្រងដីសង្គមកិច្ចខេត្តសម្រេចថាតើ ត្រូវបន្តចុះបញ្ជីដីជាដីឯកជនរបស់រដ្ឋសម្រាប់ប្រើប្រាស់ជាសម្បទានដីសង្គមកិច្ច ឬ អត់ | ៣២ |
| គ ៤.៨ | ការវាស់វែងត្រឹមត្រូវនូវព្រំប្រទល់សម្បទានដីសង្គមកិច្ច និងការប្រើប្រាស់ដី | ៣២ |
| គ ៤.៩ | ការបង្ហាញជាសាធារណៈពីការចុះបញ្ជីដីរដ្ឋក្នុងរយៈពេល ៣០ ថ្ងៃ | ៣៣ |
| គ ៤.១០ | ការដាក់ផែនទីកែតម្រូវឲ្យធ្វើការត្រួតពិនិត្យជាចុងក្រោយ | ៣៣ |
| គ ៤.១១ | ការចេញប័ណ្ណដីសម្បទានសង្គមកិច្ចដែលជាដីឯកជនរបស់រដ្ឋសម្រាប់ប្រើប្រាស់ជាដីសម្បទានសង្គមកិច្ច | ៣៣ |
| ជំហានទី ៥ : | ការប្រើប្រាស់ដីរួម និងការធ្វើផែនការហេដ្ឋារចនាសម្ព័ន្ធ | ៣៤ |
| គ ៥.១ | ការវិភាគលម្អិតអំពីប្រព័ន្ធកេ្សត្របរិស្ថានសម្បទានដីសង្គមកិច្ច | ៣៤ |

គ ៥.២ វាយតម្លៃសមត្ថភាពផ្ទុក........................................................................ ៣៥

គ ៥.៣ អនុវត្តការវាយតម្លៃពីសេចក្តីត្រូវការហេដ្ឋារចនាសម្ព័ន្ធ ..................................... ៣៥

គ ៥.៤ ពិនិត្យឡើងវិញ និងការកែសម្រួលការការពារបរិស្ថាន និងសង្គមជាលើកដំបូង ........................................................................................ ៣៦

គ ៥.៥ សិក្ខាសាលាសាធារណៈស្តីពីលទ្ធផលនៃធ្វើផែនការដែលមានការចូលរួម .......... ៣៦

ជំហានទី ៦: ការត្រួតពិនិត្យឡើងវិញ និងការអនុម័តរបាយការណ៍សម្បទាន ដីសង្គមកិច្ចថ្នាក់ឃុំ........................................................................................................៣៧

គ ៦.១ ប៉ាន់តម្លៃមូលនិធិដែលត្រូវការសម្រាប់សកម្មភាពនៃសមាសភាគទី ២...............៣៧

គ ៦.២ ត្រួតពិនិត្យការការពារសុវត្ថិភាព និងភាពស្របគ្នាជាមួយនឹងក្របខ័ណ្ឌច្បាប់....... ៣៨

គ ៦.៣ ការអនុម័តរបាយការណ៍សម្បទានដីសង្គមកិច្ចថ្នាក់ឃុំ ..................................... ៣៨

គ ៦.៤ ការកែសម្រួល និងការផ្តល់សិទ្ធិឲ្យបន្តរៀបចំផែនការសម្បទានដីសង្គមកិច្ចច្បាស់លាស់ ........................................................................................ ៣៩

ជំហានទី ៧: ការជ្រើសរើសអ្នកទទួលដី........................................................................ ៣៩

គ ៧.១ ការជូនដំណឹង និងការលើកកម្ពស់ការយល់ដឹងពីការដាក់ពាក្យសុំ និងលក្ខណវិនិច្ឆ័យលើភាពសមស្រប........................................................................ ៤០

គ ៧.២ ការទទួលពាក្យ..................................................................................... ៤០

គ ៧.៣ ការដាក់បង្ហាញជាសាធារណៈនូវបញ្ជីពាក្យស្នើសុំ............................................. ៤១

គ ៧.៤ ការជ្រើសរើសអ្នកទទួលដីដែលមានសក្តានុពល ................................................ ៤២

គ ៧.៥ ការដាក់បង្ហាញជាសាធារណៈនូវឈ្មោះអ្នកទទួលទទួលដី/ពាក្យបណ្តឹងតវ៉ាដែលមានសក្តានុពល ........................................................................................ ៤២

គ ៧.៦ ការផ្តល់សុពលភាពទៅលើព័ត៌មានស្តីពីទម្រង់ពាក្យស្នើសុំ.............................. ៤៣

គ ៧.៧ ការដាក់បង្ហាញជាសាធារណៈនូវបញ្ជីដំណោះស្រាយពាក្យបណ្តឹងតវ៉ា និងបញ្ជីដែលកែតម្រូវ......................................................................................... ៤៤

គ ៧.៨ ការប្រជុំតាមភូមិស្តីពីលទ្ធផលនៃការផ្តល់សុពលភាព........................................ ៤៤

គ ៧.៩ ការជ្រើសរើសអ្នកទទួលដី...................................................................... ៤៥

ជំហានទី ៨: ការរៀបចំផែនការសម្បទានដីសង្គមកិច្ចច្បាស់លាស់......................................... ៤៦

គ ៨.១ ការរៀបចំធ្វើផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម .................................. ៤៦

គ ៨.២ ការចាប់ឆ្នោតយកលេខក្បាលដី.............................................................. ៤៧

គ ៨.៣ ការធ្វើផែនការហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មជនបទ........................................ ៤៨

គ ៨.៤ ចងក្រង និងអនុម័តគម្រោងសម្បទានដីសង្គមកិច្ចច្បាស់លាស់ .......................... ៥០

ជំហានទី ៩: ការរៀបចំក្បាលដី និងទីតាំងលំនៅឋានសម្បទានដីសង្គមកិច្ច........................... ៥១

គ ៩.១ ការរៀបចំទីតាំង ...................................................................................... ៥១

គ ៩.២ ការរៀបចំជំនួយឧបត្ថម្ភសម្រាប់ការចូលតាំងទីលំនៅថ្មី ........ ៥២

គ ៩.៣ មុននឹងប្រគល់ដីដល់អ្នកទទួលដី ........ ៥២

គ ៩.៤ ការប្រគល់ដីជាផ្លូវការដល់អ្នកទទួលដី ........ ៥៣

ជំហានទី ១០: ជំនួយឧបត្ថម្ភសម្រាប់ការចូលតាំងទីលំនៅថ្មី និងការអភិវឌ្ឍជនបទរយៈពេលវែង ........ ៥៤

គ ១០.១ ជំនួយឧបត្ថម្ភសម្រាប់ការចូលតាំងទីលំនៅថ្មី ........ ៥៤

គ ១០.២ ការអភិវឌ្ឍជនបទរយៈពេលវែង ........ ៥៥

ឃ. សមាសភាគទី ២ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច: ហេដ្ឋារចនា សម្ព័ន្ធ និងសេវាកម្មជនបទ ........ ៥៦

ឃ ១ បរិយាយទូទៅអំពីសមាសភាគទី ២ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ........ ៥៦

ឃ ១.១ តើសមាសភាគទី ២ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ជាអ្វី? ........ ៥៦

ឃ ១.២ ការចំណាយចាំបាច់ ........ ៥៦

ឃ ១.៣ ការសម្រេចផ្តល់ជំនួយបន្ត ........ ៥៦

ឃ ១.៤ រូបមន្តវិភាជន៍ថវិកា ........ ៥៧

ឃ ១.៥ វិធីសាស្រ្តការអនុវត្ត ........ ៥៧

ឃ ២ ការរៀបចំទីតាំងដី ........ ៥៨

ឃ ២.១ ផ្លូវប្រើប្រាស់បានគ្រប់រដូវកាល ........ ៥៨

ឃ ២.២ ផ្លូវចូល ........ ៥៩

ឃ ២.៣ ការរៀបចំដី ........ ៥៩

ឃ ២.៤ ការកំណត់ព្រំក្បាលដី ........ ៥៩

ឃ ២.៥ ការផ្គត់ផ្គង់ទឹកនៅជនបទ ........ ៦០

ឃ ៣ កញ្ចប់សម្ភារៈមូលដ្ឋាន និងជំនួយឧបត្ថម្ភសម្រាប់ការចូលតាំងទីលំនៅថ្មី ........ ៦០

ឃ ៣.១ ការចាប់ផ្តើមផ្តល់ កញ្ចប់សម្ភារៈ ដីលំនៅឋាន ........ ៦១

ឃ ៣.២ ការចាប់ផ្តើមផ្តល់កញ្ចប់សម្ភារៈ ដីកសិកម្ម ........ ៦១

ឃ ៣.៣ ជំនួយឧបត្ថម្ភសម្រាប់ការចូលតាំងទីលំនៅថ្មី ........ ៦១

ឃ ៤ ការចំណាយលើសេវាកម្មដែលចាំបាច់ ........ ៦១

ឃ ៤.១ យុទ្ធនាការស្តីពីការប្រើប្រាស់ទឹក និងការអប់រំផ្នែកអនាម័យ ........ ៦២

ឃ ៤.២ សេវាឧបត្ថម្ភផ្នែកកសិកម្ម ........ ៦២

ឃ ៤.៣ ការឧបត្ថម្ភផ្នែកសុខភាព ........ ៦៣

ឃ ៥ ការចំណាយថវិកាសម្រេចផ្តល់ជំនួយបន្ត: ហេដ្ឋារចនាសម្ព័ន្ធជនបទ ........ ៦៣

ឃ ៥.១ សាលារៀន ........ ៦៣

ឃ ៥.២ រចនាសម្ព័ន្ធប្រភេទផ្សេងទៀត ........ ៦៣

ឃ ៦ ការចំណាយថវិកាសម្រេចផ្តល់ជំនួយបន្ថ: សេវាកម្មជនបទ ........ ៦៤

ឃ ៦.១ ការឧបត្ថម្ភច្រើនមុខលើផ្នែកកសិកម្ម ........ ៦៤

ឃ ៦.២ កម្មវិធីសន្សំប្រាក់ ........ ៦៥

ឃ ៦.៣ សេវាផ្សេងៗទៀត ........ ៦៦

ង. សមាសភាគទី ៣ : ការអភិវឌ្ឍកម្មវិធីប្រកបដោយចីរភាព និងតម្លាភាព ........ ៦៧

ង ១ តើមានអ្វីខ្លះក្នុងសមាសភាគទី ៣ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច? ........ ៦៧

ង ២ តួនាទី និងការទទួលខុសត្រូវនៅថ្នាក់ជាតិ ........ ៦៧

ង ២.១ គណៈកម្មាធិការសម្បទានដីសង្គមថ្នាក់ជាតិ ........ ៦៧

ង ២.២ នាយកគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ........ ៦៨

ង ២.៣ អគ្គលេខាធិកាដ្ឋានសម្បទានដីសង្គមកិច្ច ........ ៦៨

ង ២.៤ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ........ ៧០

ង ២.៥ នាយកអង្គភាពគាំទ្រកម្មវិធីរបស់គណៈកម្មាធិការជាតិសម្រាប់ការ អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ........ ៧១

ង ២.៦ ប្រធានសម្របសម្រួលគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ........ ៧២

ង ២.៧ ក្រុមការងារគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ........ ៧៣

ង ៣ តួនាទី និងការទទួលខុសត្រូវថ្នាក់ខេត្ត ស្រុក និងឃុំ ........ ៧៤

ង ៣.១ អភិបាលខេត្ត ........ ៧៤

ង ៣.២ គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ........ ៧៤

ង ៣.៣ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ........ ៧៦

ង ៣.៤ ក្រុមការងារគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចថ្នាក់ខេត្ត ........ ៧៦

ង ៣.៥ គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត ........ ៧៦

ង ៣.៦ ផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាល គណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិ ការអភិវឌ្ឍជនបទខេត្ត ........ ៧៧

ង ៣.៧ ផ្នែកហិរញ្ញវត្ថុ គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍ ជនបទខេត្ត ........ ៧៨
ង ៣.៨ ផ្នែករដ្ឋបាលមូលដ្ឋាននៃគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍ ជនបទខេត្ត ........ ៧៨
ង ៣.៩ ផ្នែកគាំទ្របច្ចេកទេស គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍ ជនបទខេត្ត ........ ៧៩
ង ៣.១០ មន្ទីរកិច្ចការនារីខេត្ត ........ ៧៩
ង ៣.១១ ក្រុមការងារថ្នាក់ស្រុក ........ ៨០
ង ៣.១២ ក្រុមការងារថ្នាក់ស្រុករបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ប្រចាំស្រុក ........ ៨១
ង ៣.១៣ ក្រុមប្រឹក្សាឃុំ ........ ៨១
ង ៣.១៤ ក្រុមការងារសម្បទានដីសង្គមកិច្ចថ្នាក់ឃុំ ........ ៨២
ង ៣.១៥ សហគមន៍អ្នកទទួលដី ........ ៨៣
ង ៣.១៦ អង្គការសង្គមស៊ីវិល ........ ៨៣
ង ៤ ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃ ........ ៨៤
ង ៥ ការកសាងសមត្ថភាព ........ ៨៥
ច. សមាសភាគទី ៤ : ការគ្រប់គ្រងគម្រោង និងការងាររដ្ឋបាល ........ ៨៦
ច. ១ ការរៀបចំផែនការប្រតិបត្តិការ និងគម្រោងថវិកា ........ ៨៦
ច. ១.១ ការចំណាយរបស់គម្រោងទៅតាមសមាសភាគ ........ ៨៦
ច ១.២ ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ........ ៨៩
ច ១.៣ ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំថ្នាក់ខេត្តរបស់គម្រោងបែងចែកដី ដើម្បី សង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ........ ៨៩
ច ១.៤ ការរៀបចំធ្វើកិច្ចសន្យា ........ ៩០
ច ១.៤.១ គោលការណ៍ទូទៅ ........ ៩០
ច ១.៤.២ កិច្ចសន្យាសម្បទានដីសង្គមកិច្ចខេត្ត ........ ៩១
ច ១.៤.៣ អនុកិច្ចសន្យា ........ ៩២
ច ២ ការគ្រប់គ្រងធនធានមនុស្ស ........ ៩២
ច ២.១ ការជ្រើសរើស និងការគ្រប់គ្រងបុគ្គលិកថ្នាក់ជាតិ ........ ៩២
ច. ៣ ការគ្រប់គ្រងហិរញ្ញវត្ថុ ........ ៩៣
ច ៣.១ ការគ្រប់គ្រងហិរញ្ញវត្ថុនៅថ្នាក់ជាតិ ........ ៩៣
ច ៣.២ នីតិវិធីចំណាយនៅថ្នាក់ជាតិ ........ ៩៤

| | | |
|---|---|---|
| ច ៣.៣ | នីតិវិធីគណនេយ្យនៅថ្នាក់ជាតិ | ៩៥ |
| ច ៣.៤ | នីតិវិធីធ្វើរបាយការណ៍ហិរញ្ញវត្ថុនៅថ្នាក់ជាតិ - សូមមើលសៀវភៅណែនាំពីការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ព័ត៌មានលម្អិត | ៩៦ |
| ច ៣.៥ | ការគ្រប់គ្រងហិរញ្ញវត្ថុនៅថ្នាក់ក្រោមជាតិ | ៩៦ |
| ច ៣.៦ | នីតិវិធីចំណាយ | ៩៧ |
| ច ៣.៧ | នីតិវិធីគណនេយ្យនៅថ្នាក់ក្រោមជាតិ | ៩៨ |
| ច ៣.៨ | នីតិវិធីការធ្វើរបាយការណ៍ហិរញ្ញវត្ថុនៅថ្នាក់ក្រោមជាតិ | ៩៨ |
| ច ៤ | លទ្ធកម្ម | ៩៩ |
| ច ៤.១ | ទិដ្ឋភាពទូទៅ | ៩៩ |
| ច ៤.២ | ការទទួលខុសត្រូវចំពោះលទ្ធកម្ម | ១០១ |
| ច ៤.៣ | វិធីសាស្ត្រលទ្ធកម្ម | ១០៣ |
| ច ៤.៤ | លទ្ធកម្មលើហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មជនបទ | ១០៥ |
| ច ៤.៤.១ | ទិដ្ឋភាពទូទៅ | ១០៥ |
| ច ៤.៤.២ | ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មដែលធ្វើកិច្ចសន្យាផ្ទាល់ដោយឃុំ | ១០៥ |
| ច ៤.៤.៣ | ការអនុវត្តវិស័យផ្នែកសេវាកម្ម: ថ្លៃចំណាយប្រតិបត្តិការ | ១០៥ |
| ច ៦ | ការត្រួតពិនិត្យតាមដាន និងការធ្វើរបាយការណ៍ | ១០៦ |

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ ១ ក:សេចក្តីណែនាំសម្រាប់ការពិនិត្យលក្ខណវិនិច្ឆ័យតំបន់អភិរក្សធម្មជាតិ ......... ១០៨
ឧបសម្ព័ន្ធ ១ ខ:ដំណើរការថ្នាក់ឃុំសម្រាប់កំណត់អត្តសញ្ញាណកម្មតំបន់ធ្វើកសិកម្មការពិនិត្យ គោលការណ៍ណែនាំស្តីពីព្រៃឈើ (មុខងារ) ដែលខូចខាត/ មិនទាន់ខូចខាត ........ ១១០
ឧបសម្ព័ន្ធ ២ : រូបមន្តវិភាជន៍ថវិកាសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មជនបទ............... ១១៥
ឧបសម្ព័ន្ធ ៣ : បទដ្ឋានបច្ចេកទេសសម្រាប់ការរៀបចំដី ........ ១១៦
ឧបសម្ព័ន្ធ ៤ : លក្ខខណ្ឌយោង: មុខតំណែងនៅក្នុងអគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច........ ១៣១
ឧបសម្ព័ន្ធ ៥ : លក្ខខណ្ឌយោង: មុខតំណែងនៅក្នុងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប)........ ១៦៣
ឧបសម្ព័ន្ធ ៦ : លក្ខខណ្ឌយោង: មុខតំណែងក្នុង គណៈកម្មធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត........ ២០៩
ឧបសម្ព័ន្ធ ៧ : លក្ខខណ្ឌយោង: មុខតំណែងនៅថ្នាក់គណៈកម្មាធិការប្រតិបត្តិ.................... ២៣០
ឧបសម្ព័ន្ធ ៨ : លក្ខខណ្ឌយោង: មុខតំណែងនៅថ្នាក់ស្រុក........ ២៤៥
ឧបសម្ព័ន្ធ ៩ : លក្ខខណ្ឌយោង: ជំនួយការស្មៀនឃុំ ........ ២៦១

# ទម្រង់បែបបទ


ទម្រង់ទី ១ : ទម្រង់ពាក្យស្នើសុំសម្បទានដីសង្គមកិច្ច ..................................................២៦៤

ទម្រង់ទី ២ : ទម្រង់ពាក្យស្នើសុំចុះបញ្ជីសម្បទានដីសង្គមកិច្ច ..........................................២៦៦

ទម្រង់ទី ៣ : ទម្រង់ស្នើសុំជំនួយសម្បទានដីសង្គមកិច្ច ..................................................២៦៧

ទម្រង់ទី ៤ : ទម្រង់ត្រួតពិនិត្យការការពារសុវត្ថិភាពសង្គម របស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ..........................................................២៦៩

ទម្រង់ទី ៥ : ទម្រង់ត្រួតពិនិត្យការការពារបរិស្ថាន ........................................................២៧៦

ទម្រង់ទី ៦: លិខិតផ្តល់សិទ្ធិរបស់អភិបាលខេត្តៈ បន្តដំណើរការធ្វើ ចំណាត់ថ្នាក់ដីរដ្ឋ..........................................................................................២៨៧

ទម្រង់ទី ៧ : បញ្ជីត្រួតពិនិត្យការវាយតម្លៃប្រព័ន្ធក្បេត្រុបរិស្ថាន .........................................២៨៨

ទម្រង់ទី ៨ : ទម្រង់អនុវត្តប្រព័ន្ធក្បេត្រុបរិស្ថាន ...............................................................២៩០

ទម្រង់ទី ៩ : លក្ខណវិនិច្ឆ័យពីភាពសមស្របសម្រាប់ការចូលរួមក្នុងគម្រោងសម្បទានដីសង្គមកិច្ច..............................................................................២៩២

ទម្រង់ទី ១០: ទម្រង់កំណត់ចំណាត់ថ្នាក់អ្នកស្នើសុំ.........................................................២៩៦

ទម្រង់ទី ១១ : ការទទួលខុសត្រូវរបស់មុខសញ្ញាអ្នកទទួលដី ..........................................២៩៨

ទម្រង់ទី ១២ : ទម្រង់ជូនដំណឹងដល់អ្នកស្នើសុំដី ...........................................................២៩៩

ទម្រង់ទី ១៣ : គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចៈ ទម្រង់របាយការណ៍វិភាគយេនឌ័រ ............................................................៣០០

ទម្រង់ទី ១៤ : ទម្រង់ពាក្យបណ្តឹងតវ៉ាៈ តំបន់សម្បទានដីសង្គមកិច្ចដែលបានស្នើសុំ ..........៣០៣

ទម្រង់ទី ១៥ : ទម្រង់ចុះបញ្ជីពាក្យបណ្តឹងៈ តំបន់សម្បទានដីសង្គមកិច្ចដែលបានស្នើសុំ...........................................................................................៣០៤

ទម្រង់ទី ១៦ : ទម្រង់ពាក្យបណ្តឹងតវ៉ាៈផែនទីសម្បទានដីសង្គមកិច្ចដែលបានេស្នើសុំ .........៣០៥

ទម្រង់ទី ១៧ : ទម្រង់ចុះបញ្ជីពាក្យបណ្តឹងៈ ផែនទីសម្បទានដីសង្គមកិច្ចដែលបានស្នើសុំ...........................................................................................៣០៦

ទម្រង់ទី ១៨ : របាយការណ៍ស្តីពីផែនការសម្បទានដីសង្គមកិច្ច ........................................៣០៧

ទម្រង់ទី ១៩ : ការវាយតម្លៃអំពីតម្រូវការហេដ្ឋារចនាសម្ព័ន្ធ.............................................. ៣១២

ទម្រង់ទី ២០ : គណនាការវិភាជន៍មូលនិធិសម្រាប់ ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មជនបទ .....................................................................................៣១៦

ទម្រង់ទី ២១ : បញ្ជីសម្រាប់ការត្រួតពិនិត្យឡើងវិញរបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត លើរបាយការណ៍សម្បទានដីសង្គមកិច្ចលើកដំបូង ...........................................................................................៣១៨

ទម្រង់ទី ២២: លិខិតបញ្ជាក់ការផ្តល់សិទ្ធិរបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដី ថ្នាក់ខេត្តៈ របាយការណ៍សម្បទានដីសង្គមកិច្ចលើកដំបូង..........................៣២៣
ទម្រង់ទី ២៣: ទម្រង់ដាក់ពាក្យបណ្តឹងតវ៉ាៈ បញ្ជីជ្រើសរើសមុខសញ្ញា អ្នកទទួលដីដំបូង ........................................................................... ៣២៥
ទម្រង់ទី ២៤: ទម្រង់បែបបទចុះបញ្ជីពាក្យបណ្តឹង-បញ្ជីពាក្យស្នើសុំសម្បទានដីសង្គមកិច្ច លើកដំបូង .................................................................................... ៣២៦
ទម្រង់ទី ២៥ : គំរូវិធីសាស្ត្រចែកចំណាត់ថ្នាក់អ្នកដាក់ពាក្យទម្រង់បែងចែកចំណាត់ថ្នាក់អ្នក ដាក់ពាក្យ ....................................................................................៣២៧
ទម្រង់ទី ២៦ : បញ្ជីឈ្មោះអ្នកដាក់ពាក្យសុំសម្បទានដីសង្គមកិច្ចដែលមានអាទិភាព.......... ៣២៩
ទម្រង់ទី ២៧ : ទម្រង់បែបបទបណ្តឹងៈ បញ្ជីឈ្មោះអ្នកដាក់ពាក្យសុំសម្បទានដីសង្គមកិច្ច ដែលមានអាទិភាព.......................................................................៣៣០
ទម្រង់ទី ២៨ : ទម្រង់ចុះបញ្ជីពាក្យបណ្តឹងៈការចែកចំណាត់ថ្នាក់ មុខសញ្ញា អ្នកទទួលដី....................................................................................៣៣១
ទម្រង់ទី ២៩ : ទម្រង់បង្ហាញពីការបែងចែកដីក្រោមគម្រោងសម្បទានដីសង្គមកិច្ច.............៣៣២
ទម្រង់ទី ៣០ : បញ្ជីសម្រាប់ការពិនិត្យឡើងវិញរបស់គណៈកម្មាធិការប្រើប្រាស់ និង បែងចែក ដីថ្នាក់ខេត្តលើផែនការសម្បទានដីសង្គមកិច្ចច្បាស់លាស់......................... ៣៣៣
ទម្រង់ទី ៣១ : ទម្រង់ទទួលបានសម្រាប់ធនធានសំខាន់ៗផ្សេងទៀត.............................. ៣៣៧
ទម្រង់ទី ៣២ : លិខិតផ្តល់សិទ្ធិរបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តៈ ផែនការផែនការសម្បទានដីសង្គមកិច្ចច្បាស់លាស់ ...................................៣៣៨
ទម្រង់ទី ៣៣ : ទម្រង់កំណត់ព្រំក្បាលដី.................................................................៣៤០
ទម្រង់ទី ៣៤ : ទម្រង់ស្នើសុំប្រើប្រាស់ដីមុនពេលប្រគល់ .......................................៣៤១
ទម្រង់ទី ៣៥ : **ទម្រង់ផ្តល់សិទ្ធិឲ្យប្រើប្រាស់ដីមុនពេល**ប្រគល់.............................................៣៤២
ទម្រង់ទី ៣៦ : **កិច្ចសន្យាប្រគល់ដី** ……………………………………………...........…....... ៣៤៣
ទម្រង់ទី៣៧ : **ទម្រង់**ផ្តល់ជំនួយឧបត្ថម្ភសម្រាប់ការចូលតាំងទីលំនៅថ្មី…....…................... ៣៤៧

**ពាក្យបំព្រួញអាត់**

| | |
|---|---|
| AWPB | ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ |
| AGRO-ECOSYSTEM | ប្រព័ន្ធកសិរុក្ខរុក្ខបរិស្ថាន |
| CAU | ផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាលគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត |
| CDP | ផែនការអភិវឌ្ឍឃុំ |
| CLP | ក្រុមប្រឹក្សាគោលនយោបាយដីធ្លី |
| CLUP | ផែនការប្រើប្រាស់ដីថ្នាក់ឃុំ |
| CMAC | មជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីនកម្ពុជា |
| CSO | អង្គការសង្គមស៊ីវិល |
| DAE | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |
| DAO | ការិយាល័យកសិកម្មស្រុក |
| DFT | មន្ត្រីសម្របសម្រួលថ្នាក់ស្រុក |
| DWG | ក្រុមការងារថ្នាក់ស្រុក |
| FA | ខណ្ឌរដ្ឋបាលព្រៃឈើ |
| FU | ផ្នែកហិរញ្ញវត្ថុ |
| GDCG | អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ |
| GIS | ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ |
| GPS | ឧបករណ៍កំណត់ទីតាំងភូគោលសាស្ត្រ |
| GSSLC | អគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច |
| GTZ | ភ្នាក់ងារបច្ចេកទេសអាឡឺម៉ង់ |
| HEF | មូលនិធិសមធម៌ដើម្បីសុខភាព |
| IDA | សមាគមអភិវឌ្ឍអន្តរជាតិ |
| IPA | ទីភ្នាក់ងារលទ្ធកម្មអន្តរជាតិ |
| IPM | ការគ្រប់គ្រងសត្វល្អិតរួមបញ្ចូលគ្នា |
| LASED | គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច |
| LAU | ផ្នែករដ្ឋបាលមូលដ្ឋាន គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត |
| LR | អ្នកទទួលដី |
| LRC | សហគមន៍អ្នកទទួលដី |

| | |
|---|---|
| M&E | ត្រួតពិនិត្យតាមដាន និងវាយតម្លៃ |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MLMUPC | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| MoC | ក្រសួងពាណិជ្ជកម្ម |
| MoH | ក្រសួងសុខាភិបាល |
| MoWA | ក្រសួងកិច្ចការនារី |
| MOWRAM | ក្រសួងធនធានទឹក និងឧតុនិយម |
| NCDD | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) |
| NCSLC | គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| PBC | គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ |
| PDA | មន្ទីរកសិកម្មខេត្ត |
| PDLMUPCC | មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្ត |
| PDoW | មន្ទីរកិច្ចការនារីខេត្ត |
| PDSA | មន្ទីរសង្គមកិច្ចខេត្ត |
| PFT | មន្ត្រីសម្របសម្រួលខេត្ត |
| PIM | សៀវភៅណែនាំការអនុវត្តគម្រោង |
| PLUAC | គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត |
| PRDC-ExCom | គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត |
| RGC | រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា |
| SLC | សម្បទានដីសង្គមកិច្ច |
| SLM | ការគ្រប់គ្រងដីសង្គមកិច្ច |
| TLR | មុខសញ្ញាអ្នកទទួលដី |
| TOR | លក្ខខណ្ឌយោង |
| TSU | ផ្នែកគាំទ្របច្ចេកទេស |
| DCA | គណនីរូបិយវត្ថុកំណត់ |

## ក. គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ច

### *ក.១ តើគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចជាគម្រោងអ្វី?*

គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គាំទ្រដល់កម្មវិធីសម្បទានដីសង្គមកិច្ចរបស់រាជរដ្ឋាភិបាលដែលបែងចែកដីលំនៅឋាន និងដីធ្វើកសិកម្មជាលក្ខណៈគ្រួសារដល់អ្នកក្រីក្រ អ្នកគ្មានដី និងអ្នកមានដីតិចតួចដើម្បីធ្វើឲ្យប្រសើរឡើងនូវជីវភាពរបស់ពួកគេ។ គម្រោងនេះអនុវត្តការធ្វើសម្បទានដីសង្គមកិច្ចដែលមាននៅតាមមូលដ្ឋានឃុំ ដែលការផ្តល់ដីនោះត្រូវបានផ្តួចផ្តើមឡើងដោយឃុំ និងសមាជិករបស់ពួកគេ។

### *ក.២ គោលបំណងរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច*

- បែងចែកដីរដ្ឋសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ រួមជាមួយនឹងការផ្តល់សេវាគាំទ្រចំពោះគ្រួសារដែលមានលក្ខណសម្បត្តិសមស្របដែលក្រីក្រ គ្មានដី និងមានដីតិចតួច និង
- ណែនាំ និងអនុវត្តដំណើរការឲ្យមានតម្លាភាព និងស្របតាមបទដ្ឋានដើម្បីអនុវត្តឲ្យបានទូលំទូលាយនូវសម្បទានដីសង្គមកិច្ច ដែលផ្តួចផ្តើមឡើងដោយមូលដ្ឋាន។

### *ក.៣ "គោលការណ៍" របស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច*

- លើកកម្ពស់អភិបាលកិច្ចល្អ និងនីតិរដ្ឋ
- គាំទ្រ និងពង្រឹងរបៀបវារៈសម្រាប់ការធ្វើកំណែទម្រង់ដីធ្លីរបស់រដ្ឋាភិបាល
- ជំរុញការចូលរួមពីប្រជាពលរដ្ឋ
- ទប់ស្កាត់ការខូចខាតបរិស្ថាន
- លើកកម្ពស់តម្លាភាព និងគណនេយ្យភាព និង
- ធានាឲ្យមានកំណើនប្រកបដោយនិរន្តរភាព

### *ក.៤ ក្របខ័ណ្ឌច្បាប់*

គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចពឹងផ្អែកទាំងស្រុងទៅលើច្បាប់ និងគោលនយោបាយបច្ចុប្បន្នរបស់រដ្ឋាភិបាល។

### *ក.៥ សមាសភាគគម្រោង*

គម្រោងបែងចែកដីដើម្បីសង្គមកិច្ចនិងការអភិវឌ្ឍសេដ្ឋកិច្ចមានសមាសភាគចំនួន ៤ ខុសៗគ្នា:

១. ការធ្វើផែនការសម្បទានដីសង្គមកិច្ច និងការបែងចែកដីថ្នាក់ឃុំ

២. ហេដ្ឋារចនាសម្ព័ន្ធជនបទ និងការផ្តល់សេវាកម្មគាំទ្រសម្បទានដីសង្គមកិច្ច
៣. ការអភិវឌ្ឍកម្មវិធីសម្បទានដីសង្គមកិច្ចប្រកបដោយតម្លាភាព និងនិរន្តរភាព និង
៤. ការគ្រប់គ្រងរដ្ឋបាលគម្រោង។

## ក.៦ រចនាសម្ព័ន្ធគ្រប់គ្រង

គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចគាំទ្រដល់ក្រុមប្រឹក្សាឃុំឲ្យមានលទ្ធភាពឆ្លើយតបទៅនឹងតម្រូវការរបស់មុខសញ្ញាអ្នកទទួលដី។

ក្រុមប្រឹក្សាឃុំត្រូវបានគាំទ្រដោយក្រុមការងារថ្នាក់ស្រុក និងស្ថាប័នផ្សេងៗទៀត។ សេចក្តីលម្អិតស្តីពីតួនាទី និងការទទួលខុសត្រូវនានារបស់ស្ថាប័ននីមួយៗ និងការរៀបចំការងាររដ្ឋបាល គឺមានពិពណ៌នានៅក្នុងសមាសភាគទី ៣ នៃសៀវភៅណែនាំអនុវត្តនេះ។

ចំណុចរួមរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺធ្វើការផ្តល់អំណាចជូនក្រុមប្រឹក្សាឃុំឲ្យធ្វើការគាំទ្រដល់សមាជិករបស់ខ្លួនតាមរយៈការផ្តល់ការគាំទ្របច្ចេកទេស និងការគ្រប់គ្រងដែលចាំបាច់សម្រាប់ឆ្លើយតបទៅនឹងតម្រូវការរបស់មុខសញ្ញាអ្នកទទួលដី។

ក្រុមប្រឹក្សាឃុំទទួលបានការជួយជ្រោមជ្រែងពីក្រុមការងារថ្នាក់ស្រុក។ ការគាំទ្របច្ចេកទេស និងរដ្ឋបាលដែលក្រុមការងារថ្នាក់ស្រុកត្រូវការដើម្បីជួយដល់ក្រុមប្រឹក្សាឃុំឲ្យប្រកបដោយប្រសិទ្ធភាព ត្រូវបានផ្តល់ឲ្យដោយស្ថាប័នមួយចំនួនធំនៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ។ ក្រុមការងារថ្នាក់ស្រុកទទួលបានការជួយគាំទ្រពីគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តទាក់ទងនឹងគោលនយោបាយ និងការងារផ្នែកច្បាប់ពាក់ព័ន្ធនឹងការធ្វើសម្បទានដីសង្គមកិច្ច និងទទួលបានពីគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត ទាក់ទងនឹងបញ្ហាហិរញ្ញវត្ថុ និងប្រតិបត្តិការ។ នៅថ្នាក់ជាតិប្រតិបត្តិការទទួលបានការគាំទ្រពីគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ពាក់ព័ន្ធនឹងបញ្ហាលទ្ធកម្ម និងហិរញ្ញវត្ថុ។ ហើយគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ទទួលបានការគាំទ្រពីអគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ចទាក់ទងនឹងការងារអនុវត្តតាមបច្ចេកទេស។

## ក.៧ ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចអនុវត្តវិធីសាស្ត្រគ្រប់គ្រងការចូលរួម "**ពីថ្នាក់ក្រោមឡើងលើ**" តាមរយៈការផ្តល់អំណាចដល់ក្រុមប្រឹក្សាឃុំ និងមុខសញ្ញាអ្នកទទួលដី។ អង្គការសង្គមស៊ីវិល និងក្រុមសហគមន៍ គឺជាដៃគូដ៏សំខាន់ក្នុងការជួយគាំទ្រដល់ការអនុវត្តគម្រោងនេះក្នុងលក្ខណៈដែលមានតម្លាភាព និងមានការចូលរួម។

### ក.៨ ការបញ្ជ្រាបយេនឌ័រនៅក្នុងគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចមានគោលបំណងទប់ស្កាត់ការរើសអើង និងភាពលំអៀងប្រឆាំងស្ត្រីក្រីក្រក្នុងការបែងចែកដី និងធានាថា តម្រូវការជាក់លាក់របស់ស្ត្រីនៅក្នុងដំណើរការសម្បទានដីសង្គមកិច្ចត្រូវបានដោះស្រាយ។

### ក.៩ ដៃគូគម្រោង

មើលនៅក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងទាំងមូល។

### ក.១០ តើនរណាខ្លះជាអ្នកទទួលផលពីគម្រោងនេះ?

អ្នកទទួលផលពីគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺប្រជាពលរដ្ឋក្រីក្រ ប្រជាពលរដ្ឋគ្មានដី ប្រជាពលរដ្ឋមានដីតិចតួច និងសហគមន៍ដែលពួកគាត់រស់នៅ។

### ក.១១ តើនរណាខ្លះដែលមានលក្ខណសម្បត្តិសក្តិសមនឹងទទួលបានដីក្រោមកម្មវិធីសម្បទានដីសង្គមកិច្ចនេះ?

គ្រួសារមួយអាចមានលក្ខណសម្បត្តិសក្តិសមនឹងទទួលបានដី ប្រសិនបើប្តី ឬ ប្រពន្ធនោះ ៖

- មានសញ្ជាតិខ្មែរ
- ជាមេគ្រួសារដែលមានសមាជិកពីរ ឬ ច្រើននាក់រស់នៅក្នុងផ្ទះតែមួយ
- រកបានប្រាក់ចំណូលតិចជាង២០០០៛/ថ្ងៃ/ម្នាក់ ឬ តិចជាង ២៥០០៛/ថ្ងៃ/ម្នាក់នៅក្នុងតំបន់ទីប្រជុំជន ឬ នៅតំបន់ជនបទ
- មិនមែនជាម្ចាស់ដីផ្សេងៗទៀត (ដែលដីទំហំអតិបរមាលើសពីការកំណត់ក្នុងបទបញ្ញត្តិ)[1]
- ត្រៀមខ្លួនជាស្រេច ស្ម័គ្រចិត្ត និងមានសមត្ថភាពចូលរួមក្នុងកម្មវិធីសម្បទានដីសង្គមកិច្ចស្របតាមផែនការសម្បទានដីសង្គមកិច្ចដែលបានអនុម័ត
- អ្នកមានពិការភាព
- អតីតយុទ្ធជនពិការ និង
- ទាហានរំសាយ។

---

[១] អនុក្រិត្យលេខ ១៩ ស្តីពីសម្បទានដីសង្គមកិច្ច មាត្រា ១៦ និង ១៧។ ដីដែលមានការអនុញ្ញាត គឺមានកំណត់ដូចខាងក្រោម: ដីលំនៅឋានក្នុងទីប្រជុំជន = មួយពាន់ពីររយម៉ែត្រការ៉េ (១២០០ម$^២$) ដីលំនៅឋានតាមជនបទ = បីពាន់ប្រាំមួយរយម៉ែត្រការ៉េ (៣៦០០ម$^២$)។ ដីធ្វើកសិកម្មលក្ខណៈគ្រួសារ = ២ – ៥ហិកតា អាស្រ័យទៅលើលក្ខណសម្បត្តិ និងសក្តានុពលនៃដី ឬ ប្រភេទដំណាំ និងកម្លាំងពលកម្ម។

### ក.១២ ប្រភេទដីផ្សេងៗគ្នាដែលបែងចែក

មានដីចំនួន៣ ប្រភេទដែលត្រូវបែងចែកក្រោមសម្បទានដីសង្គមកិច្ចនេះ គឺ:

- ដីធ្វើកសិកម្ម និងដីលំនៅឋាន
- ដីសម្រាប់តែធ្វើកសិកម្ម និង
- ដីសម្រាប់តែលំនៅឋាន

គ្រួសារដែលទទួលបានដីសម្រាប់ធ្វើកសិកម្មត្រូវបង្ហាញពីឆន្ទៈក្នុងការធ្វើកសិកម្មនៅលើដី នោះ។ ដីលំនៅឋានត្រូវស្ថិតនៅជិតកន្លែងដែលមុខសញ្ញាអ្នកទទួលដីរកប្រាក់ចំណូលចិញ្ចឹមជីវិតនាពេល បច្ចុប្បន្ននេះ។

## ២ ដំណើរការគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច និងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោង

### ២.១ តើសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងជាអ្វី?

សៀវភៅណែនាំស្តីពីការអនុវត្តគម្រោងនេះផ្តល់នូវខ្លឹមសារលម្អិតពេញលេញស្តីអំពីវិធីអនុវត្តការសម្បទានដីសង្គមកិច្ចសម្រាប់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍ សេដ្ឋកិច្ច។

ឯកសារនេះ គឺជាកំណែខ្លីមួយដើម្បីធ្វើឲ្យក្រុមប្រឹក្សាឃុំ និងអ្នកពាក់ព័ន្ធដទៃទៀតងាយស្រួលក្នុងការប្រើប្រាស់។ ក្នុងករណីមានភាពមិនច្បាស់លាស់ អ្នកអានអាចមើលនៅក្នុងកំណែទាំងមូលនៃសៀវភៅណែនាំពីប្រតិបត្តិការនេះ។

### ២.២ ខ្លឹមសារនៃសៀវភៅណែនាំនេះ

សៀវភៅណែនាំពីប្រតិបត្តិការនេះចែកចេញជា៤ ផ្នែកធំៗ។ ផ្នែកធំនីមួយៗពិពណ៌នាពីសមាសភាគមួយរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។

- **ផ្នែក** "ក" ពិពណ៌នាពីសមាសភាគទី ១ ដែលជាដំណើរការរៀបចំ និងអនុវត្តការធ្វើសម្បទានដីសង្គមកិច្ច។
- **ផ្នែក** "ខ" ពិពណ៌នាពីសមាសភាគទី ២ ដែលគាំទ្រដល់ហេដ្ឋារចនាសម្ព័ន្ធជនបទ និងសេវាកម្ម។ ផ្នែក "ខ" មិនពិពណ៌នាអំពីដំណើរការទេ ប៉ុន្តែបង្កើតបញ្ញត្តិនានាទាក់ទងនឹងវិធីធ្វើផែនការ និងប្រើប្រាស់មូលនិធិក្នុងសមាសភាគទី ២។
- **ផ្នែក** "គ" ពិពណ៌នាពីសមាសភាគទី ៣ ដែលរួមមានតួនាទី និងការទទួលខុសត្រូវរបស់ភ្នាក់ងារនីមួយៗក្នុងការអនុវត្តការធ្វើសម្បទានដីសង្គមកិច្ច។
- **ផ្នែក** "ឃ" ពិពណ៌នាពីសមាសភាគទី ៤ ទាក់ទងនឹងការរៀបចំការងាររដ្ឋបាលច្បាស់លាស់សម្រាប់អនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និង ការអភិវឌ្ឍសេដ្ឋកិច្ច។

### ២.៣ តើនរណាប្រើប្រាស់សៀវភៅណែនាំនេះ ហើយប្រើប្រាស់របៀបណា?

សូមមើលនៅក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងទាំងមូល។

### ២.៤ សទ្ទានុក្រម: ការយល់ដឹងពីភាសារបស់គម្រោង

សូមមើលនៅក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងទាំងមូលសម្រាប់សទ្ទានុក្រមនៃពាក្យបច្ចេកទេស។

### ១.៥ វិធីឆ្លើយតបទៅនឹងតម្រូវការព័ត៌មានរបស់គម្រោង

សូមមើលនៅក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងសម្រាប់ទម្រង់ពាក្យស្នើសុំច្បាស់លាស់ និងឧទាហរណ៍ផ្សេងៗ។

### ១.៦ តើនណាមានសំណួរអំពីគម្រោងនេះ

ធនធានទីមួយសម្រាប់ផ្តល់ការណែនាំអំពីគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺក្រុមការងារថ្នាក់ស្រុក។ ក្រុមការងារថ្នាក់ស្រុកអាចស្វែងរកការគាំទ្របន្ថែមទៀតពីអង្គការនានា។

ផ្នែករដ្ឋបាលមូលដ្ឋានក៏នឹងជួយដល់ក្រុមប្រឹក្សាឃុំផងដែរទាក់ទងនឹងការណែនាំ និងទំនាក់ទំនងជាមួយមន្ទីរវិស័យនានារដ្ឋាភិបាលដែលមានទំនាក់ទំនងជាមួយភារកិច្ចធម្មតារបស់ខ្លួន។

## គ. ដំណើរការសម្បទានដីសង្គមកិច្ចដែលមានមូលដ្ឋាននៅតាមឃុំ
## ដំណាក់កាលទាំង ១០ នៃដំណើរការសម្បទានដីសង្គមកិច្ច

មានដំណាក់កាលចំនួន ១០ នៅក្នុងដំណើរការសម្បទានដីសង្គមកិច្ច។ ដំណាក់កាលទាំងអស់នេះមានបង្ហាញនៅក្នុងដ្យាក្រាមខាងក្រោម។

| ដំណាក់កាល | បរិយាយ | លទ្ធផល | |
|---|---|---|---|
| ១ | ផ្តួចផ្តើម និងពិនិត្យសម្បទានដីសង្គមកិច្ច | ក្រុមប្រឹក្សាឃុំស្នើសុំសម្បទានដីសង្គមកិច្ច | |
| | | ផ្តល់ការអនុញ្ញាតឲ្យបន្តដំណើរការ | |
| ២ | សិក្សាពីបច្ចេកទេសធ្វើប្លង់ | ធ្វើផែនការការងារសម្រាប់ដំណើរការសម្បទានដីសង្គមកិច្ច | |
| ៣ | លើកកម្ពស់ការយល់ដឹង | ប្រជាពលរដ្ឋក្នុងមូលដ្ឋានយល់ដឹងអំពី សម្បទានដីសង្គមកិច្ច | ដំណាក់កាលទី ៣, ៤ និង ៥ អាចបន្តធ្វើនៅក្នុងពេលតែមួយបាន |
| | | វិធីសាស្ត្រជ្រើសរើសអ្នកទទួលដីដែលបានព្រមព្រៀង | |
| ៤ | ធ្វើផែនទីដីរដ្ឋ | ដីធ្វើជាសម្បទានដីសង្គមកិច្ចដែលបានចុះបញ្ជីជាដីឯកជនរបស់រដ្ឋ | |
| ៥ | ធ្វើផែនការចូលរួម | វិភាគប្រព័ន្ធគ្រេត្របរិស្ថាន | |
| | | វាយតម្លៃតម្រូវការហេដ្ឋារចនាសម្ព័ន្ធ | |
| | | ការការពារបរិស្ថាន និងសង្គម | |
| | | របាយការណ៍សម្បទានដីសង្គមកិច្ច | |
| ៦ | ត្រួតពិនិត្យរបាយការណ៍សម្បទានដីសង្គមកិច្ច | បែងចែកហេដ្ឋារចនាសម្ព័ន្ធជនបទ និងសេវាកម្ម | |
| | | ផ្តល់ការអនុញ្ញាតឲ្យបន្តដំណើរការ | |
| ៧ | ជ្រើសរើសអ្នកទទួលដី | ធ្វើបញ្ជីឈ្មោះអ្នកដាក់ពាក្យសុំដែលមានអាទិភាព | |
| | | ធ្វើបញ្ជីអ្នកដាក់ពាក្យសុំបម្រុង | |
| ៨ | ធ្វើផែនការសម្បទានដីសង្គមកិច្ចលម្អិត | ក្បាលដីដែលបានបែងចែក | |
| | | ផែនការសម្បទានដីសង្គមកិច្ចលម្អិតដែលបានឯកភាព | |
| ៩ | រៀបចំទីតាំង | កំណត់ព្រំប្រទល់ដី | |
| | | ផ្គត់ផ្គង់ទឹកនៅជនបទ | |
| | | ធ្វើការសម្អាតដី | |
| | | ធ្វើផ្លូវចូល | |

| | | |
|---|---|---|
| | | ការប្រគល់ដីជាផ្លូវការ |
| ១០ | ចូលតាំងទីលំនៅ និងធ្វើការអភិវឌ្ឍជនបទ | ផ្តល់ជំនួយសម្រាប់ការចូលតាំងទីលំនៅ |
| | | ផ្តល់ហេដ្ឋារចនាសម្ព័ន្ធជនបទ និងសេវាកម្មផ្សេងៗ |
| | | សហគមន៍ដែលមាននិរន្តរភាព |

## ពេលវេលាដែលត្រូវការសម្រាប់អនុវត្តន៍សម្បទានដីសង្គមកិច្ច

ពេលវេលាដែលត្រូវការចាប់តាំងពីការស្នើសុំសម្បទានដីសង្គមកិច្ចដំបូងរហូតដល់ការប្រគល់ដីជាផ្លូវការ គឺមានរយៈពេលយ៉ាងតិច ១ឆ្នាំ។ សូមចាំថា នៅដំណាក់កាលមួយចំនួនច្បាប់តម្រូវឲ្យក្រុមប្រឹក្សាឃុំបង្ហាញព័ត៌មានអំពីដំណើរការសម្បទានដីសង្គមកិច្ចក្នុងពេលវេលាមួយជាក់លាក់។ រយៈពេលសរុបនៃការបង្ហាញនេះ គឺៈ

- ដំណាក់កាលទី ៤ៈ មានរយៈពេល ៦០ ថ្ងៃ
- ដំណាក់កាលទី ៧ៈ មានរយៈពេល ១២២ ថ្ងៃ

បន្ទាប់ពីពួកគាត់បានរស់នៅ ឬ បានធ្វើកសិកម្មនៅលើដីរបស់ពួកគាត់ដោយជោគជ័យរយៈពេល ៥ឆ្នាំ អ្នកទទួលដីទាំងនោះមានសិទ្ធិស្នើសុំប្លង់ដីកម្មសិទ្ធិ។

- រយៈពេលនៃការចូលតាំងទីលំនៅដែលអ្នកទទួលដីត្រូវការជំនួយ : ៦ខែទៅ ១ឆ្នាំ
- ការអភិវឌ្ឍជនបទៈ ការអភិវឌ្ឍបន្ថែមនៅតំបន់សម្បទានដីសង្គមកិច្ច : ២ឆ្នាំ
- រយៈពេលមាននិរន្តរភាព : ២ឆ្នាំ

## *ជំហានទី ១ :  ផ្តួចផ្តើម ត្រួតពិនិត្យឡើងវិញ និងពិនិត្យកម្មវិធីសម្បទានដីសង្គមកិច្ច*

**លទ្ធផលៈ**

- ក្រុមប្រឹក្សាឃុំដាក់សំណើសុំសម្បទានដីសង្គមកិច្ច
- បន្ទាប់ពីការពិនិត្យលើកដំបូង អភិបាលខេត្តចេញលិខិតអនុញ្ញាតឲ្យបន្តដំណើរការ

## គ.១.១ សំណើសុំសម្បទានដីសង្គមកិច្ច

ការធ្វើសម្បទានដីសង្គមកិច្ចអាចផ្តួចផ្តើមឡើងដោយភាគីខាងក្រោមនេះ :

១. ក្រុមប្រឹក្សាឃុំ

២. ប្រជាពលរដ្ឋក្នុងមូលដ្ឋានម្នាក់ ឬ ច្រើននាក់ ឬ

៣. អង្គការដែលធ្វើការងារជាមួយ ឬ ជួសមុខឲ្យប្រជាពលរដ្ឋមូលដ្ឋាន

មិនថាតើសំណើដំបូងចាប់ផ្តើមឡើងដោយរបៀបណានោះទេ សំណើនោះត្រូវតែធ្វើការពិភាក្សា និងឯកភាពដោយអង្គប្រជុំក្រុមប្រឹក្សាឃុំ។

ប្រសិនបើសំណើសុំសម្បទានដីសង្គមកិច្ចផ្អែកលើឃុំមិនទាន់រៀបចំរួចរាល់នៅក្នុងផែនការរបស់ឃុំទេ ផែនការនោះគួរតែធ្វើការកែប្រែឡើងវិញដើម្បីដាក់បញ្ចូលសំណើនោះ (ការងារនេះអាចធ្វើទៅបាននៅក្នុងអំឡុងពេលរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ)។

## គ.១.២ ការរៀបចំសំណើសុំជំនួយរៀបចំសម្បទានដីសង្គមកិច្ចដាក់ជូនគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត

បន្ទាប់ពីព្រមព្រៀងដាក់សំណើសុំសម្បទានដីសង្គមកិច្ច ក្រុមប្រឹក្សាឃុំនឹងរៀបចំលិខិតស្នើសុំជំនួយពីគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តដើម្បីចាប់ផ្តើមដំណើរការសម្បទានដីសង្គមកិច្ច។ លិខិតនេះប្រើប្រាស់**ទម្រង់ទី ៣** នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច - ទម្រង់ស្នើសុំជំនួយសម្បទានដីសង្គមកិច្ច។

រួមជាមួយនឹងទម្រង់ដែលឃុំត្រូវបញ្ជូនភ្ជាប់ :

១. ផែនទីព្រាងនៃតំបន់សម្បទានដីសង្គមកិច្ច

២. បញ្ជីឈ្មោះគ្រួសារដែលគ្មានដី ឬ គ្រួសារក្រីក្រនៅក្នុងឃុំ និង

៣. ប្រវត្តិប្រើប្រាស់ដីធម្មតាដែលបង្ហាញពីប្រភេទនៃការប្រើប្រាស់ដីនៅក្នុង និងជុំវិញតំបន់ សម្បទានដីសង្គមកិច្ចបច្ចុប្បន្ន

## គ.១.៣ កិច្ចប្រជុំថ្នាក់ខេត្តដើម្បីពិនិត្យសំណើសុំសម្បទានដីសង្គមកិច្ច

អភិបាលខេត្តនឹងពិនិត្យសំណើនោះឡើងវិញ ហើយបញ្ជូនឯកសារផ្សេងៗទៅគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តដើម្បីធ្វើសកម្មភាព។ នៅពេលនោះ គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តនឹងកោះប្រជុំពិនិត្យសម្បទានដីសមង្គមកិច្ចថ្នាក់ខេត្តដើម្បីធ្វើការត្រួតពិនិត្យជាលើកដំបូងនូវសំណើសុំសម្បទានដីសង្គមកិច្ចនោះ ។

អ្នកចូលរួមក្នុងកិច្ចប្រជុំត្រួតពិនិត្យមានៈ

១. ក្រុមការងារថ្នាក់ស្រុក

២. ក្រុមប្រឹក្សាឃុំ

៣. មន្ទីរជំនាញខេត្តៈ

ក. ដី

ខ. ព្រៃឈើ

គ. កសិកម្ម

ឃ. ធនធានទឹក

ង. បរិស្ថាន

ច. វប្បធម៌ និងបេតិកភណ្ឌ

ឆ. រ៉ែ និងថាមពល

ជ. មជ្ឈមណ្ឌលសកម្មភាពកម្ចាត់មីនកម្ពុជា

ឈ. អ្នកពាក់ព័ន្ធទទួលបានសម្បទានសេដ្ឋកិច្ចដែល និង
ញ. ភាគីពាក់ព័ន្ធផ្សេងៗទៀតនៅក្នុងខេត្ត

ប្រធានបទដែលត្រូវលើកយកមកពិភាក្សាក្នុងកិច្ចប្រជុំត្រួតពិនិត្យមាន:

១. ផែនទី "កំណត់ទីតាំងសំខាន់" ក្នុងខេត្តនាពេលបច្ចុប្បន្ន - បង្ហាញពី:
   ក. តំបន់សម្បទានដីសមង្គមកិច្ចដែលមានសក្តានុពល
   ខ. តំបន់នៅព័ទ្ធជុំវិញ
   គ. តំបន់លើខ្សែទឹក និងតំបន់ក្រោមខ្សែទឹក និង
   ឃ. បញ្ហាពាក់ព័ន្ធនឹងការរក្សាសន្តិសុខសង្គម ការពារតាមផ្លូវច្បាប់ និងការពារបរិស្ថាន។

២. អ្នកទទួលភារៈគ្រប់គ្រងអាណត្តិ :[២]

   ក. មន្ទីរពាក់ព័ន្ធនានាទទួលភារៈគ្រប់គ្រងអាណត្តិលើតំបន់ផ្សេងៗស្ថិតនៅក្នុង ឬជុំវិញតំបន់ដែលបានស្នើសុំសម្បទានដីសមង្គមកិច្ច និង
   ខ. លុបចោលតំបន់ទាំងឡាយដែលមិនសមស្របសម្រាប់សម្បទានដីសមង្គមកិច្ច

៣. តំបន់ដីសម្បទានសេដ្ឋកិច្ច: ធានាថា តំបន់សម្បទានដីសង្គមកិច្ចដែលបានស្នើសុំ គឺមិនត្រូវបានយកមកប្រើដើម្បីដោះស្រាយជូនប្រជាពលរដ្ឋដែលចេញមកពីសម្បទានសេដ្ឋកិច្ចឡើយ។

៤. ផែនទីព្រាង: ពឹងផ្អែកទៅលើព័ត៌មានទទួលបានពីកិច្ចប្រជុំត្រួតពិនិត្យ:
   ក. កំណត់តំបន់ដែលមានសក្តានុពលសម្រាប់សម្បទានដីសង្គមកិច្ច និងកំណត់តំបន់ដែលត្រូវកាត់ចេញ
   ខ. រៀបចំព្រាងឡើងវិញនូវផែនទីព្រាងដំបូងផ្អែកលើលទ្ធផលដែលបានរកឃើញ
   គ. ធ្វើការសម្រេចទៅលើតំបន់សម្បទានដីសង្គមកិច្ច
   ឃ. កំណត់ថាតើតំបន់សម្បទានដីសមង្គមកិច្ចដែលបានស្នើសុំស័ក្តិសមសម្រាប់សម្បទានដីសមង្គមកិច្ច ឬ ទេ និង

[២] ចំណុចនេះសំដៅលើតំបន់នានាដែលស្ថិតក្រោមអាណត្តិរដ្ឋបាលរបស់ភ្នាក់ងាររដ្ឋាភិបាល។ ឧទាហរណ៍: តំបន់ដែលបានប្រកាសថាជាព្រៃអភិរក្ស គឺស្ថិតនៅក្រោមអាណត្តិរដ្ឋបាលរបស់ខណ្ឌរដ្ឋបាលព្រៃឈើ ដូចនេះ មិនអាចចាត់ចូលជាដីឯកជនរបស់រដ្ឋសម្រាប់សម្បទានដីសង្គមកិច្ចដោយគ្មានការឯកភាពពីខណ្ឌរដ្ឋបាលព្រៃឈើបានទេ។

ង. ប្រសិនបើតំបន់ដែលបានស្នើសុំស័ក្តិសមសម្រាប់សម្បទានដីសមង្គមកិច្ច នោះនឹងមានការណែនាំឲ្យគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តចុះពិនិត្យដល់មូលដ្ឋានដើម្បីធ្វើការពិនិត្យបន្ថែម [៣]។

## គ ១.៤ ឃុំចុះទស្សនកិច្ចដើម្បីពិនិត្យសំណើសុំសម្បទានដីសង្គមកិច្ច

ប្រសិនបើកិច្ចប្រជុំពិនិត្យលើកដំបូងកំណត់ថា តំបន់ដែលស្នើសុំនោះមានភាពសមស្របសម្រាប់សម្បទានដីសង្គមកិច្ច គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តនឹងបង្កើតក្រុមការងារវាយតម្លៃដំណាក់កាលដំបូងមួយដែលមានសមាសភាពចូលរួមដូចជា ក្រុមការងារថ្នាក់ស្រុក ផ្នែករដ្ឋបាលមូលដ្ឋាន និងផ្នែកគាំទ្របច្ចេកទេស គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត។

ក្រុមការងារវាយតម្លៃនេះចុះធ្វើទស្សនកិច្ច និងពិនិត្យមើលតំបន់សម្បទានដីសង្គមកិច្ចដែលបានស្នើសុំ ហើយពិភាក្សាជាមួយក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋក្នុងមូលដ្ឋានអំពីសម្បទានដីសង្គមកិច្ចដែលបានស្នើសុំនោះ។ ក្រុមការងារវាយតម្លៃបំពេញ***ទម្រង់ទី ៤ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចស្តីពីការពិនិត្យការការពារសុវត្ថិភាពសង្គម និងទម្រង់ទី ៥ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចស្តីពីការពិនិត្យការការពារបរិស្ថាន។***

ផ្អែកលើលទ្ធផលដែលបានរកឃើញ ក្រុមការងារវាយតម្លៃដំណាក់កាលដំបូងត្រូវរៀបចំផែនទីព្រាង របាយការណ៍ព្រាង និងអនុសាសន៍។

## គ ១.៥ ការសម្រេចរបស់អភិបាលខេត្តឲ្យបន្តដំណើរការចំណាត់ថ្នាក់ដីរដ្ឋ

អភិបាលខេត្តពិគ្រោះយោបល់ជាមួយគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តស្តីពីអនុសាសន៍របស់ក្រុមការងារវាយតម្លៃដំណាក់កាលដំបូង ហើយសម្រេចយល់ព្រមជាគោលការណ៍ចំពោះសម្បទានដីសង្គមកិច្ចដែលបានស្នើសុំ ឬ ច្រានចោលសំណើនោះ។

ក្នុងករណីមានការយល់ព្រមជាគោលការណ៍ អភិបាលខេត្តចេញលិខិតអនុញ្ញាតឲ្យធ្វើការលើដីដែលចាត់ជាដីឯកជនរបស់រដ្ឋ (***ទម្រង់ទី ៦ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចស្តីពីលិខិតអនុញ្ញាតរបស់អភិបាលខេត្តឲ្យបន្តការងារក្នុងការចំណាត់ថ្នាក់ដីរដ្ឋ***) អនុលោមតាមអនុក្រិត្យលេខ ១១៨ ដែលបញ្ជាក់ថា ដីនោះគឺប្រើសម្រាប់តែសម្បទានដីសង្គមកិច្ចប៉ុណ្ណោះ។

អភិបាលខេត្តណែនាំឲ្យគណៈកម្មាធិការប្រើប្រាស់និងបែងចែកដីថ្នាក់ខេត្តធ្វើការធានាថា កាលបរិច្ឆេទឈប់ទទួលពាក្យនឹងត្រូវធ្វើការប្រកាសជាសាធារណៈ (មើលក្នុងប្រអប់)។

---

[៣] ប្រសិនបើតំបន់ដែលបានស្នើសុំនោះមិនស័ក្តិសមសម្រាប់ធ្វើសម្បទានដីសង្គមកិច្ច សូមបន្តទៅផ្នែក ១.៥ នៅក្នុងសៀវភៅណែនាំនេះ។

**កាលបរិច្ឆេទឈប់ទទួលពាក្យ**

ការយល់ដឹងជាសាធារណៈអំពីផែនការបង្កើតតំបន់សម្បទានដីសង្គមកិច្ចត្រូវបានគេរកឃើញថា បានជំរុញឲ្យមានការទន្ទ្រានយកដី និងកាន់កាប់ដីមិនស្របច្បាប់លើសពីអ្វីដែលមានរួចមកហើយនៅក្នុងតំបន់នោះ។ ដូច្នេះហើយ គេតម្រូវឲ្យមានកាលបរិច្ឆេទឈប់ទទួលពាក្យជាមុនសម្រាប់ភាពស្របច្បាប់ទាក់ទងនឹងការផ្តល់សិទ្ធិឲ្យទទួលបានប្រាក់សំណងចំពោះការបាត់បង់ទ្រព្យសម្បត្តិនៅក្នុងសម្បទានដីសង្គមកិច្ចនេះ។ កាលបរិច្ឆេទឈប់ទទួលពាក្យត្រូវបានកំណត់ត្រឹមរយៈពេល ២ខែ មុនកិច្ចប្រជុំផ្តល់ព័ត៌មានជាសាធារណៈលើកដំបូងស្តីពីសម្បទានដីសង្គមកិច្ចដែលធ្វើឡើងជាមួយក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋក្នុងឃុំ។ ក្រុមប្រឹក្សាឃុំនឹងប្រើប្រាស់កំណត់ហេតុដែលមានស្រាប់ស្តីពីលំនៅឋាន និងការប្រើប្រាស់ដីនៅក្នុងឃុំដើម្បីផ្តល់ព័ត៌មានជាមូលដ្ឋានទាក់ទងនឹងការកាន់កាប់ដីនៅក្នុងតំបន់សម្បទានដីសង្គមកិច្ចដោយគ្មានការអនុញ្ញាត។ព័ត៌មាននេះនឹងមានបញ្ជាក់ពីក្រុមប្រឹក្សាឃុំនិងគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត និងតាមរយៈកិច្ចប្រជុំជាសាធារណៈមួយក្នុងអំឡុងដំណើរការធ្វើផែនការសម្បទានដីសង្គមកិច្ច(តពីក្របខ័ណ្ឌគោលនយោបាយការតាំងទីលំនៅសារជាថ្មីនៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច)។

## *ជំហានទី ២ : ការរៀបចំឲ្យមានការសិក្សាតាមបច្ចេកទេស*

**លទ្ធផល:** ផែនការការងារសម្រាប់រៀបចំសម្បទានដីសង្គមកិច្ច

បន្ទាប់ពីបញ្ចប់ដំណាក់កាលទី ១ របាយការណ៍សម្បទានដីសង្គមកិច្ចថ្នាក់ឃុំត្រូវតែធ្វើឡើងដើម្បីត្រួតពិនិត្យឡើងវិញ ហើយផ្តល់ការអនុញ្ញាតដោយគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត/គណៈកម្មាធិការគ្រប់គ្រងដីសង្គមកិច្ច និងភាគីពាក់ព័ន្ធផ្សេងទៀតដើម្បីបន្តធ្វើដំណើរការសម្បទានដីសង្គមកិច្ច។

ក្រុមប្រឹក្សាឃុំបង្កើតក្រុមការងារសម្បទានដីសង្គមកិច្ចមួយដើម្បីអនុវត្តការងារការរៀបចំសម្ប-ទានដីសង្គមកិច្ច និងរាយការណ៍ត្រឡប់មកក្រុមប្រឹក្សាឃុំវិញ។

ក្រុមប្រឹក្សាឃុំដាក់សំណើទៅគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្តដើម្បីសុំជំនួយសម្រាប់រៀបចំសម្បទានដីសង្គមកិច្ច។

បន្ទាប់ពីទទួលបានសំណើពីក្រុមប្រឹក្សាឃុំ គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្តនឹងធ្វើការជាមួយក្រុមការងារថ្នាក់ស្រុកដើម្បីបង្កើតផែនការការងារសម្រាប់អនុវត្តការសិក្សាបច្ចេកទេសដូចខាងក្រោមៈ

១. ការវិភាគប្រព័ន្ធកេ្សត្របរិស្ថាន (ប្រព័ន្ធកេ្សត្របរិស្ថាន )
២. ធ្វើការស្ទង់មតិទាក់ទងនឹងដីកសិកម្ម
៣. ធ្វើការស្ទង់មតិទាក់ទងនឹងបញ្ជីសារពើភ័ណ្ឌព្រៃឈើ និង
៤. ធ្វើការស្ទង់មតិទាក់ទងនឹងធនធានទឹក

ផែនការការងារបង្ហាញថា ភ្នាក់ងារណាមួយដែលទទួលខុសត្រូវក្នុងការអនុវត្តការសិក្សានីមួយៗ ពេលវេលានៃការសិក្សា និងធនធានដែលត្រូវការ។

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តទទួលបានផែនទី និងរូបភាពដែលមានទាំងអស់ពាក់ព័ន្ធនឹងតំបន់សម្បទានដីសង្គមកិច្ចដែលស្នើសុំ រួមទាំងរូបថតពីអាកាស និងរូបភាពផ្កាយរណប ប្រសិនបើធ្វើទៅបាន។

## *ជំហានទី ៣ : ព័ត៌មាន ការលើកកម្ពស់ការយល់ដឹង ការចូលរួម និងការជ្រើសរើសមុខសញ្ញាអ្នកទទួលដី*

**លទ្ធផល :**

- ប្រជាពលរដ្ឋក្នុងមូលដ្ឋានយល់ដឹងពីដំណើរការសម្បទានដីសង្គមកិច្ច
- ប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងក្រុមប្រឹក្សាឃុំព្រមព្រៀងគ្នាលើលក្ខណវិនិច្ឆ័យសម្រាប់ជ្រើសរើសអ្នកទទួលដី។

### គ ៣.១ យុទ្ធនាការផ្សព្វផ្សាយព័ត៌មាន

ប្រជាពលរដ្ឋទាំងអស់ដែលរស់នៅក្នុង និងនៅជុំវិញឃុំ ដែលអាចមានសិទ្ធិដាក់ពាក្យស្នើសុំដីក្រោមគម្រោងសម្បទានដីសង្គមកិច្ច ឬ អ្នកដែលអាចរងផលប៉ះពាល់ពីកម្មវិធីសម្បទានដីសង្គមកិច្ចត្រូវតែមានសិទ្ធិពេញលេញក្នុងការទទួលបានព័ត៌មានអំពីកម្មវិធីសម្បទានដីសង្គមកិច្ចនេះ។

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត/គណៈកម្មាធិការគ្រប់គ្រងដីសង្គមកិច្ចរៀបចំកញ្ចប់ព័ត៌មានដែលរួមមានៈ

១. អ្នកដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់សម្បទានដីសង្គមកិច្ច (**ទម្រង់ទី ៩** នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ស្តីពីលក្ខណវិនិច្ឆ័យសមស្របម្រាប់ការចូលរួមក្នុងគម្រោងសម្បទានដីសង្គមកិច្ច)
២. របៀបដាក់ពាក្យស្នើសុំសម្បទានដីសង្គមកិច្ច (**ទម្រង់ទី ១** នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចស្តីពីពាក្យស្នើសុំសម្បទានដីសង្គមកិច្ច)

៣. ការដាក់ពាក្យស្នើសុំ និងដំណើរការធ្វើសេចក្តីសម្រេច (*ទម្រង់ទី ១០ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ស្តីពីទម្រង់កំណត់ចំណាត់ថ្នាក់អ្នកស្នើសុំ*)

៤. តួនាទី និងការទទួលខុសត្រូវរបស់មុខសញ្ញាអ្នកទទួលដី (**ទម្រង់ទី** ១១ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចស្តីពីការទទួលខុសត្រូវរបស់មុខសញ្ញាអ្នកទទួលដី)

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត/គណៈកម្មាធិការគ្រប់គ្រងដីសង្គមកិច្ច រៀបចំផែនការផ្សព្វផ្សាយ រួមមាន:

១. របៀបដែលត្រូវផ្សព្វផ្សាយព័ត៌មាន (ផ្ទាំងបិទប្រកាស បាដាបង្ហាញ វិទ្យុ វីដេអូ និងវិធីសាស្ត្រផ្សេងៗ) ដោយប្រើប្រាស់***ទម្រង់ទី ១២ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចស្តីពីការជូនដំណឹងពីការដាក់ពាក្យស្នើសុំ*** សូមមើលនៅក្នុងទម្រង់។

២. ទីកន្លែងដែលត្រូវផ្សព្វផ្សាយព័ត៌មាន (រួមមានភូមិ និងតំបន់ទីប្រជុំជននានា)

៣. កាលវិភាគនៃការផ្សព្វផ្សាយ (រួមមានអំឡុងពេល និងពេលវេលានៃការផ្សព្វផ្សាយ)

អ្នកចូលរួមក្នុងយុទ្ធនាការផ្សព្វផ្សាយព័ត៌មានរួមមាន:

១. ប្រជាពលរដ្ឋគ្រប់រូបនៅក្នុងសហគមន៍មូលដ្ឋាន

២. ក្រុមការងារថ្នាក់ស្រុក

៣. ក្រុមប្រឹក្សាឃុំ និង

៤. អង្គការមិនមែនរដ្ឋាភិបាល និងក្រុមសហគមន៍

ក្រុមការងារថ្នាក់ស្រុក ជួយដល់ក្រុមប្រឹក្សាឃុំក្នុងការរៀបចំកិច្ចប្រជុំជាសាធារណៈសម្រាប់តម្រង់ទិសស្តីពីដំណើរការសម្បទានដីសង្គមកិច្ច។ កិច្ចប្រជុំនេះនឹងធ្វើឡើងក្រោមអធិបតីភាពរបស់មេឃុំ។ យ៉ាងតិចមានអ្នកសម្របសម្រួលថ្នាក់ឃុំពីររូបមានវត្តមាននៅក្នុងកិច្ចប្រជុំនេះ។ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំក៏ត្រូវមានវត្តមានដែរ។ ក្រុមប្រឹក្សាឃុំត្រូវរក្សាទុកកំណត់ហេតុនៃកិច្ចប្រជុំ រួមទាំងបញ្ជីឈ្មោះអ្នកចូលរួមផងដែរ។ គោលបំណងនៃកិច្ចប្រជុំនេះ គឺ:

១. បង្ហាញព័ត៌មាននៅក្នុងកញ្ចប់ព័ត៌មានទៅដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន

២. កំណត់តួនាទី និងការទទួលខុសត្រូវរបស់អ្នកចូលរួមក្នុងដំណើរការសម្បទានដីសង្គមកិច្ច និង

៣. ឆ្លើយតបទៅនឹងរាល់សំណួរ និងកង្វល់ទាំងអស់ដែលលើកឡើងដោយអ្នកចូលរួមប្រជុំ

## គ ៣.២ ការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រជាមុន

ក្នុងរយៈពេលកាន់តែឆាប់តាមដែលអាចធ្វើទៅបានបន្ទាប់ពីអភិបាលខេត្តបានអនុញ្ញាតឲ្យធ្វើការរៀបចំសម្បទានដីសង្គមកិច្ច មន្ទីរផែនការខេត្ត រួមជាមួយផ្នែករដ្ឋបាលមូលដ្ឋាន គួរអនុវត្តវិធីសាស្ត្រកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ (អត្តសញ្ញាណ-គ្រួសារក្រីក្រ) នៅក្នុងឃុំ។

លទ្ធផលនៃអត្តសញ្ញាណកម្មគ្រួសារក្រីក្រ គឺជាបញ្ជីឈ្មោះគ្រួសារក្រីក្រនៅក្នុងភូមិនីមួយៗ ដែលបានបែងចែកជាប្រភេទគ្រួសារក្រីក្រខ្លាំង ("គ្រួសារក្រីក្រ ១") ឬ គ្រួសារក្រីក្រ ("គ្រួសារក្រីក្រ ២")។

តាមធម្មតា មានតែគ្រួសារដែលបានរកឃើញថា ជាគ្រួសារក្រីក្រតាមរយៈវិធីសាស្ត្រកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រប៉ុណ្ណោះដែលនឹងមានសិទ្ធិទទួលបានដីក្រោមសម្បទានសង្គមកិច្ច (ទោះបីវានឹងមានករណីលើកលែងមួយចំនួនក៏ដោយ)។

ប្រសិនបើការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រជាមុនត្រូវបានធ្វើរួចមកហើយនៅក្នុងឃុំក្នុងរយៈពេល ២ឆ្នាំចុងក្រោយនេះ វាអាចនឹងមិនចាំបាច់ធ្វើការសិក្សាឡើងវិញនោះទេ។

## គ ៣.៣ ការវិភាគយេនឌ័រ

ក្រុមការងារថ្នាក់ស្រុកស្វែងរកជំនួយពីមន្ទីរកិច្ចការនារីខេត្តដើម្បីជួយធ្វើការវិភាគយេនឌ័រទាក់ទងនឹងស្ថានភាពបច្ចុប្បន្ននៃការប្រើប្រាស់ដីដោយស្ត្រី និងបុរសនៅក្នុងតំបន់សម្បទានដីសង្គមកិច្ចដែលបានស្នើសុំ។

មន្ទីរកិច្ចការនារីខេត្តរៀបចំរបាយការណ៍ដែលឆ្លើយតបទៅនឹងរាល់សំណួរដែលលើកឡើងនៅក្នុងទម្រង់របាយការណ៍ការវិភាគយេនឌ័រ (ប្រើប្រាស់*ទម្រង់ទី ១៣ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចស្តីពីរបាយការណ៍ការវិភាគ*យេនឌ័រ)

ក្រុមប្រឹក្សាឃុំនឹងប្រើប្រាស់របាយការណ៍ការវិភាគយេនឌ័រដើម្បីត្រួតពិនិត្យឡើងវិញ និងផ្តល់សុពលភាពដល់ការកំណត់អត្តសញ្ញាណកម្មដីរដ្ឋ និងការធ្វើផែនទី (បន្ទាប់ពីបញ្ចប់ដំណាក់កាលទី ៤.១៣ )។

## គ ៣.៤ កំណត់ដំណើរការ និងលក្ខណវិនិច្ឆ័យសម្រាប់ការជ្រើសរើសមុខសញ្ញាអ្នកទទួលដី

ដោយពិគ្រោះយោបល់ជាមួយនឹងក្រុមការងារថ្នាក់ស្រុក ក្រុមប្រឹក្សាឃុំ ផ្នែករដ្ឋបាលមូលដ្ឋាន និងក្រុមសហគមន៍ ត្រូវកំណត់លក្ខណវិនិច្ឆ័យជាក់លាក់ដែលត្រូវប្រើប្រាស់ សម្រាប់ជ្រើសរើសអ្នកទទួលដី និងដំណើរការបន្ទាប់ដើម្បីធានាឲ្យមានការចូលរួម និងមានតម្លាភាព។ លក្ខណវិនិច្ឆ័យទាំងនេះត្រូវរួមបញ្ចូល (ប្រើ*ទម្រង់ទី ៩ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច*) :

១. គ្រួសារធំ មានសមាជិកប្រាំមួយនាក់ (៦) ឬ លើសពីនេះ
២. ពេលវេលាដែលគ្រួសារបានរស់នៅក្នុងតំបន់ដីសម្បទានសង្គមកិច្ច
៣. មេគ្រួសារគឺជាស្ត្រី ដែលពិការ [បាត់បង់សមត្ថភាព] ជាអតីតយុទ្ធជនពិការ [បាត់បង់សមត្ថភាព] ឬ ទាហានរំសាយ និង
៤. ប្រជាពលរដ្ឋងាយរងគ្រោះ និងជនជាតិដើមភាគតិចអាចទទួលបានការយកចិត្តទុកដាក់ល្អជាងគេនៅក្នុងដំណើរការជ្រើសរើស

លក្ខណវិនិច្ឆ័យមិនត្រូវមានភាពលំអៀងប្រឆាំងនឹងភេទ ឬ ក្រុមសង្គមណាមួយឡើយ។ មន្ទីរកិច្ចការនារីខេត្តត្រូវធ្វើការណែនាំថាតើលក្ខណវិនិច្ឆ័យនេះមានអព្យាក្រឹត្យភាពចំពោះយេនឌ័រ និងពិចារណាទៅលើលទ្ធផលនៃការវិភាគយេនឌ័រដែរឬទេ។

## ***ជំហានទី ៤ : ការកំណត់អត្តសញ្ញាណកម្មដីរដ្ឋ ការធ្វើផែនទី ការចាត់ជាប្រភេទ និងការចុះបញ្ជី***

**លទ្ធផល :** តំបន់សម្បទានដីសង្គមកិច្ចត្រូវបានចុះបញ្ជីជាដីឯកជនរបស់រដ្ឋ

**ពេលវេលាសម្រាប់បង្ហាញព័ត៌មានជាសាធារណៈ: ៦០ ថ្ងៃ**

- ការបង្ហាញផែនទីព្រាងជាសាធារណៈ : រយៈពេល ៣០ ថ្ងៃ
- ការបង្ហាញការចុះបញ្ជីដីជាសាធារណៈ : រយៈពេល ៣០ ថ្ងៃ

### គ ៤.១ រៀបចំផែនទីតំបន់សម្បទានដីសង្គមកិច្ច

អ្នកជំនាញសុរិយោដី និងគ្រប់គ្រងដីរបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត/គណៈកម្មាធិការគ្រប់គ្រងដីសង្គមកិច្ចនឹងប្រើប្រាស់ផែនទីព្រាង រូបថតពីអាកាស រូបភាពផ្កាយរណប និងព័ត៌មានផ្សេងទៀតដែលមានដើម្បីរៀបចំផែនទីតំបន់សម្បទានដីសង្គមកិច្ចដែលបានស្នើសុំ និងតំបន់ដែលនៅព័ទ្ធជុំវិញដូចខាងក្រោម :

១. ផែនទីការប្រើប្រាស់ដីថ្នាក់ឃុំផ្អែកលើប្រព័ន្ធព័ត៌មានភូមិសាស្ត្រ និង
៣. ផែនទីកំណត់ "ទីតាំងសំខាន់" នៃបរិស្ថាន ឬ វប្បធម៌ [៤]

---

[៤] "ចំណុចសំខាន់" គឺជាតំបន់ដែលត្រូវការការពារបន្ថែមយ៉ាងពិសេស ផ្អែកលើសារៈសំខាន់នៃបរិស្ថាន និងជីវៈចម្រុះ បេតិកភណ្ឌវប្បធម៌ ទីសក្ការៈ និងឋានៈរបស់ខ្លួនជាតំបន់ប្រពៃណីសម្រាប់ជនជាតិដើមម្ចាស់ស្រុក ឬ ហេតុផលសំខាន់ផ្សេងទៀត។

## គ ៤.២ អនុវត្តការស្ទង់មតិទាក់ទងដី ទឹក និងព្រៃ

ការសិក្សាដែលរៀបចំក្នុងអំឡុងពេលដំណាក់កាលទី ២ គួរតែយកមកអនុវត្តនាពេលនេះ។ ភ្នាក់ងារដែលទទួលខុសត្រូវធ្វើការស្ទាបស្ទង់នេះត្រូវធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុមការងារថ្នាក់ស្រុក ក្រុមប្រឹក្សាឃុំ និងជាមួយអ្នកជំនាញសុរិយោដី និងការគ្រប់គ្រងដីរបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត/គណៈកម្មាធិការគ្រប់គ្រងដីសង្គមកិច្ច។ ភ្នាក់ងារនានារៀបចំរបាយការណ៍ និងបង្កើតបទបង្ហាញពីលទ្ធផលរកឃើញរបស់ពួកគេទៅកាន់ភាគីពាក់ព័ន្ធសំខាន់ៗ។

ការទទួលខុសត្រូវរបស់ក្រុមការងារស្ទង់មតិ មាន:

១. ស្ទង់មតិពីតំបន់សម្បទាន

២. កំណត់ព័ត៌មានលម្អិតនៃការប្រើប្រាស់ដីនាពេលបច្ចុប្បន្ន

៣. ធានាថា មិនមានការបំពានលើការការពារសុវត្ថិភាពឡើយ និង

៤. រៀបចំរបាយការណ៍ខ្លីៗស្តីអំពីដីស្ថិតក្រោមយុត្តាធិការនៃក្រសួងខ្លួននៅក្នុងតំបន់សម្បទាន។

## គ ៤.៣ ស្ទង់មតិលម្អិត និងធ្វើផែនទីតំបន់សម្បទានដែលបានស្នើសុំ

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត/គណៈកម្មាធិការគ្រប់គ្រងដីសង្គមកិច្ចប្រមូលផ្តុំក្រុមការងារស្ទង់មតិថ្នាក់ខេត្ត រួមមានតំណាងមន្ទីរពាក់ព័ន្ធ ក្រុមប្រឹក្សាឃុំ ក្រុមការងារថ្នាក់ស្រុក និងផ្នែករដ្ឋបាលមូលដ្ឋាន ហើយបណ្តុះបណ្តាលពួកគេពីវិធីធ្វើការស្ទង់មតិលម្អិតទាក់ទងនឹងតំបន់សម្បទានដី សង្គមកិច្ចដែលបានស្នើសុំ។

ផ្អែកលើផែនទី និងរូបភាពតាមផ្កាយរណបដែលរៀបចំសម្រាប់ក្រុមការងារ និងការប្រើប្រាស់ឧបករណ៍កំណត់ទីតាំងភូគោលសាស្ត្រ ក្រុមការងារស្ទង់មតិអាចអនុវត្តដូចខាងក្រោម :

១. កំណត់ព្រំប្រទល់តំបន់សម្បទានដី (GPS) សង្គមកិច្ចដែលបានស្នើសុំ

២. កំណត់តំបន់មួយចំនួននៅក្នុងតំបន់សម្បទានដីសង្គមកិច្ចដែលបានស្នើសុំ ដូចជា :

- ក. បានកាន់កាប់ជាឯកជនដោយបុគ្គល
- ខ. បានកាន់កាប់ជាក្រុម (ឧ: ក្រុមជនជាតិដើមភាគតិច)
- គ. បានកាន់កាប់ជាឯកជនស្របតាមច្បាប់ភូមិបាលឆ្នាំ ២០០១
- ឃ. ស្ថិតក្នុងការប្រើប្រាស់សម្រាប់កសិកម្ម (ត្រូវកត់ឈ្មោះអ្នកប្រើប្រាស់ដីចូល)
- ង. ស្ថិតក្នុងការប្រើប្រាស់សម្រាប់លំនៅឋាន ឬ គោលបំណងឯកជនផ្សេងទៀត (ត្រូវកត់ឈ្មោះអ្នកប្រើប្រាស់ដីចូល)
- ច. ស្ថិតក្នុងការប្រើប្រាស់ ឬ បម្រុងទុកជាដីព្រៃ
- ឆ. បឹង ទន្លេ ស្ទឹង ឬ តំបន់លិចទឹកនានាដែលរក្សាទុកជាជម្រកត្រីបង្កាត់ពូជ
- ជ. ទីតាំងដែលស្ថិតក្រោមការការពារបរិស្ថាន
- ឈ. ទីតាំងសំខាន់ៗទាក់ទងប្រវត្តិសាស្ត្រ ឬ វប្បធម៌

ញ. ទីតាំងមានសារៈសំខាន់សម្រាប់សហគមន៍ជនជាតិដើមក្នុងមូលដ្ឋាន

ដ. ដីប្រើប្រាស់ជាសាធារណៈសម្រាប់គោលបំណងនានាដូចជាធ្វើផ្លូវ ប្រព័ន្ធធារាសាស្ត្រ សាលារៀន គ្លីនិកព្យាបាលជំងឺ។ល។ និង

ឋ. ដីដែលកាត់ចេញពីសម្បទានដីសង្គមកិច្ចដោយសារហេតុផលផ្សេង។

៣. កត់ត្រាលទ្ធផលនៃការស្ទង់មតិនៅលើផែនទីព្រាង

៤. កត់ត្រាព្រំប្រទល់តំបន់សម្បទានដីសង្គមកិច្ចដែលបានស្នើសុំដោយប្រើប្រាស់ឧបករណ៍កំណត់ទីតាំងភូគោលសាស្ត្រ (GPS) និង

៥. កំណត់ព្រំប្រទល់ខាងក្រៅ និងខាងក្នុងនៃតំបន់សម្បទានដីសង្គមកិច្ចដែលបានស្នើសុំដោយប្រើប្រាស់ថ្នាំពណ៌ ឬ ស្នឹងឈើ (ការកំណត់ព្រំប្រទល់ក្បាលដីត្រឹមត្រូវនឹងត្រូវធ្វើនៅពេលក្រោយ)។

## គ ៤.៤ ការបង្ហាញផែនទីព្រាងជាសាធារណៈរយៈពេល ៣០ ថ្ងៃ

ក្រុមការងារថ្នាក់ស្រុកបង្ហាញផែនទីព្រាងជាសាធារណៈនៅសាលាឃុំ សម្រាប់រយៈពេល ៣០ ថ្ងៃ។ យ៉ាងហោចណាស់មានបុគ្គលិកម្នាក់មកពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្ត ឬ ផ្នែករដ្ឋបាលមូលដ្ឋាន ត្រូវមានវត្តមាននៅសាលាឃុំដើម្បីចុះកត់ត្រាបញ្ជាក់អះអាងណាមួយ។ប្រជាពលរដ្ឋដែលរស់នៅក្នុងឬជិតភូមិ និងតំបន់សម្បទានដីសង្គមកិច្ច អាចដាក់ពាក្យបណ្តឹង ប្រឆាំងនឹងការកំណត់តំបន់សម្បទានដីសង្គមកិច្ចដែលបានស្នើសុំ *(ប្រើ ទម្រង់ទី ១៤ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច)។* ក្រុមការងារថ្នាក់ស្រុកចុះបញ្ជីការទាមទារនីមួយៗ ហើយអញ្ជើញអង្គការមិនមែនរដ្ឋាភិបាល និងក្រុមសហគមន៍ឲ្យមកត្រួតពិនិត្យការទាមទារនីមួយៗឡើងវិញ។ ការទាមទារទាក់ទងនឹងការប្រើប្រាស់ដីដែលធ្វើឡើងបន្ទាប់ពីកាលបរិច្ឆេទឈប់ទទួលពាក្យនឹងត្រូវច្រានចោល។

## គ ៤.៥ ក្រុមការងារថ្នាក់ស្រុករៀបចំរបាយការណ៍ និងអនុសាសន៍សម្រាប់ការធ្វើចំណាត់ថ្នាក់ដីឯកជនរបស់រដ្ឋ

ក្រុមការងារថ្នាក់ស្រុកប្រមូលផែនទីដែលពាក់ព័ន្ធនឹងការទាមទារនីមួយៗ ហើយធ្វើការស្ទង់ពីទីតាំងនោះជាមួយនឹងអ្នកប្តឹងតវ៉ា។ ការទាមទារស្របច្បាប់ត្រូវដាក់បញ្ចូលទៅក្នុងផែនទីព្រាង ហើយក្រុមការងារថ្នាក់ស្រុករៀបចំរបាយការណ៍ព្រាងដើម្បីដាក់ជូនគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត/គណៈកម្មាធិការគ្រប់គ្រងដីសង្គមកិច្ច។ ***ទម្រង់ត្រួតពិនិត្យការការពារសង្គមនៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច*** (ប្រើ ***ទម្រង់ទី ៤ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច***) ***និងទម្រង់ត្រួតពិនិត្យការការពារបរិស្ថាននៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច*** (ប្រើ ***ទម្រង់ទី ៥ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច***) ដែលបានធ្វើបច្ចុប្បន្នភាពហើយដាក់បញ្ចូលទៅក្នុងរបាយការណ៍។

## គ ៤.៦ កិច្ចប្រជុំថ្នាក់ខេត្តធ្វើការធ្វើចំណាត់ថ្នាក់ដីឯកជនរបស់រដ្ឋដែលប្រើប្រាស់សម្រាប់សម្បទានដីសង្គមកិច្ច

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត/គណៈកម្មាធិការគ្រប់គ្រងដីសង្គមកិច្ចប្រជុំមន្ទីរពាក់ព័ន្ធថ្នាក់ខេត្តដែលពាក់ព័ន្ធទាំងអស់ដើម្បីត្រួតពិនិត្យផែនទីព្រាងចុងក្រោយ របាយការណ៍ និងទម្រង់នៃការការពារសុវត្ថិភាព។

## គ ៤.៧ គណៈកម្មាធិការគ្រប់គ្រងដីសង្គមកិច្ចខេត្តសម្រេចថាតើ ត្រូវបន្តចុះបញ្ជីដីជាដីឯកជនរបស់រដ្ឋសម្រាប់ប្រើប្រាស់ជាសម្បទានដីសង្គមកិច្ច ឬ អត់

ពឹងផ្អែកលើអនុសាសន៍ដែលទទួលបាន គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត/គណៈកម្មាធិការគ្រប់គ្រងដីសង្គមកិច្ចត្រូវសម្រេចនៅពេលនេះថាតើត្រូវផ្តល់ការអនុញ្ញាត ឬ ច្រានចោលតំបន់សម្បទានដីសង្គមកិច្ចដែលបានស្នើសុំនោះ។ សេចក្តីសម្រេចនេះត្រូវតែមានការឯកភាពពីគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ជាតិ។

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត/គណៈកម្មាធិការគ្រប់គ្រងដីសង្គមកិច្ចបញ្ជូនលិខិតផ្តល់យោបល់ទៅកាន់អភិបាលខេត្ត។ ក្នុងឋានៈជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីសង្គមកិច្ច អភិបាលខេត្តសរសេរលិខិតទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ជូនដំណឹងពីសេចក្តីសម្រេចរបស់ខ្លួនលើការធ្វើចំណាត់ថ្នាក់ដីនេះ។

ក្នុងករណីសម្បទានដីសង្គមកិច្ចត្រូវបានអនុញ្ញាត គណៈកម្មាធិការបែងចែក និងប្រើប្រាស់ដីថ្នាក់ខេត្ត/គណៈកម្មាធិការគ្រប់គ្រងដីសង្គមកិច្ចដាក់បញ្ចូលព្រំប្រទល់សម្បទានដីសង្គមកិច្ចនោះទៅក្នុងផែនទីដីរដ្ឋ និងកម្មវិធី Database នៅថ្នាក់ខេត្ត។

ក្នុងករណីដែលសេចក្តីសម្រេចនោះច្រានចោលសម្បទានដីសង្គមកិច្ចដែលបានស្នើសុំក្រុមប្រឹក្សាគោលនយោបាយដីធ្លីត្រួតពិនិត្យឡើងវិញនូវការរៀបចំឯកសារ ហើយអាចបញ្ជាក់ ឬ ជំទាស់ទៅនឹងការសេចក្តីសម្រេចនោះ។

## គ ៤.៨ ការវាស់វែងត្រឹមត្រូវនូវព្រំប្រទល់សម្បទានដីសង្គមកិច្ច និងការប្រើប្រាស់ដី

អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ធ្វើការវាស់វែងត្រឹមត្រូវនូវព្រំប្រទល់ខាងក្រៅនៃសម្បទានដីសង្គមកិច្ច និងព្រំប្រទល់ខាងក្នុងនៃដីដែលកាត់ចេញពីការធ្វើចំណាត់ថ្នាក់ដីឯកជនរបស់រដ្ឋ។ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រប្រើប្រាស់ឧបករណ៍កំណត់ទីតាំងភូគោលសាស្ត្រ (GPS) សម្រាប់ការវាស់វែងនេះ។

ផែនទីព្រាងត្រូវធ្វើបច្ចុប្បន្នកម្មដោយផ្អែកលើលទ្ធផលនៃការវាស់វែងនេះ។ ពេលនេះ វាបានក្លាយទៅជាផែនទីសម្បទានដីសង្គមកិច្ច។

អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រចុះបញ្ជីដីនៅក្នុងតំបន់សម្បទានដីសង្គមកិច្ចដែលបានស្នើសុំដោយយោងទៅលើការធ្វើចំណាត់ថ្នាក់ដីយ៉ាងសមស្រប។

## គ ៤.៩ ការបង្ហាញជាសាធារណៈពីការចុះបញ្ជីដីរដ្ឋក្នុងរយៈពេល ៣០ ថ្ងៃ

ក្រុមការងារថ្នាក់ស្រុកដាក់បង្ហាញជាសាធារណៈនូវផែនទីសម្បទានដីសង្គមកិច្ចនៅក្នុងការិយាល័យឃុំរយៈពេល ៣០ ថ្ងៃ។ បុគ្គលិកមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្ត ឬ បុគ្គលិកអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រត្រូវតែមានដើម្បីធ្វើការពន្យល់ និងពិភាក្សាពីផែនទីជាមួយនឹងភាគីនានាដែលចាប់អារម្មណ៍។ ក្រុមការងារថ្នាក់ស្រុកធ្វើការជាមួយអង្គការសង្គមស៊ីវិលក្នុងការពន្យល់ពីផែនទី ជាពិសេសពន្យល់ទៅកាន់អ្នកតវ៉ាដែលមានសក្តានុពល។ ការទាមទារអាចធ្វើឡើងបានដោយប្រើប្រាស់ទម្រង់ទី ១៦ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច និងការផ្តល់មតិយោបល់ ហើយការទាមទារត្រូវតែធ្វើការចុះបញ្ជី។ ក្រុមការងារថ្នាក់ស្រុកចុះបញ្ជីការទាមទារនីមួយៗ និងអញ្ជើញអង្គការសង្គមស៊ីវិលដើម្បីត្រួតពិនិត្យឡើងវិញការទាមទារនីមួយៗ។ ក្រុមការងារថ្នាក់ស្រុកកែតម្រូវផែនទីសម្បទានដីសង្គមកិច្ចឡើងវិញដើម្បីឆ្លុះបញ្ចាំងពីការទាមទារមួយចំនួនដែលមានសុពលភាព។ ការទាមទារទាក់ទងនឹងការប្រើប្រាស់ដីដែលបានធ្វើឡើងក្រោយកាលបរិច្ឆេទឈប់ទទួលពាក្យគួរតែច្រានចោល។

## គ ៤.១០ ការដាក់ផែនទីកែតម្រូវឲ្យធ្វើការត្រួតពិនិត្យជាចុងក្រោយ

មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្ត បញ្ជូនច្បាប់ចម្លងនៃផែនទីសម្បទានដីសង្គមកិច្ចដែលបានកែសម្រួលទៅកាន់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រដើម្បីត្រួតពិនិត្យឡើងវិញ និងធ្វើការសម្រេចជាចុងក្រោយ។

## គ ៤.១១ ការចេញប័ណ្ណដីសម្បទានសង្គមកិច្ចដែលជាដីឯកជនរបស់រដ្ឋសម្រាប់ប្រើប្រាស់ជាដីសម្បទានសង្គមកិច្ច

អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ត្រួតពិនិត្យឡើងវិញ និងការចុះបញ្ជីដីរដ្ឋ និងការចេញប័ណ្ណជាដីឯកជនរបស់រដ្ឋដែលប្រើប្រាស់សម្រាប់សម្បទានដីសង្គមកិច្ច។ របាយការណ៍នេះត្រូវចុះបញ្ជីជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់។

អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រដាក់បញ្ចូលប័ណ្ណដី ផែនទីសម្បទានដីសង្គមកិច្ច និងរបាយការណ៍នានាចូលទៅក្នុងផែនទីដីរដ្ឋថ្នាក់ជាតិ និងកម្មវិធី Database ហើយបញ្ជូនប័ណ្ណដីនេះទៅអភិបាលខេត្ត។

## *ជំហានទី ៥ : ការប្រើប្រាស់ដីរួម និងការធ្វើផែនការហេដ្ឋារចនាសម្ព័ន្ធ*

**លទ្ធផល:** របាយការណ៍សម្បទានដីសង្គមកិច្ចបង្ហាញពី:

- ចំនួនគ្រួសារដែលអាចរស់នៅ និងធ្វើកសិកម្មនៅលើដីសម្បទានសង្គមកិច្ច
- ហេដ្ឋារចនាសម្ព័ន្ធ (ផ្លូវថ្នល់ ការផ្គត់ផ្គង់ទឹក សាលារៀន មណ្ឌលសុខភាព ប្រព័ន្ធធារាសាស្ត្រ ។ល។) ដែលត្រូវការដើម្បីឲ្យប្រជាពលរដ្ឋអាចរស់នៅលើដីសម្បទានសង្គមកិច្ច ឬ ធ្វើកសិកម្មនៅទីនោះបាន។
- ដំណើរការដែលបានស្នើដើម្បីជ្រើសរើសមុខសញ្ញាអ្នកទទួលដី

### គ ៥.១ ការវិភាគលម្អិតអំពីប្រព័ន្ធក្បេត្រូបរិស្ថានសម្បទានដីសង្គមកិច្ច

ការវិភាគលម្អិតអំពីប្រព័ន្ធក្បេត្រូបរិស្ថានសម្បទានដីសង្គមកិច្ច គឺត្រូវធ្វើដើម្បីឆ្លើយតបតាមតម្រូវការមួយចំនួនដូចជា:

១. ផ្តល់មូលដ្ឋានបច្ចេកទេសរឹងមាំសម្រាប់ការធ្វើផែនការប្រើប្រាស់ដីកសិកម្មនៅក្នុងតំបន់សម្បទានដីសង្គមកិច្ច។
២. កំណត់ពីកត្តាការពារបរិស្ថានដ៏សំខាន់ និងបង្កើនគុណភាពនៃការពិនិត្យការការពារ។
៣. ផ្តល់មូលដ្ឋានសម្រាប់ប៉ាន់ស្មានពីសមត្ថភាពផ្ទុកនៃដីសម្បទានសង្គមកិច្ច។

*បញ្ជីត្រួតពិនិត្យប្រព័ន្ធក្បេត្រូបរិស្ថាន - ទម្រង់ទី ៧ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច* បង្ហាញពីព័ត៌មានដែលត្រូវប្រមូលនៅក្នុងប្រព័ន្ធក្បេត្រូបរិស្ថាន។ ភ្នាក់ងារដែលទទួលខុសត្រូវចំពោះប្រព័ន្ធក្បេត្រូបរិស្ថានកត់ត្រានូវលទ្ធផលស្តីពី ***ទម្រង់នៃការអនុវត្តប្រព័ន្ធក្បេត្រូបរិស្ថាន - ទម្រង់ទី ៨ ក នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច និង*** *ស្តីពីផែនទីប្រើប្រាស់ដី។*

ផែនទីប្រើប្រាស់ដីបង្ហាញពីដីដែលនឹងប្រើប្រាស់សម្រាប់កសិកម្ម លំនៅឋាន ឬ គោលបំណងរបស់សហគមន៍នៅក្នុងសម្បទានដីសង្គមកិច្ច និងកន្លែងដែលត្រូវធ្វើផ្លូវចូល។

ផែនទីប្រើប្រាស់ដីបង្ហាញពីដីកសិកម្មដែលបានបែងចែកទៅជាប្លុក (ប្លុក **ក** ប្លុក **ខ** ។ល។) រួមជាមួយនឹងព័ត៌មានដូចខាងក្រោម:

១. ទំហំប្រហាក់ប្រហែលនៃប្លុកគិតជាហិកតា
២. ប្រភេទដីនៅក្នុងប្លុក (ដីលំនៅឋាន ដីធ្វើស្រែ ដីចំការ ។ល។)
៣. ចំនួនប្រហាក់ប្រហែលនៃក្បាលដីដែលប្លុកនោះនឹងត្រូវបែងចែក
៤. សម្រាប់ដីកសិកម្ម សក្តានុពលផលិតកម្មដែលបានប៉ាន់ស្មាន:
ក. ស្រូវ (គីឡូក្រាម/ហិកតា)

ខ. ផលិតផលសាកវប្បកម្ម (យោងតាមប្រភេទដំណាំ និងអត្រាទិន្នផលប៉ាន់ស្មាន គិតជាគីឡូក្រាម/ហិកតា)

គ. ផលិតផលអនុផលព្រៃឈើ (ប្រសិនបើមាន យោងតាមប្រភេទដំណាំ និងអត្រាទិន្នផលប៉ាន់ស្មានគិតជាគីឡូក្រាម/ហិកតា)

៥. ឧទាហរណ៍ : ប្លុក **ក**

ក. ទំហំ : ៦០ ហិកតា

ខ. ដីស្រែ : ២៥ ហិកតា

គ. សក្តានុពលផលិតកម្ម: ២ ០០០គីឡូក្រាម/ហិកតា

ឃ. ចំនួនក្បាលដី: ២៥

## គ ៥.២ វាយតម្លៃសមត្ថភាពផ្ទុក

ភ្នាក់ងារដែលអនុវត្តប្រព័ន្ធក្សេត្របរិស្ថានវាយតម្លៃពីចំនួនគ្រួសារដែលដីសម្បទានសង្គមកិច្ចអាចទ្រទ្រង់ ចំនួនទឹកប្រាក់ដែលត្រូវការ និងបរិមាណទឹកកខ្វក់ដែលនឹងបង្កើតឡើង ដោយយកចិត្តទុដាក់ទៅលើបញ្ហាបរិស្ថាន។

## គ ៥.៣ អនុវត្តការវាយតម្លៃពីសេចក្តីត្រូវការហេដ្ឋារចនាសម្ព័ន្ធ

ក្រុមប្រឹក្សាឃុំគួរស្នើសុំ ផ្នែកគាំទ្របច្ចេកទេសឲ្យជួយធ្វើការវាយតម្លៃពីសេចក្តីត្រូវការហេដ្ឋារចនាសម្ព័ន្ធ។ ការវាយតម្លៃនេះត្រូវធ្វើឡើងដោយប្រើ *ទម្រង់ទី ១៩ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចស្តីពីការវាយតម្លៃសេចក្តីត្រូវការហេដ្ឋារចនាសម្ព័ន្ធ*។ ការវាយតម្លៃសេចក្តីត្រូវការហេដ្ឋារចនាសម្ព័ន្ធត្រូវតែរួមបញ្ចូល:

១. ការវិនិយោគដែលត្រូវការសម្រាប់ផ្លូវថ្នល់ និងស្ពាន ដើម្បីធានាថា គ្រួសារនីមួយៗគឺស្ថិតនៅចម្ងាយ ២គម ពីគ្រប់ផ្លូវចូលដែលប្រើប្រាស់បានគ្រប់រដូវកាលដែលអាចចេញចូលបានទាំងក្នុងរដូវប្រាំង និងរដូវវស្សា។

២. ការវិនិយោគដែលត្រូវការដើម្បីធានាថា គ្រប់ក្បាលដីលំនៅឋានទាំងអស់ គឺស្ថិតនៅចម្ងាយ ១៥០ម ពីប្រភពទឹកស្អាត។

៣. ការរៀបចំអនាម័យសមស្រប

៤. ការវិនិយោគដែលត្រូវការដើម្បីធានាថា កុមារគ្រប់រូបដែលរស់នៅក្នុងសម្បទានដីសង្គមកិច្ចមានកន្លែងរៀនសូត្រនៅក្នុងសាលាបឋមសិក្សាដែលមានចម្ងាយ ៣គម។

៥. ចម្ងាយពីតំបន់សម្បទានដីសង្គមកិច្ចដែលបានស្នើសុំទៅកាន់គ្លីនិកថែទាំសុខភាពបឋមដែលនៅជិតបំផុត។

៦. ប្រភេទផ្សេងទៀតនៃហេដ្ឋារចនាសម្ព័ន្ធដែលអាចនឹងត្រូវការ។ ឧទាហរណ៍ : ទីផ្សារ និងប្រព័ន្ធធារាសាស្ត្រ។

ការវិនិយោគផ្លូវចូល និងការផ្គត់ផ្គង់ទឹកត្រូវតែអនុវត្តនៅមុនពេលអ្នកទទួលដីផ្លាស់ចូលទៅនៅលើដីរបស់ពួកគេ។ ដូចនេះ ផ្នែកគាំទ្របច្ចេកទេសត្រូវចាប់ផ្តើមរៀបចំឯកសារដេញថ្លៃសម្រាប់ការវិនិយោគទាំងនោះឲ្យឆាប់។ ប្រសិនបើមានបំណងសាងសង់សាលាបឋមសិក្សា ត្រូវមានប្រាក់បម្រុងទុកសម្រាប់សង់សាលារៀននៅក្នុងតំបន់សម្បទានដីសង្គមកិច្ច។ ជាងនេះទៅទៀត ត្រូវមានដីបម្រុងទុកសម្រាប់ប្រភេទហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ឧទាហរណ៍ : ទីផ្សារ ប្រព័ន្ធធារាសាស្ត្រ ។ល។ ផែនទីប្រើប្រាស់ដីគួរធ្វើការកែប្រែដើម្បីបង្ហាញពីដីដែលប្រើប្រាស់សម្រាប់ហេដ្ឋារចនាសម្ព័ន្ធ និងមណ្ឌលផ្តល់សេវាកម្មសាធារណៈ។

## គ ៥.៤ ពិនិត្យឡើងវិញ និងការកែសម្រួលការការពារបរិស្ថាន និងសង្គមជាលើកដំបូង

ក្រុមការងារថ្នាក់ស្រុក និងក្រុមប្រឹក្សាឃុំ ពិនិត្យឡើងវិញនូវផែនទីសម្បទានដីសង្គមកិច្ចដើម្បីធានាថា បញ្ហានានាដែលមិនទាន់ដោះស្រាយទាក់ទងនឹងចំណុចខាងក្រោមត្រូវបានដោះស្រាយ ឬបញ្ជាក់:

១. ផលប៉ះពាល់នៃសម្បទានដីសង្គមកិច្ចដែលបានស្នើសុំទៅលើការប្រើប្រាស់ដីព្រៃឈើ និងទីជម្រកធម្មជាតិនាពេលបច្ចុប្បន្ន
២. ផលប៉ះពាល់ទៅលើជនជាតិដើមភាគតិច
៣. ភាពស្មុគស្មាញនៃការតាំងទីលំនៅសារជាថ្មី
៤. ផលប៉ះពាល់នៅលើទីតាំងបេតិកភណ្ឌវប្បធម៌
៥. ដីដែលសមស្របសម្រាប់កសិកម្ម និង
៦. ការឆ្លើយតបទៅនឹងបញ្ហានានាដែលបានលើកឡើងនៅក្នុងការវិភាគយេនឌ័រ។

ក្រុមការងារថ្នាក់ស្រុក និងក្រុមប្រឹក្សាឃុំត្រួតពិនិត្យឡើងវិញនូវទម្រង់នៃការការពារ (***ទម្រង់ទី ៤ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចស្តីពី: ការពិនិត្យការការពារសុវត្ថិភាពសង្គម និងទម្រង់ទី ៤ នៃការបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចស្តីពីការពិនិត្យការការពារបរិស្ថាន)*** ដើម្បីធ្វើឲ្យប្រាកដថាលទ្ធផលដែលទទួលបានពីសម្បទានដី សង្គមកិច្ច/ប្រព័ន្ធកេរ្តិ៍គ្រប់បរិស្ថានឆ្លុះបញ្ចាំងពីបញ្ហានានាដែលបានកំណត់នៅក្នុងទម្រង់ទាំងពីរនេះ។

បន្ទាប់មក ក្រុមការងារថ្នាក់ស្រុកប្រមូល ***ទម្រង់ពិនិត្យការការពារបរិស្ថាន និងការពារសង្គម*** សម្បទានដីសង្គមកិច្ច/ប្រព័ន្ធកេរ្តិ៍គ្រប់បរិស្ថាន ការវាយតម្លៃពីសមត្ថភាពផ្ទុក និងការវាយតម្លៃពីសេចក្តីត្រូវការហេដ្ឋារចនាសម្ព័ន្ធដាក់ចូលទៅក្នុងរបាយការណ៍ព្រាងនៃសម្បទានដីសង្គមកិច្ចថ្នាក់ឃុំ។

## គ ៥.៥ សិក្ខាសាលាសាធារណៈស្តីពីលទ្ធផលនៃធ្វើផែនការដែលមានការចូលរួម

បន្ទាប់មកទៀត ក្រុមប្រឹក្សាឃុំរៀបចំសិក្ខាសាលាជាសាធារណៈដើម្បីពិភាក្សាពីលទ្ធផលនៃការធ្វើផែនការដែលមានការចូលរួម។ ក្រុមការងារថ្នាក់ស្រុក ផ្នែករដ្ឋបាលមូលដ្ឋាន និងផ្នែកគាំទ្របច្ចេកទេស ជួយដល់ក្រុមប្រឹក្សាឃុំក្នុងការរៀបចំសិក្ខាសាលានេះ។ ឃុំត្រូវអញ្ជើញប្រជាពលរដ្ឋក្នុង

មូលដ្ឋាន និងអង្គការសង្គមស៊ីវិលឲ្យចូលរួមក្នុងសិក្ខាសាលានេះហើយត្រូវធានាថាសិក្ខាសាលានេះគឺត្រូវបានផ្សព្វផ្សាយយ៉ាងល្អប្រសើរដើម្បីឲ្យមានការចូលរួមយ៉ាងទូលំទូលាយ។

គោលបំណងរបស់សិក្ខាសាលានេះ គឺ:

១. ស្នើសុំមតិយោបល់នានាពីអ្នកចូលរួមស្តីពីរបាយការណ៍ព្រាង និងផែនទីព្រាងដែលបានកែសម្រួល និងដោះស្រាយបញ្ហាដែលនៅសេសសល់។

២. ធានាថាប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងមុខសញ្ញាអ្នកទទួលផលយល់ដឹងពីច្បាប់ និងបទបញ្ញត្តិនានាទាក់ទងនឹងសម្បទានដីសង្គមកិច្ច។

៣. បង្ហាញ និងពិភាក្សាពីការអភិវឌ្ឍនៅពេលអនាគតក្នុងតំបន់សម្បទានដីសង្គមកិច្ច និង

៤. ឈានដល់ការព្រមព្រៀងគ្នាជាមួយអ្នកចូលរួមទាក់ទងទៅនឹងខ្លឹមសារនៃរបាយការណ៍ព្រាង និងផែនទីព្រាងដែលបានកែសម្រួល។

ក្រុមប្រឹក្សាឃុំត្រូវតែធានាថា កំណត់ហេតុត្រឹមត្រូវនៃសិក្ខាសាលាត្រូវបានធ្វើឡើងក្នុងទម្រង់ជាវីដេអូក៏បាន ឬ ថតជាសម្លេង។

បន្ទាប់ពីសិក្ខាសាលាសាធារណៈ: ក្រុមប្រឹក្សាឃុំនឹងសម្រេចពិនិត្យបញ្ចប់របាយការណ៍ព្រាងស្តីពីសម្បទានដីសង្គមកិច្ច និងផែនទីសម្បទានដីសង្គមកិច្ច។ ក្រុមប្រឹក្សាឃុំបញ្ជូនរបាយការណ៍ និងផែនទីចុងក្រោយទៅអភិបាលខេត្តដើម្បីពិចារណា និងសម្រេច។

## *ជំហានទី ៦ : ការត្រួតពិនិត្យឡើងវិញ និងការអនុម័តរបាយការណ៍សម្បទានដីសង្គមកិច្ចថ្នាក់ឃុំ*

**លទ្ធផល:**

- ការវិភាជន៍ថវិកាសម្រាប់ហេដ្ឋារចនាសម្ព័ន្ធជនបទ និងសេវាកម្ម (មូលនិធិសម្រាប់សមាសភាគទី ២ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច)
- ការផ្តល់សិទ្ធឲ្យបន្តដំណើរការ

### គ ៦.១ ប៉ាន់តម្លៃមូលនិធិដែលត្រូវការសម្រាប់សកម្មភាពនៃសមាសភាគទី ២

សមាសភាគទី ២ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ជួយឧបត្ថម្ភចំពោះថ្លៃចំណាយលើការរៀបចំទីតាំងសម្បទានដីសង្គមកិច្ច ការចូលតាំងទីលំនៅថ្មីដល់អ្នកទទួលដី និងផ្តល់ហេដ្ឋារចនាសម្ព័ន្ធជនបទ និងសេវាកម្ម។

ថ្លៃចំណាយលើសកម្មភាពក្នុងសមាសភាគទី ២ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចមាន ៣ផ្នែក:

១. ថ្លៃចំណាយលើការរៀបចំទីតាំង និងហេដ្ឋារចនាសម្ព័ន្ធជនបទក្នុងបទដ្ឋានអប្បបរមាដែលអាចទទួលយកបាន។ ថ្លៃចំណាយទាំងនេះ គឺជាខ្ទង់ចំណាយដែលចាំបាច់។

២. ថ្លៃចំណាយលើការជួយឧបត្ថម្ភក្នុងការចូលតាំងទីលំនៅថ្មី និងសេវាកម្មជាមូលដ្ឋាននៅក្នុងឆ្នាំទី ១។ ថ្លៃចំណាយទាំងនេះ គឺជាខ្ទង់ចំណាយដែលចាំបាច់។
៣. ក្រុមប្រឹក្សាឃុំអាចប្រើប្រាស់ប្រាក់ជំនួយដាច់ស្រេចដើម្បីជួយគាំទ្រដល់ហេដ្ឋារចនាសម្ព័ន្ធជនបទ និងសេវាបន្ថែមក្នុងឆ្នាំទី ២ និងឆ្នាំទី ៣ ផ្អែកលើអាទិភាពរបស់អ្នកទទួលដី។

រូបមន្តសម្រាប់គណនាការវិភាជន៍មូលនិធិសម្រាប់សមាសភាគទី ២ គឺមានបង្ហាញនៅក្នុង *ទម្រង់ទី ២០ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច*។

បន្ទាប់ពីត្រួតពិនិត្យឡើងវិញនូវផែនទី និងរបាយការណ៍សម្បទានដីសង្គមកិច្ចព្រាង គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ប៉ាន់ស្មានមូលនិធិសម្រាប់សមាសភាគទី ២ ដែលត្រូវការសម្រាប់តំបន់សម្បទានដីសង្គមកិច្ចដែលបានស្នើសុំ ដោយផ្អែកទៅលើរូបមន្តដែលបានបង្ហាញនៅក្នុង *ទម្រង់ទី ២០ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។*

## គ ៦.២ ត្រួតពិនិត្យការការពារសុវត្ថិភាព និងភាពស្របគ្នាជាមួយនឹងក្របខ័ណ្ឌច្បាប់

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ពិនិត្យឲ្យឃើញថា របាយការណ៍សម្បទានដីសង្គមកិច្ចគោរពការការពារបរិស្ថាន និងសង្គម ហើយដំណើរការជ្រើសរើសមុខសញ្ញាអ្នកទទួលដី គឺស្របច្បាប់ និងមានតម្លាភាព។

## គ ៦.៣ ការអនុម័តរបាយការណ៍សម្បទានដីសង្គមកិច្ចថ្នាក់ឃុំ

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ពិនិត្យមើលគ្រប់ទិដ្ឋភាពទាំងអស់នៃរបាយការណ៍សម្បទានដីសង្គមកិច្ច រួមទាំងធានាថា ការការពារបរិស្ថាន និងសង្គម ត្រូវបានគោរពតាម ហើយដំណើរការជ្រើសរើសមុខសញ្ញាអ្នកទទួលដី គឺស្របច្បាប់ និងមានតម្លាភាព។ គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត អាចធ្វើការកែតម្រូវ និងកែសម្រួលតិចតួចទៅលើរបាយការណ៍ និងផែនទីសម្បទានដីសង្គមកិច្ច និងទៅលើគ្រោងថវិកាប្រសិនបើចាំបាច់។

ប្រសិនបើរបាយការណ៍សម្បទានដីសង្គមកិច្ចថ្នាក់ឃុំត្រូវការការកែសម្រួល ឬ ការបញ្ជាក់ច្រើន គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តត្រូវតែរៀបចំ *លិខិតផ្តល់សិទ្ធិរបស់* គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត (សូមមើលឧបសម្ព័ន្ធសម្រាប់ *ទម្រង់ទី ២២ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច) ដែលណែនាំដល់ក្រុមប្រឹក្សាឃុំឲ្យផ្តល់ :*

១. លិខិតបញ្ជាក់ជាលាយលក្ខណ៍អក្សរមិនឲ្យលើសពីមួយទំព័រ ឬ
២. បញ្ជូនរបាយការណ៍សម្បទានដីសង្គមកិច្ចតាមថ្នាក់ឃុំមានការកែសម្រួលដែលឆ្លុះបញ្ចាំងពីការកែប្រែនានាដែលស្នើឡើងដោយគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត។

ក្រុមប្រឹក្សាឃុំត្រូវតែត្រួតពិនិត្យឡើងវិញនូវសំណើមកពីគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ដើម្បីជាការបញ្ជាក់ ហើយរៀបចំលិខិតបញ្ជាក់ ឬ កែសម្រួលរបាយការណ៍

សម្បទានដីសង្គមកិច្ចថ្នាក់ឃុំ និងបញ្ជូនត្រឡប់មកគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តវិញក្នុងរយៈពេល ១៥ ថ្ងៃដើម្បីទទួលបាន***ទម្រង់ទី ២២ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចស្ដីពីលិខិតផ្ដល់សិទ្ធិរបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត***។

នៅពេលនោះ គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ត្រូវតែឆ្លើយតបទៅក្រុមប្រឹក្សាឃុំក្នុងរយៈពេល ១៥ថ្ងៃ បន្ទាប់ពីទទួលបានលិខិតបញ្ជាក់ជាលាយលក្ខណ៍អក្សរ ឬ របាយការណ៍សម្បទានដីសង្គមកិច្ចថ្នាក់ឃុំដែលបានកែសម្រួល ឬ កែសម្រួលរបាយការណ៍សម្បទានដីសង្គមកិច្ចថ្នាក់ឃុំផ្អែកលើលិខិតបញ្ជាក់ដែលទទួលបានពីក្រុមប្រឹក្សាឃុំ។

## គ ៦.៤ ការកែសម្រួល និងការផ្ដល់សិទ្ធិឲ្យបន្តរៀបចំផែនការសម្បទានដីសង្គមកិច្ចច្បាស់លាស់

នៅពេលដែលការកែសម្រួលជាចាំបាច់ទាំងអស់ត្រូវបានធ្វើឡើង គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ត្រូវតែបញ្ជូនច្បាប់ចម្លងចុងក្រោយនៃរបាយការណ៍សម្បទានដីសង្គមកិច្ចថ្នាក់ឃុំទៅក្រុមប្រឹក្សាឃុំ ហើយប្រើ***ទម្រង់ទី ២២ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចស្ដីពីលិខិតផ្ដល់សិទ្ធិរបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត*** ដែលណែនាំដល់ក្រុមប្រឹក្សាឃុំស្ដីពីការអនុម័តលើរបាយការណ៍សម្បទានដីសង្គមកិច្ចថ្នាក់ឃុំ និងការបន្តដំណើរការរៀបចំផែនការសម្បទានដីសង្គមកិច្ចច្បាស់លាស់។

## ***ជំហានទី ៧ : ការជ្រើសរើសអ្នកទទួលដី***

**លទ្ធផល:** បញ្ជីឈ្មោះអាទិភាពនៃអ្នកទទួលដី និងបញ្ជីឈ្មោះបម្រុងនៃអ្នកទទួលដី។

**ពេលវេលាអប្បបរមាដែលត្រូវការ:** ១២២ ថ្ងៃ

- រយៈពេលជូនដំណឹងអំពីដំណើរការដាក់ពាក្យស្នើសុំ: មានរយៈពេល៣០ថ្ងៃ
- រយៈពេលទទួលពាក្យស្នើសុំ: មានរយៈពេល២០ថ្ងៃ
- ការបង្ហាញជាសាធារណៈនូវបញ្ជីដាក់ពាក្យសុំ: មានរយៈពេល៣០ថ្ងៃ
- ការពិនិត្យពាក្យសុំ: មានរយៈពេល១៥ថ្ងៃ
- ការបង្ហាញអំពីបញ្ជីឈ្មោះអាទិភាព និងបញ្ជីឈ្មោះបម្រុង: មានរយៈពេល២០ថ្ងៃ
- ការបង្ហាញអំពីបញ្ជីឈ្មោះដែលបានកែសម្រួលឡើងវិញ: មានរយៈពេល៧ថ្ងៃ

## គ ៧.១ ការជូនដំណឹង និងការលើកកម្ពស់ការយល់ដឹងពីការដាក់ពាក្យសុំ និងលក្ខណៈវិនិច្ឆ័យលើភាពសមស្រប

ត្រូវធ្វើការប្រកាសជូនដំណឹងជាសាធារណៈក្នុងរយៈពេល ៣០ ថ្ងៃ ដើម្បីជូនដំណឹងដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋានអំពីដំណើរការដាក់ពាក្យស្នើសុំសម្បទានដីសង្គមកិច្ច។ ក្នុងអំឡុងពេលនោះ ក្រុមប្រឹក្សាឃុំត្រូវៈ

១. ប្រកាសអំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងទទួលពាក្យសុំដីសម្បទានសង្គមកិច្ច (*ទម្រង់ទី ១២ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ស្ដីពីការដំណឹងដល់អ្នកដាក់ពាក្យស្នើសុំ)*

២. ដាក់បង្ហាញព័ត៌មាននេះ និងលក្ខណវិនិច្ឆ័យពីភាពសមស្របដោយប្រើ *ទម្រង់ទី៩ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ស្ដីពីលក្ខណវិនិច្ឆ័យពីភាពសមស្របសម្រាប់ដាក់ពាក្យសុំសម្បទានដីសង្គមកិច្ច និងទម្រង់ជូនដំណឹងសម្រាប់អ្នកដាក់ពាក្យសុំដី (ទម្រង់ទី ១២ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច)* ។

៣. ធានាថា ការប្រកាសជូនដំណឹងជាសាធារណៈមានបញ្ចូលនូវព័ត៌មានដូចខាងក្រោមៈ
   - ក. តំបន់ដែលប្រជាពលរដ្ឋត្រូវរស់នៅដើម្បីឲ្យបានជាមូលដ្ឋានក្នុងការដាក់ពាក្យ
   - ខ. កន្លែងចែកចាយទម្រង់ពាក្យស្នើសុំ
   - គ. កន្លែងស្វែងរកការជួយបំពេញពាក្យ និង
   - ឃ. ការបរិយាយពីការទទួលខុសត្រូវរបស់អ្នកទទួលដី *(ទម្រង់ទី ១១ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចស្ដីពីការទទួលខុសត្រូវរបស់មុខសញ្ញាអ្នកទទួលដី)*

៤. ក្រោមជំនួយពីក្រុមការងារថ្នាក់ស្រុក ធ្វើយុទ្ធនាការផ្សព្វផ្សាយព័ត៌មានតាមរយៈការជូនដំណឹងជាសាធារណៈ និងការប្រជុំតាមភូមិ។

៥. ធានាថា អង្គការសង្គមស៊ីវិលអាចចូលរួមបានក្នុងដំណើរការនេះ។

## គ ៧.២ ការទទួលពាក្យ

បន្ទាប់ពីចប់រយៈពេលជូនដំណឹងជាសាធារណៈ វានឹងមានរយៈពេលយ៉ាងតិច ២០ថ្ងៃសម្រាប់ឲ្យប្រជាពលរដ្ឋក្នុងមូលដ្ឋានដាក់ពាក្យសុំ។ ក្នុងអំឡុងពេលនេះ ក្រុមការងារថ្នាក់ស្រុកត្រូវបញ្ជូនមន្ត្រីម្នាក់ដើម្បីជួយដល់ក្រុមប្រឹក្សាឃុំ។ ក្រុមប្រឹក្សាឃុំត្រូវៈ

១. ជួយអ្នកដាក់ពាក្យក្នុងការបំពេញពាក្យរបស់ពួកគាត់ (*ទម្រង់ទី១ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចស្ដីពីពាក្យសុំសម្បទានដីសង្គមកិច្ច)*។

២. ទទួលពាក្យ និង

៣. សរសេរបញ្ចូលឈ្មោះអ្នកដាក់ពាក្យសុំទៅក្នុង *ទម្រង់ចុះបញ្ជីពាក្យស្នើសុំសម្បទានដីសង្គមកិច្ច* (ប្រើ *ទម្រង់ទី ២ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច*)

## គ ៧.៣ ការដាក់បង្ហាញជាសាធារណៈនូវបញ្ជីពាក្យស្នើសុំ

បន្ទាប់ពីចប់រយៈពេលទទួលពាក្យ បញ្ជីពាក្យស្នើសុំត្រូវដាក់បង្ហាញនៅក្នុងទីតាំងសាធារណៈមួយចំនួនយ៉ាងតិច ៣០ថ្ងៃ។ ក្នុងអំឡុងពេលនេះ ប្រជាពលរដ្ឋមូលដ្ឋានអាចមានឱកាសផ្ទៀងផ្ទាត់ព័ត៌មានដែលបានផ្តល់ដោយអ្នកដាក់ពាក្យ ហើយអាចដាក់ពាក្យបណ្តឹងតវ៉ាបាន។ ក្រុមប្រឹក្សាឃុំត្រូវៈ

១. ពិនិត្យឲ្យបានច្បាស់ថា បញ្ជីឈ្មោះអ្នកដាក់ពាក្យសុំ *(ទម្រង់ទី ២ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចស្តីពីការចុះបញ្ជី ការដាក់ពាក្យសុំសម្បទានដីសង្គមកិច្ច)* មានលក្ខណៈពេញលេញ។ ផ្ញើច្បាប់ចម្លងទៅឲ្យ គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត។

២. ដាក់បង្ហាញបញ្ជីឈ្មោះអ្នកដាក់ពាក្យសុំនៅតាមទីតាំងសាធារណៈមួយចំនួនទូទាំងឃុំ និងនៅសាលាឃុំមិនឲ្យតិចជាង ៣០ថ្ងៃ[៥]។

៣. ធានាថាប្រជាពលរដ្ឋមូលដ្ឋានអាចធ្វើការពិនិត្យពាក្យស្នើសុំរបស់ខ្លួនបាននៅក្នុងតំបន់សម្បទានដីសង្គមកិច្ច។

៤. ធានាឲ្យមានការចូលរួមពីអង្គការសង្គមស៊ីវិលក្នុងដំណើរការទាំងមូលនៃការដាក់ពាក្យស្នើសុំ និងការដាក់បង្ហាញជាសាធារណៈ និងធានាថា ប្រជាពលរដ្ឋមូលដ្ឋាន និងអង្គការ សង្គមស៊ីវិលទាំងអស់ដឹងថា ពួកគាត់អាចពិនិត្យផ្ទៀងផ្ទាត់ពាក្យស្នើសុំ និងអាចដាក់ពាក្យបណ្តឹងដោយប្រើ *ទម្រង់ទី ២ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចស្តីពីបញ្ជីការដាក់ពាក្យសុំសម្បទានដីសង្គមកិច្ចលើកដំបូង។*

៥. ផ្ញើច្បាប់ចម្លងមួយច្បាប់នៃ *ទម្រង់ចុះបញ្ជីពាក្យសុំធ្វើសម្បទានដីសង្គម (ទម្រង់ទី ២ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច)* ទៅគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ដោយគោរពតាមគោការណ៍ណែនាំ [៦] របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

៦. ចុះបញ្ជីរាល់ពាក្យបណ្តឹងទាំងអស់ដោយប្រើ *ទម្រង់ទី ២៤ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចស្តីពីការចុះបញ្ជីពាក្យបណ្តឹងៈ បញ្ជីពាក្យស្នើសុំសម្បទានដីសង្គមកិច្ចលើកដំបូង* ។

---

[៥] ប្រកាសលេខ ២០០ ស្តីពីគោលការណ៍ណែនាំសម្រាប់អនុវត្តអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច មាត្រា ១៩។

[៦] ប្រកាសលេខ ២០០ មាត្រា ២០

## គ ៧.៤ ការជ្រើសរើសអ្នកទទួលដីដែលមានសក្តានុពល

ក្រុមប្រឹក្សាឃុំត្រូវពិនិត្យសម្រាំងពាក្យស្នើសុំ និងចុះបញ្ជីអ្នកដាក់ពាក្យគ្រប់រូបដែលស្របតាមលក្ខណវិនិច្ឆ័យជាមុខសញ្ញាអ្នកទទួលដី។ បញ្ជីឈ្មោះអ្នកដាក់ពាក្យស្នើសុំដែលសមស្រប គឺហៅថាបញ្ជីឈ្មោះអ្នកស័ក្តិសមទទួលបានសម្បទានដីសង្គមកិច្ចលើកដំបូង។ ការជ្រើសរើស សម្រាំងដំបូងត្រូវតែបញ្ចប់ក្នុងអំឡុងពេល ១៥ថ្ងៃ បន្ទាប់ពីចប់ការដាក់បង្ហាញជាសាធារណៈនៃបញ្ជីឈ្មោះបេក្ខជនទាំងអស់។

ក្រុមការងារថ្នាក់ស្រុក និងផ្នែករដ្ឋបាលមូលដ្ឋាន គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត ត្រូវជួយក្រុមប្រឹក្សាឃុំក្នុងដំណើរការនេះ។ ក្រុមប្រឹក្សាឃុំត្រូវអញ្ជើញអង្គការសង្គមស៊ីវិលឲ្យចូលរួមក្នុងការជ្រើសរើសសម្រាំងពាក្យស្នើសុំទាំងនេះ។ មន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ខេត្ត និងមន្ទីរកិច្ចការនារីខេត្តត្រូវពិនិត្យឡើងវិញលើដំណើរការជ្រើសរើសមុខសញ្ញាអ្នកទទួលដីដោយផ្អែកលើលក្ខណវិនិច្ឆ័យនៃការជ្រើសរើសនៅក្នុងរបាយការណ៍សម្បទានដីសង្គមកិច្ចថ្នាក់ឃុំដើម្បីធានាឲ្យមានភាពត្រឹមត្រូវ [៧]។

ប្រសិនបើចំនួនគ្រួសារនៅក្នុងបញ្ជីឈ្មោះអ្នកស័ក្តិសមទទួលបានសម្បទានដីសង្គមកិច្ចដំបូងលើសពីសមត្ថភាពផ្ទុកនៃតំបន់សម្បទានដីសង្គមកិច្ច ក្រុមប្រឹក្សាឃុំត្រូវផ្តល់អាទិភាពឲ្យអ្នកដាក់ពាក្យស្នើសុំដែលនៅក្នុងតំបន់តាមរយៈការចាត់ចំណាត់ថ្នាក់ ការចាប់ឆ្នោត ឬ តាមយន្តការផ្សេងទៀតដែលមានការឯកភាព។ ក្រុមប្រឹក្សាឃុំអាចប្រើ ***វិធីសាស្ត្រដាក់ចំណាត់ថ្នាក់អ្នកដាក់ពាក្យ*** (***ទម្រង់ទី២៥ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច***) ដើម្បីផ្តល់អាទិភាពដល់អ្នកដាក់ពាក្យសុំសម្បទានដីសង្គមកិច្ច។

គ្រួសារដែលត្រូវបានជ្រើសរើសឲ្យទទួលដីត្រូវចុះនៅក្នុង ***ទម្រង់ ២៦ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ស្តីពីបញ្ជីឈ្មោះអ្នកដាក់ពាក្យស្នើសុំសម្បទានដីសង្គមកិច្ចដែលមានអាទិភាព***។

គ្រួសារដែលមានឈ្មោះនៅក្នុងបញ្ជីស័ក្តិសមទទួលបានសម្បទានដីសង្គមកិច្ចលើកដំបូង តែមិនត្រូវបានជ្រើសរើស ត្រូវសសេរចូលក្នុងបញ្ជីឈ្មោះអ្នកដាក់ពាក្យសុំសម្បទានដីសង្គមកិច្ចបម្រុង។ ក្រុមប្រឹក្សាឃុំត្រូវពន្យល់ថា គ្រួសារទាំងនេះនឹងអាចទទួលបានដី ប្រសិនបើមានដីច្រើននៅក្នុងពេលខាងមុខ។

## គ ៧.៥ ការដាក់បង្ហាញជាសាធារណៈនូវឈ្មោះអ្នកទទួលទទួលដី/ពាក្យបណ្តឹងតវ៉ាដែលមានសក្តានុពល

ក្រុមប្រឹក្សាឃុំត្រូវដាក់បង្ហាញបញ្ជីឈ្មោះអ្នកទទួលដីសម្បទានដីសង្គមកិច្ចដែលមានសក្តានុពល ***(បញ្ជីឈ្មោះអ្នកដាក់ពាក្យសុំសម្បទានដីសង្គមកិច្ចដែលមានអាទិភាព -ទម្រង់ទី២៦ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច*** និងបញ្ជីឈ្មោះអ្នកដាក់ពាក្យស្នើសុំសម្បទានដីសង្គមកិច្ចបម្រុង) យ៉ាងតិច ២០ថ្ងៃ។ ការដាក់បង្ហាញនេះត្រូវធ្វើនៅក្នុងទីតាំងដដែលដូចការបង្ហាញជាសាធារណៈ លើកដំបូងដែរ។

---

[៧] ប្រកាសលេខ ២០០ មាត្រា ២១

ក្រុមប្រឹក្សាឃុំ ត្រូវស្វែងរកជំនួយពីអង្គការសង្គមស៊ីវិលដើម្បីបង្កើនការយល់ដឹងនៅក្នុងសហគមន៍អំពីដំណើរការជ្រើសរើសនេះ។

ប្រជាពលរដ្ឋមូលដ្ឋាន និងអង្គការសង្គមស៊ីវិលត្រូវមានឱកាសត្រួតពិនិត្យបញ្ជីឈ្មោះអ្នកដាក់ពាក្យសុំ និងទម្រង់ពាក្យស្នើសុំផងដែរ ហើយអាចដាក់ពាក្យបណ្តឹងតវ៉ាដោយប្រើ *ទម្រង់ទី ២៧ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចស្តីពីទម្រង់ពាក្យបណ្តឹងតវ៉ាៈ បញ្ជីជ្រើសរើសសម្បទានដីសង្គមកិច្ចដែលមានអាទិភាព។*

ក្រុមប្រឹក្សាឃុំត្រូវចុះបញ្ជីរាល់ពាក្យបណ្តឹងទាំងអស់ដោយប្រើ *ទម្រង់ទី ២៨ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច – ទម្រង់ចុះបញ្ជីពាក្យបណ្តឹងតវ៉ា – ការធ្វើចំណាត់ថ្នាក់មុខសញ្ញាអ្នកទទួលដី*។

ក្រុមការងារថ្នាក់ស្រុកត្រូវស៊ើបអង្កេតរាល់ពាក្យបណ្តឹងនីមួយៗ និងធ្វើការឆ្លើយតបជាលាយលក្ខណ៍អក្សរ ហើយចងក្រងជារបាយការណ៍ដាក់ជូនគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ។

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកថ្នាក់ខេត្តត្រូវពិនិត្យរបាយការណ៍ឡើងវិញ ធ្វើសេចក្តីសម្រេច និងឆ្លើយតបចំពោះពាក្យបណ្តឹងនីមួយៗក្នុងរយៈពេល ៣០ថ្ងៃ[៨]។

## គ ៧.៦ ការផ្តល់សុពលភាពនៅលើព័ត៌មានស្តីពីទម្រង់ពាក្យស្នើសុំ

ក្នុងពេលជាមួយគ្នានឹងការដាក់បង្ហាញជាសាធារណៈនូវបញ្ជីឈ្មោះអ្នកទទួលដីដែលមានសក្តានុពល វានឹងមានការផ្តល់សុពលភាពតាមរយៈការចុះទៅជួបគ្រួសារទាំងអស់ដើម្បីឲ្យប្រាកដថា ព័ត៌មានដែលផ្តល់ឲ្យដោយអ្នកដាក់ពាក្យសុំមានភាពត្រឹមត្រូវពិតប្រាកដមែន។ ការផ្តល់សុពលភាពនេះត្រូវអនុវត្តដោយៈ

១. ក្រុមការងារថ្នាក់ស្រុក
២. ផ្នែករដ្ឋបាលមូលដ្ឋាន
៣. ក្រុមប្រឹក្សាឃុំ
៤. អង្គការសង្គមស៊ីវិល

ប្រសិនបើដំណើរការជ្រើសរើសរួមបញ្ចូលការប្រើប្រាស់ទិន្នន័យដែលបានមកពីការកំណត់អត្តសញ្ញាណតាមរយៈការស្ទង់មតិគ្រួសារក្រីក្រ (អត្តសញ្ញាណកម្មគ្រួសារក្រីក្រ) ចាំបាច់ត្រូវចុះទៅដល់ផ្ទះរបស់អ្នកដាក់ពាក្យសុំទាំងអស់នៅក្នុងដំណាក់កាលផ្តល់សុពលភាព។
វិធីពិនិត្យចំនួនក្រុមគ្រួសារដែលត្រូវចុះទៅដល់ផ្ទះ គឺៈ

[៨]អនុក្រឹត្យលេខ១៩ អំពីសម្បទានដីសង្គមកិច្ច ប្រការ ១៤ និងប្រកាស ២០០ ស្តីពីសេចក្តីណែនាំលើការអនុវត្តអនុក្រឹត្យស្តីអំពីសម្បទានដីសង្គមកិច្ច ប្រការ ២៥ ។

១. គ្រួសារដែលត្រូវបានដាក់បញ្ចូលទៅក្នុង ***បញ្ជីឈ្មោះអ្នកដាក់ពាក្យសុំដែលមានអាទិភាព និងបញ្ជីអ្នកដាក់ពាក្យសុំបម្រុង*** ដែលមិនទាន់ត្រូវបានវាយតម្លៃថាជាគ្រួសារក្រីក្រនៅក្នុងដំណើរការការស្វង់មតិស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និង

២. គ្រួសារ ១០% ក្នុងចំណោមគ្រួសារទាំងអស់ដែលបានដាក់បញ្ចូលក្នុង ***បញ្ជីឈ្មោះអ្នកដាក់ពាក្យសុំដែលមានអាទិភាព និងបញ្ជីអ្នកដាក់ពាក្យសុំបម្រុង*** ដែលមិនទាន់ត្រូវបានវាយតម្លៃថាជាក្រុមគ្រួសារក្រីក្រនៅក្នុងដំណើរការស្ទង់មតិស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។

## គ ៧.៧ ការដាក់បង្ហាញជាសាធារណៈនូវបញ្ជីដំណោះស្រាយពាក្យបណ្តឹងតវ៉ា និងបញ្ជីដែលកែតម្រូវ

បន្ទាប់ពីការដាក់បង្ហាញជាសាធារណៈ និងការផ្តល់សុពលភាពបានបញ្ចប់ ក្រុមការងារថ្នាក់ស្រុកត្រូវពិនិត្យឡើងវិញនូវទម្រង់ពាក្យស្នើសុំ ***ទម្រង់ពាក្យស្នើសុំសម្បទានដីសង្គមកិច្ចជាអាទិភាព– ទម្រង់ទី ២៦ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច*** និងបញ្ជីឈ្មោះអ្នកដាក់ពាក្យសុំសម្បទានដីសង្គមកិច្ចបម្រុង ហើយផ្ញើបញ្ជីទាំងនេះជូនគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត។

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តត្រូវពិនិត្យឡើងវិញ និងអនុម័តទម្រង់ និងបញ្ជីឈ្មោះ ហើយផ្ញើវាជូនក្រុមប្រឹក្សាឃុំធ្វើការដាក់បង្ហាញជាសាធារណៈ។

ក្រុមប្រឹក្សាឃុំត្រូវៈ

១. សង្ខេបលទ្ធផលដែលបានមកពីការអនុវត្តការផ្តល់សុពលភាព

២. ដាក់បង្ហាញសេចក្តីសង្ខេប និង ***ទម្រង់ពាក្យស្នើសុំសម្បទានដីសង្គមកិច្ចដែលមានអាទិភាព – ទម្រង់ទី ២៦ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច*** និងបញ្ជីឈ្មោះអ្នកដាក់ពាក្យសង្គមកិច្ចបម្រុងនៅសាលាឃុំរយៈពេលយ៉ាងតិច៧ថ្ងៃមុនពេលបែងចែកដី។

៣. អញ្ជើញអង្គការសង្គមស៊ីវិលដើម្បីធ្វើការជូនដំណឹងដល់ប្រជាពលរដ្ឋអំពីដំណើរការនេះ

៤. សូមធ្វើឲ្យប្រាកដថា ប្រជាពលរដ្ឋទាំងអស់អាចទទួលព័ត៌មានដែលបានមកពីការអនុវត្តការផ្តល់សុពលភាពនៅក្នុងសាលាឃុំ។

## គ ៧.៨ ការប្រជុំតាមភូមិស្តីពីលទ្ធផលនៃការផ្តល់សុពលភាព

បន្ទាប់ពីការដាក់បង្ហាញជាសាធារណៈនូវបញ្ជីដំណោះស្រាយពាក្យបណ្តឹង និងបញ្ជីដែលបានកែសម្រួល ហើយដោយមានជំនួយពីក្រុមការងារថ្នាក់ស្រុក និងផ្នែករដ្ឋបាលមូលដ្ឋាន ក្រុមប្រឹក្សាឃុំត្រូវៈ

១. រៀបចំ និងធ្វើផែនការប្រជុំជាសាធារណៈថ្នាក់ភូមិដើម្បីពន្យល់ពីលទ្ធផលនៃការអនុវត្តការផ្តល់សុពលភាព
២. សុំឲ្យអង្គការសង្គមស៊ីវិលជួយក្នុងការផ្សព្វផ្សាយជាសាធារណៈអំពីការប្រជុំជាសាធារណៈនេះដើម្បីធានាឲ្យមានតម្លាភាព និងយុត្តិធម៌នៅក្នុងដំណើរការនេះ
៣. រក្សាទុកឯកសារវីដេអូ ឬ ឯកសារថតជាសម្លេងស្តីពីការប្រជុំ និងបញ្ជីឈ្មោះអ្នកចូលរួមទាំងអស់
៤. រៀបចំកែប្រែបញ្ជីឈ្មោះអ្នកដាក់ពាក្យសុំដែលមានអាទិភាព និងអ្នកដាក់ពាក្យសុំសម្បទានដីសង្គមកិច្ចបម្រុងជាលើកចុងក្រោយ ដោយផ្អែកលើកិច្ចពិភាក្សា និង
៥. រៀបចំរបាយការណ៍សង្ខេបស្តីអំពីការកែសម្រួលចំពោះការកែប្រែដែលបានស្នើសុំ ហើយដាក់វាជូនគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត។

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ត្រូវធ្វើការពិនិត្យឡើងវិញនូវកំណត់ហេតុប្រជុំ និងរបាយការណ៍សង្ខេប ហើយធ្វើពាក្យស្នើសុំ និងបញ្ជីដែលបានពិនិត្យ ឬ ឯកភាពជូនក្រុមប្រឹក្សាឃុំ។

ក្រុមប្រឹក្សាឃុំត្រូវសង្ខេបពីការកែប្រែទៅលើទម្រង់ពាក្យស្នើសុំ និង*បញ្ជីឈ្មោះអ្នកដាក់ពាក្យដែលមានអាទិភាព និងអ្នកដាក់ពាក្យសុំបម្រុង* យ៉ាងតិច ៧ ថ្ងៃមុនពេលបែងចែកដី។ ក្រុមប្រឹក្សាឃុំត្រូវតែប្រាកដថា កំណត់ហេតុនៃការស៊ើបអង្កេតពាក្យបណ្តឹងនីមួយៗអាចរកបានដើម្បីពិនិត្យឡើងវិញនៅក្នុងឃុំ។

## គ ៧.៩ ការជ្រើសរើសអ្នកទទួលដី

បន្ទាប់ពីការប្រជុំថ្នាក់ភូមិ និងការដាក់បង្ហាញបញ្ជីឈ្មោះដែលបានកែសម្រួលបញ្ចប់ ***ទម្រង់ពាក្យស្នើសុំសម្បទានដីសង្គមកិច្ចដែលមានអាទិភាព–ទម្រង់ទី២៦ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច*** ចាប់ផ្តើមមានសុពលភាព ហើយប្រជាពលរដ្ឋដែលមានឈ្មោះ ក្នុងបញ្ជីនោះនឹងទទួលបានដីសម្បទានសង្គមកិច្ច។

ក្រុមប្រឹក្សាឃុំត្រូវៈ

១. ផ្ញើច្បាប់ចម្លងចុងក្រោយនៃ*បញ្ជីឈ្មោះអ្នកដាក់ពាក្យសុំដែលមានអាទិភាព និងអ្នកដាក់ពាក្យសុំសម្បទានដីសង្គមកិច្ចបម្រុង* ជូនគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត និងក្រុមការងារថ្នាក់ស្រុក
២. ជួយអ្នកទទួលដីក្នុងការជ្រើសរើសអ្នកតំណាង ២ រូបដើម្បីចូលរួមក្នុងក្រុមការងារសម្បទានដីសង្គមកិច្ចថ្នាក់ឃុំ។

## *ជំហានទី ៨ : ការរៀបចំផែនការសម្បទានដីសង្គមកិច្ចច្បាស់លាស់*

**លទ្ធផល:**

- ក្បាលដីសម្បទានសង្គមកិច្ចដែលត្រូវបែងចែកទៅឲ្យគ្រួសារមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកស្នើសុំដែលមានអាទិភាព
- ផែនការសម្បទានដីសង្គមកិច្ចច្បាស់លាស់ដែលបានឯកភាព។

### គ ៨.១ ការរៀបចំធ្វើផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម

ដោយមានជំនួយពីក្រុមការងារថ្នាក់ស្រុក និងផ្នែករដ្ឋបាលមូលដ្ឋាន ក្រុមប្រឹក្សាឃុំត្រូវ:

១. ពន្យល់ដល់អ្នកដែលបានទទួលដីអំពីផែនទីព្រាងសម្បទានដីសង្គមកិច្ច/ប្រព័ន្ធក្សេត្របរិស្ថាន និងផែនទីព្រាងចុងក្រោយ

២. ដឹកនាំកិច្ចពិភាក្សាជាក្រុមតូចៗដើម្បីពិនិត្យឡើងវិញ និងពន្យល់អំពីរបាយការណ៍សម្បទានដីសង្គមកិច្ចក្នុងឃុំ ដោយផ្តោតជាសំខាន់លើបញ្ហាដូចខាងក្រោម:

ក. តំបន់ណាខ្លះដែលកំណត់សម្រាប់ធ្វើកសិកម្ម និងតំបន់ណាខ្លះដែលបានកំណត់សម្រាប់ការអភិរក្ស ឬ ព្រៃឈើសហគមន៍ និងសម្រាប់ការប្រើប្រាស់ផ្សេងទៀត

ខ. ការការពារបរិស្ថាន និង

គ. ប៉ាន់ស្មានពីសមត្ថភាពផ្ទុក

៣. ចំពោះដីកសិកម្ម ត្រូវពិនិត្យឡើងវិញនូវ:

ក. គុណភាពដី និងសណ្ឋានដីនៅក្នុងតំបន់នេះ

ខ. ឋានលេខាខ្នាតតូច (Micro-topography)

គ. ធនធានទឹក

ឃ. គម្របដីចាស់ និង

ង. កត្តាផ្សេងទៀតដែលបង្ហាញយ៉ាងច្បាស់ពីសក្តានុពលផ្នែកកសិកម្មនៃតំបន់សម្បទានដីសង្គមកិច្ច។

បន្ទាប់មកទៀត អ្នកទទួលដីត្រូវកំណត់ក្បាលដីកសិកម្មជាក់ស្តែងនៅក្នុងតំបន់សម្បទានដីសង្គមកិច្ច ដោយមានជំនួយពីក្រុមប្រឹក្សាឃុំ ក្រុមការងារថ្នាក់ស្រុក និងផ្នែករដ្ឋបាលមូលដ្ឋាន ។ ពួកគាត់ត្រូវ:

១. ប្រាកដថា ក្បាលដីកសិកម្មទាំងអស់មានសណ្ឋានប្រហាក់ប្រហែលគ្នា

២. កំណត់ព្រំដីបណ្តោះអាសន្នដោយបោះបង្គោលឈើ ឬ បង្គោលថ្ម

៣. ថតរូប និងកំណត់ទីតាំងព្រំដីនីមួយៗដោយប្រើប្រព័ន្ធឧបករណ៍កំណត់ទីតាំងភូគោលសាស្ត្រ

៤.	គូសព្រាងព្រំដីទាំងអស់នៅលើផែនទីដែលមាន និង
៥.	ប៉ាន់ស្មានទំហំក្បាលដីនីមួយៗ

បន្ទាប់ពីអ្នកទទួលដីបានសម្រេចចិត្តទទួលយកព្រំដីហើយ ផ្នែកប្រព័ន្ធព័ត៌មានភូមិសាស្ត្រ / មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្តត្រូវៈ

១.	ចុះលេខព្រំប្រទល់ក្បាលដីដែលបានគូសព្រាងដោយប្រព័ន្ធឌីជីថល
២.	គណនាក្រឡាផ្ទៃសរុបនៃក្បាលដីនីមួយៗ
៣.	កែតម្រូវព្រំប្រទល់ដែលបានចុះក្នុងប្រព័ន្ធឌីជីថលដើម្បីឲ្យមានទំហំដីប៉ុនគ្នា និងមាន គុណភាពល្អ។
៤.	ចុះលេខ និងបែងចែកប្រភេទក្បាលដីនីមួយៗ

## គ ៨.២ ការចាប់ឆ្នោតយកលេខក្បាលដី

*"ការចាប់ឆ្នោត"* ជាប្រព័ន្ធមួយសម្រាប់ឲ្យ ***អ្នកដាក់ពាក្យសុំសម្បទានដីសង្គមកិច្ចដែលមានអាទិភាព (អ្នកទទួលដី) ទម្រង់ទី ២៦ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច*** ចាប់យកក្បាលដីជាក់លាក់មួយកន្លែងដូចបានបង្ហាញនៅលើផែនទីប្រើប្រាស់ដី។ នេះជាដំណើរការមួយដែលជួយសម្រួល និងដឹកនាំដោយអ្នកទទួលដីដោយមានការចូលរួមពីក្រុមប្រឹក្សាឃុំ និងពីអង្គការសង្គមស៊ីវិលដើម្បីធានាឲ្យមានការចូលរួមពេញលេញពីប្រជាពលរដ្ឋ។

អ្នកទទួលដីត្រូវៈ

១.	សុំឲ្យក្រុមប្រឹក្សាឃុំ ក្រុមការងារថ្នាក់ស្រុក និងផ្នែករដ្ឋបាលមូលដ្ឋាន ជួយពួកគាត់បង្កើតប្រព័ន្ធចាប់ឆ្នោត មួយដែលមានសមភាព ដោយត្រូវពិចារណាទៅលើទំហំគ្រួសារគុណភាព និងប្រភេទ ដី។
២.	អញ្ជើញអង្គការសង្គមស៊ីវិលឲ្យជួយ និងត្រួតពិនិត្យដំណើរការចាប់ឆ្នោត។

*ការចាប់ឆ្នោត* ត្រូវធានាថា គ្រួសារទាំងអស់ត្រូវមានស្ថានភាពដូចគ្នា និងទទួលបានដីដែលមានសក្តានុពលប្រហាក់ប្រហែលគ្នា។

ជៀសវាងគ្រួសារមួយទទួលបានដីក្នុងតំបន់ដែលមានដីកសិកម្មល្អ ហើយគ្រួសារផ្សេងទៀតទទួលបានដីមានទំហំដូចគ្នានៅក្នុងតំបន់ដីកសិកម្មដែលមិនសូវមានគុណភាព។

**ដំណោះស្រាយចំពោះបញ្ហានេះអាចជា:**

- ក្បាលដីក្នុងតំបន់ដីមានគុណភាពល្អត្រូវមានទំហំតូចជាងក្បាលដីនៅក្នុងតំបន់ដីមានគុណភាពមិនសូវល្អ ឬ
- គ្រួសារទាំងអស់ទទួលបានដីមានគុណភាពល្អ ១ ប្លង់ និងដីមានគុណភាពមិនសូវ ល្អ ១ ប្លង់។

បន្ទាប់ពីចប់*ការចាប់ឆ្នោត* ក្រុមប្រឹក្សាឃុំត្រូវ:

១. រៀបចំបញ្ជីឈ្មោះអ្នកទទួលដី និងបញ្ជីបែងចែកក្បាលដីដាច់ដោយឡែករបស់ពួកគាត់ (***ទម្រង់ទី ២៩ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចស្តីពីទម្រង់ដាក់បង្ហាញសម្រាប់ការបែងចែកដីក្រោមគម្រោងសម្បទានដីសង្គមកិច្ច)***

២. ដាក់បង្ហាញបញ្ជីឈ្មោះនៅក្នុងទីតាំងសាធារណៈមួយក្នុងភូមិនីមួយៗ។

## គ ៨.៣ ការធ្វើផែនការហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មជនបទ

ផែនការហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មជនបទបង្ហាញពី:

១. ខ្ទង់ចំណាយចាំបាច់ទៅលើការរៀបចំទីតាំងលំនៅឋាន ហេដ្ឋារចនាសម្ព័ន្ធ សេវាកម្មជនបទ និងការឧបត្ថម្ភសម្រាប់ការចូលតាំងទីលំនៅថ្មីនៅក្នុងឆ្នាំទីមួយនៃសម្បទានដីសង្គមកិច្ច

២. ខ្ទង់ចំណាយតាមផែនការចេញពីជំនួយឥតសំណងដែលមានការឯកភាពក្រោមសមាសភាគទី ២ នៅក្នុងឆ្នាំទីពីរ និងឆ្នាំទីបី នៃសម្បទានដីសង្គមកិច្ច និង

៣. តម្រូវការជាអទិភាពនូវហេដ្ឋារចនាសម្ព័ន្ធបន្ថែមដែលការផ្តល់មូលនិធិនៅមិនទាន់កំណត់នៅឡើយ។

ក្រុមប្រឹក្សាឃុំត្រូវរៀបចំកិច្ចប្រជុំមួយជាមួយអ្នកទទួលដីដើម្បីធ្វើការពិនិត្យឡើងវិញនូវការចំណាយដែលចាំបាច់ និងដើម្បីកំណត់អាទិភាពសម្រាប់ការប្រើប្រាស់ជំនួយដែលមានការឯកភាព និងតម្រូវការបន្ថែម។ ក្រុមការងារថ្នាក់ស្រុក និងផ្នែករដ្ឋបាលមូលដ្ឋាន និងផ្នែកគាំទ្របច្ចេកទេសនឹងជួយក្រុមប្រឹក្សាឃុំក្នុងការរៀបចំកិច្ចប្រជុំ។ មន្ទីរកិច្ចការនារីខេត្ត និងអ្នកទទួលបន្ទុកកិច្ចការនារី

និងកុមារឃុំត្រូវចូលរួមនៅក្នុងកិច្ចប្រជុំដើម្បីជួយធ្វើឲ្យប្រាកដថាសេចក្តីត្រូវការផ្សេងៗរបស់ស្ត្រី និងបុរស ត្រូវបានគិតគូ ដោយផ្អែក លើលទ្ធផលនៃការវិភាគយេនឌ័រ។

កិច្ចប្រជុំនឹង:

១. ពិនិត្យឡើងវិញ និងពន្យល់អំពីការចំណាយចាំបាច់ដែលនឹងត្រូវអនុវត្តនៅក្នុងឆ្នាំទីមួយនៃសម្បទានដីសង្គមកិច្ច

២. ពិភាក្សាអំពីសេចក្តីត្រូវការរបស់អ្នកទទួលដីក្នុងការសុំការគាំទ្របន្ថែមនៅក្នុងឆ្នាំក្រោយៗទៀត

៣. ពិនិត្យឡើងវិញនូវសេចក្តីណែនាំសម្រាប់ការប្រើប្រាស់មូលនិធិសមាសភាគទី ២ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច (មានបង្ហាញនៅក្នុងសៀវភៅណែនាំ)

៤. កំណត់អាទិភាពខ្ពស់បំផុតដើម្បីទទួលបានមូលនិធិដោយប្រើប្រាស់មូលនិធិសមាសភាគទី២

៥. ពិនិត្យឡើងវិញនូវអាទិភាពទាំងឡាយនៅក្នុងផែនការអភិវឌ្ឍន៍ឃុំ ដើម្បីពិនិត្យមើលលទ្ធភាពផ្តល់មូលនិធិសម្រាប់សកម្មភាពអាទិភាពទាំងនេះដោយប្រើមូលនិធិសមាសភាគទី២។

៦. កត់ត្រាពីការវិភាជន៍ចំណាយនៅក្នុង *ទម្រង់ទទួលបានធនធានសំខាន់ៗផ្សេងទៀតសម្រាប់ផែនការហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មជនបទ – ទម្រង់ទី ៣១ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច*។

៧. កត់ត្រាការចំណាយចាំបាច់ សម្រាប់ឆ្នាំ នីមួយៗ ហើយបញ្ចូលក្នុង *ទម្រង់ទទួលបានធនធានសំខាន់ៗផ្សេងទៀត និងការចំណាយ សម្រាប់ផែនការហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មជនបទ – ទម្រង់ទី ៣១ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច*។

ជាធម្មតា ដំណាក់កាលរៀបចំផែនការសម្បទានដីសង្គមកិច្ចចំណាយពេលប្រមាណមួយឆ្នាំទើបចប់។ ដូច្នេះ ការរៀបចំផែនការហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មជនបទនឹងត្រូវធ្វើនៅក្នុងត្រីមាសចុងក្រោយនៃឆ្នាំទីមួយ។ ការធ្វើបែបនេះជួយឲ្យមានពេលសម្រាប់ដាក់សកម្មភាពជាច្រើននៅក្នុងផែនការហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មជនបទបញ្ចូលទៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំសម្រាប់ឆ្នាំទីពីរ (ឆ្នាំទី២) ។ ឧទាហរណ៍នៃតារាងពេលវេលាសម្រាប់ការរៀបចំផែនការហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មជនបទត្រូវបានផ្តល់ជូនខាងក្រោម។

| តារាងពេលវេលាបង្ហាញអំពីការរៀបចំផែនការហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មជនបទ | | | | | | | | |
|---|---|---|---|---|---|---|---|---|
| សកម្មភាព | ឆ្នាំទី ១ ត្រីមាសទី ៤ | ឆ្នាំទី ២ ត្រីមាសទី១ | ឆ្នាំទី ២ ត្រីមាសទី ២ | ឆ្នាំទី ២ ត្រីមាសទី ៣ | ឆ្នាំទី ២ ត្រីមាសទី ៤ | ឆ្នាំទី ៣ | ឆ្នាំទី ៤ | ឆ្នាំទី ៥ |
| ការរៀបចំផែនការហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មជនបទ | | | | | | | | |
| ការឯកភាពលើផែនការសម្បទានដីសង្គមកិច្ចច្បាស់លាស់ | | | | | | | | |
| ការរៀបចំផែនសកម្មភាព និងថវិកាប្រចាំឆ្នាំ | | | | | | | | |
| ឃុំ ស្រុក ចុះហត្ថលេខាលើអនុកិច្ចសន្យា | | | | | | | | |
| ការអនុវត្តផែនការសម្បទានដីសង្គមកិច្ចច្បាស់លាស់ | | | | | | | | |

## គ ៨.៤ ចងក្រង និងអនុម័តគម្រោងសម្បទានដីសង្គមកិច្ចច្បាស់លាស់

ក្រុមប្រឹក្សាឃុំត្រូវចងក្រងផែនការសម្បទានដីសង្គមកិច្ចច្បាស់លាស់ ហើយផ្ញើជូនគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត។

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តទទួលខុសត្រូវពិនិត្យឡើងវិញ និងផ្តល់សិទ្ធិលើផែនការសម្បទានដីសង្គមកិច្ចច្បាស់លាស់ មុនពេលដីត្រូវបានបែងចែកជាផ្លូវការទៅឲ្យអ្នកទទួលដី និងមុនពេលផ្ទេរគម្រោងថវិកាសម្រាប់ការអនុវត្តទៅឲ្យឃុំ។ ដើម្បីជួយគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តក្នុងការពិនិត្យឡើងវិញនូវរាល់ឯកសារសំខាន់ៗដើម្បីឲ្យមានភាពត្រឹមត្រូវ និងមានតម្លាភាព គោលការណ៍ណែនាំសម្រាប់ដំណើរការពិនិត្យឡើងវិញរបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តមានផ្តល់ជូននៅក្នុង *ទម្រង់ ៣០ នៃគម្រោងការបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចស្តីពីបញ្ជីត្រួតពិនិត្យសម្រាប់ការពិនិត្យឡើងវិញរបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តទៅលើផែនការសម្បទានដីសង្គមកិច្ចច្បាស់លាស់។*

## ជំហានទី ៩: ការរៀបចំក្បាលដី និងទីតាំងលំនៅឋានសម្បទានដីសង្គមកិច្ច

**លទ្ធផល:**

- បានកំណត់ផែនទីព្រំក្បាលដីសម្បទានសង្គមកិច្ច
- បានសម្អាតដី
- បានសាងសង់ផ្លូវចូល
- បានផ្តល់ការផ្គត់ផ្គង់ទឹកនៅជនបទ
- បានផ្តល់ការឧបត្ថម្ភសម្រាប់ការចូលតាំងទីលំនៅថ្មី
- ផ្តល់ដីជូនជាផ្លូវការ។

### គ ៩.១ ការរៀបចំទីតាំង

សកម្មភាពរៀបចំទីតាំង គឺជាការចំណាយដ៏ចំបាច់ក្រោមសមាសភាគទី ២ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។ សកម្មភាពរៀបចំទីតាំងត្រូវបញ្ចប់មុនពេលប្រគល់ដីជាផ្លូវការ។ សកម្មភាពកាន់តែលម្អិតស្តីពីការរៀបចំទីតាំងមានបរិយាយនៅក្នុងផ្នែក **ឃ** នៃសៀវភៅណែនាំនេះ។

១. ការសម្អាតដី
២. ការកំណត់ព្រំប្រទល់
៣. សង់ផ្លូវប្រើប្រាស់បានគ្រប់រដូវកាល
៤. ផ្លូវចូល
៥. ការផ្គត់ផ្គង់ទឹកនៅជនបទ និង
៦. ការវាយតម្លៃពីសេចក្តីត្រូវការផ្នែកកសិកម្ម។

ភាគច្រើននៃសកម្មភាពទាំងនេះនឹងត្រូវអនុវត្តដោយអ្នកទទួលការងារឯកជនដោយគោរពតាមនីតិវិធីដូចគ្នានឹងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ។ សកម្មភាពមួយចំនួននឹងត្រូវអនុវត្តផ្ទាល់ដោយមន្ទីរជំនាញ។គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្តមានតួនាទីជួយក្រុមប្រឹក្សាឃុំក្នុងដំណើរការលទ្ធកម្ម និងអនុវត្តសកម្មភាពទាំងនេះ។

ការកំណត់ពេលវេលាអនុវត្ត គឺ:

១. បន្ទាប់ពីអនុម័តលើរបាយការណ៍សម្បទានដីសង្គមកិច្ច (ជំហានទី ៦) : ការរៀបចំប្លង់ ការប៉ាន់ស្មានតម្លៃ និងឯកសារដេញថ្លៃ
២. បន្ទាប់ពីការអនុម័តលើគម្រោងសម្បទានដីសង្គមកិច្ចច្បាស់លាស់ (ជំហានទី ៨) :
   ក . បន្តដំណើរការផ្សព្វផ្សាយអំពីការដេញថ្លៃ និង

ខ. បន្តសកម្មភាពដែលត្រូវអនុវត្តដោយនាយកដ្ឋានបច្ចេកទេស (ឧ.ការវាយតម្លៃពីសេចក្តីត្រូវការផ្នែកកសិកម្ម) និង

គ. អនុវត្តសកម្មភាពនានា

## គ ៩.២ ការរៀបចំជំនួយឧបត្ថម្ភគាំទ្រសម្រាប់ការចូលតាំងទីលំនៅថ្មី

ក្រុមប្រឹក្សាឃុំត្រូវត្រៀមខ្លួនជាស្រេចដើម្បីចាប់ផ្តើមអនុវត្តការផ្តល់ជំនួយឧបត្ថម្ភសម្រាប់ការចូលតាំងទីលំថ្មីឲ្យបានលឿនបន្ទាប់ពីការប្រគល់ដីជាផ្លូវការ។ ដូច្នេះការរៀបចំ និងដំណើរការលទ្ធកម្មធ្វើឡើងនៅក្នុងជំហានទី ៩។ គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្តត្រូវជួយក្រុមប្រឹក្សាឃុំក្នុងការងារៈ

១. ផ្តល់លទ្ធកម្មគាំទ្រដល់ជីវភាពរស់នៅ និង

២. ចាប់ផ្តើមលទ្ធកម្មជាកញ្ចប់

## គ ៩.៣ មុននឹងប្រគល់ដីដល់អ្នកទទួលដី

ការប្រើប្រាស់ដីមុនពេលប្រគល់មានន័យថា អ្នកទទួលដីត្រូវបានអនុញ្ញាតឲ្យចាប់ផ្តើមការងារនៅលើក្បាលដីរបស់ពួកគាត់មុនពេលផ្ទេរដីជូនពួកគាត់ជាផ្លូវការ។ ប៉ុន្តែ ពួកគាត់មិនត្រូវផ្លាស់ទៅរស់នៅលើដីនេះឡើយ។

ការប្រើប្រាស់ដីមុនពេលប្រគល់អាចចាប់ផ្តើមបានបន្ទាប់ពីបានកំណត់ព្រំដីច្បាស់លាស់ (ដោយប្រើបង្គោលព្រំដីអចិន្ត្រៃយ៍ ឬ បណ្តោះអាសន្ន)។

ការឧបត្ថម្ភសម្រាប់ការចូលតាំងទីលំនៅថ្មី និងការឧបត្ថម្ភដល់ជីវភាពរស់នៅមិនទាន់អាចចាប់ផ្តើមបាននៅឡើយទេ លុះត្រាតែប្រគល់ដីជាផ្លូវការចប់សព្វគ្រប់។

ក្រុមប្រឹក្សាឃុំត្រូវៈ

១. ប្រកាសដល់អ្នកទទួលដីទាំងអស់ថា ពួកគាត់អាចស្នើសុំការអនុញ្ញាតចូលប្រើប្រាស់ដីរបស់ពួកគាត់បាននៅមុនពេលប្រគល់ជាផ្លូវការ។ ក្រុមប្រឹក្សាឃុំត្រូវសុំឲ្យអង្គការសង្គមស៊ីវិលចូលរួមក្នុងការផ្សព្វផ្សាយព័ត៌មាននេះ។

២. *ជួយអ្នកទទួលដីក្នុងការបំពេញ* ***ទម្រង់ទី ៣៨ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចស្តីពីពាក្យស្នើសុំសិទ្ធិប្រើប្រាស់ដីមុនពេលប្រគល់។***

៣. បន្ទាប់ពីទទួលបានសំណើហើយ អ្នកតំណាងមួយរូបមកពីក្រុមប្រឹក្សាឃុំ និងអ្នកតំណាងមួយរូបទៀតមកពីអង្គការសង្គមស៊ីវិលត្រូវចុះទៅដល់ទីតាំងដីជាមួយនឹងអ្នកទទួលដី ដើម្បីពិនិត្យ និងបញ្ជាក់ពីការកំណត់ព្រំដីដែលបានចែកឲ្យ។

៤. ផ្តល់សិទ្ធិប្រើប្រាស់ដីមុនពេលប្រគល់ដល់អ្នកទទួលដី។ បំពេញ ***ទម្រង់ទី ៣៨ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចស្តីពីការប្រគល់សិទ្ធិប្រើប្រាស់ដីមុនពេលប្រគល់*** ។

## គ ៩.៤ ការប្រគល់ដីជាផ្លូវការដល់អ្នកទទួលដី

នៅពេលចប់សកម្មភាពរៀបចំទីតាំង ការប្រគល់ដីជាផ្លូវការដល់អ្នកទទួលដីអាចចាប់ផ្តើមបាន។

ក្រុមប្រឹក្សាឃុំត្រូវរៀបចំកិច្ចប្រជុំជាមួយអ្នកទទួលដីទាំងអស់ និងអញ្ជើញអង្គការសង្គមស៊ីវិលឲ្យចូលរួម។ សកម្មទាំងឡាយនៅក្នុងការប្រជុំនេះមានដូចជា:

១. ធ្វើបទបង្ហាញស្តីពីផែនការសម្បទានដីសង្គមកិច្ចច្បាស់លាស់ រួមមាន:
   - ក. ផែនការប្រើប្រាស់ដី
   - ខ. សកម្មភាពរៀបចំទីតាំងដី (សកម្មភាពទាំងនេះត្រូវបញ្ចប់ឲ្យបានរួចរាល់)
   - គ. ការឧបត្ថម្ភសម្រាប់ការចូលតាំងទីលំនៅថ្មី (ជំនួយទាំងនេះត្រូវចាប់ផ្តើមភ្លាមៗ)
   - ឃ. សកម្មភាពអភិវឌ្ឍន៍ជនបទ (រៀបចំសកម្មភាពទាំងនេះជាចម្បងសម្រាប់ឆ្នាំខាងមុខ)

២. ធ្វើការបង្ហាញពីការទទួលខុសត្រូវរបស់អ្នកទទួលដី *(ទម្រង់ទី ១១ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច)*

៣. ធ្វើការបង្ហាញពីតួនាទីរបស់អង្គការសង្គមស៊ីវិលក្នុងការជួយដល់ការអនុវត្តសម្បទានដីសង្គមកិច្ច

៤. ធ្វើការបង្ហាញពីប្រភេទជំនួយដែលអ្នកទទួលដីអាចទទួលបាន និងកន្លែងដែលអាចទៅសុំជំនួយបាន។

៥. ចុះហត្ថលេខាលើឯកសារប្រគល់ដី *(ទម្រង់ទី ៣៦ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច)*។ សូមប្រយ័ត្នក្នុងការចម្លងឯកសារឲ្យក្រុមប្រឹក្សាឃុំ ក្រុមការងារថ្នាក់ស្រុក និងគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត។

៦. ការប្រគល់ឯកសារប្រគល់ដីជូនអ្នកទទួលដី។

## ជំហានទី ១០ :ជំនួយឧបត្ថម្ភសម្រាប់ការចូលតាំងទីលំនៅថ្មី និងការអភិវឌ្ឍជនបទរយៈពេលវែង

**លទ្ធផល:**

- ជំនួយឧបត្ថម្ភសម្រាប់ការចូលតាំងទីលំនៅថ្មីត្រូវផ្តល់ជូន (៦ខែ ទៅ ១ឆ្នាំ)
- ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មជនបទត្រូវផ្តល់ជូន (២ ឆ្នាំ)
- អ្នកទទួលដីរស់នៅនិងធ្វើស្រែចំការនៅលើដីរបស់ពួកគាត់ក្នុងភាពជាសហគមន៍មួយ ដែលមានចីរភាព។ ៥ ឆ្នាំក្រោយពួកគាត់អាចដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិកាន់កាប់ដីបាន។

### គ ១០.១ ជំនួយឧបត្ថម្ភសម្រាប់ការចូលតាំងទីលំនៅថ្មី

ជំនួយឧបត្ថម្ភសម្រាប់ការចូលតាំងទីលំនៅថ្មីនឹងចាប់ផ្តើមយ៉ាងឆាប់រហ័សបន្ទាប់ពីប្រគល់ដីជាផ្លូវការត្រូវបានបញ្ចប់។ ជំនួយឧបត្ថម្ភសម្រាប់ការចូលតាំងទីលំនៅថ្មីចែកចេញជាពីរប្រភេទ:

- ជំនួយគាំទ្រផ្នែកជីវភាពរស់នៅ និង
- កញ្ចប់ធនធានសម្រាប់គ្រួសារ និងផ្នែកកសិកម្ម (កញ្ចប់ចាប់ផ្តើមប្រតិបត្តិការ)

សកម្មភាពចាំបាច់ពីរផ្សេងទៀតត្រូវបានអនុវត្តនៅក្នុងដំណាក់កាលនេះគឺ :

- សេវាគាំទ្រផ្នែកកសិកម្ម និង
- យុទ្ធនាការស្តីពីការប្រើប្រាស់ទឹកស្អាត និងការអប់រំផ្នែកអនាម័យ

គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្តត្រូវជួយក្រុមប្រឹក្សាឃុំក្នុងការផ្តល់ជូន និងការអនុវត្តសកម្មភាពផ្តល់ជំនួយឧបត្ថម្ភសម្រាប់ការចូលតាំងទីលំនៅថ្មី។

ក្រុមប្រឹក្សាឃុំត្រូវធានាថា អ្នកទទួលដីបានយល់ច្បាស់អំពីសកម្មភាពជំនួយឧបត្ថម្ភសម្រាប់ការចូលតាំងទីលំនៅថ្មី។ ក្រុមប្រឹក្សាឃុំត្រូវកោះប្រជុំជាមួយអ្នកទទួលដីទាំងអស់ដើម្បី:

១. ពន្យល់ថាតើជំនួយឧបត្ថម្ភសម្រាប់ការចូលតាំងទីលំនៅថ្មីជាអ្វី និងអ្នកទទួលដីនឹងទទួលជំនួយនេះដោយរបៀបណា។

២. ពិនិត្យតាមដានដំណើរការផ្តល់ជំនួយឧបត្ថម្ភសម្រាប់ការចូលតាំងទីលំនៅថ្មីដោយប្រើ ***(ទម្រង់ទី ៣៧ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច)***។ សូមចំណាំថា ក្រុមប្រឹក្សាឃុំ និងអ្នកទទួលដីត្រូវទុកច្បាប់ចម្លងមួយច្បាប់នៃទម្រង់នេះសម្រាប់ខ្លួនឯង។ ច្បាប់ចម្លងដែលធ្វើឡើងដោយក្រុមប្រឹក្សាឃុំត្រូវមានចុះហត្ថលេខាពីអ្នកទទួលដី ហើយច្បាប់ចម្លងដែលរក្សាទុកដោយអ្នកទទួលដីត្រូវមានហត្ថលេខារបស់ក្រុមប្រឹក្សាឃុំ។

ក្រុមប្រឹក្សាឃុំត្រូវធ្វើការយ៉ាងជិតស្និទ្ធជាមួយនាយកដ្ឋានបច្ចេកទេស អង្គការសង្គមស៊ីវិល និងអ្នកទទួលដីដើម្បីអនុវត្តសេវាកម្មគាំទ្រផ្នែកកសិកម្ម និងយុទ្ធនាការស្តីពីការប្រើប្រាស់ដី និងការអប់រំផ្នែកអនាម័យ។

## គ ១០.២ ការអភិវឌ្ឍជនបទរយៈពេលវែង

សកម្មភាពអភិវឌ្ឍន៍ជនបទរយៈពេលវែង គឺហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មដែលរៀបចំផែនការក្រោមផែនការផ្តល់ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មជនបទ។ ភាគច្រើននៃសកម្មភាពត្រូវអនុវត្តក្នុងឆ្នាំទី ២ និងឆ្នាំទី ៣ នៃផែនការសម្បទានដីសង្គមកិច្ច បន្ទាប់ពីបញ្ចប់ដំណាក់កាលចូលតាំងទីលំនៅ។

ការអភិវឌ្ឍជនបទរយៈពេលយូរអង្វែងអាចរួមបញ្ចូលទាំងៈ

- សកម្មភាពដែលផ្តល់មូលនិធិដោយសមាសភាគទី ២ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច និង
- សកម្មភាពដែលគាំទ្រដោយប្រភពមូលនិធិផ្សេងទៀត

សកម្មភាពដែលអាចគាំទ្រដោយសមាសភាគទី ២ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចមានបរិយាយនៅក្នុងផ្នែក **គ** នៃសៀវភៅណែនាំនេះ។

គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត ត្រូវជួយក្រុមប្រឹក្សាឃុំរៀបចំ និងអនុវត្តសកម្មភាពទាំងនេះ។

ការរៀបចំគម្រោង និងដំណើរការអនុវត្តមាននៅក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់។

## ឃ. សមាសភាគទី ២ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចៈ ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មជនបទ

### *ឃ ១ បរិយាយទូទៅអំពីសមាសភាគទី ២ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច*

### ឃ ១.១ តើសមាសភាគទី ២ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចជាអ្វី?

សមាសភាគទី ២ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺការវិភាជន៍ថវិកាទៅឲ្យក្រុមប្រឹក្សាឃុំដើម្បីអនុវត្តគម្រោងបន្ត ក្រោមផែនការហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មជនបទ។ គម្រោងបន្តទាំងនេះធ្វើឡើងក្នុងគោលបំណងរៀបចំដីសម្បទានដីសង្គមកិច្ច ដើម្បីឲ្យអ្នកទទួលដីសម្បទានសង្គមកិច្ចអាចផ្លាស់មករស់នៅបាន ហើយជួយពួកគាត់ផ្លាស់ទីលំនៅ និងចាប់ផ្តើមធ្វើកសិកម្ម និងដើម្បីទ្រទ្រង់ដល់ការអភិវឌ្ឍសម្បទានដីសង្គមកិច្ច និងឃុំ។

ដំណើរការសម្រាប់ការរៀបចំផែនការ និងការអនុវត្តសកម្មភាពហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មជនបទ គឺមានរៀបរាប់នៅក្នុងសមាសភាគទី ១ នៃសៀវភៅណែនាំនេះ។ ផ្នែកនេះបង្ហាញពីគោលការណ៍ណែនាំមួយចំនួនសម្រាប់ការចំណាយទៅលើហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មជនបទដែលសមស្រប។

សមាសភាគទី ២ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ផ្តល់ជាមូលនិធិសម្រាប់*ការចំណាយចាំបាច់ និងការសម្រេចផ្តល់ជំនួយបន្ត។*

### ឃ ១.២ ការចំណាយចាំបាច់

ការចំណាយចាំបាច់ គឺជាការចំណាយដែលត្រូវការសម្រាប់រៀបចំទីតាំងដីដើម្បីឲ្យអ្នកទទួលដីផ្លាស់មករស់នៅ ដោយផ្តល់ហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋានក្នុងកម្រិតមួយអាចទទួលយកបាន និងឧបត្ថម្ភអ្នកទទួលដីក្នុងការផ្លាស់មករស់នៅលើដីរបស់ពួកគាត់។ ការចំណាយចាំបាច់ត្រូវបានរៀបចំនៅក្នុងរបាយការណ៍សម្បទានដីសង្គមកិច្ច ហើយការធ្វើលទ្ធកម្មចាប់ផ្តើមភ្លាមបន្ទាប់ពីផែនការសម្បទានដីសង្គមកិច្ចត្រូវបានអនុម័ត។ ការចំណាយដែលចាំបាច់ភាគច្រើនគឺអនុវត្តនៅក្នុងឆ្នាំទី ២ នៃសម្បទានដីសង្គមកិច្ច។

### ឃ ១.៣ ការសម្រេចផ្តល់ជំនួយបន្ត

ការសម្រេចផ្តល់ជំនួយបន្តត្រូវបានវិភាជន៍ទៅឲ្យក្រុមប្រឹក្សាឃុំដើម្បីជាការគាំទ្រសកម្មភាពដែលផ្តល់អាទិភាពដោយអ្នកទទួលដី និងក្រុមប្រឹក្សាឃុំសម្រាប់ការអភិវឌ្ឍបន្ថែមនៅតំបន់សម្បទានដីសង្គមកិច្ច។ សកម្មភាពការសម្រេចផ្តល់ជំនួយបន្តអាចគាំទ្រទាំងហេដ្ឋារចនាសម្ព័ន្ធ ឬ ទាំង

សេវាកម្ម ក្រោមផែនការហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មជនបទ។ សកម្មភាពការសម្រេចផ្ដល់ជំនួយបន្តត្រូវបានរៀបចំឡើងក្រោមផែនការសម្បទានដីសង្គមកិច្ចច្បាស់លាស់ ហើយជាធម្មតាត្រូវអនុវត្តនៅក្នុងឆ្នាំទី ២ និងឆ្នាំទី ៣ នៃសម្បទានដីសង្គមកិច្ច[៥]។

## ឃ ១.៤ រូបមន្តវិភាជន៍ថវិកា

ការវិភាជន៍ថវិកាក្នុងសមាសភាគទី ២ (ចំនួនទឹកប្រាក់ដែលវិភាជន៍ទៅឲ្យក្រុមប្រឹក្សាឃុំ ដើម្បីគាំទ្រផែនការហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មជនបទ) ត្រូវបានកំណត់ដោយរូបមន្តមួយដែលមានបង្ហាញនៅក្នុង *ទម្រង់ទី ២០ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច* ។ រូបមន្តនេះផ្អែកជាសំខាន់លើ:

- តម្លៃប៉ាន់ស្មាននៃកាចំណាយចាំបាច់ **បូកនឹង**
- ចំនួនថវិការសម្រេចផ្ដល់ជំនួយបន្ត។

ចំនួនថវិការសម្រេចផ្ដល់ជំនួយបន្តនោះ:

- ចំនួនទឹកប្រាក់ផ្អែកលើចំនួនអ្នកទទួលដីដែលទទួលបានដីកសិកម្ម បូកនឹង
- ចំនួនទឹកប្រាក់ផ្អែកលើចំនួនអ្នកទទួលដីដែលទទួលបានដីលំនៅឋាន។

រូបមន្តសម្រាប់ចំនួនថវិកាសម្រេចផ្ដល់ជំនួយបន្តគ្រាន់តែជាវិធីមួយនៃការគណនាចំនួនទឹកប្រាក់ដែលក្រុមប្រឹក្សាឃុំនឹងទទួលប៉ុណ្ណោះ។ ចំនួនថវិកាសម្រេចផ្ដល់ជំនួយបន្តប្រើសម្រាប់ការចំណាយដែលសមស្របនៅក្នុងផែនការហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មជនបទ។ ជាការសំខាន់ត្រូវយល់ថា រូបមន្តនេះមិនមែនមានន័យថា ទឹកប្រាក់មួយចំនួនត្រូវបែងចែកដើម្បីឧបត្ថម្ភផ្នែកដីធ្វើកសិកម្ម ហើយទឹកប្រាក់មួយចំនួនទៀតឧបត្ថម្ភផ្នែកដីលំនៅឋាននោះទេ។

ការចំណាយថវិកាសម្រេចផ្ដល់ជំនួយបន្តត្រូវបានវិភាជន៍ទៅឲ្យក្រុមប្រឹក្សាឃុំក្នុងរយៈពេល ២ឆ្នាំ: គឺ ៦០% នៅក្នុងឆ្នាំទី ២ នៃសម្បទានដីសង្គមកិច្ច និង ៤០% ទៀតនៅក្នុងឆ្នាំទី ៣ នៃសម្បទានដីសង្គមកិច្ច។

## ឃ ១.៥ វិធីសាស្ត្រការអនុវត្ត

សកម្មភាពសមាសភាគទី ២ អាចបញ្ចូលទាំង:

- អនុគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលអនុវត្តដោយអ្នកទទួលការឯកជន
- លទ្ធកម្មទំនិញពីក្រុមហ៊ុនផ្គត់ផ្គង់វិស័យឯកជន
- អនុគម្រោងសេវាកម្មដែលអនុវត្តដោយក្រុមហ៊ុនផ្ដល់សេវាកម្មវិស័យឯកជន និង

---

[៥] ឧទាហរណ៍: ប្រសិនបើផែនការច្បាស់លាស់ត្រូវបានអនុម័តនៅខែកក្កដា ឆ្នាំ ២០១០ ថវិកាសម្រេចផ្ដល់ជំនួយបន្តនឹងត្រូវដាក់បញ្ចូលទៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចសម្រាប់ឆ្នាំ ២០១១ និងឆ្នាំ ២០១២។

- អនុគម្រោងសេវាកម្មដែលអនុវត្តដោយមន្ទីរជំនាញនានា។

អនុគម្រោងដែលអនុវត្តដោយវិស័យឯកជន គឺធ្វើទៅតាមគោលការណ៍ណែនាំនៅក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ លើកលើកលែងតែគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) និងគណៈកម្មាធិការប្រតិបត្តិទទួលខុសត្រូវផ្នែកលទ្ធកម្ម ប្រសិនបើតម្លៃប៉ាន់ស្មានខ្ពស់ជាងកម្រិតអតិបរមាសម្រាប់ធ្វើលទ្ធកម្មដោយក្រុមប្រឹក្សាឃុំ។ កម្រិតកំណត់សម្រាប់ការធ្វើលទ្ធកម្មដោយក្រុមប្រឹក្សាឃុំគឺៈ

- **អតិបរមា** ៤០ ០០០ ដុល្លារអាមេរិកសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ និង
- **អតិបរមា** ២០ ០០០ ដុល្លារអាមេរិកសម្រាប់ការធ្វើលទ្ធកម្មទំនិញ។

ព័ត៌មានបន្ថែមទាក់ទងនីតិវិធីនៃការធ្វើលទ្ធកម្ម និងការអនុវត្ត មានផ្តល់ជូននៅក្នុងសមាសភាគទី៤។

ទោះបីជាប្រើវិធីសាស្ត្រអនុវត្តអ្វីក៏ដោយ ក៏ក្រុមប្រឹក្សាឃុំនៅតែជាម្ចាស់គម្រោងជានិច្ច។ ក្រុមប្រឹក្សាឃុំត្រូវធ្វើការយ៉ាងជិតស្និទ្ធជាមួយអ្នកទទួលដីដើម្បីរៀបចំផែនការ និងអនុវត្តអនុគម្រោង។

## ឃ ២ ការរៀបចំទីតាំងដី

សកម្មភាពរៀបចំទីតាំងដី ត្រូវការការចំណាយដ៏ចាំបាច់។ តំបន់ធំៗដែលការរៀបចំទីតាំងដីមានសារៈសំខាន់ គឺបណ្តាញផ្លូវថ្នល់ប្រើប្រាស់បានគ្រប់រដូវកាល និងផ្លូវចូលដើម្បីឲ្យអ្នកទទួលដី និងប្រជាពលរដ្ឋក្នុងភូមិជុំវិញអាចប្រើប្រាស់តំបន់សម្បទានដីសង្គមកិច្ច ទីផ្សារ និងសេវាកម្មផ្សេងៗដោយសេរី និងការជីកអណ្តូងទឹកដើម្បីយកទឹកស្អាតប្រើប្រាស់។

### ឃ ២.១ ផ្លូវប្រើប្រាស់បានគ្រប់រដូវកាល

ផ្លូវប្រើប្រាស់បានគ្រប់រដូវកាលមានន័យថា ជាផ្លូវថ្នល់ដែលយានយន្តកង់បួន (រថយន្តតូច ឬរថយន្តដឹកទំនិញធុនស្រាលអាចចរាចរបានយ៉ាងតិច ៣៣៥ ថ្ងៃក្នុងមួយឆ្នាំ។ ជាធម្មតា ផ្លូវប្រើប្រាស់គ្រប់រដូវកាលមានទទឹងយ៉ាងតិច ៤ ម៉ែត្រ (សំដៅលើទទឹងផ្ទៃផ្លូវពិតប្រាកដ មិនមែនគិតទាំងចិញ្ចើមផ្លូវ ជម្រេលជើងទេរ ប្រឡាយទឹកតាមបណ្តោយផ្លូវ។ល។ នោះទេ)។ ផ្លូវប្រើប្រាស់គ្រប់រដូវកាលត្រូវមានគ្រប់គ្រាន់នូវស្ពាន លូ ឬ ប្រភេទផ្សេងទៀតនៃសំណង់ឆ្លងកាត់ផ្លូវទឹកដើម្បីឲ្យយានយន្តអាចឆ្លងកាត់ស្ទឹង ឬ អូរ និងសំណង់ជួយបណ្តោះទឹកជំនន់ដែលហូរកាត់តាមដងផ្លូវ។ នៅកន្លែងដែលសមស្រប ផ្លូវប្រើប្រាស់បានគ្រប់រដូវកាលគួរមានផ្ទៃក្រាលថ្មបាយក្រៀម ឬ ក្រួសល្អិត។ ទោះបីជាយ៉ាងណា ផ្លូវក្រាលថ្មបាយក្រៀម ឬ ក្រួសល្អិតមានតម្លៃថ្លៃក្នុងការថែទាំជួសជុល ហើយករណីខ្លះ ប្រភេទផ្លូវផ្សេងទៀត (ផ្លូវដីស និងផ្លូវក្រាលថ្ម) អាចមានលក្ខណៈសមស្របជាង។

នៅក្នុងតំបន់សម្បទានដីសង្គមកិច្ចមួយចំនួន មានផ្លូវប្រើប្រាស់គ្រប់រដូវកាលស្រាប់ដែលអាចប្រើប្រាស់បានយ៉ាងហោចណាស់ក្នុងកម្រិតមួយដែលអាចទទួលយកបានជាអប្បបរមា។

នៅក្នុងតំបន់សម្បទានដីសង្គមកិច្ចផ្សេងទៀត វាចាំបាច់ត្រូវធ្វើការជួសជុល ឬ ធ្វើឲ្យប្រសើរឡើងនូវផ្លូវដែលមានស្រាប់ ឬ ចាំបាច់ត្រូវសាងសង់ផ្លូវថ្មីមួយ។

### ឃ ២.២ ផ្លូវចូល

កម្រិតចាំបាច់នៃការផ្តល់ជូននូវផ្លូវចូលគឺ:

- ក្បាលដីលំនៅឋានទាំងអស់ត្រូវចូលបានដោយផ្ទាល់ពីផ្លូវចូល និង
- ក្បាលដីធ្វើកសិកម្មទាំងអស់ត្រូវស្ថិតក្នុងចម្ងាយ ៥០០ម៉ែត្រពីផ្លូវចូល។

ផ្លូវចូលមានន័យថា ជាផ្លូវដីដែលយានយន្ត (រថយន្តតូច ឬ រថយន្តដឹកទំនិញធុនស្រាល) អាចចរាចរបានក្នុងរដូវរាំងស្ងួត។ ជាធម្មតា ផ្លូវចូលត្រូវមានទទឹង ៩ម៉ែត្រ (សំដៅលើទទឹងផ្ទៃផ្លូវពិតប្រាកដ មិនមែនគិតទាំងចិញ្ចើមផ្លូវ ជម្រេលជើងទេរ ប្រឡាយទឹកតាមបណ្តោយផ្លូវ។ល។នោះទេ)។ ផ្លូវចូលលើដីរាបស្មើត្រូវលើកតួផ្លូវឲ្យខ្ពស់ជាងដីកំណើតយ៉ាងតិច 0,៥ ម៉ែត្រ។ ផ្លូវចូលតាមដីជម្រេល ត្រូវសង់ផ្លូវដោយមានកាយប្រឡាយបង្ហូរទឹកតាមបណ្តោយជាយម្ខាងនៃផ្លូវ ហើយប្រើដីសម្រាប់សង់ផ្លូវ។

### ឃ ២.៣ ការរៀបចំដី

កម្រិតចាំបាច់នៃការផ្តល់ជូនការរៀបចំដី គឺដើម្បីធានាបានថា អ្នកទទួលដីពិតជាអាចផ្លាស់មករស់នៅលើដី និងអាចដាំដំណាំបានគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់គ្រួសារនៅក្នុងឆ្នាំទី ១។ គេប្រហែលជាមិនអាចសម្អាតដីក្នុងតំបន់ដែលមានដីធ្វើកសិកម្មទាំងមូលបាននោះទេ។

ជាធម្មតា ដីដែលបានបែងចែកសម្រាប់សម្បទានដីសង្គមកិច្ចមានដើមឈើ គល់ឈើ ហើយជួនកាលមានថ្មាំងថ្មធំៗដែលត្រូវយកចេញដើម្បីឲ្យអ្នកទទួលដីអនុវត្តសកម្មភាពធ្វើស្រែចំការបានសមស្រប។ ក្នុងករណីមួយចំនួន ដីមិនមានផ្ទៃរាបស្មើល្អឡើយ ហើយត្រូវពង្រាបឲ្យស្មើដើម្បីផ្តល់លទ្ធភាពសម្រាប់ធ្វើកសិកម្ម។ ការចំណាយលើការកាប់ឆ្ការដើមឈើ ការគាស់គល់ឈើ និងឧបសគ្គផ្សេងទៀត និងការចំណាយលើការពង្រាបដីឡើងវិញជាការចំណាយចេញពីមូលនិធិនៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច (សូមមើល***បទដ្ឋានបច្ចេកទេសស្តីពីការរៀបចំដីនៅក្នុងឧបសម្ព័ន្ធទី ៣***) ។ ពេលសម្អាតដីចប់រួចរាល់ អ្នកទទួលដីអាចរៀបចំដីជាចុងក្រោយដោយកាប់ឆ្ការគម្ពោតព្រៃ និងរុក្ខជាតិផ្សេងទៀតដែលនៅសេសសល់ ដោយការលើកជាភ្លឺ ហើយចាប់ផ្តើមដាំដំណាំ។

### ឃ ២.៤ ការកំណត់ព្រំក្បាលដី

ការកំណត់ព្រំក្បាលដី គឺជាការចំណាយមួយចាំបាច់។ ជាការចាំបាច់ណាស់ដែលត្រូវកំណត់ព្រំក្បាលដីទាំងអស់ដោយបោះបង្គោលព្រំអចិន្ត្រៃយ៍យ៉ាងត្រឹមត្រូវ។ ជាទូទៅ បង្គោលព្រំដីមានបោះបង្គោលថ្មនៅតាមកែងនៃព្រំក្បាលដី។ ព្រំក្បាលដី គឺជាខ្សែបន្ទាត់ត្រង់មួយស្ថិតចំពាក់កណ្តាលបង្គោលព្រំដី។

### ឃ ២.៥ ការផ្គត់ផ្គង់ទឹកនៅជនបទ

កម្រិតនៃការផ្តល់ការផ្គត់ផ្គង់ទឹកនៅជនបទដែលចាំបាច់ គឺដើម្បីធានាថា គ្រប់ដីលំនៅឋានទាំងអស់មានចម្ងាយមិនលើសពី ១៥០ម៉ែត្រពីប្រភពទឹកដែលបានកែលម្អហើយ។ ជាធម្មតា ផ្តល់ជូនប្រភពទឹកស្អាតមួយសម្រាប់ផ្គត់ផ្គង់លើដីលំនៅឋានចំនួន ២0 ប្លង់។

ប្រភពទឹកត្រូវមានទីតាំងនៅលើដីសាធារណៈ មិនមែននៅលើដីឯកជន ឬ ក្នុងក្បាលដីសម្បទានសង្គមកិច្ចណាមួយឡើយ។

ប្រភពទឹកដែលបានកែលម្អហើយ រួមមានៈ

១. អណ្តូងបុកដែលមានបំពាក់ស្នប់ដៃ អណ្តូងចម្រុះ (អណ្តូងបុកដែលមានអាងសម្រាប់ស្តុកទឹក) ឬ ជាអណ្តូងរាក់ដែលមានដាក់ខ្មោះ។ គ្រប់អណ្តូងទឹកទាំងអស់ត្រូវចាក់បេតុងខ្ពស់ព័ទ្ធជុំវិញ និងមានចង្អូរបង្ហូរទឹកដើម្បីបង្ហូរកាកសំណល់ចេញឲ្យឆ្ងាយ ពីអណ្តូង

២. ស្រះព័ទ្ធរបងដែលមានម៉ាស៊ីនបូមទឹក និងប្រព័ន្ធច្រោះទឹក (ដូច្នេះអ្នកប្រើប្រាស់មិនចាំបាច់ចូលទៅដួសទឹកផ្ទាល់ ហើយសត្វមិនអាចចូលទៅក្នុងស្រះបាន) ឬ

៣. សាទែនបញ្ឈរសាធារណៈដែលផ្គត់ផ្គង់ទឹកពីប្រព័ន្ធទឹកទុយោ។

ប្រភពទឹកស្អាតត្រូវផ្តល់ទឹកគ្រប់គ្រាន់សម្រាប់ការប្រើប្រាស់របស់គ្រួសារ (មានន័យថាយ៉ាងតិច ២០លីត្រ/ម្នាក់/ថ្ងៃ) សម្រាប់អ្នកប្រើប្រាស់គ្រប់រូបបានពេញមួយឆ្នាំ។

ការធ្វើតេស្តទឹកត្រូវអនុវត្តលើអណ្តូងទឹកទាំងអស់ដែលបានសង់ឡើងក្រោមជំនួយមូលនិធិរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ។ ការធ្វើតេស្តនេះរួមមានៈ

១. ធ្វើតេស្តរកបាក់តេរីនៅក្នុងទឹក។ ការធ្វើតេស្តនេះត្រូវអនុវត្តចំពោះគ្រប់អណ្តូងទាំងអស់ និង

២. ការធ្វើតេស្តរកសារធាតុអាសេនិកនៅក្នុងទឹក។ ត្រូវអនុវត្តការធ្វើតេស្តនេះ ពីព្រោះការិយាល័យផ្គត់ផ្គង់ និងអនាម័យទឹកតាមជនបទនៃមន្ទីរអភិវឌ្ឍជនបទខេត្តបានណែនាំថា វាមានភាពចាំបាច់បំផុតនៅក្នុងតំបន់សម្បទានដីសង្គមកិច្ច។

ក្នុងករណីទឹកកខ្វក់ សូមពន្យល់ពីលទ្ធផលនៃការធ្វើតេស្តដល់អ្នកទទួលដី តាមរយៈយុទ្ធនាការទឹកស្អាត និងអនាម័យ។

### *ឃ ៣ កញ្ចប់សម្ភារៈមូលដ្ឋាន និងជំនួយឧបត្ថម្ភសម្រាប់ការចូលតាំងទីលំនៅថ្មី*

កញ្ចប់សម្ភារៈមូលដ្ឋាន និងជំនួយឧបត្ថម្ភសម្រាប់ការចូលតាំងទីលំនៅថ្មី គឺជាការចំណាយដ៏ចាំបាច់។ គ្រួសារទាំងអស់ដែលទទួលបានដីក្រោមគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចត្រូវទទួលបានកញ្ចប់ឧបត្ថម្ភខាងលើ។ គ្រួសារទាំងអស់ដែលទទួលបានដីកសិកម្មនឹងទទួលបានជំនួយឧបត្ថម្ភសម្រាប់ការចូលតាំងទីលំនៅថ្មីដើម្បីជួយសម្រួលដល់ការរស់នៅ និងធ្វើការលើដីរបស់ពួកគាត់រហូតដល់ពេលប្រមូលផលលើកដំបូង។

### ឃ ៣.១ ការចាប់ផ្តើមផ្តល់ កញ្ចប់សម្ភារៈ ដីលំនៅឋាន

គ្រួសារទាំងអស់ដែលទទួលបានដីលំនៅឋានត្រូវទទួលបានកញ្ចប់សម្ភារៈដំបូងសម្រាប់ប្រើប្រាស់នៅក្នុងផ្ទះ។ កញ្ចប់សម្ភារៈដំបូងសម្រាប់លំនៅឋានមានរួមបញ្ចូលទាំងពាងទឹកផងដែរ។

### ឃ ៣.២ ការចាប់ផ្តើមផ្តល់កញ្ចប់សម្ភារៈ ដីកសិកម្ម

គ្រួសារទាំងអស់ដែលទទួលបានដីធ្វើកសិកម្មត្រូវទទួលបានកញ្ចប់សម្ភារៈដំបូងដែលរួមបញ្ចូលទាំងឧបករណ៍កសិកម្ម គ្រាប់ពូជ ជី និងធនធានផ្សេងទៀតដែលចាំបាច់សម្រាប់ការដាំដំណាំដំបូងនៅលើដីសម្បទានសង្គមកិច្ច។ ប្រភេទសម្ភារៈដំបូងសម្រាប់កសិកម្មនឹងត្រូវកំណត់តាមរយៈការវាយតម្លៃលើតម្រូវការផ្នែកកសិកម្ម។ សម្ភារៈមូលដ្ឋានដែលសំខាន់រួមមានៈ

- សម្ភារៈកសិកម្ម
- ពូថៅ
- កាំបិត
- រណារ
- ចបកាប់
- គ្រាប់ពូជ
- ស្រូវ (៥0 គក្រ/ហិ)
- គ្រាប់ពូជបន្លែ (សណ្តែកកួរ ស្ពៃខ្មៅ ស្ពៃចិន ស្ពៃតឿ ត្រប់វែង ត្រសក់ សាឡាត់) និង
- ជី

### ឃ ៣.៣ ជំនួយឧបត្ថម្ភសម្រាប់ការចូលតាំងទីលំនៅថ្មី

ក្នុងឆ្នាំដំបូងនៃកម្មវិធីនេះ អ្នកទទួលដីទាំងអស់ដែលមានដីកសិកម្មត្រូវទទួលបានការជួយឧបត្ថម្ភដល់ជីវភាពរស់នៅក្រោមកម្មវិធីអង្គពលកម្ម។ គោលបំណងនៃការជួយឧបត្ថម្ភដល់ជីវភាពរស់នៅនេះ គឺដើម្បីជួយឲ្យអ្នកទទួលដីទាំងអស់អាចប្រកបការងារនៅលើដីរបស់ពួកគាត់ដើម្បីប្រមូលទិន្នផលលើកដំបូង ជំនួសការចំណាយពេលវេលាទៅរកប្រាក់ផ្គត់ផ្គង់គ្រួសារក្នុងអំឡុងពេលនេះ។

### *ឃ ៤ ការចំណាយលើសេវាកម្មដែលចាំបាច់*

| |
|---|
| ផែនការសម្បទានដីសង្គមកិច្ចទាំងអស់ត្រូវរួមបញ្ចូលទាំងការផ្តល់ជូនសេវាកម្មមូលដ្ឋានក្នុងអំឡុងឆ្នាំទីមួយនៃសម្បទានដីសង្គមកិច្ច។ ការផ្តល់ជូននេះរួមមានការធ្វើយុទ្ធនាការអប់រំពីការប្រើប្រាស់ទឹក និងការរក្សាអនាម័យ ការឧបត្ថម្ភផ្នែកកសិកម្ម និងសេវាសុខភាពមូលដ្ឋាន។ |

## ឃ ៤.១ យុទ្ធនាការស្តីពីការប្រើប្រាស់ទឹក និងការអប់រំផ្នែកអនាម័យ

ក្នុងឆ្នាំទីមួយនៃសម្បទានដីសង្គមកិច្ច ត្រូវធ្វើយុទ្ធនាការស្តីពីការប្រើប្រាស់ទឹក និងការអប់រំផ្នែកអនាម័យ។ យុទ្ធនាការនេះរួមមាន:

១. ការបង្កើត និងការបណ្តុះបណ្តាល **ក្រុមអ្នកប្រើប្រាស់ទឹក និងអនាម័យ** សម្រាប់អណ្តូងនីមួយៗ ឬ កន្លែងផ្គត់ផ្គង់ទឹកផ្សេងទៀត។

២. ការបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ និងការថែរក្សាអណ្តូង ឬ ប្រភពផ្គត់ផ្គង់ទឹកផ្សេងទៀតដែលបានផ្តល់ជូនក្រោមគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

៣. ការអប់រំស្តីពីអនាម័យទឹក និងការចម្លងជំងឺ

៤. ការអប់រំស្តីពីការប្រើប្រាស់ឲ្យបានត្រឹមត្រូវនូវពាងទឹក និងចម្រោះទឹកដែលបានផ្តល់ជូនក្នុងកញ្ចប់សម្ភារៈមូលដ្ឋាន និង

៥. សកម្មភាពសហគមន៍ដោយមានការចូលរួមស្តីអំពីអនាម័យដើម្បីបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាល និងដើម្បីជំរុញលើកទឹកចិត្តឲ្យសង់បង្គន់អនាម័យ ដោយប្រើប្រាស់វិធីសាស្ត្រគ្រប់គ្រងអនាម័យរួម ដឹកនាំដោយសហគមន៍ ដែលជាវិធីសាស្ត្ររបស់អង្គការ UNICEF ។

## ឃ ៤.២ សេវាឧបត្ថម្ភផ្នែកកសិកម្ម

នៅក្នុងឆ្នាំដំបូងនៃសេវាឧបត្ថម្ភផ្នែកកសិកម្មសម្រាប់សម្បទានដីសង្គមកិច្ចនឹងជួយដល់អ្នកទទួលដីទាំងអស់ក្នុងការរៀបចំដីរបស់ពួកគាត់សម្រាប់ដាំដំណាំដំបូង។ ប្រភេទសេវាឧបត្ថម្ភដែលត្រូវការនឹងត្រូវសម្រេចនៅក្នុងអំឡុងពេលវាយតម្លៃតម្រូវការផ្នែកកសិកម្ម។ ប៉ុន្តែជាទូទៅ កញ្ចប់ឧបត្ថម្ភផ្នែកកសិកម្មនឹងរួមបញ្ចូលការបណ្តុះបណ្តាល និងការផ្សព្វផ្សាយស្តីពី:

១. ការរៀបចំដី

២. ការភ្ជួររាស់ដី

៣. ការកាប់គាស់ដី

៤. រៀបចំដីដើម្បីងាយស្រួលគ្រប់គ្រងទឹក

៥. ការសម្អាតស្មៅ

៦. ការលាយសំណល់ដំណាំ និងប្រើប្រាស់ជី

៧. ការរៀបចំថ្នាលពូជ

៨. បច្ចេកទេសដាំដុះ និង

៩. ការកំណត់ពេលនៃការដាំ

### ឃ ៤.៣ ការឧបត្ថម្ភផ្នែកសុខភាព

តាមរយៈការប្រឹក្សាយ៉ាងជិតស្និទ្ធជាមួយអ្នកទទួលដី ក្រុមប្រឹក្សាឃុំអាចជ្រើសរើសប្រើ ផ្នែកណាមួយនៃការបែងចែកសម្រាប់ធ្វើជាសេវាកម្មនៅតាមជនបទដើម្បីទ្រទ្រង់ការចំណាយលើការព្យាបាលជំងឺសម្រាប់អ្នកទទួលដី។ ការគាំទ្រនេះបែងចែកជា ៣ របៀបធំៗ។ ទីមួយ ការឧបត្ថម្ភផ្នែកថែរក្សាសុខភាពជាមូលដ្ឋានអាចផ្តល់ជូននៅក្នុងអំឡុងពេលចាប់ផ្តើមគម្រោងដំបូងតាមរយៈមន្ទីរពេទ្យនៅតាមមូលដ្ឋាន។ ទីពីរ ការថែរក្សាសុខភាពបន្តអាចផ្តល់ជូនតាមរយៈមូលនិធិសមធម៌សម្រាប់សុខភាពរបស់ក្រសួងសុខាភិបាល ឬ តាមរយៈទម្រង់ស្រដៀងគ្នាសម្រាប់តំបន់ដែលនៅក្រៅគម្រោង។ ទីបី ការថែរក្សាសុខភាពបន្តអាចផ្តល់ជូនតាមរយៈគ្លីនិកសុខភាពដែលមានស្រាប់។

### *ឃ ៥ ការចំណាយថវិកាសម្រេចផ្តល់ជំនួយបន្តៈ ហេដ្ឋារចនាសម្ព័ន្ធជនបទ*

ក្រុមប្រឹក្សាឃុំ និងអ្នកទទួលដីអាចសម្រេចចិត្តប្រើប្រាស់ថវិកាសម្រេចផ្តល់ជំនួយបន្ត ដើម្បីទ្រទ្រង់ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធជនបទ។

### ឃ ៥.១ សាលារៀន

កុមារទាំងអស់គ្រប់អាយុចូលរៀនថ្នាក់បឋមសិក្សា (៧ ទៅ ១២ឆ្នាំ) ដែលរស់នៅលើដីសម្បទានសង្គមកិច្ចត្រូវតែអាចចូលរៀនក្នុងសាលាបាន។ ដូច្នេះហើយចម្ងាយអតិបរមាពីដីសម្បទានសង្គមកិច្ចសម្រាប់លំនៅឋានទៅកាន់សាលាបឋមសិក្សា មិនត្រូវលើសពី៣គមឡើយ ហើយសាលារៀន ត្រូវមានអាគារគ្រប់គ្រាន់ដើម្បីទទួលសិស្សឲ្យចូលរៀន។

ប្រសិនបើគ្មានសាលារៀននៅក្នុងចម្ងាយ ៣គម ទេ ផែនការហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មជនបទត្រូវដាក់បញ្ចូលការសាងសង់សាលារៀនមួយខ្នង ហើយទីតាំងសម្រាប់សាលារៀនត្រូវដាក់បញ្ចូលនៅក្នុងផែនការប្រើប្រាស់ដីធ្លី។ ក្រុមប្រឹក្សាឃុំត្រូវស្វែងរកមូលនិធិសម្រាប់ការសាងសង់សាលារៀន។

### ឃ ៥.២ រចនាសម្ព័ន្ធប្រភេទផ្សេងទៀត

រចនាសម្ព័ន្ធសាធារណៈប្រភេទផ្សេងទៀតអាចផ្តល់ជូនជាការចំណាយថវិកាសម្រេចផ្តល់ជំនួយក្នុង *ផែនការហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មជនបទ*។ ហេដ្ឋារចនាសម្ព័ន្ធជនបទគឺសំដៅលើអ្វីៗដែលតាំងនៅមួយកន្លែង ហើយផ្តល់ប្រយោជន៍ដល់សហគមន៍ក្នុងមូលដ្ឋាន (មិនមែនផ្តល់ប្រយោជន៍សម្រាប់តែមួយគ្រួសារ ឬ ផ្តល់ប្រយោជន៍ដល់គ្រួសារមួយតែមួយគ្រានោះទេ)។ គ្រឿងយន្តកសិកម្មដូចជា ត្រាក់ទ័រ ឬ ម៉ាស៊ីនបូមទឹកដែលអាចចល័តបានមិនមែនជាហេដ្ឋារចនាសម្ព័ន្ធសាធារណៈទេ ហេតុនេះហើយវាមិនត្រូវបានផ្តល់មូលនិធិក្រោមគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចឡើយ។ អាគាររដ្ឋបាលរបស់រដ្ឋាភិបាល អាគារប៉ុស្ដិ៍នគរបាល ឬ សម្រាប់កងកម្លាំងសន្តិសុខផ្សេងទៀត និងអាគារសម្រាប់គណបក្សនយោបាយមិនមានលទ្ធភាពទទួលបានការផ្តល់មូលនិធិពីគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចឡើយ។

ហេដ្ឋារចនាសម្ព័ន្ធប្រភេទមួយចំនួនទៀតដែលអាចទទួលបានការផ្តល់មូលនិធិពីគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច រួមមាន:

- ប្រព័ន្ធធារាសាស្ត្រ
- មណ្ឌលសុខភាព (ដែលមានការសហការពីមន្ទីរសុខាភិបាលខេត្ត)
- កន្លែងផ្តល់សេវាសហគមន៍ដូចជា បណ្ណាល័យ សាលាមត្តេយ្យ មណ្ឌលធនធានជាដើម និង
- ការដំឡើងសញ្ញាអចល័តសម្រាប់ការពារបរិស្ថាន រួមមានការដាក់សញ្ញាកំណត់ព្រំប្រទល់ដីព្រៃ ការអភិរក្សធនធានមច្ឆា។ល។

## *ឃ ៦ ការចំណាយថវិកាសម្រេចផ្តល់ជំនួយបន្ត: សេវាកម្មជនបទ*

ក្រុមប្រឹក្សាឃុំ និងអ្នកទទួលដីអាចសម្រេចប្រើប្រាស់ថវិកាសម្រេចផ្តល់ជំនួយបន្តដើម្បីឧបត្ថម្ភការផ្តល់សេវាបន្ថែមក្នុងគោលបំណងជួយដល់អ្នកទទួលដីទាំងអស់។

### ឃ ៦.១ ការឧបត្ថម្ភច្រើនមុខលើផ្នែកកសិកម្ម

បន្ទាប់ពីសេវាឧបត្ថម្ភក្នុងឆ្នាំទីមួយ ក្រុមប្រឹក្សាឃុំ និងអ្នកទទួលដីនឹងមានជម្រើសដូចខាងក្រោមដោយផ្អែកលើលទ្ធផលនៃការពង្រីកសេវាកម្មក្នុងឆ្នាំទីមួយ:

១. ផ្តល់មូលនិធិ ១០០% សម្រាប់សេវាពង្រីកបន្ថែមមួយឆ្នាំទៀត
២. ការផ្តល់មូលនិធិជាផ្នែកសម្រាប់សេវាពង្រីកបន្ថែមសម្រាប់រយៈពេលពីរឆ្នាំបន្ថែមទៀត បូករួមនឹងការចូលរួមមូលនិធីពីអ្នកទទួលផល។ ឧទាហរណ៍: កសិករអាចស្រុះស្រួលគ្នាបង្កើត "មូលនិធិបង្គ្រប់" ដែលអ្នកទទួលផលទាំងអស់អាចបង់ប្រាក់មួយភាគនៃតម្លៃជំនួយផ្នែកបច្ចេកទេស (ឧទាហរណ៍:២៥%) រីឯចំណែកដែលនៅសល់ (៧៥%) អាចដកចេញពីមូលនិធិសម្រាប់គាំទ្របច្ចេកទេស។ ការធ្វើបែបនេះធ្វើឲ្យកសិករអាចគ្រប់គ្រងមូលនិធិគាំទ្របច្ចេកទេសដោយផ្ទាល់ និងប្រហែលជាអាចពង្រីកសកម្មភាពគាំទ្របានលើសពីពីរឆ្នាំ និង
៣. លុបចោលសេវាពង្រីកបន្ថែមក្នុងឆ្នាំទីពីរ ហើយប្រើប្រាស់មូលនិធិនោះសម្រាប់ប្រភេទសេវាកម្មផ្សេងទៀត។

ប្រភេទសេវាកម្មឧត្ថម្ភផ្នែកកសិកម្មដែលទទួលបានមូលនិធិពីការចំណាយថវិកាសម្រេចផ្តល់ជំនួយបន្តរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច អាចរួមបញ្ចូលទាំង:

១. ការគ្រប់គ្រងធនធានទឹក
២. ការរៀបចំប្លង់ប្រព័ន្ធធារាសាស្ត្រ (ចំណាំ: ការសាងសង់ប្រព័ន្ធធារាសាស្ត្រត្រូវការមូលនិធិពីផ្នែកហេដ្ឋារចនាសម្ព័ន្ធ ឬ មកពីប្រភពផ្សេងទៀត) និង
៣. បច្ចេកទេសសន្សំសំចៃទឹក

៤. ការបណ្តុះបណ្តាល និងការគាំទ្រការផ្សព្វផ្សាយស្តីពីការគ្រប់គ្រងអាហាររូបត្ថម្ភរួមគ្នាៈ

ក. ដីជាតិដី

ខ. ជីកកំប៉ុស និងជីលាមកសត្វ

គ. ការប្រើប្រាស់សាធាតុបំប៉នដែលមានតុល្យភាព

ឃ. ការគ្រប់គ្រងអាហាររូបត្ថម្ភ និង

ង. វិបត្តិអាហាររូបត្ថម្ភ និងដំណោះស្រាយ

៥. ការបណ្តុះបណ្តាល និងការគាំទ្រការផ្សព្វផ្សាយស្តីពីការគ្រប់គ្រងកត្តាចង្រៃរួមគ្នាៈ

ក. គោលការណ៍គ្រឹះនៃការគ្រប់គ្រងកត្តាចង្រៃរួមគ្នា

ខ. ស្មៅចង្រៃ និងការគ្រប់គ្រងវា

គ. សត្វល្អិតចង្រៃ និងការគ្រប់គ្រងវា

ឃ. ការគ្រប់គ្រងសត្វកកេរ និង

ង. ទំនាក់ទំនងរវាងអាហារបំប៉ន និងកត្តាចង្រៃ

៦. ការបណ្តុះបណ្តាល និងការគាំទ្រការផ្សព្វផ្សាយស្តីពីការគ្រប់គ្រងការប្រមូលផល និងក្រោយពេលប្រមូលផលៈ

ក. វិធីសាស្ត្រប្រមូលផល

ខ. ការបោកបែន (ស្រូវ)

គ. ការហាលសម្ងួត និងការសម្អាត

ឃ. ការគ្រប់គ្រង និងការរក្សាទុក

ង. ការកិន និងការកែច្នៃ (សម្រាប់ស្រូវ និងផលិតផលផ្សេងទៀត)

ច. អនុផល និងតម្លៃបន្ថែម និង

ឆ. បទដ្ឋានធានាសុខភាពមនុស្ស សត្វ

៧. សេវាកម្មពាក់ព័ន្ធផ្សេងទៀតផ្នែកកសិកម្មដូចជាៈ

ក. សុខភាពសត្វ និងការថែទាំ

ខ. ការស្វែងរកទីផ្សារ និងការឈានចូលទីផ្សារ

គ. សមាគម/សហករអ្នកទិញ និងអ្នកលក់ និង

ង. សមាគមកសិករវ័យក្មេងៗ។

## ឃ ៦.២ កម្មវិធីសន្សំប្រាក់

ក្រុមប្រឹក្សាឃុំជាមួយនឹងអ្នកទទួលដីអាចស្នើទៅឃុំដើម្បីទាក់ទងអ្នកផ្តល់សេវា (ទាំងអង្គការមិនមែនរដ្ឋាភិបាល និងផ្នែកធនាគារឯកជន ឬ ស្ថាប័នមីក្រូហិរញ្ញវត្ថុ) ឲ្យផ្តល់ជំនួយបច្ចេកទេសរដ្ឋបាល និងការគ្រប់គ្រងក្នុងការបង្កើត និងអនុវត្តកម្មវិធីសន្សំប្រាក់ថ្នាក់ភូមិ។

**ឃ ៦.៣ សេវាផ្សេងៗទៀត**

ក្រុមប្រឹក្សាឃុំជាមួយនឹងអ្នកទទួលដីអាចស្នើសុំប្រើប្រាស់ថវិកាសម្រេចផ្តល់ជំនួយបន្ត ដើម្បីផ្តល់សេវាសាធារណៈមួយចំនួន។

១. បណ្តុះបណ្តាលជំនាញកែច្នៃចំណីអាហារ

២. បណ្តុះបណ្តាលសិប្បកម្ម

៣. អភិវឌ្ឍសហគ្រាសខ្នាតតូច

៤. លើកកម្ពស់ការយល់ដឹងពាក់ព័ន្ធនឹងច្បាប់ បទបញ្ញា ទាក់ទងនឹងដីធ្លី ជលផល ព្រៃឈើ កសិកម្ម ជនជាតិដើមភាគតិច ព្រមទាំងសិទ្ធិបុគ្គល

៥. បណ្តុះបណ្តាលសមភាពយេនឌ័រ

៦. ការចូលរួមពីប្រជាពលរដ្ឋ

៧. ការពារសង្គម និងបរិស្ថាន

៨. ការកាត់បន្ថយអំពើហឹង្សាក្នុងគ្រួសារ

៩. ការទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ

១០. យល់ដឹង និងទប់ស្កាត់មេរោគអេដស៍/ជំងឺអេដស៍ និង

១១. ប្រឹក្សាពីការរៀបចំផែនការគ្រួសារ

## ខ. សមាសភាគទី ៣ : ការអភិវឌ្ឍកម្មវិធីប្រកបដោយចីរភាព និងតម្លាភាព

### *ខ ១ តើមានអ្វីខ្លះនៅក្នុងសមាសភាគទី ៣ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច?*

នៅក្នុងសមាសភាគទី ៣ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចនេះ "ការអភិវឌ្ឍកម្មវិធីប្រកបដោយចីរភាព និងតម្លាភាព" ត្រូវបានគេផ្តោតជាសំខាន់ដើម្បីដាក់ឲ្យចំកន្លែង និងដើម្បីគាំទ្រស្ថាប័ន ប្រព័ន្ធនានា និងនីតិវិធីចាំបាច់ដើម្បីគាំទ្រការអនុវត្តសម្បទានដីសង្គមកិច្ចក្នុងអំឡុងពេលនៃគម្រោងការបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចតាមរយៈក្រុមប្រឹក្សាឃុំ។

ជាក់ស្តែង សមាសភាគទី ៣ រួមមាន:

- ការផ្សព្វផ្សាយព័ត៌មាន
- ការកសាងសមត្ថភាព
- ការគាំទ្រដល់ក្រុមប្រឹក្សាឃុំក្នុងការបង្កើត និងអនុវត្តសម្បទានដីសង្គមកិច្ច
- ការបង្កើតគោលនយោបាយ និង
- ការត្រួតពិនិត្យ និងវាយតម្លៃ

### *ខ ២ តួនាទី និងការទទួលខុសត្រូវនៅថ្នាក់ជាតិ*

### ខ ២.១ គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ

គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ (ដែលបង្កើតឡើងដោយអនុក្រឹត្យលេខ ១៩ អនក/បក) ត្រួតពិនិត្យនូវរាល់កម្មវិធីសម្បទានដីសង្គមកិច្ចក្នុងនាមជាក្រុមប្រឹក្សាគោលនយោបាយដីធ្លី។ គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិបានរៀបចំវេទិកាថ្នាក់ជាតិប្រចាំឆ្នាំ ដើម្បីពិនិត្យបទពិសោធន៍ និងបញ្ហាពាក់ព័ន្ធជាមួយនឹងសម្បទានដីសង្គមកិច្ចទាំងអស់ និងដើម្បីកំណត់តំបន់សម្រាប់ការអភិវឌ្ឍគោលនយោបាយបន្ត។ គណៈកម្មាធិការជាតិក៏បានចុះពិនិត្យសម្បទានដីសង្គមកិច្ចក្នុងមូលដ្ឋានផងដែរ។

គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិទទួលខុសត្រូវចំពោះការផ្តល់សិទ្ធិ ឬ ការបដិសេធនូវរាល់សម្បទានដីសង្គមកិច្ចដែលអនុម័តដោយគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត (សូមមើលខាងក្រោម)។ គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិទទួលខុសត្រូវធ្វើការត្រួតពិនិត្យវិញ និងកំណត់គោលនយោបាយ និងច្បាប់ទាក់ទងនឹងគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច និងការអនុវត្តសម្បទានដីសង្គមកិច្ច។

## ខ ២.២ នាយកគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

នាយកគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ត្រូវបានតែងតាំងដោយគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ។ នាយកគម្រោងនេះទទួលខុសត្រូវចំពោះការអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចទាំងមូល។ ការទទួលខុសត្រូវជាក់លាក់របស់នាយកគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច រួមមាន:

១. ចូលរួមជាមួយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ធ្វើផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំសម្រាប់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

២. សម្របសម្រួលជាមួយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ស្តីពីហិរញ្ញវត្ថុ លទ្ធកម្ម ការធ្វើកិច្ចសន្យា និងគោលនយោបាយទាក់ទងនឹងបញ្ហានានា

៣. អនុម័តការសម្រេចគោលនយោបាយសំខាន់ៗដូចជាការជ្រើសរើសខេត្តគោលដៅ

៤. ចងសម្ព័ន្ធភាពរវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារពិភពលោក រួមទាំងទទួលក្រុមបេសកកម្មត្រួតពិនិត្យរបស់ធនាគារពិភពលោក ដោយធ្វើការពន្យល់ខ្លីៗ និងពន្យល់លម្អិតពីគម្រោង

៥. ត្រួតពិនិត្យការងារដាក់ឲ្យដោយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសម្បទានដីសង្គមកិច្ចទាក់ទងនឹងគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

៦. ធានាថា បញ្ហានានាទាក់ទងនឹងគោលនយោបាយ និងផ្លូវច្បាប់ និងការអនុម័តសម្បទានដីសង្គមកិច្ច គឺត្រូវបញ្ជូនទៅគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិនៅពេលចាំបាច់ និង

៧. ចូលរួមជាមួយគណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ធ្វើរបាយការណ៍ស្តីពីការរីកចម្រើនប្រចាំឆ្នាំនៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។

## ខ ២.៣ អគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច

អគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ចសម្របសម្រួលការជួយឧបត្ថម្ភដល់សម្បទានដីសង្គមកិច្ច និងបម្រើជាលេខាធិកាដ្ឋានរបស់គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិសម្រាប់បញ្ហាទាំងអស់ទាក់ទងនឹងសម្បទានដីសង្គមកិច្ច ដែលរួមមានការត្រួតពិនិត្យការអនុវត្តសម្បទានដីសង្គមកិច្ច គោលនយោបាយ និងគោលការណ៍ណែនាំព្រាងសម្រាប់ការពិចារណាទៅលើក្រុមប្រឹក្សាគោលនយោបាយដីធ្លី ព្រមទាំងផ្តល់របាយការណ៍ និងការវាយតម្លៃក្រុមប្រឹក្សាគោលនយោបាយដីធ្លីស្តីពីសម្បទានដីសង្គមកិច្ច។ លើសពីនេះទៀតអគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ចរៀបចំព័ត៌មាន និងសម្ភារៈបណ្តុះបណ្តាល និងធ្វើការជាមួយក្រសួងពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន

អង្គការមិនមែនរដ្ឋាភិបាល និងបណ្តាភាគីពាក់ព័ន្ធដទៃទៀតក្នុងការលើកកម្ពស់ និងគាំទ្រសម្បទានដីសង្គមកិច្ច។

នៅក្នុងគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចនេះ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការសម្បទានដីសង្គមកិច្ចទទួលខុសត្រូវចំពោះ :

១. ការត្រួតពិនិត្យគោលនយោបាយ និងទិសដៅទូទៅរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច និងការធានានូវភាពចុះសម្រុងគ្នាជាមួយគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីសម្បទានដីសង្គមកិច្ច

២. បញ្ជូនគោលនយោបាយ និងបញ្ញាផ្លូវច្បាប់ទាក់ទងនឹងការអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចទៅគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ នៅពេលដែលចាំបាច់

៣. ទទួលសម្បទានដីសង្គមកិច្ចដែលអនុម័តដោយគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ហើយរៀបចំឲ្យមានការត្រួតពិនិត្យឡើងវិញដោយគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ

៤. សហការជាមួយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ក្នុងការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំសម្រាប់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

៥. ការបង្កើតឯកសារបណ្តុះបណ្តាលសម្រាប់កសាងសមត្ថភាពទាក់ទងនឹងសម្បទានដីសង្គមកិច្ច សម្រាប់ប្រើប្រាស់នៅក្នុងគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច និងកន្លែងផ្សេងទៀត

៦. សហការជាមួយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ក្នុងការរៀបចំល័ក្ខខ័ណ្ឌយោងសម្រាប់អ្នកផ្តល់ប្រឹក្សារយៈពេលវែង និងរយៈពេលខ្លីនៅថ្នាក់ជាតិសម្រាប់ការសិក្សាពីគោលនយោបាយស្តីពីសម្បទានដីសង្គមកិច្ច និងសម្រាប់ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

៧. ពិនិត្យតាមដានការអនុវត្តសម្បទានដីសង្គមកិច្ច (ដីដែលបានបែងចែក ចំនួនមុខសញ្ញាអ្នកទទួលដី និងលទ្ធផលសម្បទានដីសង្គមកិច្ច

៨. វាយតម្លៃពីការវិវឌ្ឍឆ្ពោះទៅរកគោលដៅមូលដ្ឋានរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច និង

៩. ប្រមូលរបាយការស្តីពីការរីកចម្រើនប្រចាំឆ្នាំនៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។

## ខ ២.៤ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប)

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គជអប) ទទួលខុសត្រូវចំពោះការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច លើកលែងតែចំពោះសកម្មភាពទាំងឡាយណាដែលជាការទទួលខុសត្រូវរបស់អគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច ។

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គជអប) បែងចែកការទទួលខុសត្រូវទាំងនេះតាមរយៈនាយកអង្គភាពគាំទ្រកម្មវិធីនៃលេខាធិការដ្ឋាន គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ នាយកគាំទ្រអង្គភាពកម្មវិធីទទួលខុសត្រូវចំពោះការអនុម័តសេចក្តីសម្រេចលើផ្នែកហិរញ្ញវត្ថុ និងការអនុវត្តគម្រោងសំខាន់ៗរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិទាក់ទងនឹងការបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។ មិនចាំបាច់មានការផ្តល់សិទ្ធិកម្រិតខ្ពស់ឡើយដើម្បីធ្វើការសម្រេចទាក់ទងនឹងការចំណាយ ឬ សកម្មភាពទាំងឡាយដែលត្រូវបានអនុម័តនៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច លើកលែងតែ*មានលិខិតជំទាស់* ពីសមាគមអភិវឌ្ឍអន្តរជាតិ រួមជាមួយនឹងកិច្ចព្រមព្រៀងផ្តល់ហិរញ្ញប្បទាន។[១០]

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិចាត់តាំងក្រុមបុគ្គលិកទទួលបន្ទុកដែល ជាប្រធានទទួលខុសត្រូវជាចម្បងចំពោះការងារប្រចាំថ្ងៃរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ទាក់ទងនឹងគម្រោង បែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។ ក្រុមបុគ្គលិកទទួលបន្ទុកគឺដឹកនាំដោយ ប្រធានសម្របសម្រួលគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច (*លក្ខខណ្ឌយោង* សម្រាប់មុខតំណែងរបស់បុគ្គលិកនៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិទាំងអស់គឺអាចមើលឃើញនៅក្នុង*ឧបសម្ព័ន្ធទី៥–លក្ខខណ្ឌ យោង-មុខតំណែងរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ ក្រោមជាតិ*)។

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិប្រគល់ការទទួលខុសត្រូវប្រតិបត្តិភាគច្រើនជូនគណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្តក្នុងខេត្តដែលចូលរួម។ភារកិច្ចប្រតិបត្តិមួយផ្នែកត្រូវអនុវត្តនៅថ្នាក់ជាតិដោយអង្គភាពគាំទ្រកម្មវិធីរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

១. ការគ្រប់គ្រងហិរញ្ញវត្ថុរបស់គម្រោងទាំងមូល

---

[១០] សម្រាប់ព័ត៌មានលម្អិត គឺមានផ្តល់ជូននៅក្នុងឧបសម្ព័ន្ធលទ្ធកម្ម។

២. លទ្ធកម្មទូទៅ

៣. ការគ្រប់គ្រងរដ្ឋបាល

៤. ការពិនិត្យតាមដាន និងការវាយតម្លៃ

៥. ការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ

៦. ការរៀបចំរបាយការណ៍ប្រចាំឆ្នាំ

### ខ ២.៥ នាយកអង្គភាពគាំទ្រកម្មវិធីរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប)

នាយកអង្គភាពគាំទ្រកម្មវិធី ទទួលខុសត្រូវចំពោះសកម្មភាពដូចខាងក្រោម:

១. ត្រួតពិនិត្យការអនុវត្តផ្នែកនានានៃផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចដែលស្ថិតក្រោមការទទួលខុសត្រូវរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

២. អនុម័តនូវរាល់សេចក្តីសម្រេចធ្វើការចំណាយសំខាន់ៗពាក់ព័ន្ធនឹងមូលនិធិគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈអង្គភាពគាំទ្រកម្មវិធីរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

៣. អនុម័តសំណើដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបំពេញគណនីគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

៤. អនុម័តការផ្ទេរមូលនិធិពីគណនីគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិទៅក្នុងគណនីថ្នាក់ខេត្តរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

៥. ជ្រើសរើស គ្រប់គ្រង និងបញ្ឈប់បុគ្គលិក និងអ្នកផ្តល់ប្រឹក្សាដែលជួលដោយផ្នែកគាំទ្រកម្មវិធីរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដែលប្រើប្រាស់មូលនិធិរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច និង

៦. អនុម័តល័ក្ខខ័ណ្ឌយោងសម្រាប់អ្នកផ្តល់ប្រឹក្សារយៈពេលវែង និងរយៈពេលខ្លីដែលបានជួលដើម្បីជួយដល់ការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ឬ សម្រាប់ការធ្វើសវនកម្មហិរញ្ញវត្ថុដោយសារវាទាក់ទងនឹងការងារដែលគ្របដណ្តប់ក្រោមការត្រួតពិនិត្យរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

៧. ការរៀបចំ និងដាក់ស្នើទៅធនាគារពិភពលោកចំពោះករណីមិនមានការជំទាស់ចំពោះ ផែនការលទ្ធកម្មរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

៨. ត្រួតពិនិត្យរាល់លទ្ធកម្មទាំងអស់ដែលស្ថិតក្រោម ការបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ។

## ខ ២.៦ ប្រធានសម្របសម្រួលគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច[១១]

ប្រធានសម្របសម្រួលគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចទទួលខុសត្រូវចំពោះ :

១. រក្សាសម្ព័ន្ធភាពជិតស្និទ្ធជាមួយនាយកគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចដែលជាបុគ្គលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

២. ត្រួតពិនិត្យការងារក្រុមស្នូលរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច រួមទាំងផ្តល់អនុសាសន៍សម្រាប់ការតែងតាំង ការគ្រប់គ្រង និងការបញ្ឈប់បុគ្គលិកនៅពេលចាំបាច់

៣. ត្រួតពិនិត្យការរៀបចំរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ/ផ្នែកនានានៃគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្តទាក់ទងនឹងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ហើយបញ្ជូនទៅប្រធានគម្រោងគាំទ្រការអភិវឌ្ឍដើម្បីអនុម័ត

៤. សម្របសម្រួលការអនុវត្តភារកិច្ចរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ស្ថិតក្រោមផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

៥. ពិនិត្យ និងសម្របសម្រួលការប្រើប្រាស់ និងការធ្វើគណនេយ្យសមស្របទាក់ទងនឹងមូលនិធិនៅក្នុងគណនីគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

៦. ដោយអនុលោមតាមផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ស្នើសុំការអនុម័តពីនាយកគាំទ្រកម្មវិធីដែលធ្វើឡើងដោយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ជាមួយគណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិ

---

[១១] ប្រធានសម្របសម្រួលគម្រោងនឹងរាយការណ៍ដោយផ្ទាល់ទៅនាយកគាំទ្រកម្មវិធី។

វឌ្ឍជនបទខេត្តសម្រាប់ប្រតិបត្តិការរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

៧. ដោយអនុលោមតាមផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ធ្វើការអនុម័តឯកសារដេញថ្លៃដែលរៀបចំឡើងដោយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិមុនពេលដាក់ជូនភ្នាក់ងារលទ្ធកម្មឯករាជ្យដើម្បីចាប់ផ្តើមសកម្មភាពលទ្ធកម្ម និងធានាឲ្យមានការអនុវត្តត្រឹមត្រូវនូវសេចក្តីសម្រេចធ្វើលទ្ធកម្មដែលបានណែនាំដោយទីភ្នាក់ងារលទ្ធកម្មអន្តរជាតិ

៨. ធានាថា ប្រតិបត្តិការរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចដែលស្ថិតក្រោមគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវបានត្រួតពិនិត្យយ៉ាងពេញលេញ

៩. ធានាឲ្យមានការចែកចាយរបាយការណ៍ប្រតិបត្តិ និងហិរញ្ញវត្ថុទៀងទាត់ពេលវេលា

១០. សម្របសម្រួលជាមួយប្រធានគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដើម្បីទទួលក្រុមបេសកកម្មពិនិត្យតាមដានរបស់សមាគមអភិវឌ្ឍអន្តរជាតិសម្រាប់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

១១. ធានាឲ្យមានភាពស្របគ្នាជាមួយនឹងក្របខណ្ឌអភិបាលកិច្ចល្អរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

១២. ធានាឲ្យមានភាពស្របគ្នាជាមួយនឹងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងសមាគមអភិវឌ្ឍអន្តរជាតិពាក់ព័ន្ធនឹងប្រតិបត្តិការរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច និង

១៣. អនុវត្តភារកិច្ចដទៃទៀតដែលអាចនឹងប្រគល់ដោយប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

## ខ ២.៧ ក្រុមការងារគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច របស់គណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប)

សមាជិកនៃក្រុមការងារទទួលបន្ទុករបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ចនិងការអភិវឌ្ឍសេដ្ឋកិច្ចត្រូវបានចាត់តាំងទៅអង្គភាពមុខងារនៅក្នុងអង្គភាពគាំទ្រកម្មវិធីរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) - គម្រោងគាំទ្រការអភិវឌ្ឍ)។ ក្រុមការងារគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិទទួលខុស
ត្រូវចំពោះសកម្មភាពដូចខាង ក្រោម:

១. រៀបចំ និងអនុវត្តកិច្ចសន្យាសម្បទានដីសង្គមកិច្ចជាមួយបណ្តាខេត្តដែលចូលរួម ដើម្បីបង្ហាញពីផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច
២. លទ្ធកម្មថ្នាក់ជាតិ ការគ្រប់គ្រងហិរញ្ញវត្ថុ ការពិនិត្យតាមដានការរីកចម្រើនផ្នែករូបវន្តប្រៀបទៅនឹងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ
៣. ធ្វើរបាយការណ៍ហិរញ្ញវត្ថុ
៤. រៀបចំរបាយការណ៍រីកចម្រើនប្រចាំឆ្នាំរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។

## ខ ៣ តួនាទី និងការទទួលខុសត្រូវថ្នាក់ខេត្ត ស្រុក និងឃុំ

### ខ ៣.១ អភិបាលខេត្ត

អភិបាលខេត្តទទួលខុសត្រូវទាំងស្រុងក្នុងការធានាថាកម្មវិធីសម្បទានដីសង្គមកិច្ចត្រូវបានអនុវត្តស្របតាមច្បាប់ និងគោលការណ៍ណែនាំ រួមជាមួយនឹងតម្រូវការជាក់លាក់របស់ដៃគូអភិវឌ្ឍន៍។

### ខ ៣.២ គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តដែលដឹកនាំដោយអភិបាលខេត្តទទួលខុសត្រូវចំពោះការអនុវត្តគោលនយោបាយស្តីពីសម្បទានដីសង្គមកិច្ចនៅថ្នាក់ខេត្ត។ គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តរាយការណ៍ទៅគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ តាមរយៈអគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ចលើបញ្ហានានាដែលទាក់ទងនឹងការអនុវត្តសម្បទានដីសង្គមកិច្ច រួមទាំងរបាយការណ៍សម្បទានដីសង្គមកិច្ចដែលគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិមានសិទ្ធិជំទាស់។

ការទទួលខុសត្រូវរួមរបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តគឺ:
១. រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ជាមួយផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាល គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត
២. អនុវត្តគោលនយោបាយដីធ្លីរបស់អគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច និង
៣. អនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំទាក់ទងនឹងបញ្ហាដីធ្លី

នៅក្នុងដំណើរការសម្បទានដីសង្គមកិច្ច គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តទទួលខុសត្រូវដោយផ្ទាល់ដូចខាងក្រោម:
១. ធានាឲ្យមានបទដ្ឋានសម្រាប់ការធ្វើចំណាត់ថ្នាក់ដី ការរៀបចំផែនការប្រើប្រាស់ដី
២. កំណត់អត្តសញ្ញាណកម្មដីសាធារណៈរបស់រដ្ឋ និងដីកម្មសិទ្ធិឯកជនរបស់រដ្ឋ

៣. អនុម័តការធ្វើចំណាត់ថ្នាក់ដី ផែនការប្រើប្រាស់ដី និងសេចក្តីសម្រេចនានាអំពីការបែងចែកដីរដ្ឋនៅថ្នាក់ខេត្ត
៤. ឯកភាព បដិសេធ ឬ កែប្រែផែនការសម្បទានដីសង្គមកិច្ចដែលស្នើដោយក្រុមប្រឹក្សាឃុំ
៥. បញ្ជូនផែនការសម្បទានដីសង្គមកិច្ច និងការអនុម័តផែនការសម្បទានដីសង្គមកិច្ច ដើម្បីឲ្យគណៈកម្មាធិការជាតិសម្បទានដីសង្គមកិច្ចធ្វើការត្រួតពិនិត្យឡើងវិញ
៦. សម្របសម្រួលជាមួយក្រសួងផ្សេងៗទៀតលើការរៀបចំផែនការប្រើប្រាស់ដីទូទៅសម្រាប់ការអភិវឌ្ឍ និង
៧. ធ្វើកិច្ចសហការជាមួយអាជ្ញាធរបោសសម្អាតគ្រាប់មីន ចំពោះតំបន់ដែលមានគ្រាប់មីន

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តផ្តល់ការគាំទ្របច្ចេកទេសដល់ក្រុមការងារថ្នាក់ស្រុកលើបញ្ហានានាទាក់ទងនឹងសម្បទានដីសង្គមកិច្ច និងជាពិសេសចំពោះបញ្ហាដែលបានលើកឡើងខាងលើ។

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តក៏អនុវត្តការទទួលខុសត្រូវដូចខាងក្រោមតាមរយៈការត្រួតពិនិត្យរបស់គណៈកម្មាធិការស្រុក (សូមមើលខាងក្រោម)៖

១. ត្រួតពិនិត្យ និងប៉ាន់ស្មានទំហំដីដែលមានដើម្បីបំពេញតម្រូវការរបស់មុខសញ្ញាអ្នកទទួលដីក្នុងស្រុកទាំងអស់របស់ខេត្តនីមួយៗ
២. ពិនិត្យ និងវាយតម្លៃផែនការប្រើប្រាស់ដី និងផែនការសម្បទានដីសង្គមកិច្ចដែលស្នើដោយក្រុមប្រឹក្សាឃុំ
៣. ជួយក្រុមប្រឹក្សាឃុំបង្កើតផែនការប្រើប្រាស់ដី និងការធ្វើចំណាត់ថ្នាក់ដី
៤. ធានាថា គ្រប់នីតិវិធី និងតម្រូវការទាំងអស់ក្នុងសៀវភៅណែនាំនេះ ត្រូវបានអនុវត្ត រួមទាំងនីតិវិធី និងតម្រូវការទាក់ទងនឹងការការពារដីដែលមានក្តីព្រួយបារម្ភពីបរិស្ថាន និងសង្គម និងតាមដានឲ្យបានត្រឹមត្រូវនូវសកម្មភាពដែលបានអនុវត្ត និង
៥. រក្សាការកត់ត្រា (ដែលបើកចំហសម្រាប់សាធារណៈជន រួមទាំងក្រុមសង្គមស៊ីវិលផងដែរ) បណ្តឹងទាំងអស់ដែលដាក់ទៅថ្នាក់ឃុំ ស្រុក និងថ្នាក់ខេត្តសម្រាប់គ្រប់ទិដ្ឋភាពនៃសម្បទានដីសង្គមកិច្ចទាំងអស់នៅក្នុងខេត្ត បូករួមទាំងសៀវភៅកត់ត្រាសកម្មភាពដែលមានចុះកាលបរិច្ឆេទនៃការដាក់បណ្តឹងលើកទីមួយ ការទទួលពាក្យនៅថ្នាក់ស្រុក ការទទួលពាក្យនៅថ្នាក់ខេត្ត កាលបរិច្ឆេទពិនិត្យបណ្តឹង និងកិច្ចប្រជុំមួយចំនួនជាមួយអ្នកដាក់ពាក្យបណ្តឹង ការចាត់វិធានការដោះស្រាយបណ្តឹង និងការជូនដំណឹងពីចំណាត់ការចំពោះអ្នកដាក់ពាក្យបណ្តឹង។

## ខ ៣.៣ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត

គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តទទួលខុសត្រូវដឹកនាំដំណើរការកំណត់ និងធ្វើផែនទីដីរដ្ឋ[១២] និងផ្តួចផ្តើមការចុះបញ្ជីដីរដ្ឋនៅពេលបញ្ចប់ការកំណត់អត្តសញ្ញាណកម្មដីនិងការធ្វើផែនទី។

## ខ ៣.៤ ក្រុមការងារគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចថ្នាក់ខេត្ត

ក្រុមការងារគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចថ្នាក់ខេត្ត គឺដឹកនាំដោយការិយាល័យសាលាខេត្ត ប៉ុន្តែប្រតិបត្តិការប្រចាំថ្ងៃរបស់គម្រោងនេះមានមូលដ្ឋាននៅក្នុងសាលាខេត្ត ហើយគាំទ្រការទទួលខុសត្រូវរបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត និងគណៈកម្មាធិការគ្រប់គ្រងដីសង្គមកិច្ច។ ក្រុមការងារគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចថ្នាក់ខេត្តនឹងមានបុគ្គលិកចំនួនប្រាំ (៥) រូប[១៣] *(**លក្ខខណ្ឌយោង** សម្រាប់មុខតំណែងបុគ្គលិករបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តទាំងអស់ គឺអាចរកមើលបាននៅក្នុង**ឧបសម្ព័ន្ធ ៦ – លក្ខខណ្ឌយោង - មុខតំណែងរបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត**)*។

១. ប្រធានគ្រប់គ្រងថ្នាក់ខេត្ត
២. ប្រធានគ្រប់គ្រងសុរិយោដី/ដីធ្លី
៣. អ្នកឯកទេសអភិវឌ្ឍជនបទ
៤. អ្នកឯកទេសជំនាញកសិកម្ម និង
៥. អ្នកឯកទេសជ្រើសរើសអ្នកទទួលផល
៦. មន្ត្រីកិច្ចការនារី
៧. មន្ត្រីធនធានទឹក
៨. មន្ត្រីបរិស្ថាន
៩. មន្ត្រីខណ្ឌរដ្ឋបាលព្រៃឈើ

## ខ ៣.៥ គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត

គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្តដែលដឹកនាំដោយអភិបាលខេត្តទទួលខុសត្រូវដូចខាងក្រោម:

---

[១៣] លេខាធិការដ្ឋានគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក៏នឹងណែនាំឲ្យបណ្តាក្រសួងផ្សេងទៀតធ្វើការលើបញ្ហានានាទាក់ទងនឹងការវិភាគប្រព័ន្ធក្សេត្របរិស្ថាន, ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ ការចុះបញ្ជីដីធ្លី និងព្រៃសហគមន៍។

១. គាំទ្រកិច្ចប្រតិបត្តិការលើទិដ្ឋភាពបច្ចេកទេសទាំងមូលស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងកិច្ចសន្យា លទ្ធកម្ម ចំណាយរដ្ឋបាល និងប្រតិបត្តិការនៃការអនុវត្តរបស់គម្រោង បែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចថ្នាក់ខេត្ត ថ្នាក់ស្រុក និងឃុំ។
២. ដឹកនាំ ឬ ទទួលខុសត្រូវត្រួតពិនិត្យរាល់ការគ្រប់គ្រងគម្រោង និងភារកិច្ចគ្រប់គ្រងហិរញ្ញវត្ថុ និង
៣. ជួយក្រុមប្រឹក្សាឃុំ ក្រុមការងារថ្នាក់ស្រុក ក្រុមការងារគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចរបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត។

គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្តបែងចែកការទទួលខុសត្រូវនេះតាមរយៈផ្នែកមុខងារទាំង ៤ របស់ខ្លួន។ ផ្នែកនីមួយៗក្នុងចំណោមនេះនឹងត្រូវពង្រឹងតាមរយៈការដាក់បញ្ចូលបុគ្គលិកបន្ថែមមួយរូបទៀតដែលនឹងត្រូវចាត់តាំងជាគោលការណ៍ឲ្យទៅធ្វើការជាមួយគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។

## ខ ៣.៦ ផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាល គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត

ផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាលគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជន បទខេត្តទទួលខុសត្រូវចំពោះបញ្ហានានាទាក់ទងនឹងការអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការ អភិវឌ្ឍសេដ្ឋកិច្ច ដូចខាងក្រោមៈ

១. ព្រាងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំថ្នាក់ខេត្តរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដោយមានជំនួយផ្នែកបច្ចេកទេសពីគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត និងពីផ្នែកប្រតិបត្តិដទៃទៀត
២. បញ្ហារដ្ឋបាលផ្ទៃក្នុងនានាដែលរួមមាន បុគ្គលិក យានជំនិះ សម្ភារៈ អាគារ ។ល។ ព្រមទាំងការត្រួតពិនិត្យលទ្ធកម្ម
៣. ជួយមន្ទីរជំនាញខេត្តបង្កើតការចំណាយជាឯកតាសម្រាប់ធនធានដែលក្រុមប្រឹក្សាឃុំត្រូវការសម្រាប់អនុវត្តសម្បទានដីសង្គមកិច្ចតាមរយៈការប្រើប្រាស់អត្រាចំណាយតាមបទដ្ឋានដែលអនុម័តដោយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
៤. ព្រាង ពិនិត្យឡើងវិញ និងដាក់ឲ្យចុះហត្ថលេខា និងពិនិត្យការអនុវត្តកិច្ចសន្យាសម្រាប់ការអនុវត្តសកម្មភាពគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចរវាងគណៈកម្មាធិការប្រតិបត្តិ និងភ្នាក់ងារអនុវត្ត ដែលរួមមាន គណៈកម្មាធិការ

ប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត មន្ទីរជំនាញ និងក្រុមការងារថ្នាក់ស្រុកនៅពេលចាំបាច់

៥. ការពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំថ្នាក់ខេត្តរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច និង

៦. ជួយមន្ទីរកិច្ចការនារីខេត្តពិនិត្យតាមដានដំណើរការបញ្ជ្រាបយេនឌ័រនៅក្នុងគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។

## ខ ៣.៧ ផ្នែកហិរញ្ញវត្ថុ គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទ ខេត្ត

ផ្នែកហិរញ្ញវត្ថុ គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្តទទួលខុសត្រូវចំពោះបញ្ហាទាក់ទងនឹងការអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចដូចខាងក្រោម:

១. គ្រប់គ្រងគណនីថ្នាក់ខេត្តរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងធនាគារពាណិជ្ជ និងកំណត់ជាប្រាក់ដុល្លារអាមេរិក

២. រក្សាគណនីគម្រោងដោយប្រើប្រាស់កម្មវិធីគណនេយ្យ Peachtree

៣. ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ថ្នាក់ជាតិ និង

៤. បើកការចំណាយស្របតាមនីតិវិធីទាំងឡាយ។

## ខ ៣.៨ ផ្នែករដ្ឋបាលមូលដ្ឋាន គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត

ផ្នែករដ្ឋបាលមូលដ្ឋាន គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្តជួយអភិបាលខេត្តបែងចែកមុខងាររបស់ផ្នែករដ្ឋបាលមូលដ្ឋានថ្នាក់ខេត្ត។ តួនាទីនេះរួម មាន:

១. ការកសាងសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ

២. ការពិនិត្យតាមដាន និងវាយតម្លៃដំណើរការអនុវត្តការងារ និងសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ និង

៣. ការលើកកម្ពស់កិច្ចសហប្រតិបត្តិការ និងភាពជាដៃគូរវាងក្រុមប្រឹក្សាឃុំ និងមន្ទីរជំនាញ

៤. ផ្តល់ប្រឹក្សាដល់ឃុំក្នុងការបង្កើតផែនការសកម្មភាព និងថវិកាទាក់ទងនឹងសម្បទានដីសង្គមកិច្ច និងជួយអនុវត្តផែនការសកម្មភាព និងថវិកាដូចបានចង្អុលបង្ហាញនៅក្នុងច្បាប់ និងបទបញ្ញត្តិរបស់គម្រោង។

បុគ្គលិកចុះមូលដ្ឋានរបស់ផ្នែករដ្ឋបាលមូលដ្ឋាន គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត គឺជាសមាជិករបស់ក្រុមសម្របសម្រួលថ្នាក់ខេត្ត និងក្រុមសម្របសម្រួលថ្នាក់ស្រុក។ នៅក្នុងគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ក្រុមសម្រប

សម្រួលថ្នាក់ខេត្ត និងក្រុមសម្របសម្រួលថ្នាក់ស្រុកសហការយ៉ាងជិតស្និទ្ធជាមួយក្រុមការងារថ្នាក់ស្រុក ហើយទទួលខុសត្រូវជាសំខាន់ចំពោះ៖

១. ការផ្សព្វផ្សាយព័ត៌មានស្តីពីគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ចដល់ក្រុមប្រឹក្សាឃុំ

២. ការគាំទ្រកម្មវិធីបណ្តុះបណ្តាល និងការកសាងសមត្ថភាពសម្រាប់ក្រុមប្រឹក្សាឃុំទាក់ទងនឹងសម្បទានដីសង្គមកិច្ច

៣. ជួយ និងសម្របសម្រួលក្រុមប្រឹក្សាឃុំឲ្យអនុវត្តតួនាទី និងការទទួលខុសត្រូវទូទៅរបស់ពួកគេទាក់ទងនឹងសម្បទានដីសង្គមកិច្ច និង

៤. ពិនិត្យតាមដានការអនុវត្តសម្បទានដីសង្គមកិច្ចដោយក្រុមប្រឹក្សាឃុំស្របតាមគោលការណ៍ណែនាំ និងណែនាំឲ្យមានអន្តរាគមន៍ នៅពេលដែលចាំបាច់។

## ខ ៣.៩ ផ្នែកគាំទ្របច្ចេកទេស គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត

ផ្នែកគាំទ្របច្ចេកទេស គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្តផ្តល់សេវាវិស្វកម្មដល់ក្រុមប្រឹក្សាឃុំទាក់ទិននឹងការវាស់វែង ការរៀបចំ ការធ្វើលទ្ធកម្ម និងការត្រួតពិនិត្យ ការសាងសង់គម្រោងហេដ្ឋារចនាខ្នាតតូចទាំងអស់។ បុគ្គលិកផ្នែកគាំទ្របច្ចេកទេសត្រូវបានគេស្គាល់ថា ជាមន្ត្រីគាំទ្របច្ចេកទេស។ ជាទូទៅ គេបែងចែកឲ្យមានមន្ត្រីបច្ចេកទេសម្នាក់ទៅកាន់ស្រុកនីមួយៗ។

ក្រុមប្រឹក្សាឃុំទទួលជំនួយអនុគម្រោងសម្រាប់ការអនុវត្តហេដ្ឋារចនាសម្ព័ន្ធ និងសេវានានានៅក្នុងការជួយគាំទ្រដល់សម្បទានដីសង្គមកិច្ច (ឧ. សមាសភាគទី ២ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច)។ ក្នុងករណីមួយចំនួន អនុគម្រោងទាំងនេះមានទំហំធំពេកធ្វើឲ្យមន្ត្រីគាំទ្របច្ចេកទេសមិនអាចអនុវត្តបាននូវការស្ទង់មតិ ការរៀបចំ និងការងារចងក្រងឯកសារដោយមិនមានជំនួយ។ ផ្អែកលើអនុសាសន៍របស់មន្ត្រីគាំទ្របច្ចេកទេស គេអាចនឹងធ្វើកិច្ចសន្យាទទួលភារកិច្ចទាំងនេះពីមន្ទីរជំនាញខេត្ត (ឧ. មន្ទីរអភិវឌ្ឍន៍ជនបទសម្រាប់ផ្លូវជនបទ មន្ទីរធនធានទឹក និងឧតុនិយមសម្រាប់ធារាសាស្ត្រ)។ ផ្នែកគាំទ្របច្ចេកទេសបន្តទទួលខុសត្រូវចំពោះការជួយក្រុមប្រឹក្សាឃុំក្នុងដំណើរការលទ្ធកម្ម និងការងារត្រួតពិនិត្យកិច្ចសន្យា។

## ខ ៣.១០ មន្ទីរកិច្ចការនារីខេត្ត

មន្ទីរកិច្ចការនារីខេត្ត ទទួលខុសត្រូវក្នុងការត្រួតពិនិត្យសកម្មភាពបញ្ជ្រាបយេនឌ័ររបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចនៅថ្នាក់ខេត្ត។ សកម្មភាពសំខាន់ៗដែលមន្ទីរកិច្ចការនារីខេត្តដឹកនាំ ឬ ចូលរួម គឺ:

១. ការកសាងសមត្ថភាពដើម្បីការបញ្ជ្រាបយេនឌ័រ

២. ការវិភាគយេនឌ័រ
៣. ផ្តល់ការណែនាំលើផ្នែកនៃដំណើរការសម្បទានដីសង្គមកិច្ច នៅលទ្ធផលនៃការវិភាគយេនឌ័រត្រូវឲ្យមានការយកចិត្តទុកដាក់ និង
៤. ជួយក្រុមប្រឹក្សាឃុំ និងក្រុមការងារថ្នាក់ស្រុកក្នុងការពិនិត្យតាមដានបញ្ហាយេនឌ័រ។

មន្ទីរកិច្ចការនារីខេត្តតែងតាំងមន្ត្រីមួយរូបជាបុគ្គលស្នូលសម្រាប់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។ មន្ត្រីមួយរូបរបស់មន្ទីរកិច្ចការនារីខេត្ត ឬ ការិយាល័យ កិច្ចការនារីស្រុក គឺជាសមាជិករបស់ក្រុមការងារថ្នាក់ស្រុក ។

## ខ ៣.១១ ក្រុមការងារថ្នាក់ស្រុក

ក្រុមការងារថ្នាក់ស្រុកមានមុខងារ និងភារកិច្ចដូចខាងក្រោម:

១. អនុវត្តការងារទាំងអស់របស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តនៅថ្នាក់ស្រុក
២. ផ្តល់ជំនួយបច្ចេកទេសដល់ក្រុមប្រឹក្សាឃុំដើម្បីកំណត់ និងបែងចែកប្រភេទដី បង្កើតផែនទីប្រើប្រាស់ដី ជ្រើសរើសមុខសញ្ញាអ្នកទទួលដី និងអភិវឌ្ឍ និងអនុវត្តផែនការសម្បទានដីសង្គមកិច្ច
៣. ធានាថា ការបែងចែកដីសម្បទានសង្គមកិច្ចនៅមូលដ្ឋាន គឺមានប្រសិទ្ធភាព និងតម្លាភាព
៤. ពិនិត្យតាមដាន និងរាយការណ៍ជូនគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តស្តីពីការអនុវត្តផែនការសម្បទានដីសង្គមកិច្ច និង
៥. ទទួលរបាយការណ៍ពីការិយាល័យកិច្ចការនារីស្រុកទាក់ទងនឹងការអនុវត្តដំណើរការបញ្ជ្រាបយេនឌ័រ ហើយរាយការណ៍ជូនគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ។

សមាជិកភាពស្នូលរបស់ក្រុមការងារថ្នាក់ស្រុក ដូចបានកំណត់ដោយអនុក្រឹត្យលេខ ១៩ ស្តីពីសម្បទានដីសង្គមកិច្ច គឺ:

១. អភិបាលស្រុក (ឬ អភិបាលស្រុករង) ជាប្រធាន
២. ប្រធានការិយាល័យស្រុកតំណាងឲ្យបណ្តាក្រសួង និងស្ថាប័នដែលជាសមាជិករបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត និង
៣. អ្នកតំណាងរបស់អាជ្ញាធរមូលដ្ឋាន ឧ. ក្រុមប្រឹក្សាឃុំ។

បុគ្គលិកគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្តត្រូវបានបញ្ជូនទៅកាន់ស្រុក (ក្នុងករណីបុគ្គលិកផ្នែករដ្ឋបាលមូលដ្ឋាន គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការ

អភិវឌ្ឍជនបទខេត្ត និងផ្នែកគាំទ្របច្ចេកទេស) ឬ ចាត់តាំងឲ្យជួយគាំទ្រសកម្មភាពរបស់ក្រុមការងារថ្នាក់ស្រុករបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងស្រុកលើសពីមួយ (ផ្នែកហិរញ្ញវត្ថុ និងផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាលគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត ) ត្រូវចូលរួមកិច្ចប្រជុំរបស់ក្រុមការងារថ្នាក់ស្រុកក្នុងនាមជាអ្នកផ្តល់ប្រឹក្សា។

## ខ ៣.១២ ក្រុមការងារថ្នាក់ស្រុករបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ប្រចាំស្រុក

នៅក្នុងស្រុកអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ក្រុមការងារថ្នាក់ស្រុកស្ថិតក្រោមការដឹកនាំរបស់អភិបាលស្រុកនឹងមានក្រុមការងារគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចថ្នាក់ស្រុកដែលមានបុគ្គលិកចំនួនប្រាំ (៥) រូបទទួលរ៉ាប់រងប្រតិបត្តិការប្រចាំថ្ងៃ (*លក្ខខណ្ឌយោង* សម្រាប់គ្រប់មុខតំណែងក្នុងក្រុមការងារ គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចថ្នាក់ស្រុកអាចរកបាននៅក្នុង*ឧបសម្ព័ន្ធទី ៨ - លក្ខខណ្ឌយោងស្តីពីមុខតំណែងថ្នាក់ស្រុក*)។

១. ប្រធានសម្របសម្រួល
២. មន្ត្រីកំណត់អត្តសញ្ញាណកម្មដីថ្នាក់ស្រុក (១)
៣. មន្ត្រីកំណត់មុខសញ្ញាអ្នកទទួលដីថ្នាក់ស្រុក (១)
៤. មន្ត្រីអភិវឌ្ឍន៍ថ្នាក់ស្រុក- ផ្នែកសេវាកម្ម (១) និង
៥. មន្ត្រីអភិវឌ្ឍន៍ថ្នាក់ស្រុក - ផ្នែកហេដ្ឋារចនាសម្ព័ន្ធ (១)
៦. មន្ត្រីកសិកម្ម
៧. មន្ត្រីកិច្ចការនារី
៨. មន្ត្រីធនធានទឹក
៩. មន្ត្រីបរិស្ថាន
១០. មន្ត្រីអាជ្ញាធរព្រៃឈើ

## ខ ៣.១៣ ក្រុមប្រឹក្សាឃុំ

ក្រុមប្រឹក្សាឃុំមានការទទួលខុសត្រូវចម្បងចំពោះការដាក់សំណើ ការអភិវឌ្ឍ និងការអនុវត្តសម្បទានដីសង្គមកិច្ចក្រោមគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។ ក្រុមប្រឹក្សាឃុំទទួលខុសត្រូវក្នុងការដាក់សំណើដំបូងសុំសម្បទានដីសង្គមកិច្ចជូនគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត។ បន្ទាប់ពីគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តអនុម័តសំណើដំបូងនេះហើយ ក្រុមប្រឹក្សាឃុំបង្កើតសំណើដោយមានជំនួយពីគណៈកម្មាធិការស្រុក (ក្រុមការងារថ្នាក់ស្រុក) ហើយបញ្ជូនរបាយការណ៍ស្តីពីសម្បទានដីសង្គមកិច្ចលើកដំបូង។

បន្ទាប់ពីគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តអនុម័តលើរបាយការណ៍ស្ដីពីសម្បទានដីសង្គមកិច្ចលើកដំបូងរួច តាមរយៈធ្វើការជាមួយនឹងការជួយគាំទ្រពីក្រុមការងារស្រុក ក្រុមប្រឹក្សាឃុំអនុវត្តនូវមុខងារមួយចំនួនដូចខាងក្រោម:

១. កំណត់មុខសញ្ញាអ្នកទទួលដី
២. រៀបចំផែនការប្រើប្រាស់ដីដែលមានការចូលរួម
៣. រៀបចំគម្រោងថវិកាសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ និងសេវាជនបទដើម្បីគាំទ្រសម្បទានដីសង្គមកិច្ច និង
៤. ដាក់របាយការណ៍សម្បទានដីសង្គមកិច្ចច្បាស់លាស់ជូនគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត

បន្ទាប់ពីគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តបានអនុម័តរបាយការណ៍ពេញលេញ ក្រុមប្រឹក្សាឃុំទទួលខុសត្រូវចំពោះ៖

១. ការគាំទ្រមុខសញ្ញាអ្នកទទួលដី ហើយជាពិសេសធ្វើលទ្ធកម្មហេដ្ឋារចនាសម្ព័ន្ធ និងសេវានានាដោយផ្ទាល់ និងតាមរយៈក្រុមការងារថ្នាក់ស្រុក
២. ការពិនិត្យតាមដានភាពរីកចម្រើននៃសម្បទានដីសង្គមកិច្ច និង
៣. រាយការណ៍ជូនគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ពីបញ្ហាមួយចំនួនដែលត្រូវការអន្តរាគមន៍។

## ខ ៣.១៤ ក្រុមការងារសម្បទានដីសង្គមកិច្ចថ្នាក់ឃុំ

ក្រុមប្រឹក្សាឃុំបានតែងតាំងក្រុមការងារមួយឲ្យជួយបង្កើតសំណើសុំសម្បទានដីសង្គមកិច្ច ដោយចូលរួមជាមួយបណ្ដាភាគីពាក់ព័ន្ធនានា។

សមាជិកក្រុមការងារសម្បទានដីសង្គមកិច្ចរួមមាន មេឃុំ (ឬ អ្នកតំណាងរបស់គាត់) ជាប្រធាន អ្នកសម្របសម្រួលថ្នាក់ឃុំពីររូបផ្សេងទៀត និងសមាជិកគណៈកម្មាធិការកសាងផែនការ និងថវិកាឃុំសម្រាប់បណ្ដាភូមិដែលរងផលប៉ះពាល់ដោយសារការអភិវឌ្ឍដីសង្គមកិច្ច។ ភូមិនីមួយៗមានសមាជិកគណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ (គ.ផ.ថ) ចំនួនពីររូប ហើយមួយរូបក្នុងចំណោមនោះ គឺជាមេភូមិ និងមួយរូបទៀតជាស្ត្រី។ យ៉ាងហោចណាស់មានសមាជិកមួយរូបជ្រើសចេញពីមេឃុំ ហើយសមាជិកសម្របសម្រួលទាំងពីររូបគួរតែជាស្ត្រី ឬ ប្រសិនបើមិនមានអ្នកសម្របសម្រួលជាស្ត្រី ឬ ស្ត្រីនៅថ្នាក់ឃុំទេ អ្នកទទួលបន្ទុកកិច្ចការនារី នឹងកុមារឃុំត្រូវគេអញ្ជើញឲ្យចូលរួមក្រុមការងារនេះ។ បន្ទាប់ពីបែងចែកដីរួច មុខសញ្ញាអ្នកទទួលដីនឹងត្រូវអញ្ជើញឲ្យធ្វើការជ្រើសរើសបុរសម្នាក់ និងស្ត្រីម្នាក់ដើម្បីធ្វើជាតំណាងរបស់ពួកគេក្នុងនាមជាសមាជិកក្រុមការងារនេះ។

គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ផ្តល់មូលនិធិជូនក្រុមប្រឹក្សាឃុំឲ្យជួលមនុស្សដែលមានលក្ខណសម្បត្តិសមស្របឲ្យធ្វើជាជំនួយការស្មៀនទាក់ទងនឹងសម្បទានដីសង្គមកិច្ច។ បុគ្គលិករូបនេះនឹងជួយក្រុមការងារក្នុងកិច្ចការរដ្ឋបាល។ ជំនួយការស្មៀនក្នុងគម្រោងសម្បទានដីសង្គមកិច្ចមិនមែនជាសមាជិកក្រុមប្រឹក្សាឃុំ ឬ ពុំមានឈ្មោះជាផ្លូវការនៅក្នុងបញ្ជីប្រាក់បៀវត្សរ៍របស់រដ្ឋាភិបាលឡើយ។*លក្ខខណ្ឌយោង* ស្តីពីតួនាទីនេះត្រូវបានដាក់ភ្ជាប់ជា***ឧបសម្ព័ន្ធទី ៩***។

អង្គការមិនមែនរដ្ឋាភិបាល និងបណ្តាអង្គការសង្គមស៊ីវិលនានា ព្រមទាំងបុគ្គលិកសង្គមកិច្ចដែលមានភាពសកម្មនៅក្នុងឃុំ គួរតែអញ្ជើញឲ្យចូលរួមកិច្ចប្រជុំរបស់ក្រុមការងារនេះក្នុងនាមជាអ្នកអង្កេតការ និងផ្តល់ប្រឹក្សា។

រាល់សេចក្តីសម្រេចរបស់ក្រុមការងារសម្បទានដីសង្គមកិច្ចថ្នាក់ឃុំ គឺត្រូវមានការបញ្ជាក់ពីក្រុមប្រឹក្សាឃុំ។

## ខ ៣.១៥ សហគមន៍អ្នកទទួលដី

អ្នកទទួលផលសម្បទានដីសង្គមកិច្ចដែលបានជ្រើសរើស ត្រូវបានលើកទឹកចិត្តឲ្យបង្កើតសហគមន៍អ្នកទទួលដី ក្នុងគោលបំណងជួយពិនិត្យតាមដានការអនុវត្តសម្បទានដីសង្គមកិច្ច និងបង្ហាញពីចំណាប់អារម្មណ៍របស់អ្នកទទួលផលដល់ក្រុមប្រឹក្សាឃុំ។

សហគមន៍អ្នកទទួលដីនេះមិនស្ថិតក្រោមរចនាសម្ព័ន្ធរបស់រដ្ឋាភិបាល ឬ ក្រុមប្រឹក្សាឃុំឡើយ ប៉ុន្តែជាអង្គការសង្គមស៊ីវិលឯករាជ្យមួយ។ អង្គការនេះមិនមានតួនាទីជាផ្លូវការនៅក្នុងដំណើរការនេះឡើយ លើកលែងតែមានការតែងតាំងអ្នកតំណាងឲ្យចូលក្នុងក្រុមការងារសម្បទានដីសង្គមកិច្ចថ្នាក់ឃុំ។

សហគមន៍អ្នកទទួលដីគួរមានលក្ខន្តិកធម្មតាមួយចំនួនក្នុងនាមជាសមាគម និងគួរគ្រប់គ្រងការចំណាយរបស់ខ្លួនតាមរយៈការចូលរួមវិភាគទានតិចតួចពីសមាជិករបស់សហគមន៍នេះ។
បន្ទាប់ពីរយៈពេល ៥ឆ្នាំ នៅពេលប័ណ្ណកម្មសិទ្ធិដីត្រូវបានចេញជូនអ្នកទទួលដី សហគមន៍អ្នកទទួលដីគួរបញ្ចប់ ឬ អាចបង្កើតជាអង្គការដែលមានទីតាំងនៅក្នុងសហគមន៍មូលដ្ឋានជាមួយនឹងសមាជិកភាពបើកទូលាយចំពោះប្រជាពលរដ្ឋគ្រប់រូបក្នុងមូលដ្ឋាន។

## ខ ៣.១៦ អង្គការសង្គមស៊ីវិល

អង្គការសង្គមស៊ីវិលនៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋានអាចគាំទ្របណ្តាឃុំនានាក្នុងការអភិវឌ្ឍ និងការអនុវត្តសម្បទានដីសង្គមកិច្ច។ កិច្ចការទាំងអស់នេះអាចធ្វើឡើងតាមរយៈកិច្ចព្រមព្រៀងផ្លូវការជាមួយគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត/ក្រុមការងារថ្នាក់ស្រុក និង/ឬ ឃុំ និងក្រៅផ្លូវការតាមរយៈសកម្មភាពដែលកើតឡើងថ្មីរបស់ពួកគេជាមួយឃុំ និងមុខសញ្ញាអ្នកទទួលដី។ ជំនួយរបស់អង្គការសង្គមស៊ីវិលអាចរួមមានការផ្សព្វផ្សាយព័ត៌មាន ការចូលរួមតម្លាភាព ការដោះស្រាយជម្លោះ ឬ ការគាំទ្របច្ចេកទេស។ នៅគ្រប់ករណីទាំងនេះ អង្គការសង្គម

ស៊ីវិលត្រូវធ្វើការឲ្យស៊ីសង្វាក់គ្នាជាមួយក្របខ័ណ្ឌច្បាប់ និងគោលការណ៍ណែនាំផ្លូវការ និងនីតិវិធីនានាសម្រាប់សម្បទានដីសង្គមកិច្ច។ អង្គការសង្គមស៊ីវិលមានសិទ្ធិស្នើទៅអគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច ឬ លេខាធិការដ្ឋានគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ដើម្បីផ្តល់ឲ្យពួកគេនូវព័ត៌មានទាក់ទងនឹងនីតិវិធី សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីផ្សេងៗទៀតនៅក្នុងដំណើរការអភិវឌ្ឍ ការរៀបចំផែនការ និងការអនុវត្តសម្បទានដីសង្គមកិច្ច។ លេខាធិការដ្ឋានអគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច និងគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ត្រូវផ្តល់ព័ត៌មាននេះនៅពេលមានការស្នើសុំ។ មានការរំពឹងផងដែរថា អង្គការសង្គមស៊ីវិល គឺជាអ្នកចូលរួមក្នុងសិក្ខាសាលាផ្តល់ព័ត៌មាន និងវាយតម្លៃដោយមានការចូលរួម។ អង្គការសង្គមស៊ីវិលអាចនឹងមិនតំណាងឲ្យឃុំ ឬ មុខសញ្ញាអ្នកទទួលដីនៅក្នុងការដាក់ពាក្យ ឬ ដំណើរការធ្វើកិច្ចសន្យាឡើយ។

បុគ្គលិករបស់អង្គការសង្គមស៊ីវិលដែលធ្វើការងារនៅក្នុងគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចត្រូវឆ្លងកាត់ការបណ្តុះបណ្តាលស្តីពីយេនឌ័រ មុនពេលធ្វើការជាមួយគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច[១៤]។

## ១៤ ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃ

មូលដ្ឋានសម្រាប់ការត្រួតពិនិត្យតាមដាន និងវាយតម្លៃរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺបង្ហាញនៅក្នុងក្របខ័ណ្ឌគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។ សូចនាករទាំងនេះមាននៅចំណុចនិយាយពីដំណើរការលទ្ធផល និងកម្រិតនៃផលប៉ះពាល់។

សមភាពយេនឌ័រនៅក្នុងដំណើរការលទ្ធផល និងផលប៉ះពាល់ការបែងចែកដីដើម្បី សង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចត្រូវតែពិនិត្យតាមដានដោយគណៈកម្មាធិការយេនឌ័រនៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយមានការណែនាំពីក្រសួងកិច្ចការនារី។ មុនពេលអ្នកទទួលបន្ទុកកិច្ចការស្ត្រី និងកុមារប្រមូលព័ត៌មានស្តីពីសូចនាករយេនឌ័រ ហើយរាយការណ៍ជូនក្រុមការងារថ្នាក់ស្រុក និងការិយាល័យកិច្ចការនារីស្រុក។ ក្រុមការងារថ្នាក់ស្រុក បញ្ជូនរបាយការណ៍ទៅគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ហើយគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តដាក់របាយការណ៍នេះទៅគណៈកម្មាធិការយេនឌ័រ។

សៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមានសេចក្តីពណ៌នាពិស្តារពីការត្រួតពិនិត្យតាមដាន និងការវាយតម្លៃរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។

[១៤] យោងតាមគោលការណ៍ណែនាំពីការបណ្តុះបណ្តាលរបស់ក្រសួងកិច្ចការនារី

## ខ៥ ការកសាងសមត្ថភាព

គោលបំណងសំខាន់នៃសកម្មភាពកសាងសមត្ថភាពក្រោមសមាសភាគទី ៣ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺធ្វើការបង្កើនសមត្ថភាពភ្នាក់ងាររដ្ឋាភិបាលនៅថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់ឃុំ ដើម្បីអនុវត្តតួនាទី និងការទទួលខុសត្រូវដែលបានប្រគល់ឲ្យពួកគេក្រោមកម្មវិធីសម្បទានដីសង្គមកិច្ច។

នៅក្នុងករណីមួយចំនួន សកម្មភាពកសាងសមត្ថភាពក្រោមគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច មានគោលបំណងធ្វើការលើកកម្ពស់សមត្ថភាពវិស័យឯកជន ឬ អ្នកផ្តល់សេវាដែលជាអង្គការមិនមែនរដ្ឋាភិបាលដើម្បីផ្គត់ផ្គង់សេវាដែលឃុំត្រូវការសម្រាប់ការអនុវត្តសម្បទានដីសង្គមកិច្ច។

ការបណ្តុះបណ្តាលមុខសញ្ញាអ្នកទទួលដីគោលដៅទាក់ទងនឹងផលិតកម្មកសិកម្ម ឬ ជំនាញដែលពាក់ព័ន្ធនឹងជីវភាពរស់នៅដទៃទៀត គឺជាផ្នែកនៃសមាសភាគទី ២ នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច (ហេដ្ឋារចនាសម្ព័ន្ធ និងសេវាជនបទ) ហើយវាមិនមានបរិយាយនៅក្នុងផ្នែកនេះនៃសៀវភៅណែនាំនេះឡើយ។

សៀវភៅណែនាំស្តីពីការអនុវត្តគម្រោងនេះមានបរិយាយពិស្តារពីការរៀបចំកសាងសមត្ថភាពសម្រាប់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។

## ច. សមាសភាគទី ៤ : ការគ្រប់គ្រងគម្រោង និងការងាររដ្ឋបាល

### *ច. ១ ការរៀបចំផែនការប្រតិបត្តិការ និងគម្រោងថវិកា*

### ច. ១.១ ការចំណាយរបស់គម្រោងទៅតាមសមាសភាគ

ការចំណាយរបស់គម្រោងសម្រាប់ ***សមាសភាគទី ១*** នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច រួមមាន:

១. ចំណាយសម្រាប់ប្រតិបត្តិការរបស់ក្រុមប្រឹក្សាឃុំក្នុងការធ្វើផែនការ និងអនុវត្តសម្បទានដីសង្គមកិច្ច។ ចំណាយទាំងនេះរួមមាន ចំណាយលើធ្វើដំណើរ និងកិច្ចប្រជុំនៅថ្នាក់ឃុំ ចំណាយលើសម្ភារៈផ្សព្វផ្សាយព័ត៌មាន ចំណាយលើការបោះពុម្ពទម្រង់បែបបទដែលចាំបាច់សម្រាប់ដំណើរការសម្បទានដីសង្គមកិច្ច ។ល។

២. ចំណាយលើយុទ្ធនាការផ្សព្វផ្សាយព័ត៌មានដើម្បីផ្សព្វផ្សាយព័ត៌មានស្តីពីកម្មវិធីសម្បទានដីសង្គមកិច្ចជាក់លាក់

៣. ដំណើរការជ្រើសរើសមុខសញ្ញាអ្នកទទួលដី

៤. ចំណាយលើការកំណត់អត្តសញ្ញាណកម្មដីរដ្ឋ និងការធ្វើផែនទី និងការត្រួតពិនិត្យមើលពីការការពារសង្គម និងបរិស្ថាន និង

៥. ចំណាយលើការចុះបញ្ជីដីឯកជនរបស់រដ្ឋ។

ការចំណាយរបស់គម្រោងសម្រាប់ ***សមាសភាគទី ២*** នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺជាចំណាយផ្ទាល់ទៅលើហេដ្ឋារចនាសម្ព័ន្ធ និងសេវាជនបទ ហើយត្រូវបានបែងចែកជាប្រភេទដូចខាងក្រោម:

១. ការរៀបចំដី

២. ជំនួយឧបត្ថម្ភក្នុងការចូលតាំងទីលំនៅថ្មី

៣. ការផ្គត់ផ្គង់ជីវភាពរស់នៅ

៤. សេវាកម្មជនបទ និង

៥. ហេដ្ឋារចនាសម្ព័ន្ធជនបទ

ការចំណាយរបស់គម្រោងសម្រាប់ ***សមាសភាគទី ៣*** នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច រួមមាន:

១. ចំណាយសម្រាប់ប្រតិបត្តិការរបស់អគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច។ ចំណាយទាំងនេះរួមមានប្រាក់រង្វាន់លើកទឹកចិត្តបុគ្គលិកក្រោមកម្មវិធីចំណាយ

ប្រតិបត្តិការអាទិភាព [១៥] ការចំណាយក្នុងការិយាល័យ និងការចំណាយលើការធ្វើដំណើរ របស់បុគ្គលិកអគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច

២. ចំណាយសម្រាប់ប្រតិបត្តិតាមកម្រិតសម្រាប់គណៈកម្មាធិការប្រតិបត្តិផ្អែកលើគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ការចំណាយលើបុគ្គលិកបន្ថែម និងការចំណាយផ្គត់ផ្គង់ផ្ទាល់នៅក្នុងផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាលគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត ផ្នែកហិរញ្ញវត្ថុ ផ្នែករដ្ឋបាលមូលដ្ឋានគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត និងផ្នែកគាំទ្របច្ចេកទេស ហើយនឹងការរួមចំណែកដល់ធនធានរួម

៣. ចំណាយសម្រាប់ប្រតិបត្តិការរបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត គណៈកម្មាធិការគ្រប់គ្រងដីសម្បទានដីសង្គមកិច្ច និងចំណាយលើក្រុមការងារគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចថ្នាក់ខេត្ត រួមទាំងជំនួយប្រាក់បៀវត្សរ៍ក្រោមកម្មវិធីចំណាយប្រតិបត្តិការអាទិភាព[១៦]

៤. ចំណាយប្រតិបត្តិការរបស់ក្រុមការងារស្រុក។ ទាំងនេះរួមមានប្រាក់រង្វាន់លើកទឹកចិត្តបុគ្គលិកក្រោមកម្មវិធីចំណាយ ប្រតិបត្តិការអាទិភាព

៥. ចំណាយលើការកសាងសមត្ថភាព: ការបណ្តុះបណ្តាល និងសិក្ខាសាលា គឺសំដៅលើចំណាយសម្រាប់ការបណ្តុះបណ្តាលដែលរួមមាន ចំណាយលើទីតាំង ការរៀបចំសម្ភារៈ អាហារ និងធ្វើដំណើរ និងការចំណាយលើការស្នាក់នៅរបស់សិក្ខាកាមដោយអនុលោមតាមគោលការណ៍ណែនាំរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប)។ ការចំណាយលើការបណ្តុះបណ្តាល និងសិក្ខាសាលាមិនរួមបញ្ចូលការចំណាយលើគ្រូបង្គោលសម្រាប់ថ្លៃឈ្នួលបណ្តុះបណ្តាលព្រោះពួកគាត់នឹងក្លាយជាបុគ្គលិកដែលជាទូទៅគាំទ្រដោយកម្មវិធីរង្វាន់លើកទឹកចិត្តផ្អែកលើស្នាដៃអនុវត្តការងារ ឬ ក្រុមបេសកកម្មអាទិភាពនោះឡើយ។

៦. ការចំណាយលើការត្រួតពិនិត្យតាមដាន និងការវាយតម្លៃ: ចំណាយលើសេវាប្រឹក្សាបន្ថែមពីលើបុគ្គលិកត្រួតពិនិត្យតាមដាន និងវាយតម្លៃរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចសម្រាប់កម្មវិធីត្រួតពិនិត្យតាមដាន និងវាយតម្លៃ និង

[១៥] ចំណាយប្រតិបត្តិការអាទិភាព

[១៦] ចំណាយប្រតិបត្តិការអាទិភាព

៧. ចំណាយលើជំនួយបច្ចេកទេស: ចំណាយលើសេវាប្រឹក្សាសម្រាប់ផ្តល់ជំនួយបច្ចេកទេសដល់អគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច ឬ គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ។

ការចំណាយរបស់គម្រោងសម្រាប់ ***សមាសភាគទី ៤*** នៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច រួមមានៈ

១. ចំណាយសម្រាប់ប្រតិបត្តិតាមកម្រិតរបស់ផ្នែកគាំទ្រកម្មវិធីរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប)។ ចំណាយទាំងនេះរួមមាន ឧបត្ថម្ភប្រាក់បៀវត្សរ៍ ចំណាយក្នុងការិយាល័យ និងចំណាយលើការធ្វើដំណើររបស់បុគ្គលិករបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) -គម្រោងគាំទ្រការអភិវឌ្ឍ

២. លទ្ធកម្មយានជំនិះ និងឧបករណ៍សម្ភារៈ

៣. ចំណាយលើជំនួយបច្ចេកទេស: ចំណាយលើសេវាប្រឹក្សាសម្រាប់ផ្តល់ជំនួយបច្ចេកទេសដល់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ឬ ដល់គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត ។

តារាងចំណាយដែលបង្ហាញពីការចំណាយរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងឆ្នាំសមាសភាគនីមួយៗទៅតាមឆ្នាំត្រូវបានរៀបចំ និងរួមបញ្ចូលក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោង។ ក្នុងពេលនីមួយៗដែលគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចចាប់ផ្តើមធ្វើការនៅក្នុងស្រុកថ្មីមួយ និងពេលនីមួយៗដែលសម្បទានដីសង្គមកិច្ចត្រូវបានផ្តួចផ្តើម ឬ អនុម័ត ពេលនោះនឹងមានការទាក់ទងគ្នាចំពោះតារាងចំណាយទាំងនេះៈ

១. ការចំណាយជាក់ស្តែងទៅតាមសមាសភាគរហូតដល់ឆ្នាំបច្ចុប្បន្ន និង

២. ការព្យាករណ៍ពីការចំណាយដែលបានកែសម្រួលទៅតាមសមាសភាគសម្រាប់ឆ្នាំខាងមុខ។

នីតិវិធីនេះជួយធានាឲ្យមានមូលនិធិគ្រប់គ្រាន់សម្រាប់ឆ្លើយតបទៅនឹងការប្តេជ្ញាដែលបង្កើតឡើងតាមរយៈការផ្តួចផ្តើមសម្បទានដីសង្គមកិច្ចនីមួយៗ ហើយធានាថា មូលនិធិបន្ថែមអាចនឹងផ្តល់ជូនសម្រាប់គោលបំណងដែលសមស្រប។ តារាងចំណាយដែលបានធ្វើបច្ចុប្បន្នកម្មត្រូវរួមបញ្ចូលនូវឧបសម្ព័ន្ធមួយទៅក្នុងរបាយការណ៍ស្តីពីការរីកចម្រើនប្រចាំឆ្នាំរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។ ការបែងចែកមូលនិធិឡើងវិញរវាងសមាសភាគនានា ឬ រវាងប្រភេទនៃការចំណាយអាចនឹងទាមទារឲ្យមានលិខិតមិនជំទាស់ពីធនាគារពិភពលោក។

## ច ១.២ ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចពណ៌នាគ្រប់សកម្មភាព និងការចំណាយទាំងអស់របស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចដែលបានរៀបចំផែនការសម្រាប់ឆ្នាំហិរញ្ញវត្ថុនីមួយៗ។

ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចមានផ្នែកដូចខាងក្រោម:

១. ការពណ៌នាពិស្តារពីផែនការការងារ
២. គោលដៅប្រចាំឆ្នាំទាក់ទងនឹងសូចនាករតារាងផែនការនៅកម្រិតផ្តល់លទ្ធផល
៣. ផែនការការងារនៅក្នុងទម្រង់តារាង Gant សម្រាប់អគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) - អង្គភាពគាំទ្រកម្មវិធី និងខេត្តទាំងឡាយដែលចូលរួម:
៤. ផែនការលទ្ធកម្ម
៥. ស្ថានភាពថវិកាសង្ខេប
៦. គម្រោងថវិកាលម្អិតសម្រាប់អគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) - អង្គភាពគាំទ្រកម្មវិធី និងខេត្តទាំងឡាយដែលចូលរួម និង
៧. ការព្យាករណ៍ពីការចំណាយតាមខែ

## ច ១.៣ ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំថ្នាក់ខេត្តរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

ជារៀងរាល់ឆ្នាំ គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត និងគណៈកម្មាធិការប្រតិបត្តិ-ផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាលគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្តរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំសម្រាប់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។ ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំថ្នាក់ខេត្តត្រូវបានដាក់ជូនតាមរយៈគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត ហើយត្រូវមានការអនុម័តពីគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ជាមួយច្បាប់ថតចម្លងជូនអគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច។ ផែនការសកម្មភាព និងថវិការួមបញ្ចូលនូវមូលនិធិដែលបែងចែកក្រោមសមាសភាគទី ២ (សេវាអភិវឌ្ឍន៍ និងការវិនិយោគជនបទ) ព្រមទាំងចំណាយប្រតិបត្តិការ និងចំណាយលើការកសាងសមត្ថភាព (សមាសភាគទី ៣) ដែលបានពណ៌នាខាងលើ។

ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចថ្នាក់ខេត្តត្រូវបានបែងចែកជាផ្នែកទូទៅដូចខាងក្រោម:

១. ចំណាយលើសកម្មភាព និងប្រតិបត្តិការរបស់គណៈកម្មាធិការប្រតិបត្តិតាមរយៈគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។ ចំណាយទាំងនេះរួមមានចំណាយលើប្រតិបត្តិការរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត សម្រាប់បុគ្គលិកបន្ថែម ការចំណាយលើការផ្គត់ផ្គង់ផ្ទាល់របស់ពួកគេនៅក្នុងផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាល ផ្នែកហិរញ្ញវត្ថុ ផ្នែករដ្ឋបាលមូលដ្ឋាន និងផ្នែកគាំទ្របច្ចេកទេស និងការចូលរួមវិភាគទានដល់ធនធានរួម (សមាសភាគទី ៣)
២. ចំណាយលើសកម្មភាព និងប្រតិបត្តិការរបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត គណៈកម្មាធិការគ្រប់គ្រងដីសង្គមកិច្ច និងក្រុមការងារគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចថ្នាក់ខេត្ត
៣. សកម្មភាពកសាងសមត្ថភាពនានាដូចជា ការបណ្តុះបណ្តាល និងសិក្ខាសាលា និងចំណាយផ្សេងៗ (សមាសភាគទី ៣)
៤. ចំណាយលើសកម្មភាព និងប្រតិបត្តិការរបស់ក្រុមការងារថ្នាក់ស្រុក (សមាសភាគទី ៣)។
៥. ការកំណត់តំបន់គោលដៅថ្មីសម្រាប់សម្បទានដីសង្គមកិច្ច និងចំណាយដែលអាចធ្វើទៅបាន និង
៦. ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំសម្រាប់សម្បទានដីសង្គមកិច្ចសម្រាប់ឃុំនីមួយៗដោយបានបែងចែកជា:
   ក. ចំណាយលើសកម្មភាព និងប្រតិបត្តិការរបស់ក្រុមប្រឹក្សាឃុំក្នុងការរៀបចំរបាយការណ៍សម្បទានដីសង្គមកិច្ច (សមាសភាគទី ៣)
   ខ. ចំណាយលើសកម្មភាព និងប្រតិបត្តិការតាមកម្រិតរបស់ក្រុមប្រឹក្សាឃុំក្នុងការអនុវត្តសម្បទានដីសង្គមកិច្ច (សមាសភាគទី ១)
   គ. ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មផ្សេងៗដែលផ្តល់លទ្ធកម្មដោយផ្ទាល់តាមរយៈក្រុមប្រឹក្សាឃុំ (សមាសភាគទី ២) និង
   ឃ. សេវាកម្មផ្សេងៗដែលផ្តល់លទ្ធកម្មតាមរយៈគណៈកម្មាធិការស្រុកដោយមន្ទីរពាក់ព័ន្ធតាមខេត្ត ឬ ការិយាល័យជំនាញថ្នាក់ស្រុក ក្នុងនាមជាក្រុមប្រឹក្សាឃុំ (សមាសភាគទី ២)។

## ច ១.៤ ការរៀបចំធ្វើកិច្ចសន្យា

### ច ១.៤.១ គោលការណ៍ទូទៅ

គ្រប់សកម្មភាពអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចត្រូវបានគ្រប់គ្រងដោយកិច្ចសន្យាដែលពណ៌នាយ៉ាងច្បាស់ពីផែនការសកម្មភាព និងថវិកាលទ្ធផលរំពឹងទុក ការទទួលខុសត្រូវចំពោះការអនុវត្ត និងល័ក្ខខ័ណ្ឌនៃការចំណាយ។

កិច្ចសន្យាសំខាន់ៗ គឺធ្វើឡើងរវាងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) និងគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្តនៅក្នុងខេត្តនីមួយៗ។ ជាងនេះទៅទៀត នឹងមានអនុកិច្ចសន្យារវាងគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត និងគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត។ សកម្មភាពទាំងឡាយដែលត្រូវអនុវត្តដោយមន្ទីរជំនាញ តាមរយៈក្រុមការងារថ្នាក់ស្រុក និងតាមរយៈក្រុមប្រឹក្សាឃុំ មានដូចខាងក្រោមៈ

១. រួមបញ្ចូលក្នុងកិច្ចព្រមព្រៀងរវាងគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត និងទីភ្នាក់ងារអនុវត្ត ឬ
២. រួមបញ្ចូលក្នុងអនុកិច្ចសន្យាដាក់ដោយឡែករវាងគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត និងទីភ្នាក់ងារអនុវត្ត។

ជម្រើសរវាងវិធីទាំងពីរនេះនឹងក្លាយជាជម្រើសដ៏សមស្រប ប៉ុន្តែជាទូទៅ អនុកិច្ចសន្យាគួរតែប្រើនៅពេលដែលមានកញ្ចប់ធំសម្រាប់សកម្មភាព និងថវិកាដែលត្រូវអនុវត្តដោយភ្នាក់ងារតែមួយ។

### ច ១.៤.២ កិច្ចសន្យាសម្បទានដីសង្គមកិច្ចខេត្ត

ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំថ្នាក់ខេត្តរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចត្រូវបានបង្ហាញនៅក្នុងកិច្ចសន្យាសម្បទានដីសង្គមកិច្ចថ្នាក់ខេត្តប្រចាំឆ្នាំរវាងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) និងគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត ។

កិច្ចសន្យាសម្បទានដីសង្គមកិច្ចថ្នាក់ខេត្ត រួមបញ្ចូលៈ

១. សកម្មភាព និងការចំណាយដែលនឹងត្រូវបែងចែកកំណត់នៅអនុកិច្ចសន្យា និង
២. សកម្មភាព និងការចំណាយដែលនឹងត្រូវអនុវត្តផ្ទាល់ដោយគណៈកម្មាធិការប្រតិបត្តិ។

| វចនាសម្ព័ន្ធកិច្ចសន្យាសម្បទានដីសង្គមកិច្ចៈ ថ្នាក់ខេត្ត | |
|---|---|
| ផ្នែកនៃកិច្ចសន្យា | ហត្ថលេខាលើកិច្ចសន្យា |
| ១. លក្ខន្តិកបទដ្ឋាន<br>២. ការពណ៌នាពិស្តារពីផែនការសកម្មភាព<br>៣. តារាងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ | ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) -អង្គភាពគាំទ្រកម្មវិធីអភិបាលខេត្ត (ប្រធានគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត) |

| |
|---|
| **សម្គាល់:** ចំណាយប្រតិបត្តិការតាមកម្រិតរបស់គណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត និងចំណាយលើការកសាងសមត្ថភាពត្រូវបានរួមបញ្ចូលនៅក្នុងថវិកាប្រតិបត្តិការរបស់គណៈកម្មាធិការអភិវឌ្ឍជនបទខេត្តប្រចាំឆ្នាំ។ ថវិកាប្រតិបត្តិការរបស់គណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត រួមបញ្ចូលការបែងចែក និងការចំណាយពីប្រភពមូលនិធិទាំងអស់ដែលបានអនុវត្តតាមរយៈរចនាសម្ព័ន្ធរបស់គណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត ។ |

### ច ១.៤.៣ អនុកិច្ចសន្យា

សកម្មភាព និងការចំណាយនានាដែលត្រូវរួមបញ្ចូលក្នុងអនុកិច្ចសន្យារួមមានៈ

១. ចំណាយប្រតិបត្តិការរបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តគណៈកម្មាធិការសម្បទានដីសង្គមកិច្ច និងក្រុមគាំទ្រគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចថ្នាក់ខេត្ត

២. ចំណាយប្រតិបត្តិការរបស់ក្រុមការងារថ្នាក់ស្រុក និងក្រុមគាំទ្រគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចថ្នាក់ស្រុក

៣. ចំណាយប្រតិបត្តិការរបស់ក្រុមប្រឹក្សាឃុំ

៤. ចំណាយលើការកសាងសមត្ថភាព (លើកលែងចំណាយណាដែលអនុវត្តផ្ទាល់ដោយគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត) និង

៥. ចំណាយលើហេដ្ឋារចនាសម្ព័ន្ធ និងសេវាជនបទ។

| **រចនាសម្ព័ន្ធកិច្ចសន្យាសម្បទានដីសង្គមកិច្ច** | |
|---|---|
| ផ្នែកនៃកិច្ចសន្យា | ហត្ថលេខាលើកិច្ចសន្យា |
| ១. លក្ខន្តិកៈបទដ្ឋាន<br>២. ការពណ៌នាពិស្តារពីផែនការសកម្មភាព<br>៣. គម្រោងថវិកាលម្អិត និងកាលវិភាគចំណាយ | ▪ អភិបាលខេត្ត (ប្រធានគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត)<br>▪ ប្រធានទីភ្នាក់ងារអនុវត្ត |

## *ច ២ ការគ្រប់គ្រងធនធានមនុស្ស*

### ច ២.១ ការជ្រើសរើស និងការគ្រប់គ្រងបុគ្គលិកថ្នាក់ជាតិ

បុគ្គលិកដែលចាត់តាំងទៅអង្គភាពគាំទ្រកម្មវិធីរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ដើម្បីបំពេញសេចក្តីត្រូវការបុគ្គលិករបស់គម្រោងការបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺត្រូវស្ថិតក្រោមល័ក្ខខ័ណ្ឌយោង។

ស្រដៀងគ្នានេះដែរ បុគ្គលិករបស់អគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច គឺត្រូវស្ថិតក្រោមល័ក្ខខ័ណ្ឌយោងសម្រាប់បុគ្គលិករបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) និងអគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច

ដែលធ្វើការពេញម៉ោង និងមិនពេញម៉ោងលើគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចដែលមានភ្ជាប់ជាឧបសម្ព័ន្ធ។

## ច.៣ ការគ្រប់គ្រងហិរញ្ញវត្ថុ

លំហូរមូលនិធិរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

ការគ្រប់គ្រងហិរញ្ញវត្ថុ ការចំណាយ




### ច ៣.១ ការគ្រប់គ្រងហិរញ្ញវត្ថុនៅថ្នាក់ជាតិ

ដោយមិនរាប់បញ្ចូលនូវគណនីកំណត់ដែលគ្រប់គ្រងផ្ទាល់ដោយអគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច ការគ្រប់គ្រងហិរញ្ញវត្ថុរួមលើធនធានគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺជាការទទួលខុសត្រូវរបស់គណ:កម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ អង្គភាពគាំទ្រកម្មវិធី (គជអប) ។

សៀវភៅណែនាំស្តីពីហិរញ្ញវត្ថុរបស់គណ:កម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ អនុវត្តចំពោះបញ្ហាទាំងអស់ដែលទាក់ទងនឹងការគ្រប់គ្រងហិរញ្ញវត្ថុរបស់គម្រោងការបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចនៅថ្នាក់ជាតិ ជាពិសេសទាក់ទងនឹង គណ:កម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិលើកលែងតែបញ្ហាទាំងឡាយណាដែលការរៀបចំគម្រោងជាក់លាក់ត្រូវបានឯកភាពយ៉ាងច្បាស់រវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារពិភពលោក។

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ [១៧] បង្កើតគណនីកំណត់សម្រាប់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដែលទទួលមូលនិធិផ្ទាល់ពីសមាគមអភិវឌ្ឍន៍អន្តរជាតិ។ គណនីនេះត្រូវរក្សានៅស្ថាប័នហិរញ្ញវត្ថុមួយដែលមានការទទួលស្គាល់ ហើយត្រូវគិតជាប្រាក់ដុល្លារអាមេរិក។ គណនីនេះមិនត្រូវបានប្រើប្រាស់សម្រាប់គោលបំណងផ្សេងណាមួយឡើយ លើកលែងតែការគ្រប់គ្រងមូលនិធិរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។

អគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច ក៏នឹងមានគណនីកំណត់មួយផង ដែរដែលទទួលមូលនិធិផ្ទាល់ពីសមាគមអភិវឌ្ឍអន្តរជាតិ។ គណនីនេះត្រូវរក្សាទុកនៅស្ថាប័នហិរញ្ញវត្ថុមួយដែលមានការទទួលស្គាល់ ហើយត្រូវបានគិតជាប្រាក់ដុល្លារអាមេរិក។ គណនីនេះមិនត្រូវបានប្រើប្រាស់សម្រាប់គោលបំណងផ្សេងណាមួយឡើយ លើកលែងតែការគ្រប់គ្រងមូលនិធិរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។

បន្ទាប់មក គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិផ្ទេរធនធានចូលទៅក្នុងគណនីគម្រោងថ្នាក់ខេត្ត ដែលដំណើរការដោយគណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្តនៅក្នុងខេត្តដែលចូលរួម (គេស្គាល់ថា ជាគណនីថ្នាក់ខេត្តរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច)។ ធនធានទាំងនេះត្រូវបានគ្រប់គ្រងស្របទៅតាមផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ និងក្នុងករណីទាក់ទងនឹងគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត និងស្របតាមកិច្ចសន្យាសម្បទានដីសង្គមកិច្ចប្រចាំឆ្នាំ ធ្វើឡើងរវាងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត ។

## ច ៣.២ នីតិវិធីចំណាយនៅថ្នាក់ជាតិ

នីតិវិធីចំណាយដែលបានពិពណ៌នានៅក្នុងសៀវភៅណែនាំស្តីពីហិរញ្ញវត្ថុរបស់គណៈកម្មាធិ-ការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺអនុវត្តទៅលើមូលនិធិរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចៈ

១. លទ្ធកម្មផ្គត់ផ្គង់ សេវាកម្ម និងឧបករណ៍ សម្ភារៈផ្សេងៗ
២. បុរេប្រទានជាសាច់ប្រាក់អាចត្រូវប្រើសម្រាប់ដោះស្រាយចំណាយធ្វើដំណើរ កិច្ចប្រជុំសិក្ខាសាលា និងចំណាយស្រដៀងគ្នានេះ។ បុរេប្រទាននេះត្រូវទូទាត់ទាំងស្រុងនៅក្នុងរយៈពេល ១០ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបំពេញសកម្មភាព និង
៣. សាច់ប្រាក់ក្នុងបេឡា″ មានចំនួនអតិបរមា ១ ០០០ ដុល្លារអាមេរិក ត្រូវបានរក្សាទុកដោយផ្នែកហិរញ្ញវត្ថុរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិប

[17] នឹងមានគណនីធនាគារចំនួនពីរ មួយសម្រាប់មូលនិធិដៃគូ និងទីពីរសម្រាប់គណនីកំណត់ដែលបានរៀបចំចំពោះទិដ្ឋភាពខុសគ្នានៃហិរញ្ញវត្ថុរបស់គម្រោងឡាសិត។

តេយ្យនៅថ្នាក់ក្រោមជាតិ ហើយប្រើដើម្បីឆ្លើយតបនឹងចំណាយបន្ទាប់បន្សំដែលមិនលើសពី ១០០ដុល្លារអាមេរិកឡើយ។

## ច ៣.៣ នីតិវិធីគណនេយ្យនៅថ្នាក់ជាតិ

ផ្នែកហិរញ្ញវត្ថុនៃអង្គភាពគាំទ្រកម្មវិធីរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ទទួលខុសត្រូវចំពោះការរក្សាទុកគណនីគ្រប់ប្រភេទសម្រាប់ប្រតិបត្តិការហិរញ្ញវត្ថុទាំងអស់ ដែលបានទូទាត់តាមរយៈគណនីកំណត់ដែលបានរៀបចំរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិសម្រាប់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។ ដំណើរការនេះរួមបញ្ចូលនូវការចំណាយដែលធ្វើឡើងផ្ទាល់ដោយគម្រោងគាំទ្រការអភិវឌ្ឍរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ឬ ផ្នែកហិរញ្ញវត្ថុនៃអង្គភាពគាំទ្រកម្មវិធីរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនៅថ្នាក់ក្រោមជាតិ និងលេខាធិការដ្ឋានគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត/គណៈកម្មាធិការគ្រប់គ្រងដីសង្គមកិច្ច ហើយក៏ទទួលខុសត្រូវផងដែរចំពោះ៖

១. ការជូនដំណឹងអំពីស្ថានភាពសាច់ប្រាក់នៅក្នុងគណនីកំណត់ដែលបានរៀបចំ
២. ពិនិត្យបន្ទាត់ថវិកាដែលបានបែងចែកដល់គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត និងលេខាធិការដ្ឋានគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត /គណៈកម្មាធិការគ្រប់គ្រងដីសង្គមកិច្ច និង
៣. រាយការណ៍ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពីការប្រើប្រាស់ធនធានដែលទទួលបាន

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិប្រើប្រាស់កម្មវិធីគណនេយ្យ Peachtree។ គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្តអនុវត្តកម្មវិធី Peachtree នៅក្នុងខេត្តនីមួយៗ។ របាយការណ៍ដែលជាឯកសារលើក្រដាសត្រូវបានបង្កើតចេញពីកម្មវិធី Peachtree ហើយត្រូវបានត្រួតពិនិត្យ និងបញ្ជាក់មុនពេលដាក់ជូនគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ បន្ថែមពីនេះទៀតគណនីអេឡិចត្រូនិចត្រូវបញ្ចូលគ្នាតាមកាលបរិច្ឆេទកំណត់នៅថ្នាក់ជាតិ។

អគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច ទទួលខុសត្រូវចំពោះការរក្សាទុកគណនីគ្រប់ប្រភេទសម្រាប់ប្រតិបត្តិការហិរញ្ញវត្ថុទាំងអស់ដែលទូទាត់តាមរយៈគណនីកំណត់ដែលបានរៀបចំរបស់អគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ចសម្រាប់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។ មន្ត្រីហិរញ្ញវត្ថុរបស់អគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ចទទួលខុសត្រូវចំពោះ៖

- ការជូនដំណឹងពីស្ថានភាពសាច់ប្រាក់នៃគណនីកំណត់ដែលបានរៀបចំ
- ពិនិត្យខ្ទង់ថវិកា និងការចំណាយដែលបានបែងចែកដល់អគ្គលេខាធិការដ្ឋាន

សម្បទានដីសង្គមកិច្ច និង

- រាយការណ៍ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពីការប្រើប្រាស់ធនធានដែលទទួលបាន។

## ច ៣.៤ នីតិវិធីធ្វើរបាយការណ៍ហិរញ្ញវត្ថុនៅថ្នាក់ជាតិ - សូមមើលសៀវភៅណែនាំពីការគ្រប់គ្រងហិរញ្ញវត្ថុ របស់ក្រសួងសេដ្ឋកិច្ច *និងហិរញ្ញវត្ថុ* សម្រាប់ព័ត៌មានលម្អិត

ទាំងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងអគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ចរៀបចំរបាយការណ៍ហិរញ្ញវត្ថុនៅពេលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារពិភពលោកត្រូវការ។ របាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស មានៈ

១. របាយការណ៍ផ្ទៀងផ្ទាត់គណនីកំណត់

២. របាយការណ៍ហិរញ្ញវត្ថុបណ្តោះអាសន្ន និង

៣. សំណើសម្រាប់បំពេញចំណាយគណនីកំណត់ឡើងវិញ

## ច ៣.៥ ការគ្រប់គ្រងហិរញ្ញវត្ថុនៅថ្នាក់ក្រោមជាតិ

សៀវភៅណែនាំស្តីពីហិរញ្ញវត្ថុរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិអនុវត្តទៅលើរាល់បញ្ហាទាំងអស់ដែលទាក់ទងនឹងការគ្រប់គ្រងហិរញ្ញវត្ថុរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចនៅថ្នាក់ខេត្ត លើកលែងតែបញ្ហាទាំងឡាយណាដែលការរៀបចំគម្រោងជាក់លាក់ត្រូវបានឯកភាពយ៉ាងច្បាស់រវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារពិភពលោក។

តាមរយៈប្រព័ន្ធនេះ គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្តគ្រប់គ្រងធនធានដែលបានផ្ទេរចូលពីគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិតាមរយៈកម្មវិធី Imprest Scheme និងអនុលោមតាមកិច្ចសន្យាសម្បទានដីសង្គមកិច្ចប្រចាំឆ្នាំ។ គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្តរក្សាទុកមូលនិធិគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងគណនីថ្នាក់ខេត្តរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដែលគិតជាប្រាក់ដុល្លារអាមេរិកនៅក្នុងស្ថាប័នហិរញ្ញវត្ថុដែលមានការទទួលស្គាល់។ គណនីនេះមិនត្រូវបានប្រើប្រាស់សម្រាប់គោលបំណងណាមួយក្រៅពីការគ្រប់គ្រងមូលនិធិរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចឡើយ។

ក្រុមប្រឹក្សាឃុំមានសិទ្ធិពេញលេញក្នុងការផ្តល់កិច្ចសន្យា និងកំណត់ការចំណាយមួយចំនួនដែលអនុលោមតាមកិច្ចសន្យាអនុវត្តរបស់ពួកគេ។ ប៉ុន្តែក្រុមប្រឹក្សាឃុំមិនគ្រប់គ្រងធនធានរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចដោយផ្ទាល់ឡើយ ហើយការចំណាយនានាក្រោមកិច្ចសន្យាទាំងនេះត្រូវទូទាត់តាមរយៈការចំណាយដែលអនុវត្តដោយគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត ។

ភ្នាក់ងារអនុវត្ត រួមមាន គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត/គណៈកម្មាធិការគ្រប់គ្រងដីសង្គមកិច្ច, ក្រុមការងារថ្នាក់ខេត្តរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ក្រុមការងារថ្នាក់ស្រុករបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គណៈកម្មាធិការប្រតិបត្តិ និងមន្ទីរជំនាញ មិនដំណើរការគណនីធនាគារ ឬ មូលនិធិដែលមានសាច់ប្រាក់តិចតួចសម្រាប់ការគ្រប់គ្រងធនធានរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចឡើយ លើកលែងតែបុរេប្រទានជាសាច់ប្រាក់ដែលធ្វើឡើងសម្រាប់គោលបំណងជាក់លាក់ប៉ុណ្ណោះ។ រាល់ការចំណាយទាំងអស់ទៅលើបុគ្គលិក និងអ្នកទទួលការ ឬ អ្នកផ្គត់ផ្គង់ត្រូវបានអនុវត្តដោយផ្នែកហិរញ្ញវត្ថុរបស់គណៈកម្មាធិការប្រតិបត្តិ។

រាល់ការចំណាយទាំងអស់ ត្រូវ:

១. ស្នើដោយភ្នាក់ងារអនុវត្ត (មានគណៈកម្មាធិការប្រតិបត្តិ ក្រុមការងារថ្នាក់ស្រុករបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត/គណៈកម្មាធិការគ្រប់គ្រងដីសង្គមកិច្ច ឬ ក្រុមប្រឹក្សាឃុំ)
២. បញ្ជាក់ដោយមន្ត្រីដែលបានចាត់តាំងសម្រាប់ធ្វើការបញ្ជាក់ និង
៣. អនុម័តដោយមន្ត្រីដែលបានចាត់តាំងសម្រាប់ការអនុម័ត

## ច ៣.៦ នីតិវិធីចំណាយ

ប្រភេទនៃការចំណាយខាងក្រោមនេះត្រូវបានអនុវត្តផ្ទាល់ដោយគណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត:

១. ការផ្តល់សិទ្ធិជូនបុគ្គលិកផ្សេងទៀតត្រូវចំណាយផ្ទាល់ដោយផ្នែកហិរញ្ញវត្ថុរបស់គណៈកម្មាធិការប្រតិបត្តិដល់បុគ្គលិកដែលពាក់ព័ន្ធ
២. លទ្ធកម្មផ្គត់ផ្គង់ និងសេវាកម្មនានាសម្រាប់ផ្នែកប្រតិបត្តិ: ផ្នែកចំណាយត្រូវដាក់សំណើសុំទូទាត់ប្រាក់ទៅផ្នែកហិរញ្ញវត្ថុ។ ពេលមានការអនុម័ត ការទូទាត់នឹងត្រូវធ្វើឡើងដោយផ្ទាល់ជាមួយអ្នកផ្គត់ផ្គង់ និងអ្នកទទួលការ។
៣. បុរេប្រទានសាច់ប្រាក់អាចនឹងត្រូវផ្តល់ទៅឲ្យគណៈកម្មាធិការប្រតិបត្តិសម្រាប់គោលបំណងជាក់លាក់មួយចំនួនដូចជា ការរៀបចំសិក្ខាសិលា និងសកម្មភាពបណ្តុះបណ្តាល។ ប្រាក់បុរេប្រទាននឹងត្រូវធ្វើការទូទាត់ទាំងស្រុងក្នុងរយៈពេល ១០ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបញ្ចប់សកម្មភាព។
៤. "សាច់ប្រាក់មានក្នុងបេឡា" ត្រូវកាន់កាប់ដោយបេឡារបស់គណៈកម្មាធិការប្រតិបត្តិ និងត្រូវយកទៅប្រើប្រាស់សម្រាប់គ្រប់ការចំណាយតិចតួចដែលមានចំនួនទឹកប្រាក់មិនលើសពី ១០០ដុល្លារអាមេរិក លើរាល់ការចំណាយនីមួយៗ និង
៥. ការទូទាត់ប្រាក់ទៅឲ្យអ្នកទទួលការឯកជន និងអ្នកផ្តល់សេវាកម្មដែលស្ថិតក្រោមជំនួយបន្តសម្រាប់រចនាសម្ព័ន្ធ និងសេវាកម្មដើម្បីគាំទ្រការធ្វើសម្បទានដីសង្គមកិច្ច

(សមាសភាគទី ២) ត្រូវបានអនុវត្តដោយផ្នែកហិរញ្ញវត្ថុរបស់គណៈកម្មាធិការប្រតិបត្តិ ផ្ទៀបទៅនឹងសំណើសុំទូទាត់ប្រាក់ដែលដាក់ជូនដោយមេឃុំដែលជាមន្ត្រីទទួលបន្ទុកក្នុងការធ្វើសំណើ។

## ច ៣.៧ នីតិវិធីគណនេយ្យនៅថ្នាក់ក្រោមជាតិ

ផ្នែកហិរញ្ញវត្ថុរបស់គណៈកម្មាធិការប្រតិបត្តិ ទទួលខុសត្រូវក្នុងការរក្សាទុករាល់គណនីសម្រាប់ផ្ទេរហិរញ្ញវត្ថុដែលទូទាត់តាមរយៈគណនីខេត្តរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។ ដំណើរការនេះរួមបញ្ចូលការចំណាយដែលធ្វើផ្ទាល់ដោយ គណៈកម្មាធិការប្រតិបត្តិ ឬ ដោយលេខាធិការដ្ឋាននៃគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត/គណៈកម្មាធិការគ្រប់គ្រងដីសង្គមកិច្ច។ ផ្នែកហិរញ្ញវត្ថុរបស់គណៈកម្មាធិការប្រតិបត្តិត្រូវទទួលខុសត្រូវក្នុងការៈ

១. ជូនដំណឹងពីស្ថានភាពសាច់ប្រាក់នៅក្នុងគណនីខេត្តរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច
២. ពិនិត្យតាមដានមើលបន្ទាត់សាច់ប្រាក់ដែលត្រូវបានបែងចែកទៅឲ្យភ្នាក់ងារអនុវត្តគម្រោង និង
៣. ធ្វើរបាយការណ៍អំពីការប្រើប្រាស់ធនធានដែលទទួលបានពីថ្នាក់ជាតិ។

ក្រុមការងារថ្នាក់ស្រុកត្រូវថែរក្សារាល់គណនីខាងក្រោមៈ

១. សៀវភៅបញ្ជីសាច់ប្រាក់បន្ទាប់បន្សំ និង
២. ទម្រង់ពិនិត្យតាមដានលេខកូដថវិកា

រៀងរាល់ខែ ភ្នាក់ងារអនុវត្តគម្រោងត្រូវរៀបចំជាសង្ខេបនូវទម្រង់ពិនិត្យតាមដាន ដើម្បីដាក់ជូនគណៈកម្មាធិការប្រតិបត្តិ (របាយការណ៍ហិរញ្ញវត្ថុប្រចាំខែ)។

## ច ៣.៨ នីតិវិធីការធ្វើរបាយការណ៍ហិរញ្ញវត្ថុនៅថ្នាក់ក្រោមជាតិ

ភ្នាក់ងារអនុវត្តដែលទទួលខុសត្រូវក្នុងការអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ទាំងស្ថិតក្រោមអនុកិច្ចសន្យាទទួលការបន្តទៅឲ្យគណៈកម្មាធិការអភិវឌ្ឍជនបទថ្នាក់ខេត្ត ឬ ក្រោមកិច្ចព្រមព្រៀងជាមួយគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ត្រូវរៀបចំ និងដាក់របាយការណ៍ប្រចាំខែជូនគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត ។

របាយការណ៍ទាំងនេះរួមមានៈ

១. របាយការណ៍ស្តីពីការរីកចម្រើននៃសកម្មភាពរូបវន្តផ្ទៀបនឹងផែនការការងារ និង
២. របាយការណ៍ស្តីពីស្ថានភាពថវិកា

គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្តរៀបចំ និងដាក់របាយការណ៍ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំជូនគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប)។ របាយការណ៍ទាំងនេះមាន ២ ផ្នែក:

១. របាយការណ៍ស្តីពីការរីកចម្រើននៃសកម្មភាពរូបវន្តធៀបនឹងផែនការការងារ និង

២. របាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុប្រចាំខែរួមមាន:

១. របាយការណ៍លំហូរសាច់ប្រាក់

២. របាយការណ៍ចំណាយ និង

៣. ឯកសារផ្ទៀងផ្ទាត់គណនីថ្នាក់ខេត្តរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍ សេដ្ឋកិច្ច

របាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស គឺជារបាយការណ៍ហិរញ្ញវត្ថុប្រចាំខែសម្រាប់ខែនោះដែលបូកជាមួយរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ត្រីមាសនោះ។

របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ គឺដូចគ្នាទៅនឹងរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសដែរដោយបូកជាមួយបញ្ជីសារពើភណ្ឌនៃអចលនទ្រព្យរបស់គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត ។

## ច ៤ លទ្ធកម្ម

### ច ៤.១ ទិដ្ឋភាពទូទៅ

គ្រប់លទ្ធកម្មទាំងអស់ក្រោមគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ត្រូវបានអនុវត្តស្របតាម "គោលការណ៍ណែនាំស្តីពីលទ្ធកម្មក្រោមប្រាក់កម្ចីរបស់ IBRD និងឥណទានរបស់សមាគមអភិវឌ្ឍអន្តរជាតិ" របស់ធនាគារពិភពលោក ចុះខែឧសភា ឆ្នាំ២០០៤ និងត្រូវបានកែសម្រួលនៅ ខែតុលា ឆ្នាំ ២០០៦ និង "គោលការណ៍ណែនាំស្តីពីការជ្រើសរើស និងការជួលអ្នកផ្តល់ទីប្រឹក្សាដោយអ្នកទទួលជំនួយពីធនាគារពិភពលោក" ចុះខែឧសភា ឆ្នាំ២០០៤ ហើយធ្វើការកែសម្រួលនៅក្នុងឆ្នាំ២០០៦។

យោងតាមបទបញ្ញត្តិខាងលើ វិធីសាស្ត្រដេញថ្លៃ និងទិញទំនិញប្រកបដោយភាពប្រកួតប្រជែងនៅថ្នាក់ជាតិសម្រាប់លទ្ធកម្មទំនិញ និងការងារសំណង់ផ្សេងៗ អាចនឹងត្រូវធ្វើលទ្ធកម្មតាមរយៈនីតិវិធីដែលមានចែងនៅក្នុងអនុក្រឹត្យលេខ១៤ ដែលប្រកាសឲ្យប្រើប្រាស់នីតិវិធីបទដ្ឋានសម្រាប់ការអនុវត្តគម្រោងដែលគាំទ្រដោយធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ និងបទបញ្ញត្តិដែលពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹង

សៀវភៅណែនាំពីលទ្ធកម្មរបស់គម្រោងដែលមានការគាំទ្រពីខាងក្រៅចំពោះទំនិញការងារសំណង់ និងសេវាកម្មផ្អែកលើការកែលម្អ ដែលបានចុះក្នុងឧបសម្ព័ន្ធភ្ជាប់ទៅនឹងកិច្ចព្រមព្រៀងផ្តល់ហិរញ្ញប្បទានអភិវឌ្ឍ។

ទោះបីយ៉ាងណាក៏ដោយ នៅក្នុងករណី **សមាសភាគទី ២** (ជំនួយបន្តក្នុងសហគមន៍សម្រាប់ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មដើម្បីគាំទ្រដល់សម្បទានដីសង្គមកិច្ច) លទ្ធកម្មអាចអនុវត្តដោយក្រុមប្រឹក្សាឃុំក្រោមប្រកាស ២៣១/គោលការណ៍ណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីលទ្ធកម្មថ្នាក់ឃុំ និងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ ដែលអាចត្រូវធ្វើការកែសម្រួលពីពេលមួយទៅពេលមួយ ហើយសមាគមអភិវឌ្ឍអន្តរជាតិអាចទទួលយកបាន។ លទ្ធកម្មដោយក្រុមប្រឹក្សាឃុំ គឺអាស្រ័យទៅលើតម្លៃផ្តួចផ្តើមអតិបរមាដូចមានបញ្ជាក់ខាងក្រោម។

ប្រភេទនៃលទ្ធកម្មខាងក្រោមនេះត្រូវបានអនុវត្តក្រោមគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចៈ

១. ***ទំនិញៈ*** យានយន្ត ឧបករណ៍សម្ភារៈការិយាល័យ និងរបស់របរដទៃទៀតដែលចាំបាច់សម្រាប់អគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច គម្រោងគាំទ្រការអភិវឌ្ឍរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្តគណៈកម្មការស្រុក និងភ្នាក់ងារដទៃទៀតដែលអនុវត្តសកម្មភាពរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។

២. ***ការងារសំណង់*** ការជួសជុល និងថែទាំបន្តិចបន្តួចទៅលើការិយាល័យរដ្ឋបាលថ្នាក់ស្រុក និងថ្នាក់ខេត្ត

៣. **សេវាកម្មផ្តល់ប្រឹក្សា** រួមមានៈ

៤. ជំនួយបច្ចេកទេសសម្រាប់កសាងសមត្ថភាព ជាពិសេសសម្រាប់ការរៀបចំឯកសារបណ្តុះបណ្តាល

៥. ជំនួយបច្ចេកទេសសម្រាប់ការអនុវត្តគម្រោង

៦. សេវាផ្តល់ប្រឹក្សាសម្រាប់ការសិក្សាពីគោលនយោបាយ ការត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង

៧. សេវាសវនកម្មហិរញ្ញវត្ថុ និង

៨. ***ទំនិញ ការងារសំណង់ និងសេវាកម្ម ដែលផ្តល់ហិរញ្ញវត្ថុដោយជំនួយបន្ត*** សម្រាប់ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មជនបទដែលត្រូវអនុវត្តដោយក្រុមប្រឹក្សាឃុំ រួមមានហេរចនាសម្ព័ន្ធ និងសេវាកម្មដើម្បីគាំទ្រដល់ការធ្វើសម្បទានដីសង្គមកិច្ចក្រោមលទ្ធកម្មរបស់អ្នកទទួលការងារវិស័យឯកជន អ្នកផ្គត់ផ្គង់ និងអ្នកផ្គត់ផ្គង់សេវាកម្ម។

## ច ៤.២ការទទួលខុសត្រូវចំពោះលទ្ធកម្ម

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិមានការទទួលខុសត្រូវទាំងស្រុងចំពោះលទ្ធកម្មតាមរយៈការប្រើប្រាស់មូលនិធិរបស់គម្រោងការបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។ ការទទួលខុសត្រូវទាំងនេះ រួមមានៈ

១. ការរៀបចំ និងដាក់ជូនធនាគារពិភពលោកដើម្បីសុំការមិនទាស់ទៅលើផែនការលទ្ធកម្មរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច
២. បង្កើតសម្ព័ន្ធភាពជាមួយភ្នាក់ងារលទ្ធកម្មឯករាជ្យដែលតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជា ដែលអាចអនុវត្តបាន
៣. ដឹកនាំលទ្ធកម្មការងារសំណង់ ទំនិញ និងសេវាកម្មនានា ដែលអាចអនុវត្តបាន
៤. ត្រួតពិនិត្យមើលលទ្ធកម្មដោយថ្នាក់ឃុំ ថ្នាក់ស្រុក និងថ្នាក់ខេត្ត ដែលអាចអនុវត្តបាន។

តារាងខាងក្រោមនេះផ្តល់នូវការបរិយាយសង្ខេបអំពីនីតិវិធី និងការទទួលខុសត្រូវផ្សេងៗ។ តម្លៃកម្រិតអតិបរមាដែលបង្ហាញនៅក្នុងតារាងនេះអាចនឹងមានការកែសម្រួលជាបន្តបន្ទាប់តបតាមសំណើរបស់រាជរដ្ឋាភិបាលកម្ពុជា និងមានការឯកភាពពីធនាគារពិភពលោក។

| ការទទួលខុសត្រូវចំពោះលទ្ធកម្មតាមប្រភេទ (មិនរួមបញ្ចូលសមាសភាគទី ២) | | | |
|---|---|---|---|
| ប្រភេទលទ្ធកម្ម | តម្លៃ | ការទទួលខុសត្រូវ | កំណត់សម្គាល់ |
| ទំនិញ និងឧបករណ៍សម្ភារៈ | លើសពី ៥០ ០០០ ដុល្លារ | ភ្នាក់ងារលទ្ធកម្ម ឯករាជ្យ | ភ្នាក់ងារលទ្ធកម្មឯករាជ្យតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីគ្រប់គ្រងការងារលទ្ធកម្មក្រោមគម្រោងរបស់ធនាគារពិភពលោកក្នុងនាមគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) |
| ទំនិញ និងឧបករណ៍សម្ភារៈ | ក្រោម ៥០ ០០០ ដុល្លារ | គជអប | |
| សេវាកម្មផ្តល់ប្រឹក្សា (កិច្ចសន្យាជាមួយក្រុមហ៊ុន) | | ភ្នាក់ងារលទ្ធកម្ម ឯករាជ្យ | ភ្នាក់ងារលទ្ធកម្មឯករាជ្យតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីគ្រប់គ្រងការងារលទ្ធកម្មក្រោមគម្រោងរបស់ធនាគារពិភពលោកក្នុងនាមគណៈកម្មាធិការជាតិសម្រាប់ |

| | | | |
|---|---|---|---|
| | | | ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) |
| សេវាកម្មផ្ដល់ប្រឹក្សា (កិច្ចសន្យាបុគ្គល) | | គជអប | |
| សំណង់ស៊ីវិល | លើសពី ១០០ ០០០ ដុល្លារ | ភ្នាក់ងារលទ្ធកម្ម ឯករាជ្យ | ភ្នាក់ងារលទ្ធកម្មឯករាជតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជាដើម្បីគ្រប់គ្រងការងារលទ្ធកម្មក្រោមគម្រោងរបស់ធនាគារពិភពលោកក្នុងនាមគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) |
| សំណង់ស៊ីវិល | ក្រោម ១០០ ០០០ ដុល្លារ | គជអប | |
| កម្មវិធីអង្គរពលកម្ម | | គជអប | > ២០០ ០០០ ដុល្លារអាមេរិក អាចធ្វើលទ្ធកម្ម ក្រោមវិធីសាស្ត្រលទ្ធកម្មពីទីភ្នាក់ងារអង្គការសហប្រជាជាតិ និងពីការិយាល័យអង្គការ សហប្រជាជាតិផ្នែកសេវាកម្មគម្រោង (UNOPS) និងកម្មវិធីអង្គរពលកម្មពិភពលោក (WFP) |

| សមាសភាគទី ២ (ជំនួយសម្រាប់អនុគម្រោង) ការទទួលខុសត្រូវចំពោះលទ្ធកម្មតាមប្រភេទ | | | |
|---|---|---|---|
| **ប្រភេទលទ្ធកម្ម** | **តម្លៃ** | **ការទទួលខុសត្រូវ** | **កំណត់សម្គាល់** |
| ទំនិញ និងឧបករណ៍សម្ភារៈ | លើសពី ៥០ ០០០ ដុល្លារ | ភ្នាក់ងារលទ្ធកម្មឯករាជ្យ | ភ្នាក់ងារលទ្ធកម្មឯករាជ្យតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជា |
| ទំនិញ និងឧបករណ៍ សម្ភារៈ | ក្រោម ៥០ ០០០ ដុល្លារ ប៉ុន្តែលើសពី ២០ ០០០ ដុល្លារ | គជអប ឬ គ.ប្រ នៃ គអជខ | គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មការអភិវឌ្ឍជនបទខេត្តលុះត្រាតែមានការបញ្ជាក់ពីធនាគារពិភពលោកថាមានសមត្ថភាពគ្រប់គ្រាន់។ |
| ទំនិញ និងគ្រឿងបរិក្ខារ | ក្រោម ២០០០០ ដុល្លារ | ក្រុមប្រឹក្សាឃុំ | គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្តដើម្បីគាំទ្រ |
| ការងារសំណង់ | លើសពី ១០០ ០០០ ដុល្លារ | ភ្នាក់ងារលទ្ធកម្មឯករាជ្យ | > ៥០ ០០០ ដុល្លារអាមេរិក ទីភ្នាក់ងារលទ្ធកម្មឯករាជ្យដែលតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជា |

| | | | |
|---|---|---|---|
| ការងារសំណង់ | ក្រោម ១០០ ០០០ ដុល្លារ ប៉ុន្តែលើស៤០ ០០០ ដុល្លារ | គជអប ឬ គ.ប្រ នៃគអជខ | គណ:កម្មាធិការប្រតិបត្តិ នៃគណ:កម្មការអភិវឌ្ឍជនបទខេត្តលុះត្រាតែមានការបញ្ជាក់ពីធនាគារពិភពលោកថាមានសមត្ថភាពគ្រប់គ្រាន់។ |
| ការងារសំណង់ | ក្រោម ៤០ ០០០ ដុល្លារ | ក្រុមប្រឹក្សាឃុំ | ≤៤០ ០០០ ដុល្លារអាមេរិក |
| សេវាកម្មពិគ្រោះយោបល់ | | គណ:កម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) / ក្រុមប្រឹក្សាឃុំ | សម្រាប់តែទីប្រឹក្សាក្នុងស្រុកជាលក្ខណបុគ្គលប៉ុណ្ណោះ |

## ច ៤.៣ វិធីសាស្ត្រលទ្ធកម្ម

វិធីសាស្ត្រលទ្ធកម្មខាងក្រោមនេះត្រូវបានប្រើនៅថ្នាក់ស្រុក ថ្នាក់ខេត្ត និងថ្នាក់ជាតិ។

| វិធីសាស្ត្រលទ្ធកម្មទៅតាមប្រភេទ (ដោយមិនរួមបញ្ចូលសមាសភាគទី ២) | | |
|---|---|---|
| ប្រភេទលទ្ធកម្ម | វិធីសាស្ត្រ | កំណត់សម្គាល់ |
| ទំនិញនិងឧបករណ៍សម្ភារ: | ការដេញថ្លៃដោយប្រកួតប្រជែងជាអន្តរជាតិ | > ១០០ ០០០ ដុល្លារអាមេរិក/កិច្ចសន្យា |
| ទំនិញនិងឧបករណ៍សម្ភារ: | ការដេញថ្លៃដោយប្រកួតប្រជែងជាអន្តរជាតិ | ≤ ១០០ ០០០ ដុល្លារអាមេរិក/កិច្ចសន្យា |
| ការងារសំណង់ទ្រង់ទ្រាយតូច | ការទិញសម្ភារ:សំណង់ដោយផ្ទាល់ (Shopping) | ≤ ៤០ ០០០ ដុល្លារ /កិច្ចសន្យា |
| ការងារសំណង់ | ការដេញថ្លៃដោយប្រកួតប្រជែងថ្នាក់ជាតិ | < ៣០០ ០០០ ដុល្លារ /កិច្ចសន្យា |
| ទំនិញ | ការទិញសម្ភារ:បរិក្ខារដោយផ្ទាល់ (Shopping) | < ២០ ០០០ ដុល្លារ /កិច្ចសន្យា |

| សមាសភាគទី ២ (ជំនួយលើអនុគម្រោង) វិធីសាស្ត្រលទ្ធកម្មតាមប្រភេទ | | |
|---|---|---|
| ប្រភេទលទ្ធកម្ម | វិធីសាស្ត្រ | កំណត់សម្គាល់ |
| ទំនិញនិងឧបករណ៍ សម្ភារ: | ការដេញថ្លៃដោយប្រកួតប្រជែងថ្នាក់ជាតិ | > ២០ ០០០ ដុល្លារអាមេរិក ដែលធ្វើលទ្ធកម្មដោយគណ:កម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ឬ គណ:កម្មាធិការប្រតិបត្តិ នៃគណ: |

| | | |
|---|---|---|
| | | កម្មាធិការអភិវឌ្ឍជនបទខេត្ត |
| ទំនិញនិងឧបករណ៍ សម្ភារៈ | វិធីសាស្រ្តលទ្ធកម្មនៅឃុំៈ គោលការណ៍ណែនាំស្តីពីលទ្ធកម្មថ្នាក់ឃុំ (ប្រកាសលេខ ២៣១/ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០៥) | < ២០ ០០០ ដុល្លារអាមេរិក ដែលធ្វើលទ្ធកម្មដោយក្រុមប្រឹក្សាឃុំ។<br>សៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់មិនបានផ្តល់គោលការណ៍ណែនាំលម្អិតគ្រប់គ្រាន់សម្រាប់ធ្វើលទ្ធកម្មទំនិញ ដូច្នេះនីតិវិធីជាក់លាក់មួយដើម្បីប្រើនៅក្នុងគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចស្របតាមប្រកាសលេខ ២៣១ ត្រូវបានព្រាងឡើង។ |
| ការងារសំណង់ | វិធីសាស្រ្តលទ្ធកម្មឃុំៈ សៀវភៅណែនាំពីការអនុវត្តគម្រោងមូលនិធិឃុំសង្កាត់ | ≤ ៤០ ០០០ ដុល្លារអាមេរិក ដែលធ្វើលទ្ធកម្មដោយក្រុមប្រឹក្សាឃុំ |
| ការងារសំណង់ | ការដេញថ្លៃដោយប្រកួតប្រជែងថ្នាក់ជាតិ | > ៤០ ០០០ ដុល្លារអាមេរិក ធនធានបច្ចេកទេសដែលត្រូវរៀបចំដោយផ្នែកគាំទ្របច្ចេកទេសរបស់គណៈកម្មាធិការប្រតិបត្តិ បន្ទាប់មកត្រូវបានត្រួតពិនិត្យដោយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ត្រូវធ្វើលទ្ធកម្មដោយគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត |
| ទំនិញ (កញ្ចប់សម្ភារៈមូលដ្ឋាន) | វិធីសាស្រ្តលទ្ធកម្មឃុំៈ គោលការណ៍ណែនាំស្តីពីលទ្ធកម្មថ្នាក់ឃុំ សង្កាត់ (ប្រកាសលេខ ២៣១/ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០៥) | < ២០ ០០០ ដុល្លារអាមេរិក ដែលធ្វើលទ្ធកម្មដោយក្រុមប្រឹក្សាឃុំ។<br>សៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំមិនបានផ្តល់គោលការណ៍ណែនាំលម្អិតគ្រប់គ្រាន់សម្រាប់ធ្វើលទ្ធកម្មទំនិញ ដូច្នេះនីតិវិធីជាក់លាក់មួយដើម្បីប្រើនៅក្នុងគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចស្របតាមប្រកាសលេខ ២៣១ ត្រូវបានព្រាងឡើង។ |
| ទំនិញ (កញ្ចប់សម្ភារៈមូលដ្ឋានសម្រាប់ការចូលតាំងទីលំនៅថ្មី) | ការដេញថ្លៃដោយប្រកួតប្រជែងថ្នាក់ជាតិ | > ២០ ០០០ ដុល្លារអាមេរិក ធនធានបច្ចេកទេសដែលត្រូវរៀបចំដោយ ផ្នែកគាំទ្របច្ចេកទេសរបស់គណៈកម្មាធិការប្រតិបត្តិ បន្ទាប់មកត្រូវត្រួតពិនិត្យដោយ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប)<br>- ធ្វើលទ្ធកម្មដោយគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត |

## ច ៤.៤ លទ្ធកម្មលើហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មជនបទ

### ច ៤.៤.១ ទិដ្ឋភាពទូទៅ

ទម្រង់បឋមនៃលទ្ធកម្មលើហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មជនបទ (សមាសភាគទី ២) គឺធ្វើឡើងដោយការដេញថ្លៃដោយប្រកួតប្រជែង។ ប៉ុន្តែ ការដេញថ្លៃដោយប្រកួតប្រជែងអាចធ្វើទៅបានប្រសិនបើមានអ្នកផ្តល់សេវាកម្មវិស័យឯកជនមានសមត្ថភាពគ្រប់គ្រាន់។ ប្រសិនបើមិនមានអ្នកផ្តល់សេវាកម្មវិស័យឯកជនដែលសក្តិសមទេ សេវាកម្មនោះនឹងត្រូវផ្តល់ដោយភ្នាក់ងាររបស់រដ្ឋ (ជាទូទៅផ្តល់ដោយការិយាល័យបច្ចេកទេសស្រុក ឬ មន្ទីរពាក់ព័ន្ធរបស់ខេត្ត)។ ក្នុងករណីនេះ តម្លៃសេវាកម្មនឹងត្រូវគិតទៅតាមតម្លៃប្រតិបត្តិការជាក់ស្តែង។

### ច ៤.៤.២ ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មដែលធ្វើកិច្ចសន្យាផ្ទាល់ដោយឃុំ

យោងទៅតាមល័ក្ខខ័ណ្ឌសម្រាប់ធ្វើលទ្ធកម្មដោយភ្នាក់ងារលទ្ធកម្មឯករាជ្យដូចមានលើកឡើងខាងលើ ក្រុមប្រឹក្សាឃុំធ្វើលទ្ធកម្មលើទំនិញ ការងារសំណង់ (ពេលមានអ្នកផ្គត់ផ្គង់វិស័យឯកជនស័ក្តិសម) និងសេវាកម្មដោយផ្ទាល់ពីអ្នកផ្តល់សេវាផ្នែកឯកជន។ ការរៀបចំ ការធ្វើលទ្ធកម្ម ការគ្រប់គ្រងកិច្ចសន្យា និងការអនុវត្តកិច្ចសន្យាទាំងនេះត្រូវអនុវត្តទៅតាមគោលការណ៍ណែនាំស្តីពីការធ្វើលទ្ធកម្មរបស់ឃុំ (ប្រកាសលេខ ២៣១/ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០៥) និងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ ដែលអាចនឹងមានការកែសម្រួលនៅពេលណាមួយ ហើយសមាគមអភិវឌ្ឍអន្តរជាតិអាចទទួលយកបានពាក់ព័ន្ធលើគ្រប់បញ្ហាលើកលែងតែសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ និងការបញ្ចប់ការចំណាយ។ ការទូទាត់ប្រាក់ក្រោមកិច្ចសន្យានេះ គឺធ្វើឡើងដោយការិយាល័យហិរញ្ញវត្ថុរបស់គណៈកម្មាធិការប្រតិបត្តិតបតាមសំណើរបស់មេឃុំ។

### ច ៤.៤.៣ ការអនុវត្តវិស័យផ្នែកសេវាកម្មៈ ថ្លៃចំណាយប្រតិបត្តិការ

សម្រាប់សេវាកម្មដែលផ្តល់ដោយមន្ទីរពាក់ព័ន្ធ និងការិយាល័យបច្ចេកទេសស្រុក គឺមិនមានដំណើរការដេញថ្លៃដោយប្រកួតប្រជែងនោះទេ។ តម្លៃសេវាកម្ម គឺអាស្រ័យលើតម្លៃឯកតាស្របតាមបទដ្ឋាន (ឧៈ ចំណាយលើការធ្វើដំណើរ និងបេសកកម្មជាដើម) ដែលអនុម័តដោយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ។

ការិយាល័យបច្ចេកទេសស្រុក គឺជាកន្លែងទំនាក់ទំនងផ្ទាល់ដើម្បីឲ្យគណៈកម្មាធិការស្រុកធ្វើលទ្ធកម្មសេវាកម្មពីមន្ទីរ ឬ ការិយាល័យបច្ចេកទេស។ ការិយាល័យបច្ចេកទេសស្រុកអាចស្នើសុំការគាំទ្រពីមន្ទីរខេត្តក្នុងករណីចាំបាច់។ ប៉ុន្តែ ប្រសិនបើមិនមានការិយាល័យបច្ចេកទេសស្រុកដែលមានសមត្ថភាពសមស្របទេ ក្រុមការងារថ្នាក់ស្រុកធ្វើការទំនាក់ទំនងទៅមន្ទីរពាក់ព័ន្ធនៅថ្នាក់ខេត្តដោយផ្ទាល់។

ផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាលគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្តធ្វើការចរចារជាមួយមន្ទីរខេត្តដើម្បីគណនាការចំណាយប្រតិបត្តិការជាមួយខាងមន្ទីរ ឬ

ការិយាល័យបច្ចេកទេសស្រុក ដើម្បីផ្តល់សេវាកម្មដែលក្រុមប្រឹក្សាឃុំត្រូវការ។ ការចំណាយលើប្រតិបត្តិការនឹងត្រូវគណនាដោយផ្អែកលើមូលដ្ឋានថវិកាជាឯកតាស្របតាមបទដ្ឋាន។ ឧទាហរណ៍ ប្រសិនបើគណៈកម្មាធិការប្រតិបត្តិបានសម្រេចចិត្តថា សេវាផ្សព្វផ្សាយកសិកម្មគួរតែផ្តល់ឲ្យដោយវិស័យរដ្ឋ ផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាលគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្តនឹងធ្វើការជាមួយមន្ទីរកសិកម្មខេត្ត ដើម្បីរៀបចំគម្រោងថវិកាសម្រាប់ការផ្សព្វផ្សាយកសិកម្មដោយប្រើប្រាស់ទម្រង់បទដ្ឋាន និងការចំណាយដែលអនុម័តដោយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ។

សេវាកម្មជនបទដែលនឹងត្រូវអនុវត្តដោយវិស័យរដ្ឋ ត្រូវបានដាក់បញ្ចូលទៅក្នុងកិច្ចសន្យាទទួលការបន្តប្រចាំឆ្នាំរវាងគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត និងវិស័យបច្ចេកទេស ឬ ដោយក្រសួងពាក់ព័ន្ធតាមរយៈមន្ទីរជំនាញនៅថ្នាក់ក្រោមជាតិ។

គម្រោងថវិកាសម្រាប់សកម្មភាពសេវាកម្មជនបទនីមួយៗ ត្រូវផ្អែកទៅលើគម្រោងថវិកាជាឯកតាស្របតាមបទដ្ឋានដោយមានការចរចារវាងផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាលគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត និងមន្ទីរជំនាញខេត្ត។

***ឧទាហរណ៍:*** *គម្រោងថវិកាជាឯកតាស្របតាមបទដ្ឋានសម្រាប់សេវាផ្សព្វផ្សាយបង្ហាញថា សម្រាប់កសិករចំនួន ១០០នាក់ ថ្លៃចំណាយនឹងរួមបញ្ចូលដោយគិតពីចំនួនថ្ងៃ X បេសកកម្មចំនួនលីត្រនៃប្រេងឥន្ធនៈ Y និងចំណាយលើសម្ភារៈ Z ។* សម្បទានដីសង្គមកិច្ច *មានកសិករ ១០០នាក់ ដូច្នេះគម្រោងថវិកានឹងស្មើ ៣,៥ x ចំនួនថ្ងៃ X បេសកកម្ម, ៣,៥ x ចំនួនលីត្រនៃប្រេងឥន្ធនៈ Y និង ៣,៥ x ចំណាយលើសម្ភារៈ Z ។*

## ច ៦ ការត្រួតពិនិត្យតាមដាន និងការធ្វើរបាយការណ៍

ជាទូទៅ ភ្នាក់ងារអនុវត្តទាំងឡាយដែលទទួលខុសត្រូវចំពោះសកម្មភាពក្រោមគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ត្រូវទទួលខុសក្នុងការរៀបចំ និងបញ្ជូនរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ។

ជាទូទៅ របាយការណ៍មាន ២ ផ្នែកៈ របាយការណ៍សកម្មភាព និងរបាយការណ៍ហិរញ្ញវត្ថុ។ តម្រូវការធ្វើរបាយការណ៍ហិរញ្ញវត្ថុ គឺមានពិពណ៌នានៅក្នុងផ្នែក **ច ៣** ខាងលើ។

របាយការណ៍រៀបរាប់ពីសកម្មភាពពិស្តារត្រូវធ្វើឡើងជាសង្ខេប និងប្រើប្រាស់ទម្រង់ស្របតាមបទដ្ឋាន នៅពេលដែលអាចធ្វើទៅបាន។ មធ្យោបាយសំខាន់ៗនៃការរាយការណ៍ពីសកម្មភាពក្រោមកិច្ចសន្យាសម្បទានដីសង្គមកិច្ចថ្នាក់ខេត្ត គឺតាមរយៈកម្មវិធីគ្រប់គ្រងកិច្ចសន្យារបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ។

# ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី ១ ក:**

## គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

## ដំណើរការកំណត់ទីតាំងដីដែលអាចធ្វើកសិកម្មបាននៅថ្នាក់ឃុំ

# សេចក្តីណែនាំសម្រាប់ការពិនិត្យលក្ខណាវិនិច្ឆ័យតំបន់អភិរក្សធម្មជាតិ

ការជ្រើសរើសតំបន់នានាសម្រាប់តាំងលំនៅឋានត្រូវតែជាកម្មវត្ថុដែលត្រូវធ្វើការពិនិត្យជាបឋមដើម្បី ជៀសវាងការប៉ះពាល់តំបន់ដែលចាត់ទុកជាតំបន់អភិរក្សធម្មជាតិសំខាន់ៗ ដូចមានចែងក្នុងគោលនយោបាយប្រតិបត្តិការលេខ ៤,០៤ របស់ធនាគារពិភពលោក។ នៅក្នុងគោលនយោបាយប្រតិបត្តិលេខ OP ៤,០៤ តំបន់មួយចំនួនដូចជាតំបន់ព្រៃត្រូពិច និងព្រៃបៃតងជានិរន្តរ តំបន់ដីសើម បឹង និងទន្លេដែលមានសក្តានុពល ហើយចាត់ទុកជាតំបន់អភិរក្សធម្មជាតិដែលអាចនាំឲ្យប៉ះពាល់ពីការប្រើប្រាស់ និងការពង្រីកដីរបស់ប្រជាពលរដ្ឋ។

តំបន់ធម្មជាតិសំខាន់ៗ គឺជាតំបន់ដែលបានទទួលស្គាល់ជាផ្លូវការដោយស្ថាប័ននានា ដូចជាសហគមន៍ អភិរក្សពិភពលោក (IUCN) ឬ RAMSAR នៅក្នុងករណីតំបន់ដីសើម។ ធនាគារពិភពលោកក៏អាចរៀបចំ ឬ ស្នើសុំអាជ្ញាធរមានសមត្ថកិច្ចដូចជា ក្រសួងបរិស្ថានក្នុងការរៀបចំបន្ថែមនូវបញ្ជីទីតាំង និងផែនទីនៃ "តំបន់អភិរក្សបរិស្ថានសំខាន់ៗ" ថ្នាក់ខេត្ត ដែលតំបន់ទាំងនោះមិនគួរអនុញ្ញាតឲ្យមានលំនៅឋាន (ឧ. តំបន់ជីវៈចម្រុះ តំបន់ដែលបានទទួលស្គាល់ដោយសហគមន៍មូលដ្ឋាន និងតំបន់សត្វ ផ្លាស់ទីជម្រកតាមរដូវ ឬ តំបន់សត្វបន្តពូជ)។

**ក. នៅថ្នាក់ជាតិ: តើតំបន់ទាំងនោះស្ថិតក្រោមការយកចិត្តទុកដាក់ស្របតាម IUCN ដែរឬទេ?**

(I) តំបន់ហាមឃាត់សម្រាប់រក្សាទុកអភិរក្សធនធានធម្មជាតិ/តំបន់សត្វព្រៃ ឬ ដែនការពារជម្រកសត្វព្រៃ

(II) ឧទ្យានជាតិដែលត្រូវគ្រប់គ្រងសម្រាប់ការពារប្រព័ន្ធអេកូឡូស៊ី និងសម្រាប់ជាតំបន់ធម្មជាតិកកើតឡើងវិញដោយខ្លួនឯង

(III) បូជនីយដ្ឋានធម្មជាតិដែលត្រូវគ្រប់គ្រងសម្រាប់ការអភិរក្សជាលក្ខណៈពិសេសនៃអត្តសញ្ញាណជាតិ

(IV) តំបន់គ្រប់គ្រងជម្រកសត្វព្រៃដែលត្រូវការពារប្រភេទរុក្ខជាតិ និងសត្វសំខាន់ៗ

(V) តំបន់ការពារទេសភាពធម្មជាតិ ឬ ទេសភាពឆ្នេរសមុទ្រ

(VI)

(VII) តំបន់ការពារធនធានធម្មជាតិ និងតំបន់ដែលបានគ្រប់គ្រង និងប្រើប្រាស់ដោយនិរន្តរភាពក្នុងការដកយកធនធានធម្មជាតិ ដូចជាឈើ ឬ អនុផលព្រៃឈើ

*ពិគ្រោះយោបល់ជាមួយនាយកដ្ឋានការពារ និងការអភិរក្សធម្មជាតិ (DNCP) របស់ក្រសួងបរិស្ថានទាក់ទងទៅនឹងការប្រើប្រាស់ផែនទី និងព្រំប្រទល់នៅក្នុងខេត្ត ដោយកាត់ចេញតំបន់បរិស្ថានទាំងនោះពីតំបន់ដែលគ្រោងរៀបចំជាតំបន់លំនៅឋាន។*

ខ. **នៅថ្នាក់ខេត្ត:** តំបន់ការពារសួ្វលថ្នាក់ជាតិដែលបានពណ៌នានៅខាងលើមិនអាចកើតមានឡើងតែឯកឯងបាននោះទេ។ តំបន់ការពារទាំងនោះចាំបាច់ត្រូវទ្រទ្រង់បន្ថែមដោយត្រូវអនុញ្ញាតឲ្យមានការផ្លាស់ទីរបស់សត្វតាមច្រកដែលបានបង្កើតដូចជាច្រកបរិស្ថាន ឬច្រកសម្រាប់ការគ្រប់គ្រង។ តំបន់បែងចែក ឬ ច្រកដែលសមស្របគួរត្រូវបានកំណត់នៅក្នុងកិច្ចសហប្រតិបត្តិការជាមួយនឹងឃុំ ហើយច្រករបស់សហគមន៍មូលដ្ឋាននឹងមានភាពខុសគ្នាទាក់ទងនឹងប្រវែងទទឹងប្រហែល ៥០ម៉ែត្រ ទៅ ៣០០ម៉ែត្រ អាស្រ័យទៅលើសត្វតូច ឬ ធំដែលត្រូវអនុញ្ញាត និងការប្រើប្រាស់ដីដែលនៅក្បែរនឹងច្រក។ ឧទាហរណ៍ : ច្រកនេះប្រហែលជាអាចតូចជាងមុនក្នុងករណីព្រៃដែលបានគ្រប់គ្រងក្រៅពីកសិកម្មកើតមានឡើង នៅក្បែរច្រកនេះ។ តំបន់បែងចែកគួរតែបង្កើតឡើង ដើម្បីបញ្ចៀសផលប៉ះពាល់ដល់ដីកសិកម្មដែលមានស្រាប់ រួមទាំងការតាំងលំនៅឋានរបស់ប្រជាពលរដ្ឋ។ ជាធម្មតា តំបន់នេះ គឺជាតំបន់ការពារបណ្ដោះអាសន្នដែលស្ថិតនៅចន្លោះតំបន់ការពារ (តំបន់មួយប្រភេទក្នុងចំណោមតំបន់ទាំងប្រាំមួយខាងលើ) និងតំបន់ដីដែលប្រើប្រាស់សម្រាប់ការធ្វើកសិកម្ម ឬ រក្សាទុកព្រៃឈើ។ ជាចំណុចចាប់ផ្ដើម ត្រូវពិចារណាលើផែនទីគោលការណ៍ជាក់ស្តែងនៃតំបន់បែងចែកដែលមានប្រវែងផ្ទៃដីចំនួន ១០% នៃតំបន់ការពារដើម្បីទុកជាតំបន់ព្រំប្រទល់។

គ. **នៅថ្នាក់ឃុំ**

បុគ្គលិកឃុំ និងសហគមន៍ភូមិ ត្រូវកំណត់ទីតាំងដីរួមដែលបង្កើតឡើងដើម្បីប្រើប្រាស់ក្នុងលក្ខណ:ជាតំបន់ការពារព្រៃដែលបានគ្រប់គ្រង (រួមទាំងអនុផលព្រៃឈើ) ការនេសាទត្រី/ការឲ្យចំណីសត្វដែលបានគ្រប់គ្រងទីកន្លែងសក្ការបូជា ឬ តំបន់សម្រាប់ការពារជីវ:ចម្រុះ។ ធ្វើការចរចាជាមួយសហគមន៍ដែលមានស្រាប់អំពីទំហំច្រកការពារផ្លូវទឹកដែលត្រូវបង្កើតឡើងអាស្រ័យទៅលើប្រឡាយទឹកហូរជាប្រចាំ ឬ តាមរដូវកាល។ យោងតាមការណែនាំ ប្រឡាយទឹកហូរតាមរដូវកាលគួរមានប្រវែងការពារ ២០ ម៉ែត្រម្ខាង ហើយផ្លូវទឹកហូរជាប្រចាំវិញ ត្រូវមានប្រវែងការពារ ៥០ម៉ែត្រ។

**ឧបសម្ព័ន្ធទី ១ ខ:**

# ដំណើរការថ្នាក់ឃុំសម្រាប់កំណត់អត្តសញ្ញាណកម្មតំបន់ធ្វើកសិកម្ម ការពិនិត្យគោលការណ៍ណែនាំស្តីពីព្រៃឈើ (មុខងារ) ដែលខូចខាត/ មិនទាន់ខូចខាត

ជាការបន្ថែមទៅលើគោលនយោបាយប្រតិបត្តិការលេខ ៤.០៤ ស្តីអំពីជម្រកធម្មជាតិសំខាន់ៗ ធនាគារពិភពលោកគាំទ្រដល់គោលនយោបាយប្រតិបត្តិការ (OP ៤.៣៦) ដែលផ្តោតលើការប្រើប្រាស់នូវសក្តានុពលព្រៃឈើសម្រាប់កាត់បន្ថយភាពក្រីក្រប្រកបដោយចីរភាព ដោយបញ្ចូលព្រៃឈើទាំងនោះទៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងការពារសេវាបរិស្ថានក្នុងមូលដ្ឋានតាមរយៈព្រៃឈើ។

**និយមន័យ**

និយមន័យទាំងឡាយខាងក្រោមអនុវត្តនៅក្នុងគោលនយោបាយនេះ :

ក) *ព្រៃឈើ* សំដៅលើផ្ទៃដីដែលមានទំហំលើសពី ១,0 ហិកតា ដែលមានគម្របព្រៃឈើ (ឬ កម្រិតសមមូល) លើសពី ១0% ដោយមានដើមឈើដែលអាចលូតលាស់ដល់កម្ពស់ ២ម នៅពេលវាគ្រប់អាយុកាល។ ព្រៃឈើអាចមានសណ្ឋានជាព្រៃបិទដែលមានដើមឈើមានកម្ពស់ខុសៗគ្នា និងដើមឈើតូចៗគ្របដណ្តប់មួយផ្នែកធំនៃដី ឬ ព្រៃបើក។ រុក្ខជាតិតូចៗ និងដំណាំទាំងអស់ដែលមិនទាន់លូតលាស់ដល់ដង់ស៊ីតេ ១0% ឬ ដល់កម្ពស់ ២ម ត្រូវរាប់បញ្ចូលជាព្រៃក្រោម ពីព្រោះជាធម្មតាវាជាតំបន់ដែលបង្កើតជាផ្នែកនៃតំបន់ព្រៃឈើដែលត្រូវបានកាប់ចេញជាបណ្តោះអាសន្ន ដោយសារអន្តរាគមន៍របស់មនុស្សដូចជា ការប្រមូលផល ឬ មូលហេតុធម្មជាតិផ្សេង ប៉ុន្តែគេរំពឹងថា វានឹងក្លាយទៅជាព្រៃវិញ។ និយមន័យនេះ*រាប់បញ្ចូលទាំង*ព្រៃដែលរួមចំណែកដល់ផលិតកម្មព្រៃឈើ ការការពារ ការប្រើប្រាស់ច្រើនប្រភេទ ឬ ការអភិរក្ស មិនថាមានការទទួលស្គាល់ជាផ្លូវការ ឬ អត់នោះទេ។ និយមន័យនេះ*មិនរាប់បញ្ចូល*តំបន់ទាំងឡាយដែលការប្រើប្រាស់ដីមិនពឹងផ្អែកទៅលើបរិមាណនៃគម្របព្រៃឈើនោះទេ ដូចជា តំបន់ធ្វើកសិកម្ម តំបន់ចំណីសត្វ ឬ តំបន់តាំងទីលំនៅជាដើម។ នៅក្នុងប្រទេសមួយចំនួនដែលមានគម្របព្រៃឈើតិចតួច និយមន័យនេះអាចនឹងពង្រីក ដើម្បីរាប់បញ្ចូលតំបន់នានាដែលបានគ្របដណ្តប់ដោយដើមឈើដែលមានកម្រិត ១0% សម្រាប់ដង់ស៊ីតេគម្របព្រៃ ប៉ុន្តែត្រូវបានទុកថាជាព្រៃស្ថិតក្រោមល័ក្ខខ័ណ្ឌក្នុងមូលដ្ឋាន។

ខ) *ព្រៃធម្មជាតិ* គឺជាដីព្រៃ ហើយមានផ្លូវទឹកប្រទាក់គ្នា ដែលសហគមន៍ជីវសាស្ត្រនៃប្រព័ន្ធអេកូឡូស៊ីបានបង្កើតឡើងភាគច្រើនដោយពពួករុក្ខជាតិ និងសត្វព្រៃ ហើយជាកន្លែងដែលសកម្មភាពរបស់មនុស្សមិនបានកែប្រែមុខងារជីវសាស្ត្រអេកូឡូស៊ីដ៏សំខាន់របស់តំបន់នោះ។

គ) *តំបន់ព្រៃសំខាន់* គឺជាតំបន់ព្រៃដែលមានលក្ខណសម្បត្តិសមស្របសម្រាប់ជាជម្រកធម្មជាតិដ៏សំខាន់ស្របតាមគោលនយោបាយលេខ OP ៤.0៤ ស្តីពី *ជម្រកធម្មជាតិ*។ តំបន់ព្រៃសំខាន់ គឺជាផ្នែកតូចៗនៃដីព្រៃធម្មជាតិដែលគ្របដណ្តប់ :

(i) តំបន់ការពារដែលមានស្រាប់ និងតំបន់ដែលបានស្នើសុំជាផ្លូវការដោយរដ្ឋាភិបាល ដើម្បីធ្វើជាតំបន់ការពារ (ដូចជា ការបម្រុងដែលអនុលោមទៅតាមលក្ខណវិនិច្ឆ័យនៃការបែងចែកប្រភេទដីរបស់សហគមន៍អភិរក្សពិភពលោក (IUCN)) តំបន់នានាដែលបានទទួលស្គាល់ជាដំបូងថាជាតំបន់ការពារដោយសហគមន៍មូលដ្ឋានតាមបែបប្រពៃណី (ដូចជា ព្រៃអារក្ស) និងទីតាំងនានាដែលរក្សាបានល័ក្ខខ័ណ្ឌចាំបាច់សម្រាប់ភាពគង់វង្សនៃតំបន់ការពារទាំងអស់នេះ (ដូចបានកំណត់នៅក្នុងដំណើរការវាយតម្លៃបរិស្ថាន) ឬ

(ii) ទីតាំងទាំងឡាយដែលបានកំណត់នៅលើតារាងបន្ថែមដែលរៀបចំដោយធនាគារនេះ ឬប្រភពមានសមត្ថកិច្ចដែលបានកំណត់ដោយអង្គភាពវិស័យបរិស្ថានក្នុងតំបន់។ ទីតាំងប្រភេទនេះ អាចរាប់បញ្ចូលទាំងតំបន់មួយចំនួនដែលបានទទួលស្គាល់ដោយសហគមន៍មូលដ្ឋានតាមបែបប្រពៃណី (ដូចជា ព្រៃអារក្ស) តំបន់មានភាពសមស្របខ្ពស់សម្រាប់ការអភិរក្សជីវៈចម្រុះ និងទីតាំងដែលមានសារៈសំខាន់សម្រាប់ពពួកសត្វកម្រ សត្វងាយរងគ្រោះ សត្វផ្លាស់ប្តូរជម្រកតាមរដូវ ឬ ពពួកសត្វជិតផុតពូជ។ ការចុះបញ្ជី គឺពឹងផ្អែកទៅលើការវាយតម្លៃជាប្រព័ន្ធទៅលើកត្តាទាំងអស់ទៅតាមភាពសម្បូរប្រភេទសត្វ កម្រិតនៃតំបន់មានភាពកម្រ និងភាពងាយរងគ្រោះនៃពពួកសត្វ រួមនឹងភាពជាតំណាង និងភាពស៊ីគ្នានៃដំណើរការប្រព័ន្ធអេកូឡូស៊ី។

ឃ) *សហគមន៍ក្នុងមូលដ្ឋាន* គឺសំដៅទៅលើក្រុមប្រជាពលរដ្ឋដែលរស់នៅក្នុង ឬ ជិតព្រៃដែលគេចាត់ទុកថាជាអ្នកដែលពឹងផ្អែកកម្រិតខ្ពស់ទៅលើ ឬ មានទំនាក់ទំនងជាមួយព្រៃឈើ។

ង) *ព្រៃប្រតិបត្តិការស្ថិតក្រោមការគ្រប់គ្រងព្រៃរួម ឬ ការគ្រប់គ្រងសហគមន៍* គឺជាព្រៃដែលសហគមន៍មូលដ្ឋានជាអ្នកចូលរួមជាចម្បងនៅក្នុងផលិតកម្ម និងសកម្មភាពផ្សេងៗទៀតនៅក្នុងព្រៃនេះ និងជាអ្នកទទួលផលសំខាន់នៅក្នុងដំណើរការ។

ជាទូទៅ នៅក្នុងប្រទេសកម្ពុជា តាមរយៈមេរៀនដែលបានរៀនពីគម្រោងព្រៃឈើកាលពីអតីតកាល និងដំណើរការអនុវត្តយុទ្ធសាស្ត្រ និងដំណើការធ្វើផែនការតាមវិស័យផ្ទាល់របស់រដ្ឋាភិបាលធនាគារដោយសហការជាមួយដៃគូអភិវឌ្ឍផ្សេងៗទៀតបានរៀបចំឯកសារព្រាងមួយដែលមានចំណងជើងថា "ក្របខ័ណ្ឌដៃគូយុទ្ធសាស្ត្រគ្រប់គ្រងធនធានធម្មជាតិ"។ ក្របខ័ណ្ឌនេះដាក់ចេញនូវកម្មវិធីរយៈពេលច្រើនឆ្នាំដើម្បីដោះស្រាយបញ្ហាប្រឈមសំខាន់ៗតាមទិដ្ឋភាពជាច្រើននៃការគ្រប់គ្រងធនធានធម្មជាតិ ដែលរួមមាន ដី ព្រៃឈើ និងការអភិរក្សជីវៈចម្រុះ គឺផ្អែកទាំងអស់ដែលធនាគារបានចូលរួម និងបន្តចូលរួមដោយផ្ទាល់ជាមួយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រ

កម្ពុជា។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាមានគោលដៅរក្សាគម្របព្រៃឈើឲ្យបាន ៦០% (ជិតស្មើនឹងកម្រិត ៥៨% ដូចបានកំណត់តាមរយៈការវាយតម្លៃបញ្ជីព្រៃឈើរបស់អង្គការ FAO ក្នុងឆ្នាំ២០០៥) រហូតដល់ឆ្នាំ ២០១៥។ ទិដ្ឋភាពពិបាកបំផុតក្នុងការជ្រើសរើសទីតាំងដែលមានព្រៃដុះគឺថា មិនមានសេចក្តីសម្រេចណាមួយត្រូវបានធ្វើឡើងថា តើបញ្ញត្តិនៃច្បាប់ព្រៃឈើ ឬ ច្បាប់ភូមិបាល និងក្រិត្យស្តីពីសម្បទានដីសង្គមកិច្ចណាខ្លះគួរមានអាទិភាពក្នុងករណីពាក់ព័ន្ធនឹងព្រៃឈើនៅក្នុងតំបន់សម្បទានដីសង្គមកិច្ច។ ដូច្នេះហើយ ដំណើរការដាក់បញ្ចូល/កាត់ព្រៃឈើចេញនៅក្នុងតំបន់សម្បទានដីសង្គមកិច្ច នៅតែជាបញ្ហាដែលត្រូវធ្វើការចរចាជាមួយនឹងរដ្ឋបាលព្រៃឈើ។

## សេចក្តីបញ្ជាក់អំពីគោលការណ៍

គម្រោងសម្បទានដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច មានគោលបំណងរក្សាព្រៃឈើដែលមានមុខងារទាក់ទងនឹងគុណតម្លៃផ្ទាល់របស់វា (ឈើ, អនុផលព្រៃឈើ) និងគុណតម្លៃប្រយោលរបស់វា (ការពារផ្លូវទឹក រក្សាទុក និងស្រូបជាតិកាបូន ជម្រករបស់មនុស្ស និងសត្វ ទប់ស្កាត់សំណឹក) ព្រមទាំងផលប្រយោជន៍សេដ្ឋកិច្ចនៅពេលអនាគតរបស់វាផងដែរ (ឧស្សាហកម្មការកែច្នៃ ឱសថ កសិកម្ម)។ ជាទូទៅ គម្រោងនេះមានគោលបំណងបញ្ចៀសបម្រែបម្រួលនៃ "ព្រៃដែលមានមុខងារ" ដែលគេអាចចាត់ទុកយ៉ាងទូលំទូលាយថាជាតំបន់ព្រៃមិនខូចខាត ដោយវាមានគុណតម្លៃមួយ ឬ ច្រើនក្នុងចំណោមគុណតម្លៃទាំងនេះ។ ជាពិសេស សូម្បីតែទីណាដែលគេមិនចាត់ទុកវាថាជាព្រៃឈើដែលមានមុខងារពេញលេញទាក់ទងនឹងដង់ស៊ីតេ ឬ ការគ្របដណ្តប់ក៏ដោយ ក៏គុណតម្លៃខាងសេដ្ឋកិច្ចដ៏មានសក្តានុពលរបស់វាគួរតែត្រូវបានវាយតម្លៃ (ពិចារណាអំពីគុណភាពទីតាំង) និងប្រៀបធៀបទៅនឹងគុណតម្លៃនៃជម្រើសខាងកសិកម្មមុនពេលស្នើឲ្យមានការកែប្រែ។

"ព្រៃឈើមានមុខងារ" អាចស្គាល់តាមរយៈលក្ខណសម្បត្តិមួយចំនួនដែលត្រូវការឲ្យធ្វើការពិចារណារួមគ្នាក្នុងការវាយតម្លៃពីភាពសមស្របរបស់ទីតាំងសម្រាប់ការផ្លាស់ប្តូរទៅជាតំបន់កសិកម្ម ឬ តំបន់រក្សាទុកព្រៃឈើ។

- មុខកាត់របស់ដើមឈើកម្ពស់ត្រឹមដើមទ្រូង។ ជាធម្មតា គេបែងចែកជា :
  0-៥ ម៉ែត្រការ៉េ/ហិកតា - ព្រៃរបោះ ឬ ព្រៃខូចខាត
  ៥-១០ ម៉ែត្រការ៉េ/ហិកតា - ព្រៃដង់ស៊ីតេមធ្យម
  ១០-១៥ ម៉ែត្រការ៉េ/ហិកតា - ព្រៃដែលនៅសល់ល្អ

មុខកាត់ដើមឈើ ត្រូវបានវាស់វែងយ៉ាងត្រឹមត្រូវបំផុត វិធីសាស្ត្ររួមនៃដង់ស៊ីតេដើមឈើ និងអង្កត់ផ្ចិតរបស់វាកម្ពស់ត្រឹមដើមទ្រូង (DBH) ហើយបន្ទាប់មកប៉ាន់ស្មានទំហំផ្ទៃសរុប។

វិធីសាស្ត្រ "ទស្សន៍ទាយត្រឹមត្រូវ" ដ៏សាមញ្ញមួយក្នុងការកំណត់មុខកាត់ គឺត្រូវដាក់មេដៃនៅប្រវែងមួយកាងដៃ ហើយប្រៀបធៀបប្រវែងទទឹងរបស់វាជាមួយនឹងអង្កត់ផ្ចិតនៅកម្ពស់ត្រឹមដើមទ្រូងរបស់ដើមឈើមួយណាក៏បានក្នុងកម្រិត ៣៦០ដឺក្រេនៃគំហើញ។ ប្រើការរាប់ដើមឈើបែបនេះដែលមានទំហំតូចជាង ឬ ធំជាងមេដៃ (មិនរាប់បញ្ចូលដើមឈើងាប់ទេ) នោះគេអាចប៉ាន់ស្មានមុខកាត់ជាមធ្យមរបស់ដើមឈើដែលធំជាងមេដៃតាមរយៈការវាយតម្លៃជាច្រើនដង ១.១។ ប្រសិនបើមានដើមឈើដុះលើដីទំហំ ៥ម៉ែត្រការ៉េ ឬ ច្រើនជាងនេះក្នុងមួយហិកតា ពេលនោះត្រូវមានការប្រុងប្រយ័ត្នក្នុងការពិចារណាអំពីការផ្លាស់ប្ដូរឲ្យទៅរកការប្រើប្រាស់ផ្សេងៗទៀត ហើយធ្វើការវាយតម្លៃពីគម្របព្រៃឈើ។

- គម្របព្រៃឈើ: តាមធម្មតា ព្រៃមានមុខងារមានគម្រប ៤៥ ៣៥ និង ២៥% សម្រាប់ព្រៃបៃតងជានិរន្តរក្នុងតំបន់សើម ព្រៃបៃតងជានិរន្តរចម្រុះគ្នា និងព្រៃដែលជ្រុះស្លឹកពេលរាំងស្ងួតដោយឡែកៗពីគ្នា។ ប្រសិនបើព្រៃដែលមានបំពេញតាមកម្រិតគម្របព្រៃឈើខាងលើនេះ គេមិនគួរផ្លាស់ប្ដូរទៅរកការប្រើប្រាស់ផ្សេងនោះទេ។

- វត្តមាននៃប្រភេទរុក្ខជាតិផលិតជ័រចុង ឬស្សី និងអនុផលព្រៃឈើផ្សេងទៀត ដោយមានការទទួលស្គាល់ពីសហគមន៍មូលដ្ឋាន។

*តើបានរៀបចំផែនទីបង្ហាញតំបន់ដែលបានជ្រើសរើសជាក់លាក់ហើយ ឬ នៅបន្ទាប់ពីការពិនិត្យយ៉ាងទូលំទូលាយពីតំបន់ដែលមានសក្ដានុពលនៅក្នុងខេត្ត? កំណត់ប្រភេទចំការដំណាំ និងវិសាលភាពនៃការខូចខាតទាក់ទងនឹងគម្របព្រៃឈើ និងគុណភាពដូចខាងក្រោមនេះ :*

ក. ប៉ាន់ស្មានអំពីមុខកាត់របស់ដើមឈើដោយប្រើប្រាស់ដង់ស៊ីតេ និងអង្កត់ផ្ចិតនៅកម្ពស់ត្រឹមដើមទ្រូង ឬ វិធីសាស្ត្រវាស់មេដៃ

ខ. ប្រសិនបើអាចធ្វើទៅបាន ត្រូវផ្ដុំរូបថតពីលើអាកាសនៃតំបន់ដែលបានជ្រើសរើស ហើយប៉ាន់ស្មានផ្ទៃដីដែលព្រៃគ្របដណ្ដប់។

គ. ដោយសារការបែងចែកតំបន់លើកដំបូងសមស្របសម្រាប់តាំងទីលំនៅ ត្រូវកំណត់តំបន់ព្រៃឈើខូចខាតឲ្យដូចតំបន់ទាំងឡាយដែលមានភាគរយទាបជាងភាគរយអប្បបរមានៃគម្របព្រៃ និងមុខកាត់។

ឃ. ត្រូវកំណត់តំបន់ដែលជាជម្រកធម្មជាតិសំខាន់ៗ ដូចជា ផ្លូវដើររបស់សត្វព្រៃនៅតាមបណ្ដោយផ្លូវទឹកដែលត្រូវការពារ។

ង. កត់សម្គាល់ពីវត្តមាននៃអនុផលព្រៃឈើ ជាពិសេសរុក្ខជាតិផលិតជ័រចុង និងឫស្សី ហើយចែករំលែកធនធាននេះដល់សហគមន៍ដែលមានស្រាប់។

នៅពេលដែលលក្ខណៈព្រៃទាំងអស់នេះត្រូវបានកំណត់ ត្រូវពិចារណាពីគុណភាពរបស់ទីតាំងទាក់ទងនឹងជម្រៅដី សណ្ឋានដី (ដីឥដ្ឋកាន់តែច្រើនផ្ដល់គុណភាពនៃការផ្ទុកទឹកបានកាន់តែ

ល្អសម្រាប់ការប្រើប្រាស់ខាងកសិកម្ម) និងវត្ថុមានរបស់ថ្ម។ មិនត្រូវប៉ុនប៉ងកែប្រែព្រៃនៅលើទីតាំងដែលមានស្រទាប់ដីរាក់នៅលើថ្ម ឬ នៅក្នុងស្ថានភាពដែលមានការប្រើប្រាស់ជីគីមី ឬ ជីលាមកសត្វ ជាពិសេសជាតិផូស្វ័រសម្រាប់បន្លែ ព្រោះមិនមានលទ្ធភាពទិញ ឬ មិនអាចធ្វើទៅបាន។

**ឧបសម្ព័ន្ធទី ២** :

## រូបមន្តបែងចែកដីសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មជនបទ

| ប្រភេទ | ការបែងចែកដីសម្រាប់មុខសញ្ញាអ្នកទទួលដីម្នាក់ ($US) | | |
|---|---|---|---|
| | ដីលំនៅឋាន ប៉ុណ្ណោះ | ដីកសិកម្ម លក្ខណៈគ្រួសារ ប៉ុណ្ណោះ | ដីលំនៅឋាន និង ដីកសិកម្ម |
| *ការរៀបចំក្បាលដី* | | | |
| ការវាស់វែងដី | ២ | ៤ | ៤ |
| ការសម្អាតដី | ០ | ២០០ | ២០០ |
| ការកំណត់ព្រំប្រទល់ | ២៥ | ២៥ | ២៥ |
| ផ្លូវចូល | ២៣ | ៧១ | ៧១ |
| ***សរុបរងសម្រាប់ការរៀបចំក្បាលដី*** | ***៥០*** | ***៣០០*** | ***៣០០*** |
| *ការឧបត្ថម្ភដល់ការចូលតាំងទីលំនៅដំបូង* | | | |
| ការចាប់ផ្តើមផ្តល់កញ្ចប់ | ៥០ | ១៥០ | ១៥០ |
| ការឧបត្ថម្ភសម្រាប់ជីវភាពរស់នៅ | ០ | ២០០ | ២០០ |
| ***សរុបរងសម្រាប់ការឧបត្ថម្ភដល់ការចូលតាំងទីលំនៅដំបូង*** | ***៥០*** | ***៣៥០*** | ***៣៥០*** |
| *ការផ្តល់សេវាកម្មនៅជនបទ* | | | |
| ការវាយតម្លៃតម្រូវការផ្នែកកសិកម្ម | ០ | ២ | ២ |
| ការផ្សព្វផ្សាយកសិកម្មឆ្នាំទី1 | ០ | ២០ | ២០ |
| ការផ្សព្វផ្សាយកសិកម្មឆ្នាំទី2 | ០ | ២០ | ២០ |
| យុទ្ធនាការផ្សព្វផ្សាយការប្រើប្រាស់ទឹក កម្មវិធីអនាម័យ និងទឹកស្អាត | ៥ | ០ | ៥ |
| ការផ្តល់សេវាកម្មផ្សេងៗទៀត | ៤៥ | ៨ | ៥៣ |
| ***សរុបរងសម្រាប់ការផ្តល់សេវាកម្មតាមជនបទ*** | ***៥០*** | ***៥០*** | ***៨០*** |
| *ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធជនបទ* | | | |
| ផ្លូវប្រើប្រាស់គ្រប់រដូវកាល | ៥០ | ១២៥ | ១៥០ |
| ការផ្គត់ផ្គង់ទឹកនៅជនបទ | ៧៥ | ០ | ៧៥ |
| ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត | ២៥ | ២៥ | ៧៥ |
| ***សរុបរងសម្រាប់ហេដ្ឋារចនាសម្ព័ន្ធជនបទ*** | ***១៥០*** | ***១៥០*** | ***៣០០*** |
| ***សរុបសម្រាប់ហេដ្ឋារចនាសម្ព័ន្ធជនបទ និងសេវាកម្ម*** | ***៣០០*** | ***៨៥០*** | ***១០៥០*** |

**ឧបសម្ព័ន្ធទី ៣** :

# បទដ្ឋានបច្ចេកទេសសម្រាប់ការរៀបចំដី

ការរៀបចំដីរួមមានសកម្មភាពមួយចំនួន ឬ សកម្មភាពទាំងអស់ដូចខាងក្រោមនេះ :

- ការកាប់ដើមឈើ គាស់គល់ឈើ និងឫសឈើចេញ
- ការកាប់ឆ្ការគុម្ពោធព្រៃ
- ការយកដុំថ្មចេញ
- ការឈូសឆាយសំបុកស្រមោច
- ការពង្រាបដី
- ការភ្ជួរដី

តំបន់ដែលត្រូវអនុត្តជាមួយនឹងសកម្មភាពនីមួយៗ គឺមានបង្ហាញនៅក្នុងផែនទីព្រាង។

បរិមាណឯកតាសម្រាប់សកម្មភាពទាំងអស់ គឺមួយហិកតា។ ការវាស់វែង គឺធ្វើទៅកាន់ដី 0,១ហិកតាដែលនៅជិតបំផុត។

ទំហំការងារជាក់ស្តែងដែលត្រូវធ្វើសម្រាប់ដីមួយហិកតានឹងមានការប្រែប្រួលទៅតាមស្ថានភាពជាក់ស្តែងរបស់ទីតាំង។ ដូច្នេះ អ្នកដេញថ្លៃត្រូវតែពិនិត្យមើលទីតាំងដោយយកចិត្តទុកដាក់មុនពេលដេញថ្លៃ។ កិច្ចសន្យានឹងត្រូវអនុវត្តដោយផ្អែកទៅលើការយល់ឃើញថាអ្នកឈ្នះក្នុងការដេញថ្លៃបានយល់យ៉ាងច្បាស់អំពីស្ថានភាពជាក់ស្តែងរបស់ទីតាំង។

### ***ការកាប់ដើមឈើ គាស់គល់ឈើ និងឫសឈើចេញ***

អ្នកទទួលការត្រូវសម្អាតតំបន់ដែលបានបង្ហាញនៅក្នុងទីតាំងដោយកាប់ដើមឈើចេញ និងគល់ឈើទាំងអស់ដែលមានអង្កត់ផ្ចិតលើសពី ៧៥មម។ ត្រូវគាស់គល់ឈើ និងឫសឈើចេញក្នុងជម្រៅដែលមិនតិចជាង ៦00មម ចុះក្នុងដី។ រណ្តៅដែលកើតចេញពីការគាស់ដើមឈើ គល់ឈើ និងឫសឈើចេញត្រូវតែចាក់ដីបំពេញវិញ ហើយបង្ហាប់ឲ្យណែនយ៉ាងតិចបំផុតមានកំហាប់ស្មើនឹងដីដែលនៅជុំវិញនោះ ធ្វើដូចនេះដើម្បីកុំឲ្យនៅមានក្រហូងជ្រៅលើសពី ៥0មម។

មិនត្រូវកាប់ដើមឈើខាងក្រោមនេះចេញទេ លុះត្រាតែមានការណែនាំឲ្យធ្វើដោយផ្ទាល់ពីសំណាក់អ្នកត្រួតពិនិត្យបច្ចេកទេស:

- ដើមឈើដែលបានដាក់សញ្ញាចំណាំនៅលើផែនទីព្រាងថាត្រូវតែរក្សាទុក

- ដើមឈើដែលដុះក្នុងចម្ងាយ ០,៥ម នៃខ្សែបន្ទាត់ព្រំប្រទល់ ដូចមានបង្ហាញនៅលើផែនទីព្រាង
- ដើមឈើដែលមានអង្កត់ផ្ចិតធំជាង ៣00មម ។

## ការកាប់សម្អាតគុម្ពោតព្រៃ និងរុក្ខជាតិតូចៗ

អ្នកទទួលការត្រូវសម្អាតតំបន់ដែលបានចង្អុលបង្ហាញដោយធ្វើការកាប់សម្អាតគុម្ពោតព្រៃ និងរុក្ខជាតិតូចៗដែលមានកម្ពស់លើសពី ១00មម ខ្ពស់ជាងនីវ៉ូដី ហើយត្រូវប្រមូលសំណល់ពីការកាប់នោះចេញ ឲ្យអស់ពីទីតាំង។

## ការប្រមូលយកដុំថ្មចេញ

អ្នកទទួលការត្រូវប្រមូលយកដុំថ្មចេញទាំងអស់ពីតំបន់ដែលបានបង្ហាញនៅក្នុងទីតាំង គឺដុំថ្មដែលមានទំហំតូចបំផុត (ទំហំតូចបំផុតដោយវាស់ចំពាក់កណ្តាលនៃដុំថ្មពីគែមម្ខាងទៅគែមម្ខាងទៀត) ធំជាង ២៥0មម ហើយដែលអាចមើលឃើញនៅលើផ្ទៃដី ឬ លេចចេញក្រោយការកាប់ដើមឈើចេញ ការបំផ្លាញសំបុក ការពង្រាបដី និងការភ្ជួរដី ឬសកម្មភាពផ្សេងៗទៀតដែលតម្រូវឲ្យធ្វើស្របតាមកិច្ចសន្យា។ គ្រប់រណ្តៅដែលកើតចេញពីការយកថ្មចេញត្រូវតែចាក់ដីបំពេញវិញ ហើយបង្ហាប់ឲ្យណែនឲ្យមានកំហាប់ដូចគ្នានឹងដីដែលនៅជុំវិញដើម្បីកុំឲ្យនៅមានក្រហូងជ្រៅជាង ៥0មម

## ការបំផ្លាញសំបុកស្រមោច/ដំបូកកណ្តៀរ

អ្នកទទួលការត្រូវឈ្វសឆាយសំបុកស្រមោច ឬ ដំបូកកណ្តៀរចេញពីតំបន់ដែលបានបង្ហាញនៅក្នុងទីតាំងសម្រាប់សំបុកស្រមោច ឬ ដំបូកដែលមានកម្ពស់លើសពី 0,៥ម ខ្ពស់ជាងនីវ៉ូដី។ ត្រូវឈ្វសឆាយសំបុកស្រមោច និងដំបូកកណ្តៀរចេញក្នុងជម្រៅ ២00មម ទាបជាងនីវ៉ូដីទូទៅ ហើយក្រហូងដែលកើតចេញពីការធ្វើបែបនេះត្រូវតែចាក់ដីបំពេញវិញ ហើយបង្ហាប់ឲ្យណែនដូចដីដែលនៅជុំវិញ ដើម្បីកុំឲ្យនៅមានក្រហូងជ្រៅជាង ៥0មម។

## ការពង្រាបដី

អ្នកទទួលការត្រូវដាក់ជូនអ្នកត្រួតពិនិត្យបច្ចេកទេសនូវផែនការរៀបចំទ្រង់ទ្រាយដីនៅក្នុងតំបន់ដែលបានបង្ហាញក្នុងទីតាំងទៅជាពីរប្រភេទ :

- ជម្រេលដែលមានមុំចន្លោះបន្ទាត់ឈរ ១ និងបន្ទាត់ដេក ៣ និងបន្ទាត់ឈរ ៣ និង បន្ទាត់ដេក ៥។

- ដីរាបស្មើដែលមិនមានការប្រែប្រួលអ្វីទាំងអស់ទាក់ទងនឹងកម្ពស់ដែលលើសពី ១00មម ពីផ្នែកម្ខាងទៅផ្នែកម្ខាងទៀត ហើយមិនមានចំណុចខ្ពស់ ឬ ទាបដែលប្រែប្រួលលើសពី ១00មម ពីនីវ៉ូដីទូទៅនៅព័ទ្ធជុំវិញ។

ស្របតាមការឯកភាពយល់ព្រមទៅលើផែនការពីសំណាក់អ្នកត្រួតពិនិត្យបច្ចេកទេស អ្នកទទួលការត្រូវបន្តរានសម្អាតដី និងរក្សាទុកដីស្រទាប់លើត្រឹមជម្រៅ ១៥0មម។ បន្ទាប់ពីការរៀបចំ ទ្រង់ទ្រាយដីស្របទៅតាមផែនការ និងការយល់ព្រមពីអ្នកត្រួតពិនិត្យបច្ចេកទេសរួច អ្នកទទួលការត្រូវពង្រាយដីស្រទាប់លើឲ្យស្មើគ្នាពីលើផ្ទៃដីរាបស្មើ។

## ការភ្ជួរដី

អ្នកទទួលការត្រូវប្រើប្រាស់ត្រាក់ទ័រដែលមានកំលាំងមិនតិចជាង ៥0 bhp ដើម្បីភ្ជួរដី។ អ្នកទទួលការត្រូវភ្ជួរដីតំបន់ដែលបានបង្ហាញក្នុងទីតាំងឲ្យដល់ជម្រៅមិនតិចជាង ១៥0 មម ហើយនឹងដាស់ដីម្តង។

## ការចោលកាកសំណល់

មិនមានផ្តល់ប្រាក់បន្ថែមសម្រាប់ការប្រមូលកាកសំណល់បោះចោលឡើយ។ កាកសំណល់ធម្មជាតិ រួមមាន រុក្ខជាតិតូចៗដែលយកចេញមកពីទីតាំង ដែល [អាច/មិនអាច][១៨] ដុតបាននៅលើទីតាំង។ រាល់ការដុតទាំងអស់ត្រូវធ្វើឡើងនៅក្នុងពេលវេលា និងទីតាំងដែលមានការព្រមព្រៀងជាមុនពីអ្នកត្រួតពិនិត្យបច្ចេកទេស។

ចំពោះដុំថ្ម កាកសំណល់សំបុកស្រមោច និងកាកសំណល់រុក្ខជាតិតូចៗដែលមិនអាចដុតបាន គឺត្រូវយកទៅបោះចោលនៅទីតាំងដែលបានដាក់សញ្ញាចំណាំនៅលើផែនទីព្រាង។

អ្នកទទួលការមានសិទ្ធិប្រមូលយកកាកសំណល់គ្រប់ប្រភេទចេញពីទីតាំង ហើយប្រើប្រាស់សម្រាប់គោលបំណងណាមួយនូវប្រភេទវត្ថុដែលតម្រូវឲ្យយកចេញពីទីតាំងស្របតាមកិច្ចសន្យា។

## បទដ្ឋានបច្ចេកទេសសម្រាប់ការកំណត់ព្រំដី

ការងារកំណត់ព្រំដីរួមមានសកម្មភាពកំណត់ព្រំក្បាលដីដូចមានបង្ហាញនៅលើផែនទីព្រាងដោយប្រើបង្គោលព្រំដីអចិន្ត្រៃយ៍ធ្វើពីបេតុង។ ទីតាំងព្រំក្បាលដីត្រូវឲ្យមានការបញ្ជាក់ ពីការិយាល័យសុរិយោដីរបស់មន្ទីរគ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់។

---

[១៨] លុបចោលប្រសិនបើសមស្របទៅនឹងទីតាំងជាក់លាក់

បរិមាណឯកតាសម្រាប់ការកំណត់ព្រំដី គឺបង្គោលបេតុងមួយដើម។

ការងារដែលត្រូវធ្វើសម្រាប់ការកំណត់ព្រំដីនឹងមានភាពខុសគ្នាអាស្រ័យទៅលើស្ថានភាពជាក់ស្តែងរបស់ទីតាំង។ ដូច្នេះហើយ អ្នកដេញថ្លៃត្រូវតែពិនិត្យមើលទីតាំងដោយយកចិត្តទុកដាក់មុនពេលធ្វើការដេញថ្លៃ។ កិច្ចសន្យានឹងត្រូវអនុវត្តដោយផ្អែកលើការយល់ឃើញថា អ្នកឈ្នះក្នុងការដេញថ្លៃបានយល់យ៉ាងច្បាស់អំពីស្ថានភាពជាក់ស្តែងរបស់ទីតាំង។

## បង្គោលបេតុង

បង្គោលបេតុងដែលប្រើសម្រាប់កំណត់ព្រំដីត្រូវមានរាងបួនជ្រុង ជាបង្គោលបេតុងចាក់ពុម្ព ផលិតឡើងពីបេតុងរឹងមាំ។ គុលបង្គោលបេតុងត្រូវមានអង្កត់ផ្ចិតអបប្បរមា ១១០មម² និងចុងមានអង្កត់ផ្ចិត ១០០ម²។ បង្គោលព្រំត្រូវមានប្រវែងអប្បបរមា ១,៨ម។ បេតុងដែលប្រើសម្រាប់ផលិតបង្គោលព្រំដីត្រូវលាយដោយប្រើបរិមាណស៊ីម៉ង់ត៍ ១ + ខ្សាច់ ២ + កំម្ទេចថ្ម ៤ ឬ មានកម្លាំងអប្បបរមា ២០N/មម²។ បង្គោលព្រំដីត្រូវមានដែកសរសៃដែលមានអង្កត់ផ្ចិតតិចបំផុត ៦មម ចំនួន ៤ដើម ហើយដែកសរសៃនីមួយៗត្រូវមានប្រវែងស្មើគ្នានឹងប្រវែងបណ្តោយរបស់បង្គោល។ បង្គោលត្រូវមានរន្ធ ២ សម្រាប់ស៊កខ្សែលួស (មិនតម្រូវឲ្យអ្នកទទួលការផ្តល់ខ្សែលួសនោះទេ)។

## ការដាំបង្គោល

បង្គោល គឺត្រូវដាំនៅលើដីក្នុងជម្រៅអប្បបរមា ០,៤ម និងជម្រៅអតិបរមា ០,៧ម (ឬជម្រៅអបប្បរមា ១/៣ នៃប្រវែងសរុបរបស់បង្គោល ប្រសិនបើបង្គោលវែងជាង ១,៨ម)។ ត្រូវចាក់ដីចូលក្នុងរណ្តៅដាំបង្គោលវិញ ហើយបង្ហាប់ឲ្យហាប់ណែនដើម្បីឲ្យបង្គោលមានភាពរឹងមាំ ហើយមិនអាចដកចេញដោយដៃបាន។ លំងាកអតិបរមាពីបន្ទាត់ឈរដែលអនុញ្ញាតបាន គឺ ៥០មម ដោយវាស់ចេញពីផ្នែកកំពូលរបស់បង្គោលទៅដល់នីវ៉ូដី។ ត្រូវដាំបង្គោលដោយឲ្យរន្ធស៊កខ្សែលួសរត់ត្រង់គ្នាតាមបណ្តោយព្រំដីឲ្យចំពាក់កណ្តាលរវាងខ្សែបន្ទាត់ព្រំដីទាំងសងខាងនៅត្រង់កែង។

## ចំនួន និងទីតាំងរបស់បង្គោល

ចម្ងាយអតិប្បបរមារវាងបង្គោលនីមួយៗ គឺ ៥០ម។ ត្រូវដាំបង្គោលនៅគ្រប់កែង និងកន្លែងពុះចែករវាងព្រំក្បាលដីនីមួយៗ។ ត្រូវដាំបង្គោលដោយធ្វើយ៉ាងណាកុំឲ្យមានចំណុចដែលមានចម្ងាយផ្តេកឆ្ងាយលើសពី ០,៥ម ពីខ្សែបន្ទាត់ត្រង់ដែលតភ្ជាប់រវាងបង្គោលដែលនៅជិតគ្នា។ ទីតាំងព្រំក្បាលដីទាំងអស់ត្រូវមានការបញ្ជាក់ពីការិយាល័យសុរិយោដី។

## បទដ្ឋានសម្រាប់ផ្លូវចូល

ភ្នាក់ងារប្រតិបត្តិសម្រាប់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺជាអគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ចដែលមានមូលដ្ឋាននៅក្នុងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ យោងតាមអនុសារណៈនៃការយោគយល់គ្នា ដែលបានចុះហត្ថលេខារវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងមហាផ្ទៃនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ ២០០៧ បានចែងថា លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិទទួលខុសត្រូវនូវរាល់ទិដ្ឋភាពប្រតិបត្តិការរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចនៅថ្នាក់ក្រោមជាតិ រួមទាំងការគ្រប់គ្រងកិច្ចសន្យា ការគ្រប់គ្រងហិរញ្ញវត្ថុ និងការត្រួតពិនិត្យ និងការវាយតម្លៃប្រតិបត្តិការ ក៏ដូចជាការទទួលខុសត្រូវចំពោះការត្រួតពិនិត្យលើការអនុវត្តនៅក្នុងក្របខ័ណ្ឌនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៧ ក្រុមបង្គោលរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ត្រូវបានបង្កើតឡើងនៅក្នុងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិតាមសេចក្តីសម្រេចចេញដោយឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ក្រុមបង្គោលរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចដឹកនាំដោយអនុប្រធានគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច និងមានសមាជិកដែលធ្វើការនៅក្នុងផ្នែកនីមួយៗរបស់អង្គភាពគាំទ្រកម្មវិធី។

**មន្ត្រីរដ្ឋបាលទូទៅគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច** គឺជាសមាជិករបស់ក្រុមបង្គោលរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ហើយធ្វើការនៅផ្នែករដ្ឋបាលគម្រោងរបស់អង្គភាពគាំទ្រកម្មវិធី។ មន្ត្រីរដ្ឋបាលទូទៅរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ជួយប្រធានផ្នែករដ្ឋបាលកម្មវិធី ដើម្បីធានាថា:

- ការទទួលខុសត្រូវរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ សម្រាប់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការ អភិវឌ្ឍសេដ្ឋកិច្ច ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធផល និងប្រសិទ្ធភាព និងស្របទៅតាមគោលការណ៍របស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច
- រាល់ផ្នែករបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិសម្រាប់ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ត្រូវរៀបចំដើម្បីទទួលការយល់ព្រមពីគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចនៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ដើម្បីបញ្ជូនបន្តឲ្យបានទាន់ពេលទៅកាន់ប្រធានគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

- រាល់លិខិតទាក់ទង និងលិខិតរដ្ឋបាលរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ត្រូវគ្រប់គ្រង និងចងក្រងជាឯកសារស្របទៅតាមនីតិវិធីរដ្ឋបាលរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឲ្យបានទាន់ពេលវេលា
- រាល់ឧបករណ៍សម្ភារៈណាមួយរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវដាក់បញ្ចូលឲ្យបានត្រឹម ត្រូវទៅក្នុងសន្និធិនៃឧបករណ៍សម្ភារៈរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការ អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងត្រូវគ្រប់គ្រងស្របទៅតាមគោលនយោបាយ និងនីតិវិធី
- គោលនយោបាយលើការដឹកជញ្ជូនរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវអនុវត្តចំពោះរាល់យានយន្តរបស់ គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចឲ្យបានត្រឹមត្រូវ
- ទីធ្លា និងរាល់អាគារផ្សេងៗ ត្រូវរៀបចំដើម្បីធ្វើកិច្ចប្រជុំ សិក្ខាសាលា និងការបណ្តុះបណ្តាលដែលចាំបាច់
- រៀបចំរបាយការណ៍ និងផែនការការងារដទៃទៀតប្រចាំខែនៅពេលចាំបាច់
- អនុវត្តភារកិច្ចដទៃទៀតដែលស្នើឡើងដោយប្រធានផ្នែករដ្ឋបាលកម្មវិធី និងប្រធានសម្របសម្រួលរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។

## លក្ខណសម្បត្តិ និងបទពិសោធន៍

បេក្ខជនដាក់ពាក្យស្នើសុំត្រូវមានលក្ខណសម្បត្តិដូចខាងក្រោមៈ

- មានបរិញ្ញាបត្រ និង/ឬ បទពិសោធន៍សមស្រប
- មានជំនាញរៀបចំផែនការ ការគ្រប់គ្រង និងការធ្វើរបាយការណ៍
- មានជំនាញទំនាក់ទំនងបានល្អ ទាំងសរសេរ និងនិយាយជាភាសាខ្មែរ (ចាំបាច់) និងភាសាអង់គ្លេស (កាន់តែប្រសើរ)។

# លក្ខខណ្ឌការងារ

មុខតំណែង: មន្ត្រីត្រួតពិនិត្យ តាមដាន និងវាយតម្លៃគម្រោងឡាសិត
ឈ្មោះគម្រោង: គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច
ខ្ទង់ថវិកា:
កន្លែងបំពេញភារកិច្ច: រាជធានីភ្នំពេញ
រយៈពេល: មួយឆ្នាំ (ដោយមានការត្រួតពិនិត្យការអនុវត្តការងារប្រចាំឆ្នាំ)

## ទិដ្ឋភាពទូទៅ

ស្ថិតនៅក្រោមអំណាចទាំងស្រុងរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិទទួលខុសត្រូវក្នុងការអនុវត្តកម្មវិធីរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ឆ្នាំ២០០៧-២០០៩។ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ស្ថិតនៅក្រោមការគ្រប់គ្រងទាំងស្រុងរបស់អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ។ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) មានអង្គភាពគាំទ្រកម្មវិធីមួយដែលមាន ៤ ផ្នែក: ផ្នែករដ្ឋបាលកម្មវិធី ផ្នែកហិរញ្ញវត្ថុ ផ្នែកតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយ និងផ្នែកគ្រប់គ្រងកិច្ចសន្យា និងសម្របសម្រួលគម្រោង។

គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺជាគម្រោងមួយសម្រាប់គាំទ្រការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចរបស់រាជរដ្ឋាភិបាលដើម្បីចែកចាយដីទៅឲ្យប្រជាពលរដ្ឋគ្មានដី និងមានដីតិចតួចតាមរយៈសម្បទានដីសង្គមកិច្ចដើម្បីលើកកម្ពស់ជីវភាពគ្រួសារក្រីក្រ និងប្រជាពលរដ្ឋងាយរងគ្រោះតាមរយៈសម្បទានដីសង្គមកិច្ចផ្អែកលើឃុំ។ គោលបំណងរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺដើម្បី:

- ចែកដីរដ្ឋដែលសមស្របសម្រាប់កសិកម្ម រួមជាមួយនឹងសេវាកម្មគាំទ្រសមស្របដល់គ្រួសារគ្មានដី និងមានដីតិចតួចពិតប្រាកដ និង
- ណែនាំ និងអនុវត្តនូវដំណើរការប្រកបដោយតម្លាភាព និងមានបទដ្ឋានសម្រាប់ការអនុវត្តទូលំទូលាយនូវសម្បទានដីសង្គមកិច្ចដែលបានផ្តួចផ្តើមនៅថ្នាក់មូលដ្ឋាន។
- ការអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចគោរពតាមគោលការណ៍ដូចខាងក្រោម:
- លើកកម្ពស់អភិបាលកិច្ចល្អ និងនីតិរដ្ឋ
- គាំទ្រ និងពង្រឹងរបៀបវារៈកំណែទម្រង់ដីរបស់រដ្ឋាភិបាល
- លើកទឹកចិត្តឲ្យមានការចូលរួមពីប្រជាពលរដ្ឋ

- ទប់ស្កាត់ការខូចខាតបរិស្ថាន
- លើកកម្ពស់តម្លាភាព និងគណនេយ្យភាព និង
- ធានាបាននូវការរីកចម្រើនប្រកបដោយចីរភាព។

ភ្នាក់ងារប្រតិបត្តិសម្រាប់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺជាអគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ចដែលមានមូលដ្ឋាននៅក្នុងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ យោងតាមអនុសារណៈនៃការយោគយល់គ្នា ដែលបានចុះហត្ថលេខារវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងមហាផ្ទៃនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ ២០០៧ បានចែងថា លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិទទួលខុសត្រូវនូវរាល់ទិដ្ឋភាពប្រតិបត្តិការរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចនៅថ្នាក់ក្រោមជាតិ រួមទាំងការគ្រប់គ្រងកិច្ចសន្យា ការគ្រប់គ្រងហិរញ្ញវត្ថុ និងការត្រួតពិនិត្យ និងការវាយតម្លៃប្រតិបត្តិការ ក៏ដូចជាការទទួលខុសត្រូវចំពោះការត្រួតពិនិត្យលើការអនុវត្តនៅក្នុងក្របខ័ណ្ឌនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៧ ក្រុមបង្គោលរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ត្រូវបានបង្កើតឡើងនៅក្នុងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិតាមសេចក្តីសម្រេចចេញដោយឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ក្រុមក្រុមបង្គោលរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចដឹកនាំដោយអនុប្រធានគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច និងមានសមាជិកដែលធ្វើការនៅក្នុងផ្នែកនីមួយៗរបស់អង្គភាពគាំទ្រកម្មវិធី។

**មន្ត្រីត្រួតពិនិត្យ តាមដាន និងវាយតម្លៃរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច** គឺជាសមាជិករបស់ក្រុមបង្គោលរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ហើយធ្វើការនៅផ្នែកតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយរបស់អង្គភាពគាំទ្រកម្មវិធី។ មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ជួយប្រធានផ្នែកតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយ ដើម្បីធានាថា ការពិនិត្យ និងវាយតម្លៃទៅលើរាល់ដំណើរការរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ត្រូវបានអនុវត្តស្របទៅតាមអនុសារណៈនៃការយោគយល់គ្នា និងកិច្ចព្រមព្រៀងរវាងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) និងអគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច។

**សហប្រតិបត្តិការបច្ចេកទេស**
(**អ្នកផ្តល់ប្រឹក្សា**)

**ភារកិច្ចជាក់លាក់**

ភារកិច្ច និងការទទួលខុសត្រូវ:

- ធ្វើការជាមួយមន្ត្រីត្រួតពិនិត្យ និងវាយតម្លៃរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច នៅក្នុងអគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច
- ធ្វើការជាមួយទីប្រឹក្សាផ្នែកព័ត៌មានវិទ្យា និងផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាលគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត ដើម្បីបញ្ចូល កិច្ចសន្យានៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ចូលទៅក្នុងទិន្នន័យកិច្ចសន្យារបស់ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប)
- រៀបចំផែនការការងារត្រួតពិនិត្យ តាមដាន និងវាយតម្លៃប្រតិបត្តិការរបស់គម្រោងបែងចែកដី ដើម្បីសង្គមកិច្ចដែលជាផ្នែកមួយនៃការដាក់ជូនឯកសាររបស់គណៈកម្មាធិការជាតិសម្រាប់ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) សម្រាប់ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច
- ធានាថា ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចត្រូវបានគេយល់ដឹង និងអនុវត្តដោយស្ថាប័នទាំងអស់ដែលកំពុងតែអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច
- សម្របសម្រួលកិច្ចដំណើរការពិនិត្យមើលការអនុវត្តគម្រោងថ្នាក់ខេត្តរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច
- ពិនិត្យមើលរបាយការណ៍ដែលទទួល បានពីបណ្តាខេត្តដែលស្ថិតនៅក្រោមប្រព័ន្ធរាយការណ៍ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) និងពិនិត្យដើម្បីបញ្ចូលគ្នាឲ្យទៅជារបាយការណ៍តែមួយ
- ជួយក្នុងការរៀបចំ និងការអនុវត្តកម្មវិធីបណ្តុះបណ្តាល (រួមមានសម្ភារៈ និងមេរៀនសម្រាប់ការបណ្តុះបណ្តាល) ស្តីពីនីតិវិធីត្រួតពិនិត្យ និងវាយតម្លៃ និងរាល់ឧបករណ៍សម្រាប់មន្ត្រីថ្នាក់ជាតិ និងថ្នាក់ខេត្តដែលស្របតាមផែនការត្រួតពិនិត្យ និងវាយតម្លៃរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប)
- ធានាថា ប្រព័ន្ធទិន្នន័យកិច្ចសន្យារបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ត្រូវបានរក្សាទុកយ៉ាងត្រឹមត្រូវ ដោយគោរពតាម កិច្ចសន្យារបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច
- សម្របសម្រួល/ចូលរួមក្នុងការបង្កើត និងការអនុវត្តការសិក្សា និងស្ទង់មតិការត្រួតពិនិត្យ និងវាយតម្លៃ និងក្នុងការប្រមូល និងការវិភាគទិន្នន័យពាក់ព័ន្ធ
- ចុះតាមខេត្តក្នុងករណីចាំបាច់ដើម្បីតាមដានមើលទាំងបញ្ហាទូទៅ និងជាក់ស្តែងទាក់ទិននឹងការត្រួតពិនិត្យដំណើរការរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

- ធ្វើការយ៉ាងជិតស្និទ្ធជាមួយមន្ត្រីគោលនយោបាយ និងប្រព័ន្ធ ដើម្បីធានាថា មេរៀនគោលនយោបាយកំពុងត្រូវបានបង្កើតឡើង និងផ្សព្វផ្សាយតាមរយៈប្រព័ន្ធរាយការណ៍ និងប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ
- បំពេញភារកិច្ចដទៃទៀតដែលតម្រូវដោយប្រធានផ្នែកត្រួតពិនិត្យ និងវាយតម្លៃ និងព័ត៌មាន ឬ ប្រធានសម្របសម្រួលគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

## លក្ខណសម្បត្តិ និងបទពិសោធន៍

បេក្ខជនដាក់ពាក្យសុំត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម:

- មានបរិញ្ញាបត្រផ្នែកអភិវឌ្ឍសេដ្ឋកិច្ចសង្គម និង/ឬ មានបទពិសោធន៍សមស្រប
- មានបទពិសោធន៍យ៉ាងតិច ៥ ឆ្នាំនៅក្នុងមុខតំណែងប្រហាក់ប្រហែល និង/ឬ មុខតំណែងដែល មានការទទួលខុសត្រូវខាងធ្វើរបាយការណ៍ និងខាងការគ្រប់គ្រងផ្ទាល់
- មានជំនាញក្នុងការរៀបចំគម្រោង ការគ្រប់គ្រងគម្រោង ការត្រួតពិនិត្យ និងវាយតម្លៃគម្រោង និងធ្វើរបាយការណ៍
- មានបទពិសោធន៍ក្នុងការប្រើប្រាស់ប្រព័ន្ធកុំព្យូទ័រ (កម្មវិធី Word processing Excel និង database)
- មានចំណេះដឹង និងមានបទពិសោធន៍ផ្នែក Spreadsheet និងការងារគ្រប់គ្រងទិន្នន័យ
- ជាមន្ត្រីរាជការនៅក្រសួងនៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប)
- មានជំនាញទំនាក់ទំនងល្អ ដោយរួមបញ្ចូលភាពស្ទាត់ជំនាញទាំងការសរសេរ និងនិយាយភាសាអង់គ្លេស និងភាសាខ្មែរ។

# លក្ខខណ្ឌការងារ

មុខតំណែង: សវនករផ្ទៃក្នុងគម្រោងឡាសិត
ឈ្មោះគម្រោង: គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច
ខ្នង់ថវិកា:
កន្លែងបំពេញភារកិច្ច: រាជធានីភ្នំពេញ
រយៈពេល: មួយឆ្នាំ (ដោយមានការត្រួតពិនិត្យការអនុវត្តការងារប្រចាំឆ្នាំ)
មូលដ្ឋាន: កិច្ចសន្យាផ្តល់ប្រឹក្សាជាលក្ខណៈបុគ្គល
និយោជក: គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប)

**ទិដ្ឋភាពទូទៅ**

ស្ថិតនៅក្រោមអំណាចទាំងស្រុងរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ទទួលខុសត្រូវក្នុងការអនុវត្តកម្មវិធីរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ឆ្នាំ ២០០៧-២០០៩។ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ស្ថិតនៅក្រោមការគ្រប់គ្រងទាំងស្រុងរបស់អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ។ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) មានអង្គភាពគាំទ្រកម្មវិធីមួយដែលមាន ៤ ផ្នែក: ផ្នែករដ្ឋបាលកម្មវិធី ផ្នែកហិរញ្ញវត្ថុ ផ្នែកតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយ និងផ្នែកគ្រប់គ្រងកិច្ចសន្យា និងសម្របសម្រួលគម្រោង។

គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺជាគម្រោងមួយសម្រាប់គាំទ្រការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចរបស់រាជរដ្ឋាភិបាលដើម្បីចែកចាយដីទៅឲ្យប្រជាពលរដ្ឋគ្មានដី និងមានដីតិចតួចតាមរយៈសម្បទានដីសង្គមកិច្ចដើម្បីលើកកម្ពស់ជីវភាពគ្រួសារក្រីក្រ និងប្រជាពលរដ្ឋងាយរងគ្រោះតាមរយៈសម្បទានដីសង្គមកិច្ចផ្អែកលើឃុំ។ គោលបំណងរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺដើម្បី:

- ចែកដីរដ្ឋដែលសមស្របសម្រាប់កសិកម្ម រួមជាមួយនឹងសេវាកម្មគាំទ្រសមស្របដល់គ្រួសារគ្មានដី និងមានដីតិចតួចពិតប្រាកដ និង
- ណែនាំ និងអនុវត្តនូវដំណើរការប្រកបដោយតម្លាភាព និងមានបទដ្ឋានសម្រាប់ការអនុវត្តទូលំទូលាយនូវសម្បទានដីសង្គមកិច្ចដែលបានផ្តួចផ្តើមនៅថ្នាក់មូលដ្ឋាន។

ការអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គោរពតាមគោលការណ៍ដូចខាងក្រោមៈ

- លើកកម្ពស់អភិបាលកិច្ចល្អ និងនីតិរដ្ឋ
- គាំទ្រ និងពង្រឹងរបៀបវារៈកំណែទម្រង់ដីរបស់រដ្ឋាភិបាល
- លើកទឹកចិត្តឲ្យមានការចូលរួមពីប្រជាពលរដ្ឋ
- ទប់ស្កាត់ការខូចខាតបរិស្ថាន
- លើកកម្ពស់តម្លាភាព និងគណនេយ្យភាព និង
- ធានាបាននូវការរីកចម្រើនប្រកបដោយចីរភាព។

ភ្នាក់ងារប្រតិបត្តិសម្រាប់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺជាអគ្គលេខាធិការដ្ឋានសម្រាប់សម្បទានដីសង្គមកិច្ច ដែលមានមូលដ្ឋាននៅក្នុងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ យោងតាមអនុស្សរណៈយោគយល់គ្នា ដែលបានចុះហត្ថលេខារវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងមហាផ្ទៃនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៧ បានចែងថា លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិទទួលខុសត្រូវលើផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច លើកលែងតែសកម្មភាពណាដែលជាការទទួលខុសត្រូវផ្ទាល់របស់អគ្គលេខាធិការដ្ឋានសម្រាប់សម្បទានដីសង្គមកិច្ច។ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) គ្រប់គ្រង និងរៀបចំរបាយការណ៍ ស្តីពីមូលនិធិសម្រាប់ដំណើរការថ្នាក់ក្រោមជាតិទាំងអស់របស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈកិច្ចសន្យាជាមួយគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត និងគណៈកម្មាធិការប្រតិបត្តិរបស់ខ្លួន។ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្តីពីទិដ្ឋភាពដំណើរការរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចនៅថ្នាក់ក្រោមជាតិដែលរួមមានការគ្រប់គ្រងកិច្ចសន្យា ការគ្រប់គ្រងហិរញ្ញវត្ថុ និងការពិនិត្យ និងវាយតម្លៃប្រតិបត្តិការ និងត្រួតពិនិត្យការអនុវត្តការងារនៅក្នុងក្របខ័ណ្ឌកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិផ្ទេរការទទួលខុសត្រូវលើដំណើរការទាំងមូលទៅឲ្យគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្តនៅក្នុងបណ្តាខេត្តដែលចូលរួមក្នុងគម្រោង។ ប្រភេទភារកិច្ចប្រតិបត្តិការដែលមានកំណត់ត្រូវបានអនុវត្តនៅថ្នាក់ជាតិតាមរយៈក្រុមការងារគាំទ្រគម្រោងរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ការទទួលខុសត្រូវទាំងនោះរួមមានៈ

- ការគ្រប់គ្រងហិរញ្ញវត្ថុគម្រោងទាំងមូល

- ការធ្វើលទ្ធកម្មទាំងមូល
- ការគ្រប់គ្រងកិច្ចសន្យា
- ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ
- ការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ និង
- ការរៀបចំរបាយការណ៍ប្រចាំឆ្នាំ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ជ្រើសតាំងប្រធានសម្របសម្រួលគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដោយផ្តល់នូវសិទ្ធិពេញលេញក្នុងការត្រួតពិនិត្យ និងសម្របសម្រួលការចែករំលែកការទទួលខុសត្រូវរបស់ក្រុមការងារគាំទ្រគម្រោងនៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដោយគោរពតាមការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។

**សវនករផ្ទៃក្នុងរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច (គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ)** ទទួលខុសត្រូវចំពោះការត្រួតពិនិត្យសវនកម្មផ្ទៃក្នុងនៃមូលនិធិគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដែលរៀបចំដោយ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## ការគ្រប់គ្រងមុខតំណែង

សវនករផ្ទៃក្នុងរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច (គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ) រាយការណ៍ផ្ទាល់ទៅកាន់អគ្គនាយកនៃគណៈនាយករដ្ឋបាលមូលដ្ឋាន។

## ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ

សវនករផ្ទៃក្នុងរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច (គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ) ធ្វើការសហការយ៉ាងជិតស្និទ្ធជាមួយប្រធានសម្របសម្រួលគម្រោងរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច និងជាមួយទីប្រឹក្សាប្រតិបត្តិការអន្តរជាតិរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច និងទីប្រឹក្សាប្រតិបត្តិការជាតិរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។ សវនករផ្ទៃក្នុងរបស់សវនករផ្ទៃក្នុងរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច (គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ) ត្រូវបានផ្តល់ការណែនាំស្តីពីបញ្ហាបច្ចេកទេសដោយទីប្រឹក្សាសវនករផ្ទៃក្នុងអន្តរជាតិរបស់

គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដែលមានទំនាក់ទំនងគ្នានឹងអគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច។

សវនករផ្ទៃក្នុងរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច (គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ) សហការ និងចែករំលែកព័ត៌មានជាមួយសវនករផ្ទៃក្នុង របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) និងបណ្តាសវនករផ្ទៃក្នុងរបស់គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត។

## ភារកិច្ចជាក់លាក់

សវនករផ្ទៃក្នុងរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច (គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ) ទទួលខុសត្រូវមុខងារសវនកម្មផ្ទៃក្នុងដែលពាក់ព័ន្ធនឹងសកម្មភាពនានារបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដែលត្រូវបានផ្តល់ហិរញ្ញវត្ថុតាមរយៈគណនីគម្រោងដែលរៀបចំដោយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប)។ ពួកគាត់មិនទទួលខុសត្រូវចំពោះសវកម្មផ្ទៃក្នុងនៃសកម្មភាពដែលផ្តល់ហិរញ្ញវត្ថុតាមរយៈគណនីគម្រោងរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច នៃអគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច។

ជាក់ស្តែង ចំពោះមូលនិធិរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដែលគ្រប់គ្រងដោយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ សវនករផ្ទៃក្នុងរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច (គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ) នឹង:

១. ផ្ទៀងផ្ទាត់ការទូទាត់ប្រាក់សម្រាប់សកម្មភាពនានាទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាភាពត្រឹមត្រូវលើឯកសារ និងសកម្មភាពអនុវត្តជាក់ស្តែង ហើយថា កំណត់ត្រាគណនេយ្យ និងការចុះឯកសារឲ្យបានត្រឹមត្រូវ ត្រូវបានគេរក្សាទុកសម្រាប់សកម្មភាពរបស់គម្រោង

២. អនុវត្តការពិនិត្យជាទៀងទាត់ និងត្រួតពិនិត្យការគ្រប់គ្រងហិរញ្ញវត្ថុ និងមុខងារលទ្ធកម្ម ដើម្បីធានាការអនុលោមតាមគោលនយោបាយនីតិវិធី និងការអនុវត្តពាក់ព័ន្ធនឹងភាពត្រឹមត្រូវទៅតាមប្រព័ន្ធរបស់គម្រោង

៣. ចុះតាមមូលដ្ឋានម្តងម្កាល ដើម្បីវាយតម្លៃការប្រកាន់ខ្ជាប់ទៅតាមនីតិវិធីដែលបានបង្កើតនៅគ្រប់កម្រិត ការអនុវត្តសកម្មភាពរបស់គម្រោង ជាពិសេសនៅកម្រិតថ្នាក់ក្រោមជាតិ និងដើម្បីធានាការលេចរូបរាងជារូបវន្តនៃទ្រព្យសម្បត្តិ និងលទ្ធផលគម្រោង

៤. ពិនិត្យមើលភាពអាចទទួលបាន ភាពសមហេតុសមផល និងភាពត្រឹមត្រូវនៃការចំណាយលើគម្រោងដែលកើតឡើងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងថា មូលនិធិត្រូវបានគេយកទៅប្រើប្រាស់តែទៅលើគម្រោងដែលគេផ្តល់ឲ្យតែប៉ុណ្ណោះ

៥. ត្រួតពិនិត្យមើលថា កំណត់ត្រាដែលគ្រប់គ្រាន់ត្រូវបានគេរក្សាទុកយ៉ាងត្រឹមត្រូវ ដើម្បីកត់ត្រា និងត្រួតពិនិត្យមើលទ្រព្យសម្បត្តិ ហើយថា ការផ្ទៀងផ្ទាត់ទ្រព្យសម្បត្តិជាក់ស្តែង កំពុងត្រូវបានធ្វើឡើងតាមរយៈការគ្រប់គ្រងតាមកាលកំណត់។ អនុវត្តការផ្ទៀងផ្ទាត់ទៅលើទ្រព្យសម្បត្តិជាក់ស្តែងលើមូលដ្ឋានការធ្វើតេស្ត

៦. ពិនិត្យមើលការអនុវត្តលទ្ធកម្មម្តងម្កាលដើម្បីធានាថា ការអនុវត្តទាំងនោះត្រូវបានរៀបចំស្របទៅតាមនីតិវិធីអនុវត្ត ការប្រគល់ទំនិញ ការងារសំណង់ និងសេវា គឺអនុវត្តស្របទៅតាមបរិមាណ និងគុណភាពនៃកិច្ចសន្យា ដែលមានការបញ្ជាក់ និងដំណើរការអនុម័តត្រឹមត្រូវសម្រាប់ការទូទាត់ប្រាក់ទៅលើកិច្ចសន្យា និងមានឯកសារដែលត្រឹមត្រូវ និងគ្រប់គ្រាន់ត្រូវបានគេរក្សាទុក

៧. ពិនិត្យនូវភាពគ្រប់គ្រាន់ និងប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់គម្រោង និងជាពិសេសការត្រួតពិនិត្យផ្ទៃក្នុង និងផ្តល់ការណែនាំសម្រាប់កែលម្អប្រព័ន្ធគ្រប់គ្រង ការត្រួតពិនិត្យ និងឧបករណ៍ដទៃទៀត។ សវនករគួរណែនាំនូវមធ្យោបាយសម្រាប់កែលម្អ ប្រព័ន្ធគ្រប់គ្រងដែលខ្សោយ ឬ បង្កើតប្រព័ន្ធគ្រប់គ្រងនៅទីដែលមិនមាន។ ត្រូវមានការយកចិត្តទុកដាក់ពិសេសលើដំណើរការស្តីពីគម្រោងផ្តល់ប្រាក់ឧបត្ថម្ភពិសេសសម្រាប់ការចុះដល់ទីកន្លែងជាក់ស្តែង និងការទូទាត់ប្រាក់

៨. វាយតម្លៃការអនុលោមតាមលក្ខន្តិកៈនៃកិច្ចព្រមព្រៀងផ្តល់ហិរញ្ញប្បទាននៃគម្រោង ជាពិសេស កិច្ចព្រមព្រៀងពាក់ព័ន្ធនឹងបញ្ហាហិរញ្ញវត្ថុ

៩. បញ្ជាក់អះអាងការជាប់ទាក់ទងយ៉ាងច្បាស់រវាងសៀវភៅគណនី និងការពិនិត្យមើលការគ្រប់គ្រងហិរញ្ញវត្ថុប្រចាំត្រីមាស និងថា ការពិនិត្យមើលការគ្រប់គ្រងហិរញ្ញវត្ថុប្រចាំត្រីមាសឆ្លុះបញ្ចាំងពីស្ថានភាពហិរញ្ញវត្ថុយ៉ាងត្រឹមត្រូវ

១០. ពិនិត្យមើលសកម្មភាពនានាដែលអនុវត្តដោយការគ្រប់គ្រងឆ្លើយតបទៅនឹងការរកឃើញពីសវនកម្មផ្ទៃក្នុងកន្លងទៅ ហើយផ្តល់ការណែនាំ និងចំពោះការរកឃើញពីសវនកម្មខាងក្រៅ ហើយផ្តល់ការណែនាំ

១១. អនុវត្តសវនកម្មផ្ទៃក្នុងជាពិសេស ដូចតាមការណែនាំនៃការគ្រប់គ្រងគម្រោង

១២. ទំនាក់ទំនងជាមួយសវនករខាងក្រៅ អំឡុងពេលការអនុវត្តសវនកម្មពីខាងក្រៅ និងការផ្តល់នូវរបាយការណ៍សវនកម្មផ្ទៃក្នុងថតចម្លងទាំងអស់ទៅឲ្យសវនករខាងក្រៅ (-សវនករផ្ទៃក្នុងមិនមានការទទួលខុសត្រូវចំពោះការគូសបញ្ជាក់នូវការរកឃើញរបស់សវនករខាងក្រៅ ដែលការណែនាំត្រូវបានអនុវត្តតាម- នេះគឺជាតួនាទីនៃការគ្រប់គ្រង) និង

១៣. តួនាទីដែលសមហេតុផលផ្សេងទៀតទាក់ទិននឹងភារកិច្ចខាងលើដូចបានបង្ហាញដោយ អគ្គនាយកនៃគណៈនាយករដ្ឋបាលមូលដ្ឋានដែលលើកឡើងថា តួនាទីនេះមិនបង្កើតឲ្យមានជម្លោះផលប្រយោជន៍ដែលមានសក្តានុពលជាមួយមុខងារសវនកម្មផ្ទៃក្នុងស្នូល (ឧ. សវនករផ្ទៃក្នុងមិនអាចទទួលខុសត្រូវចំពោះរាល់មុខងារគណនេយ្យណាមួយនោះទេ)។

## លក្ខណសម្បត្តិ និងបទពិសោធន៍

**សវនករផ្ទៃក្នុង** ត្រូវមានលក្ខណសម្បត្តិដូចខាងក្រោមៈ

១. មានបរិញ្ញាបត្រ និង/ឬ សញ្ញាបត្រខាងផ្នែកគណនេយ្យ គ្រប់គ្រង ហិរញ្ញវត្ថុ ឬ មុខវិជ្ជាពាក់ព័ន្ធដទៃផ្សេងៗទៀត

២. មានបទពិសោធន៍យ៉ាងតិច ៣ ឆ្នាំ ក្នុងគម្រោងជួយសង្គ្រោះពហុភាគី ឬ គម្រោងដែលមានលក្ខណៈស្រដៀងគ្នា

៣. មានការយល់ដឹងគ្រប់គ្រាន់លើនីតិវិធីលទ្ធកម្ម និងការបើកប្រាក់ចំណាយរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងធនាគារពិភពលោក

៤. មានការប្តេជ្ញាខ្ពស់ដើម្បីអនុវត្តការធ្វើសវនកម្មផ្ទៃក្នុងដោយឯករាជ្យ គ្មានលម្អៀង និងប្រកបដោយសីលធម៌

៥. និយាយ និងសរសេរភាសាអង់គ្លេសបានល្អ

៦. សរសេរអក្សរខ្មែរបានល្អ

៧. មានសញ្ជាតិខ្មែរ និង

៨. មានឆន្ទៈ និងសមត្ថភាពធ្វើដំណើរក្នុងស្ថានភាពលំបាក។

# លក្ខខណ្ឌការងារ

| | |
|---|---|
| មុខតំណែង: | ទីប្រឹក្សាប្រតិបត្តិការអន្តរជាតិគម្រោងឡាសិត |
| ឈ្មោះគម្រោង: | គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច |
| ខ្ទង់ថវិកា: | |
| កន្លែងបំពេញភារកិច្ច: | រាជធានីភ្នំពេញ |
| រយៈពេល: | មួយឆ្នាំ (ដោយមានការត្រួតពិនិត្យការអនុវត្តការងារប្រចាំឆ្នាំ) |
| មូលដ្ឋាន: | កិច្ចសន្យាផ្តល់ប្រឹក្សាជាលក្ខណៈបុគ្គល |
| និយោជក: | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) |

## ទិដ្ឋភាពទូទៅ

ស្ថិតនៅក្រោមអំណាចទាំងស្រុងរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិទទួលខុសត្រូវក្នុងការអនុវត្តកម្មវិធីរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ឆ្នាំ២០០៧-២០០៩។ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ស្ថិតនៅក្រោមការគ្រប់គ្រងទាំងស្រុងរបស់អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ។ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) មានអង្គភាពគាំទ្រកម្មវិធីមួយដែលមាន ៤ ផ្នែក: ផ្នែករដ្ឋបាលកម្មវិធី ផ្នែកហិរញ្ញវត្ថុ ផ្នែកតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយ និងផ្នែកគ្រប់គ្រងកិច្ចសន្យា និងសម្របសម្រួលគម្រោង។

គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺជាគម្រោងមួយសម្រាប់គាំទ្រការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចរបស់រាជរដ្ឋាភិបាលដើម្បីចែកចាយដីទៅឲ្យប្រជាពលរដ្ឋគ្មានដី និងមានដីតិចតួចតាមរយៈសម្បទានដីសង្គមកិច្ចដើម្បីលើកកម្ពស់ជីវភាពគ្រួសារក្រីក្រ និងប្រជាពលរដ្ឋងាយរងគ្រោះតាមរយៈសម្បទានដីសង្គមកិច្ចផ្អែកលើឃុំ។ គោលបំណងរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺដើម្បី:

- ចែកដីរដ្ឋដែលសមស្របសម្រាប់កសិកម្ម រួមជាមួយនឹងសេវាកម្មគាំទ្រសមស្របដល់គ្រួសារគ្មានដី និងមានដីតិចតួចពិតប្រាកដ និង
- ណែនាំ និងអនុវត្តនូវដំណើរការប្រកបដោយតម្លាភាព និងមានបទដ្ឋានសម្រាប់ការអនុវត្តទូលំទូលាយនូវសម្បទានដីសង្គមកិច្ចដែលបានផ្តួចផ្តើមនៅថ្នាក់មូលដ្ឋាន។

ការអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចគោរពតាមគោលការណ៍ដូចខាងក្រោម:

- លើកកម្ពស់អភិបាលកិច្ចល្អ និងនីតិរដ្ឋ
- គាំទ្រ និងពង្រឹងរបៀបវារៈកំណែទម្រង់ដីរបស់រដ្ឋាភិបាល
- លើកទឹកចិត្តឲ្យមានការចូលរួមពីប្រជាពលរដ្ឋ
- ទប់ស្កាត់ការខូចខាតបរិស្ថាន
- លើកកម្ពស់តម្លាភាព និងគណនេយ្យភាព និង
- ធានាបាននូវការរីកចម្រើនប្រកបដោយចីរភាព។

ភ្នាក់ងារប្រតិបត្តិសម្រាប់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺជាអគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច ដែលមានមូលដ្ឋាននៅក្នុងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ យោងតាមអនុសារណៈនៃការយោគយល់គ្នាដែលបានចុះហត្ថលេខារវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងមហាផ្ទៃនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៧ បានចែងថា លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ទទួលខុសត្រូវលើផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច លើកលែងតែសកម្មភាពណាដែលជាការទទួលខុសត្រូវផ្ទាល់របស់អគ្គលេខាធិការដ្ឋានសម្រាប់សម្បទានដីសង្គមកិច្ច។ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) គ្រប់គ្រង និងរៀបចំរបាយការណ៍ ស្ដីពីមូលនិធិសម្រាប់ដំណើរការថ្នាក់ក្រោមជាតិទាំងអស់របស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈកិច្ចសន្យាជាមួយគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត និងគណៈកម្មាធិការប្រតិបត្តិរបស់ខ្លួន។ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្ដីពីទិដ្ឋភាពដំណើរការរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចនៅថ្នាក់ក្រោមជាតិដែលរួមមានការគ្រប់គ្រងកិច្ចសន្យា ការគ្រប់គ្រងហិរញ្ញវត្ថុ និងការពិនិត្យ និងវាយតម្លៃប្រតិបត្តិការ និងត្រួតពិនិត្យការអនុវត្តការងារនៅក្នុងក្របខ័ណ្ឌកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិផ្ទេរការទទួលខុសត្រូវលើដំណើរការភាគច្រើនទៅឲ្យគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត នៅក្នុងបណ្ដាខេត្តដែលចូលរួមក្នុងគម្រោង។ ភារកិច្ចលើដំណើរការដែលមានភាពកំហិត ត្រូវបានអនុវត្តនៅថ្នាក់ជាតិ តាមរយៈអង្គភាពគាំទ្រគម្រោងរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិ ការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ការទទួលខុសត្រូវទាំង នោះរួមមានៈ

- ការគ្រប់គ្រងហិរញ្ញវត្ថុគម្រោងទាំងមូល
- ការធ្វើលទ្ធកម្មទាំងមូល
- ការគ្រប់គ្រងកិច្ចសន្យា
- ការពិនិត្យ តាមដាន និងការវាយតម្លៃ

- ការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ និង
- ការរៀបចំរបាយការណ៍ប្រចាំឆ្នាំ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ តែងតាំងប្រធានសម្របសម្រួលគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចដែលមានអំណាចពេញលេញ ក្នុងការត្រួតពិនិត្យ និងសម្របសម្រួលការចែករំលែកលើការទទួលខុសត្រូវរបស់អង្គភាពគាំទ្រកម្មវិធីនៃលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដោយអនុវត្តតាមផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។

**ទីប្រឹក្សាប្រតិបត្តិការអន្តរជាតិរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច** ធ្វើការយ៉ាងជិតស្និទ្ធជាមួយប្រធានសម្របសម្រួលគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដើម្បីពិនិត្យ ផ្តល់យោបល់ និងជួយចែករំលែកការទទួលខុសត្រូវរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ស្របតាមគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច និងផ្តល់យោបល់ដល់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិលើបញ្ហាដែលទាក់ទងនឹងសម្បទានដីសង្គមកិច្ច។

## ការគ្រប់គ្រងមុខតំណែង

ទីប្រឹក្សាប្រតិបត្តិការអន្តរជាតិរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ធ្វើការក្រោមការគ្រប់គ្រងទាំងស្រុងរបស់អគ្គនាយកនៃគណៈនាយករដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ និងធ្វើកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ ជាមួយប្រធានសម្របសម្រួលគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។

## ការទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ

ទីប្រឹក្សាប្រតិបត្តិការអន្តរជាតិរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច សហការយ៉ាងជិតស្និទ្ធជាមួយទីប្រឹក្សាជាតិ និងអន្តរជាតិដែលមានទំនាក់ទំនងជាមួយក្រុមគាំទ្រកម្មវិធីនៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ជាពិសេសក្រុមទីប្រឹក្សានៃភាពជាដៃគូដើម្បីគាំទ្រវិមជ្ឈការ និងវិសហមជ្ឈការ។ គោលបំណងគឺថា បណ្តាទីប្រឹក្សារបស់ក្រុមគាំទ្រកម្មវិធីនៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ចែករំលែកព័ត៌មាន សម្របសម្រួលសកម្មភាពរបស់ពួកគេ ហើយជាទូទៅដើរតួជាក្រុមដែលជិតស្និទ្ធមួយ ដើម្បីគាំទ្រគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ក្រុមប្រឹក្សាប្រតិបត្តិការអន្តរជាតិរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច នឹងធ្វើការសម្របសម្រួល និងសហការជាមួយបណ្តាទីប្រឹក្សាជាតិ និង

អន្តរជាតិដែលត្រូវផ្តល់ភារកិច្ចដើម្បីគាំទ្រការអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈអគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ចនៅថ្នាក់ក្រោមជាតិ។

ទីប្រឹក្សាប្រតិបត្តិការអន្តរជាតិរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ត្រូវបានជួយនៅក្នុងតួនាទីរបស់ខ្លួនដោយទីប្រឹក្សាប្រតិបត្តិការជាតិរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច និងទីប្រឹក្សាប្រតិបត្តិការថ្នាក់ខេត្តរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។

## ភារកិច្ចជាក់លាក់

ទីប្រឹក្សាប្រតិបត្តិការអន្តរជាតិរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច មានតួនាទីសំខាន់ៗ ២ គឺ:

១. ផ្តល់យោបល់ដល់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិស្តីពីគោលនយោបាយទាក់ទិននឹងសម្បទានដីសង្គមកិច្ច និងយុទ្ធសាស្ត្រអនុវត្តរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

២. ផ្តល់ដំបូន្មាន និងជួយដល់ប្រធានសម្របសម្រួលគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចនូវគ្រប់ភារកិច្ចដែលទាក់ទិននឹងការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ។

ជាក់ស្តែង ក្រោមតួនាទីទី (១) ទីប្រឹក្សាប្រតិបត្តិការអន្តរជាតិរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច នឹង:

១. ចូលរួម និងសម្របសម្រួលកិច្ចពិភាក្សាទាក់ទិននឹងគោលនយោបាយសម្បទានដីសង្គមកិច្ចនៅក្នុងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ឬ រវាងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងបណ្តាទីភ្នាក់ងារដទៃទៀតនៅពេលចាំបាច់

២. ជួយធ្វើសុខដុមនីយកម្មទៅលើនីតិវិធីអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចជាមួយគម្រោង និងកម្មវិធីផ្សេងៗទៀត ដែលស្ថិតក្រោមក្របខ័ណ្ឌវិមជ្ឈការ និងវិសហមជ្ឈការ

៣. ទាក់ទងជាមួយទីប្រឹក្សាដទៃទៀតដែលមានទំនាក់ទំនងនឹងអគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច ដើម្បីសម្របសម្រួលការចែករំលែកព័ត៌មាន ភាពចុះសម្រុងគ្នា និងកិច្ចសហប្រតិបត្តិការល្អរវាងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងអគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច

៤. ពិនិត្យផែនការសកម្មភាព និងថវិកាព្រាងប្រចាំឆ្នាំរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ជាមួយគម្រោង និងពិនិត្យមើលឲ្យមានសង្គតភាពស្របទៅតាមក្រប

ខ័ណ្ឌសមហេតុសមផលរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច សៀវភៅណែនាំស្តីពីការអនុវត្តគម្រោង និងតារាងបង្ហាញពីការចំណាយរបស់គម្រោង

៥. ជួយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្នុងការទាក់ទងជាមួយបេសកកម្មត្រួតពិនិត្យរបស់សមាគមអភិវឌ្ឍអន្តរជាតិ។

ជាក់ស្តែង ក្រោមតួនាទីទី (២) ទីប្រឹក្សាប្រតិបត្តិការអន្តរជាតិរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច នឹង:

១. ពិនិត្យមើលរាល់ទិដ្ឋភាពនៃការអនុវត្តរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច កត់សម្គាល់នូវបញ្ហាពាក់ព័ន្ធណាមួយ និងធ្វើរបាយការណ៍ទៅកាន់ប្រធានសម្របសម្រួលគម្រោង និងអគ្គនាយកនៅពេលចាំបាច់

២. ចុះទៅកាន់បណ្តាខេត្តដែលអនុវត្តគម្រោងរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច និងតំបន់សម្បទានដីសង្គមកិច្ចឲ្យបានទៀងទាត់ ដើម្បីពិនិត្យដំណើរការ និងរក្សាកិច្ចពិភាក្សាជាមួយគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត

៣. ផ្តល់ដំបូន្មានលើបញ្ហាដែលទាក់ទិននឹងការគ្រប់គ្រងហិរញ្ញវត្ថុរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

៤. ផ្តល់ដំបូន្មានលើបញ្ហាដែលទាក់ទិននឹងការគ្រប់គ្រងកិច្ចសន្យារបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

៥. ជួយដោយផ្ទាល់ក្នុងការពិនិត្យនូវឯកសារលទ្ធកម្ម និងសម្របសម្រួលជាមួយភ្នាក់ងារលទ្ធកម្មឯករាជ្យដែលនឹងទទួលខុសត្រូវនៅផ្នែកលទ្ធកម្មកម្រិតជាតិ ក្នុងនាមជាគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

៦. ជួយក្នុងការព្រាងរបាយការណ៍ជាភាសាអង់គ្លេសស្តីពីការអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច នៅពេលចាំបាច់

៧. បំពេញតួនាទីដទៃទៀតទាក់ទិននឹងគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដែលតម្រូវដោយអគ្គនាយកនៃគណៈ នាយករដ្ឋបាលមូលដ្ឋាន។

## លក្ខណសម្បត្តិ

លក្ខណសម្បត្តិដែលតម្រូវសម្រាប់មុខតំណែងជាទីប្រឹក្សាប្រតិបត្តិការខេត្តរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច មានដូចខាងក្រោម:

១. មានសញ្ញាបត្រអនុបណ្ឌិត (ឬខ្ពស់ជាងនេះ) នៅក្នុងមុខវិជ្ជាដែលទាក់ទិននឹងការគ្រប់គ្រងគម្រោង ឬ ការអភិវឌ្ឍជនបទ

២. មានបទពិសោធន៍យ៉ាងតិច ១០ ឆ្នាំ ក្នុងកិច្ចការជួយអភិវឌ្ឍតាមខេត្តក្នុងវិស័យដែលទាក់ទិននឹងការអភិវឌ្ឍជនបទ ឬ គោលនយោបាយទាក់ទិននឹងដីជនបទ

៣. មានការយល់ដឹងពីការចេញប័ណ្ណកម្មសិទ្ធិដីជនបទ

៤. មានបទពិសោធន៍យ៉ាងតិច ៥ ឆ្នាំ ក្នុងមុខតំណែងដែលមានការទទួលខុសត្រូវលើការគ្រប់គ្រងគម្រោងសំខាន់ៗ

៥. មានការយល់ដឹងលើការគ្រប់គ្រងហិរញ្ញវត្ថុ និងគោលការណ៍ និងនីតិវិធីលទ្ធកម្ម

៦. មានការយល់ដឹងលើគោលការណ៍ត្រួតពិនិត្យ និងវាយតម្លៃ និងនីតិវិធី

៧. មានភាពស្ទាត់ជំនាញក្នុងការសរសេរ និងការនិយាយភាសាអង់គ្លេស

៨. មានបទពិសោធន៍កន្លងទៅក្នុងប្រទេសកម្ពុជា និងបណ្ដាប្រទេសកំពុងអភិវឌ្ឍនៅអាស៊ីអាគ្នេយ៍ដទៃទៀតនឹងត្រូវផ្ដល់អាទិភាព

៩. មានចំណេះដឹងខាងភាសាខ្មែរនឹងត្រូវផ្ដល់អាទិភាព

១០. មានឆន្ទៈ និងសមត្ថភាពធ្វើដំណើរក្នុងស្ថានភាពលំបាក។

# លក្ខខណ្ឌការងារ

| | |
|---|---|
| មុខតំណែង: | ទីប្រឹក្សាប្រតិបត្តិការជាតិ គម្រោងឡាសិត |
| ឈ្មោះគម្រោង: | គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច |
| ខ្ទង់ថវិកា: | |
| កន្លែងបំពេញភារកិច្ច: | រាជធានីភ្នំពេញ |
| រយៈពេល: | មួយឆ្នាំ (ដោយមានការត្រួតពិនិត្យការអនុវត្តការងារប្រចាំឆ្នាំ) |
| មូលដ្ឋាន: | កិច្ចសន្យាផ្តល់ប្រឹក្សាជាលក្ខណៈបុគ្គល |
| និយោជក: | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) |

## ទិដ្ឋភាពទូទៅ

ស្ថិតនៅក្រោមអំណាចទាំងស្រុងរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ទទួលខុសត្រូវក្នុងការអនុវត្តកម្មវិធីរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ឆ្នាំ ២០០៧-២០០៩។ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ស្ថិតនៅក្រោមការគ្រប់គ្រងទាំងស្រុងរបស់អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ។ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) មានអង្គភាពគាំទ្រកម្មវិធីមួយដែលមាន ៤ ផ្នែក: ផ្នែករដ្ឋបាលកម្មវិធី ផ្នែកហិរញ្ញវត្ថុ ផ្នែកតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយ និងផ្នែកគ្រប់គ្រងកិច្ចសន្យា និងសម្របសម្រួលគម្រោង។

គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺជាគម្រោងមួយសម្រាប់គាំទ្រការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចរបស់រាជរដ្ឋាភិបាលដើម្បីចែកចាយដីទៅឲ្យប្រជាពលរដ្ឋគ្មានដី និងមានដីតិចតួចតាមរយៈសម្បទានដីសង្គមកិច្ចដើម្បីលើកកម្ពស់ជីវភាពគ្រួសារក្រីក្រ និងប្រជាពលរដ្ឋងាយរងគ្រោះតាមរយៈសម្បទានដីសង្គមកិច្ចផ្អែកលើឃុំ។ គោលបំណងរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺដើម្បី:

- ចែកដីរដ្ឋដែលសមស្របសម្រាប់កសិកម្ម រួមជាមួយនឹងសេវាកម្មគាំទ្រសមស្របដល់គ្រួសារគ្មានដី និងមានដីតិចតួចពិតប្រាកដ និង
- ណែនាំ និងអនុវត្តនូវដំណើរការប្រកបដោយតម្លាភាព និងមានបទដ្ឋានសម្រាប់ការអនុវត្តទូលំទូលាយនូវសម្បទានដីសង្គមកិច្ចដែលបានផ្តួចផ្តើមនៅថ្នាក់មូលដ្ឋាន។
- ការអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចគោរពតាមគោលការណ៍ដូចខាងក្រោម:
- លើកកម្ពស់អភិបាលកិច្ចល្អ និងនីតិរដ្ឋ

- គាំទ្រ និងពង្រឹងរបៀបវារៈកំណែទម្រង់ដីរបស់រដ្ឋាភិបាល
- លើកទឹកចិត្តឲ្យមានការចូលរួមពីប្រជាពលរដ្ឋ
- ទប់ស្កាត់ការខូចខាតបរិស្ថាន
- លើកកម្ពស់តម្លាភាព និងគណនេយ្យភាព និង
- ធានាបាននូវការរីកចម្រើនប្រកបដោយចីរភាព។

ភ្នាក់ងារប្រតិបត្តិសម្រាប់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺជាអគ្គលេខាធិការដ្ឋានសម្រាប់សម្បទានដីសង្គមកិច្ច ដែលមានមូលដ្ឋាននៅក្នុងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ យោងតាមអនុស្សារណៈយោគយល់គ្នា ដែលបានចុះហត្ថលេខារវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងមហាផ្ទៃនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៧ បានចែងថា លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ទទួលខុសត្រូវលើផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់បែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច លើកលែងតែសកម្មភាពណាដែលជាការទទួលខុសត្រូវផ្ទាល់របស់អគ្គលេខាធិការដ្ឋានសម្រាប់សម្បទានដីសង្គមកិច្ច។ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) គ្រប់គ្រង និងរៀបចំរបាយការណ៍ ស្តីពីមូលនិធិសម្រាប់ដំណើរការថ្នាក់ក្រោមជាតិទាំងអស់របស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈកិច្ចសន្យាជាមួយគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត និងគណៈកម្មាធិការប្រតិបត្តិរបស់ខ្លួន។ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្តីពីទិដ្ឋភាពដំណើរការរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច នៅថ្នាក់ក្រោមជាតិ ដែលរួមមានការគ្រប់គ្រងកិច្ចសន្យា ការគ្រប់គ្រងហិរញ្ញវត្ថុ និងការពិនិត្យ និងវាយតម្លៃប្រតិបត្តិការ និងត្រួតពិនិត្យការអនុវត្តការងារនៅក្នុងក្របខ័ណ្ឌកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ដូច្នេះ បន្ទាប់ពីការផ្តល់សិទ្ធិទៅលើផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំដោយប្រធានគម្រោង (អគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច) គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) មិនតម្រូវឲ្យមានការផ្តល់សិទ្ធិរបស់អគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច ចំពោះការសម្រេចចិត្តពាក់ព័ន្ធនឹងការចំណាយ ឬ សកម្មភាពណាដែលត្រូវបានយល់ព្រមនៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចឡើយ។

**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** ផ្ទេរការទទួលខុសត្រូវលើដំណើរការភាគច្រើនទៅឲ្យគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្តនៅក្នុងបណ្តាខេត្តដែលចូលរួមក្នុងគម្រោង។ ភារកិច្ចលើកិច្ចប្រតិបត្តិដែលមានភាពកំណត់ ត្រូវបានអនុវត្តនៅថ្នាក់ជាតិ តាមរយៈក្រុមការងារគាំទ្រគម្រោងរបស់លេខាធិការដ្ឋាននៃ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ការទទួលខុសត្រូវទាំងនោះរួមមានៈ

- ការគ្រប់គ្រងហិរញ្ញវត្ថុគម្រោងទាំងមូល
- ការធ្វើលទ្ធកម្មទាំងមូល
- ការគ្រប់គ្រងកិច្ចសន្យា
- ការពិនិត្យ និងវាយតម្លៃ
- ការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ និង
- ការរៀបចំរបាយការណ៍ប្រចាំឆ្នាំ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ តែងតាំងប្រធានសម្របសម្រួលគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដែលមានអំណាចពេញលេញ ក្នុងការត្រួតពិនិត្យ និងសម្របសម្រួលការចែករំលែកការទទួលខុសត្រូវរបស់អង្គភាពគាំទ្រកម្មវិធីនៃលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដោយអនុវត្តតាមផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។

**ទីប្រឹក្សាប្រតិបត្តិការជាតិរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច** ធ្វើការយ៉ាងជិតស្និទ្ធជាមួយប្រធានសម្របសម្រួលគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដើម្បីពិនិត្យ ផ្តល់យោបល់ និងជួយចែករំលែកការទទួលខុសត្រូវរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ស្របតាមគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច និងផ្តល់យោបល់ដល់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិអំពីបញ្ហាដែលទាក់ទងនិងសម្បទានដីសង្គមកិច្ច។

## ការគ្រប់គ្រងមុខតំណែង

ទីប្រឹក្សាប្រតិបត្តិការអន្តរជាតិរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ធ្វើការក្រោមការគ្រប់គ្រងទាំងស្រុងរបស់អគ្គនាយកនៃគណៈនាយករដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ និងក្រោមការត្រួតពិនិត្យជាប្រចាំពីប្រធានសម្របសម្រួលគម្រោងរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។ ដោយស្ថិតនៅក្រោមការត្រួតពិនិត្យពីមន្ត្រីគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ទាំងនោះ ទីប្រឹក្សាប្រតិបត្តិការជាតិរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចក៏បានធ្វើការយ៉ាងជិតស្និទ្ធ និងទទួលការការណែនាំពីទីប្រឹក្សាប្រតិបត្តិការអន្តរជាតិរបស់គម្រោងរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចផងដែរ។

## ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ

ទីប្រឹក្សាប្រតិបត្តិការជាតិរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ក៏បានសហការយ៉ាងជិតស្និទ្ធជាមួយបណ្តាទីប្រឹក្សាជាតិ និងអន្តរជាតិដទៃទៀតដែលមានទំនាក់ទំនងជាមួយក្រុមគាំទ្រកម្មវិធីនៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ជាពិសេសក្រុមទីប្រឹក្សានៃភាពជាដៃគូដើម្បីគាំទ្រវិមជ្ឈការ និងវិសហមជ្ឈការ។ គោលបំណងគឺថា បណ្តាទីប្រឹក្សារបស់ក្រុមគាំទ្រកម្មវិធីនៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ចែករំលែកព័ត៌មាន សម្របសម្រួលសកម្មភាពរបស់ពួកគេ ហើយជាទូទៅដើរតួជាក្រុមដែលជិតស្និទ្ធមួយដើម្បីគាំទ្រគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ក្រុមប្រឹក្សាប្រតិបត្តិការអន្តរជាតិរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច នឹងធ្វើការសម្របសម្រួល និងសហការជាមួយបណ្តាទីប្រឹក្សាជាតិ និងអន្តរជាតិដែលត្រូវផ្តល់ភារកិច្ចដើម្បីគាំទ្រការអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈអគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ចច និងនៅថ្នាក់ក្រោមជាតិ។

## ភារកិច្ចជាក់លាក់

តួនាទីចម្បងរបស់ទីប្រឹក្សាប្រតិបត្តិការជាតិរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺផ្តល់យោបល់ និងជួយប្រធានសម្របសម្រួលគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច នូវរាល់ទិដ្ឋភាពនៃភារកិច្ចរបស់ពួកគេទាក់ទិននឹងការអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។

ជាក់ស្តែង ទីប្រឹក្សាប្រតិបត្តិការជាតិនឹង:

១. អាន ស្វែងយល់ និងផ្តល់យោបល់ដល់គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្តលើការបកស្រាយនូវក្របខ័ណ្ឌសមហេតុផលរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច និងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច និងតារាងបង្ហាញពីការចំណាយរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

២. ពិនិត្យសេចក្តីព្រាងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច និងពិនិត្យមើលឲ្យមានសង្គតភាពស្របទៅតាមក្របខ័ណ្ឌសមហេតុសមផលរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច សៀវភៅណែនាំស្តីពីការអនុវត្តគម្រោង និងតារាងបង្ហាញពីការចំណាយរបស់គម្រោង

៣. ជួយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្នុងការធ្វើទំនាក់ទំនងជាមួយនឹងបេសកកម្មត្រួតពិនិត្យរបស់សមាគមអភិវឌ្ឍន៍អន្តរជាតិ

៤. ជួយប្រធានសម្របសម្រួលគម្រោង និងទីប្រឹក្សាប្រតិបត្តិការអន្តរជាតិ ដើម្បីពិនិត្យនូវរាល់ទិដ្ឋភាពនៃការអនុវត្តរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច កត់សម្គាល់បញ្ហាពាក់ព័ន្ធណាមួយ និងចាត់វិធានការតាមដាននៅពេលចាំបាច់

៥. ជួយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីវាយតម្លៃប្រសិទ្ធផល និងប្រសិទ្ធភាពនៃដំណើរការគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

៦. ចុះទៅកាន់បណ្តាខេត្តដែលអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច និងតំបន់សម្បទានដីសង្គមកិច្ចឲ្យបានទៀងទាត់ ដើម្បីត្រួតពិនិត្យដំណើរការ និងរក្សាកិច្ចពិភាក្សាជាមួយគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត

៧. ជួយដោយផ្ទាល់ក្នុងការពិនិត្យឯកសារលទ្ធកម្មមុនពេលដាក់បញ្ជូនទៅកាន់ភ្នាក់ងារលទ្ធកម្មឯករាជ្យ ពិនិត្យនូវសេចក្តីណែនាំពីភ្នាក់ងារលទ្ធកម្មឯករាជ្យ និងជួយក្នុងការចាត់វិធានការតាមដានត្រួតពិនិត្យ

៨. ជួយរៀបចំធ្វើរបាយការណ៍ផ្សេងៗ

៩. បំពេញភារកិច្ចដទៃទៀតទាក់ទិននឹងគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចដែលតម្រូវឲ្យធ្វើដោយអគ្គនាយកនៃគណៈនាយករដ្ឋបាលមូលដ្ឋាន

**លក្ខណសម្បត្តិ**

លក្ខណសម្បត្តិដែលតម្រូវសម្រាប់មុខតំណែងជាទីប្រឹក្សាប្រតិបត្តិការជាតិរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច មានដូចខាងក្រោម:

១. មានបរិញ្ញាបត្រ (អនុបណ្ឌិតផ្តល់អាទិភាព) នៅក្នុងមុខវិជ្ជាដែលទាក់ទិននឹងការគ្រប់គ្រងគម្រោង ឬ ការអភិវឌ្ឍជនបទ

២. មានបទពិសោធន៍យ៉ាងតិច ៧ ឆ្នាំ ក្នុងការអនុវត្តគម្រោងក្នុងវិស័យដែលទាក់ទិននឹងការអភិវឌ្ឍជនបទ ឬ គោលនយោបាយដីធ្លីជនបទ

៣. មានការយល់ដឹងស្តីពីបញ្ហាកម្មសិទ្ធិដីធ្លីជនបទ

៤. មានបទពិសោធន៍យ៉ាងតិច ៣ ឆ្នាំ ក្នុងមុខតំណែងដែលមានការទទួលខុសត្រូវលើការគ្រប់គ្រងគម្រោងសំខាន់ៗ

៥. មានការយល់ដឹងលើការគ្រប់គ្រងហិរញ្ញវត្ថុ និងគោលការណ៍ និងនីតិវិធីលទ្ធកម្ម

៦. មានការយល់ដឹងលើគោលការណ៍ត្រួតពិនិត្យ និងវាយតម្លៃ និងនីតិវិធីនានា

៧. មានភាពស្ទាត់ជំនាញក្នុងការសរសេរ និងការនិយាយភាសាអង់គ្លេស

៨. មានចំណេះដឹងខាងការសរសេរអក្សរខ្មែរ

៩.មានសញ្ជាតិខ្មែរ និង

១០. មានឆន្ទៈ និងសមត្ថភាពធ្វើដំណើរក្នុងស្ថានភាពលំបាក។

# លក្ខខណ្ឌការងារ

| | |
|---|---|
| មុខតំណែង: | ទីប្រឹក្សាប្រតិបត្តិការខេត្ត គម្រោងឡាសិត |
| ឈ្មោះគម្រោង: | គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច |
| ខ្ទង់ថវិកា: | |
| កន្លែងបំពេញភារកិច្ច: | រាជធានីភ្នំពេញ |
| រយៈពេល: | មួយឆ្នាំ (ដោយមានការត្រួតពិនិត្យការអនុវត្តការងារប្រចាំឆ្នាំ) |
| មូលដ្ឋាន: | កិច្ចសន្យាផ្តល់ប្រឹក្សាជាលក្ខណៈបុគ្គល |
| និយោជក: | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) |

## ទិដ្ឋភាពទូទៅ

ស្ថិតនៅក្រោមអំណាចទាំងស្រុងរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ទទួលខុសត្រូវក្នុងការអនុវត្តកម្មវិធីរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ឆ្នាំ ២០០៧-២០០៩។ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ស្ថិតនៅក្រោមការគ្រប់គ្រងទាំងស្រុងរបស់អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ។ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) មានអង្គភាពគាំទ្រកម្មវិធីមួយដែលមាន ៤ ផ្នែក: ផ្នែករដ្ឋបាលកម្មវិធី ផ្នែកហិរញ្ញវត្ថុ ផ្នែកតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយ និងផ្នែកគ្រប់គ្រងកិច្ចសន្យា និងសម្របសម្រួលគម្រោង។

គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺជាគម្រោងមួយសម្រាប់គាំទ្រការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចរបស់រាជរដ្ឋាភិបាលដើម្បីចែកចាយដីទៅឲ្យប្រជាពលរដ្ឋគ្មានដី និងមានដីតិចតួចតាមរយៈសម្បទានដីសង្គមកិច្ចដើម្បីលើកកម្ពស់ជីវភាពគ្រួសារក្រីក្រ និងប្រជាពលរដ្ឋងាយរងគ្រោះតាមរយៈសម្បទានដីសង្គមកិច្ចផ្អែកលើឃុំ។ គោលបំណងរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺដើម្បី:

- ចែកដីរដ្ឋដែលសមស្របសម្រាប់កសិកម្ម រួមជាមួយនឹងសេវាកម្មគាំទ្រសមស្របដល់គ្រួសារគ្មានដី និងមានដីតិចតួចពិតប្រាកដ និង
- ណែនាំ និងអនុវត្តនូវដំណើរការប្រកបដោយតម្លាភាព និងមានបទដ្ឋានសម្រាប់ការអនុវត្តទូលំទូលាយនូវសម្បទានដីសង្គមកិច្ចដែលបានផ្តួចផ្តើមនៅថ្នាក់មូលដ្ឋាន។

ការអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចគោរពតាមគោលការណ៍ដូចខាងក្រោម:

- លើកកម្ពស់អភិបាលកិច្ចល្អ និងនីតិរដ្ឋ
- គាំទ្រ និងពង្រឹងរបៀបវារៈកំណែទម្រង់ដីរបស់រដ្ឋាភិបាល
- លើកទឹកចិត្តឲ្យមានការចូលរួមពីប្រជាពលរដ្ឋ
- ទប់ស្កាត់ការខូចខាតបរិស្ថាន
- លើកកម្ពស់តម្លាភាព និងគណនេយ្យភាព និង
- ធានាបាននូវការរីកចម្រើនប្រកបដោយចីរភាព។

ភ្នាក់ងារប្រតិបត្តិសម្រាប់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺជាអគ្គលេខាធិការដ្ឋានសម្រាប់សម្បទានដីសង្គមកិច្ច ដែលមានមូលដ្ឋាននៅក្នុងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ យោងតាមអនុសារណៈយោគយល់គ្នា ដែលបានចុះហត្ថលេខារវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងមហាផ្ទៃនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៧ បានចែងថា លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ទទួលខុសត្រូវលើផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច លើកលែងតែសកម្មភាពណាដែលជាការទទួលខុសត្រូវផ្ទាល់របស់អគ្គលេខាធិការដ្ឋានសម្រាប់សម្បទានដីសង្គមកិច្ច។ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) គ្រប់គ្រង និងរៀបចំរបាយការណ៍ ស្តីពីមូលនិធិសម្រាប់ដំណើរការថ្នាក់ក្រោមជាតិទាំងអស់របស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈកិច្ចសន្យាជាមួយគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត និងគណៈកម្មាធិការប្រតិបត្តិរបស់ខ្លួន។ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្តីពីទិដ្ឋភាពដំណើរការរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចនៅថ្នាក់ក្រោមជាតិ ដែលរួមមានការគ្រប់គ្រងកិច្ចសន្យា ការគ្រប់គ្រងហិរញ្ញវត្ថុ និងការពិនិត្យ និងវាយតម្លៃប្រតិបត្តិការ និងត្រួតពិនិត្យការអនុវត្តការងារនៅក្នុងក្របខ័ណ្ឌកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ដូច្នេះ បន្ទាប់ពីការផ្តល់សិទ្ធិទៅលើផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំដោយប្រធានគម្រោង (អគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច) គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) មិនតម្រូវឲ្យមានការផ្តល់សិទ្ធិរបស់អគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច ចំពោះការសម្រេចចិត្តពាក់ព័ន្ធនឹងការចំណាយ ឬ សកម្មភាពណាដែលត្រូវបានយល់ព្រមនៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចឡើយ។

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ផ្ទេរការទទួលខុសត្រូវលើដំណើរការភាគច្រើនទៅឲ្យគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍ

ជនបទខេត្តនៅក្នុងបណ្តាខេត្តដែលចូលរួមក្នុងគម្រោង។ គណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្តត្រូវបានដឹកនាំដោយអភិបាលខេត្ត ហើយការងារប្រចាំថ្ងៃរបស់ខ្លួនត្រូវបានសម្របសម្រួលដោយសមាជិកអចិន្ត្រៃយ៍។ គណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្តមានផ្នែកមុខងារចំនួន ៤៖

- ផ្នែកហិរញ្ញវត្ថុ
- ផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាល
- ផ្នែករដ្ឋបាលមូលដ្ឋាន និង
- ផ្នែកគាំទ្របច្ចេកទេស

តាមរយៈនោះដែរ ការទទួលខុសត្រូវរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច នឹងត្រូវបានចែករំលែក។ ការទទួលខុសត្រូវទាំងនោះរួមមាន:

- ការអនុវត្តគម្រោងរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចនៅថ្នាក់ខេត្ត/ក្រុង តាមរយៈអនុកិច្ចសន្យាជាមួយគណៈកម្មាធិការបែងចែក និងរៀបចំដែនដីថ្នាក់ខេត្ត ក្រុមការងារថ្នាក់ស្រុក ក្រុមប្រឹក្សាឃុំ និង បណ្តាភ្នាក់ងាររដ្ឋដទៃទៀត
- ដឹកនាំ និងត្រួតពិនិត្យការទទួលខុសត្រូវរាល់ការគ្រប់គ្រងគម្រោង និងភារកិច្ចគ្រប់គ្រងហិរញ្ញវត្ថុ និង
- ផ្តល់ជំនួយដល់រាល់ក្រុមប្រឹក្សាឃុំតាមរយៈផ្នែករដ្ឋបាលមូលដ្ឋាន ផ្នែកគាំទ្របច្ចេកទេស និងបណ្តាក្រុមការងារថ្នាក់ស្រុក

**ទីប្រឹក្សាប្រតិបត្តិការខេត្តរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច** ធ្វើការយ៉ាងជិតស្និទ្ធជាមួយសមាជិកអចិន្ត្រៃយ៍នៃគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត ដើម្បីត្រួតពិនិត្យ ផ្តល់យោបល់ និងជួយចែករំលែកការទទួលខុសត្រូវរបស់គណៈកម្មាធិការប្រតិបត្តិនៃ គណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត ចំពោះគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។

## ការគ្រប់គ្រងមុខតំណែង

ទីប្រឹក្សាបច្ចេកទេសខេត្តរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ធ្វើការក្រោមការគ្រប់គ្រងទាំងស្រុងនៃអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋានរបស់ក្រសួងមហាផ្ទៃ។ ទីប្រឹក្សាប្រតិបត្តិការខេត្តរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចនឹងធ្វើការជាសមាជិកនៃក្រុមទីប្រឹក្សាដែលមានទំនាក់ទំនងគ្នានឹងគណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត និងការងារជាប្រចាំរបស់ខ្លួននឹងត្រូវបានសម្របសម្រួលដោយទីប្រឹក្សាកម្មវិធីជាន់ខ្ពស់ប្រចាំខេត្តនៃក្រុមទីប្រឹក្សាភាពជាដៃគូសម្រាប់វិមជ្ឈការ និងវិសហមជ្ឈការ។

### ទំនាក់ទំនង និងការសហប្រតិបត្តិការ

ទីប្រឹក្សាប្រតិបត្តិការខេត្តរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ត្រូវផ្តល់ដំបូន្មាន និងជួយសមាជិកអចិន្ត្រៃយ៍នៃប្រធានសម្របសម្រួលគម្រោងរបស់គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្តនូវរាល់ទិដ្ឋភាពនៃការទទួលខុសត្រូវរបស់គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត ពាក់ព័ន្ធនឹងគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។ ទីប្រឹក្សាប្រតិបត្តិការខេត្តរបស់គម្រោងបែងចែកដី ដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ក៏បានសហការយ៉ាងជិតស្និទ្ធជាមួយក្រុមទីប្រឹក្សាខេត្តរបស់ភាពជាដៃគូសម្រាប់វិមជ្ឈការ និងវិសហមជ្ឈការ និងជាមួយទីប្រឹក្សាដែលមានទំនាក់ទំនងគ្នាជាមួយគណៈកម្មាធិការបែងចែក និងរៀបចំដែនដីខេត្ត។

ទីប្រឹក្សាប្រតិបត្តិការខេត្តរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ត្រូវបានជួយនៅក្នុងតួនាទីរបស់ខ្លួន តាមរយៈទីប្រឹក្សាប្រតិបត្តិការអន្តរជាតិរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច និងទីប្រឹក្សាប្រតិបត្តិការជាតិរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។

### ភារកិច្ចជាក់លាក់

ទីប្រឹក្សាប្រតិបត្តិការខេត្តរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ត្រូវផ្តល់យោបល់ និងជួយសមាជិកអចិន្ត្រៃយ៍នៃគណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត នូវរាល់បញ្ហាទាក់ទិននឹងការទទួលខុសត្រូវរបស់គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្តសម្រាប់ការអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។

ជាក់ស្តែង ទីប្រឹក្សាប្រតិបត្តិការខេត្តនឹងៈ

១. អាន ស្វែងយល់ និងផ្តល់យោបល់ដល់គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្តលើការបកស្រាយសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងរបស់បែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

២. ជួយគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត ដើម្បីធ្វើសេចក្តីព្រាង និងដាក់បញ្ចូលគ្នានូវផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គម្រោងរបស់បែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច និងពិនិត្យទៅលើសង្គតភាពដែលមានក្របខ័ណ្ឌសមហេតុផលរបស់គម្រោងរបស់បែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច និងពិនិត្យលើសៀវភៅណែនាំការអនុវត្តគម្រោង និងតារាងបង្ហាញពីការចំណាយរបស់គម្រោង

៣. ជួយផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាលដើម្បីរៀបចំទទួលការងារបន្តសម្រាប់ការអនុវត្តទៅលើសកម្មភាពរបស់គម្រោងរបស់បែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

៤. ជួយផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាលដើម្បីពិនិត្យមើលការអនុវត្តជារូបវន្តនៃការទទួលការងារបន្ត និងដើម្បីវាយតម្លៃប្រសិទ្ធភាព និងប្រសិទ្ធផលនៃដំណើរការរបស់គម្រោងរបស់បែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

៥. គាំទ្រក្រុមការងារស្រុកដើម្បីជួយក្រុមប្រឹក្សាឃុំអនុវត្តសមាសភាគទី២ របស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច (ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មជនបទ) ជាពិសេស:

ក.ការចរចាលើកិច្ចសន្យាសម្រាប់ការអនុវត្តសកម្មភាពនានារបស់សមាសភាគទី២ របស់គម្រោងរបស់បែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដោយភ្នាក់ងាររដ្ឋ និងតាមដានការត្រួតពិនិត្យការអនុវត្តគម្រោង

ខ.រៀបចំឯកសារស្នើសុំ ការត្រួតពិនិត្យលទ្ធកម្ម និងកិច្ចសន្យានៃកិច្ចសន្យាដែលបានចុះជាមួយអ្នកទទួលការងារវិស័យឯកជន អ្នកផ្គត់ផ្គង់ និងអ្នកផ្តល់សេវា។

## លក្ខណសម្បត្តិ

លក្ខណសម្បត្តិដែលតម្រូវសម្រាប់មុខតំណែងជាទីប្រឹក្សាប្រតិបត្តិការជាតិរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច មានដូចខាងក្រោម:

១. មានបរិញ្ញាបត្រ (អនុបណ្ឌិតផ្តល់អាទិភាព) នៅក្នុងមុខវិជ្ជាដែលទាក់ទិននឹងការគ្រប់គ្រងគម្រោង ឬ ការអភិវឌ្ឍជនបទ

២. មានបទពិសោធន៍យ៉ាងតិច ៥ ឆ្នាំក្នុងការអនុវត្តគម្រោងក្នុងវិស័យដែលទាក់ទិននឹងការអភិវឌ្ឍជនបទ ឬ គោលនយោបាយដីធ្លីជនបទ

៣. មានការយល់ដឹងស្តីពីបញ្ហាកម្មសិទ្ធិដីធ្លីជនបទ

៤. មានការយល់ដឹងលើគោលការណ៍ និងនីតិវិធីលទ្ធកម្ម

៥. មានការយល់ដឹងលើការត្រួតពិនិត្យ និងការវាយតម្លៃគោលការណ៍ និងនីតិវិធីនានា

៦. មានភាពស្ទាត់ជំនាញក្នុងការសរសេរ និងការនិយាយភាសាអង់គ្លេស

៧. មានចំណេះដឹងខាងការសរសេរអក្សរខ្មែរ

៨. មានសញ្ជាតិខ្មែរ និង

៩. មានឆន្ទៈ និងសមត្ថភាពធ្វើដំណើរក្នុងស្ថានភាពលំបាក។

**ឧបសម្ព័ន្ធទី ៦ : លក្ខខណ្ឌយោង:**

# មុខតំណែងក្នុង គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត

## <u>លក្ខខណ្ឌការងារ</u>

| | |
|---|---|
| មុខតំណែង: | ប្រធានគ្រប់គ្រងគម្រោងឡាសិតថ្នាក់ខេត្ត |
| ឈ្មោះគម្រោង: | គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច |
| ខ្ទង់ថវិកា: | |
| ទីកន្លែងបំពេញការងារ: | គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត /គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត |
| រយៈពេល: | ១ ឆ្នាំ (ដោយមានការត្រួតពិនិត្យការអនុវត្តប្រចាំឆ្នាំ) |

### ទិដ្ឋភាពទូទៅ

គោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺស្ថិតនៅក្រោមអំណាច និងការគ្រប់គ្រងទាំងស្រុងរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប)។ អង្គភាពគាំទ្រកម្មវិធីរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិទទួលខុសត្រូវក្នុងការអនុវត្តកម្មវិធី។ គណៈកម្មាធិការអភិវឌ្ឍន៍ជនបទថ្នាក់ខេត្តដែលដឹកនាំដោយអភិបាលខេត្តទទួលខុសត្រូវចំពោះការគ្រប់គ្រងកិច្ចការនេះនៅថ្នាក់ខេត្ត។

អភិបាលខេត្តបានបង្កើតគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត និងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត គឺដើម្បីអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ និងការងារប្រចាំថ្ងៃរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងគោលបំណងបំពេញការទទួលខុសត្រូវផ្នែកប្រតិបត្តិរបស់ខ្លួនក្នុងការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ។

គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកច្ចិ គឺជាគម្រោងមួយដែលគាំទ្រការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចរបស់រាជរដ្ឋាភិបាល ដើម្បីបែងចែកដីជូនប្រជាពលរដ្ឋដែលគ្មានដី និងមានដីតិចតួចតាមរយៈសម្បទានដីសង្គមកិច្ច ដើម្បីលើកកម្ពស់ជីវភាពរបស់គ្រួសារក្រីក្រ និងប្រជាពលរដ្ឋងាយរងគ្រោះតាមរយៈការធ្វើសម្បទានដីសង្គមកិច្ចផ្អែកលើឃុំ។ គោលបំណងរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺដើម្បី:

- បែងចែកដីរដ្ឋដែលសមស្របសម្រាប់ធ្វើកសិកម្ម រួមជាមួយនឹងសេវាគាំទ្រសមស្របមួយចំនួនដល់គ្រួសារគ្មានដី និងគ្រួសារមានដីតិចតួចពិតប្រាកដ និង

- ណែនាំ និងអនុវត្តដំណើរការប្រកបដោយតម្លាភាព និងមានបទដ្ឋានសម្រាប់ការអនុវត្តបន្ថែមលើសម្បទានដីសង្គមកិច្ចដែលបានចាប់ផ្តើមឡើងនៅតាមមូលដ្ឋាន។
- ការអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចគោរពតាមគោលការណ៍ដូចខាងក្រោមៈ
- លើកកម្ពស់អភិបាលកិច្ចល្អ និងនីតិរដ្ឋ
- គាំទ្រ និងពង្រឹងរបៀបវារៈធ្វើកំណែទម្រង់ដីធ្លីរបស់រដ្ឋាភិបាល
- លើកទឹកចិត្តឲ្យមានការចូលរួមពីប្រជាពលរដ្ឋ
- ទប់ស្កាត់ការខូចខាតដល់បរិស្ថាន
- លើកកម្ពស់តម្លាភាព និងគណនេយ្យភាព និង
- ធានាឲ្យមានកំណើនប្រកបដោយនិរន្តរភាព។

ភ្នាក់ងារប្រតិបត្តិសម្រាប់គម្រោងបែងចែកដីដើម្បីសង្គមសេដ្ឋកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺជាអគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច ដែលមានមូលដ្ឋាននៅក្នុងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ យោងតាមអនុសារណៈយោគយល់ដែលបានចុះហត្ថលេខារវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងមហាផ្ទៃនៅថ្ងៃទី ២៤ ខែសីហា ឆ្នាំ ២០០៧ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ត្រូវទទួលខុសចំពោះរាល់ទិដ្ឋភាពប្រតិបត្តិការរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចនៅថ្នាក់ក្រោមជាតិ រួមទាំងការគ្រប់គ្រងកិច្ចសន្យា ការគ្រប់គ្រងហិរញ្ញវត្ថុ និងការត្រួតពិនិត្យតាមដាន និងការវាយតម្លៃ ក៏ដូចជាដើម្បីត្រួតពិនិត្យការអនុវត្តនៅក្នុងក្របខ័ណ្ឌនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) នឹងអនុវត្តការទទួលខុសត្រូវនេះតាមរយៈគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត/គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត។

**ប្រធានគ្រប់គ្រងគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចថ្នាក់ខេត្ត** គឺជាបុគ្គលិកមួយរូបរបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត/គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ដែលមានតួនាទីជួយដល់អភិបាលខេត្តក្នុងការគាំទ្រការអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។ ប្រធានគ្រប់គ្រងគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចប្រចាំខេត្ត នឹងអនុវត្តការងារនេះដោយផ្ទាល់តាមរយៈការគាំទ្រ ណែនាំ និងការជួយដល់ក្រុមការងារថ្នាក់ស្រុក និងក្រុមប្រឹក្សាឃុំ។

## ការគ្រប់គ្រងមុខតំណែង

ប្រធានគ្រប់គ្រងគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចថ្នាក់ខេត្តធ្វើការក្រោមការត្រួតពិនិត្យដោយផ្ទាល់ពីអភិបាលខេត្ត។

## សហប្រតិបត្តិការបច្ចេកទេស

ប្រធានគ្រប់គ្រងគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចថ្នាក់ខេត្តទទួលបានការគាំទ្រពីអគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច និងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ។

## ភារកិច្ចជាក់លាក់

១. ផ្តល់ការគ្រប់គ្រងបុគ្គលិកដែលបានចាត់តាំងទៅលេខាធិការដ្ឋានបច្ចេកទេសរបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត និងធានាចំពោះការអនុវត្តការទទួលខុសត្រូវរបស់ពួកគេក្នុងការអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

២. ជួយ និងគាំទ្រអភិបាលខេត្ត និងគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តក្នុងការលើកកម្ពស់ការចូលរួមរបស់ឃុំនៅក្នុងដំណើរការសម្បទានដីសង្គមកិច្ច និងគាំទ្រការបែងចែកដីឯកជនរបស់រដ្ឋជូនប្រជាពលរដ្ឋដែលគ្មានដី និងមានដីតិចតួចតាមរយៈសម្បទានដីសង្គមកិច្ច។

៣. ធ្វើការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត និងគណៈកម្មាការប្រតិបត្តិ ដើម្បីធានាឲ្យមានការសម្របសម្រួលការគាំទ្រពីខេត្តចំពោះគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងខេត្តដែលមានមន្ទីរពាក់ព័ន្ធក្រោមឱវាទ។

៤. ជួយដល់ស្រុកដែលពាក់ព័ន្ធក្នុងការពង្រឹង និងលើកកម្ពស់ក្រុមការងារថ្នាក់ស្រុកដើម្បីគាំទ្រការរៀបចំសំណើសុំសម្បទានដីសង្គមកិច្ចរបស់ឃុំដែលបានអនុម័ត។

៥. ធានាឲ្យមានការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពជាមួយនឹងគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត

៦. រាយការណ៍ជូន និងឆ្លើយតបចំពោះសំណើរបស់អគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច និងលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប)

៧. ផ្តល់ការណែនាំពីការអនុវត្តទាំងស្រុងដល់ក្រុមការងារថ្នាក់ស្រុក និងក្រុមប្រឹក្សាឃុំ ស្តីពីការអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

៨. ដោយមានការណែនាំពីអភិបាលខេត្ត ការគាំទ្រការងាររបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត/គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តនៅក្នុងការគាំទ្រការអនុវត្ត

ការគាំទ្របច្ចេកទេសដល់អ្នកទទួលផលពីគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

៩. ផ្តល់នូវព័ត៌មានដែលចាំបាច់សម្រាប់ការរៀបចំដំណើរការផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ និងដាក់សំណើចុងក្រោយជូនអភិបាលខេត្តដើម្បីសុំការឯកភាព។

១០.ដោយមានការណែនាំពីអភិបាលខេត្ត ត្រូវត្រួតពិនិត្យគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត/គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត និងក្រុមការងារថ្នាក់ស្រុក លើការផ្តល់ការបណ្តុះបណ្តាល និងការកសាងសមត្ថភាពក្រោមគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

១១.តាមដានការត្រួតពិនិត្យ និងការវាយតម្លៃលើសកម្មភាពគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

១២.ទទួលខុសត្រូវចំពោះការរៀបចំ និងបែងចែកសកម្មភាព និងរបាយការណ៍ហិរញ្ញវត្ថុតាមពេលទៀងទាត់ រួចហើយដាក់ជូនអភិបាលខេត្តសុំការអនុញ្ញាត និងដាក់ជូនគណៈកម្មាធិការប្រតិបត្តិសុំការដាក់បញ្ចូល និងចេញសេចក្តីប្រកាសជូនលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ។

១៣.ធានាឲ្យមានភាពស្របគ្នាតាមក្របខ័ណ្ឌអភិបាលកិច្ចល្អរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច និង

១៤.ធានាឲ្យមានភាពស្របគ្នាជាមួយកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងសមាគមអភិវឌ្ឍអន្តរជាតិ ពាក់ព័ន្ធនឹងប្រតិបត្តិការរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

១៥.ជួយសម្រួលទំនាក់ទំនងរវាងក្រុមការងារថ្នាក់ស្រុក គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត/គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត និងលេខាធិការដ្ឋាននៃគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត និង

១៦. ភារកិច្ចផ្សេងទៀតដែលដឹកនាំដោយប្រធានគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត/គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត។

**លក្ខណៈសម្បត្តិ**

១. ជាមន្ត្រីរាជការថ្នាក់ខេត្តដែលរៀនចប់កម្រិតមធ្យម ឬ ឧត្តម និងបូករួមនឹងបទពិសោធន៍ការងារសមរម្យ

២. មានចំណេះដឹងល្អខាងលេខនព្វន្ត

៣. មានជំនាញល្អខាងសរសេររបាយការណ៍ ទំនាក់ទំនង និងសម្របសម្រួល

៤. មានចំណេះដឹង និងបទពិសោធន៍ទាក់ទងនឹងការគ្រប់គ្រងដី និងការអភិវឌ្ឍជនបទ

៥. មានចំណេះដឹងផ្នែកដំណើរការរៀបចំផែនការ

៦. មានជំនាញ និងចំណេះដឹងអំពីមូលដ្ឋានគ្រឹះកុំព្យូទ័រ និង
៨. មានសមត្ថភាពខាងប្រព័ន្ធព័ត៌មានភូមិសាស្ត្រ ឧបករណ៍កំណត់ទីតាំងភូគោលសាស្ត្រ និងកម្មវិធី software ទាក់ទងផ្សេងទៀត។

# លក្ខខណ្ឌការងារ

| | |
|---|---|
| មុខតំណែង: | អ្នកឯកទេសថ្នាក់ជាតិផ្នែកកសិកម្ម |
| ឈ្មោះគម្រោង: | គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច |
| ខ្ទង់ថវិកា: | |
| ទីកន្លែងបំពេញការងារ: | គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត /គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត |
| រយៈពេល: | មួយឆ្នាំ (ដោយមានការត្រួតពិនិត្យការអនុវត្តប្រចាំឆ្នាំ) |

## ទិដ្ឋភាពទូទៅ

គោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺស្ថិតនៅក្រោមអំណាច និងការគ្រប់គ្រងទាំងស្រុងរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប)។ អង្គភាពគាំទ្រកម្មវិធីរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិទទួលខុសត្រូវក្នុងការអនុវត្តកម្មវិធី។ គណៈកម្មាធិការអភិវឌ្ឍន៍ជនបទថ្នាក់ខេត្តដែលដឹកនាំដោយអភិបាលខេត្តទទួលខុសត្រូវចំពោះការគ្រប់គ្រងកិច្ចការនេះនៅថ្នាក់ខេត្ត។

អភិបាលខេត្តបានបង្កើតគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ុត និងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត គឺដើម្បីអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ និងការងារប្រចាំថ្ងៃរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងគោលបំណងបំពេញការទទួលខុសត្រូវផ្នែកប្រតិបត្តិរបស់ខ្លួនក្នុងការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ។

គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកចិ្ច គឺជាគម្រោងមួយដែលគាំទ្រការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចរបស់រាជរដ្ឋាភិបាល ដើម្បីបែងចែកដីជូនប្រជាពលរដ្ឋដែលគ្មានដី និងមានដីតិចតួចតាមរយៈសម្បទានដីសង្ុគមកិច្ច ដើម្បីលើកកម្ពស់ជីវភាពរបស់គ្រួសារក្រីក្រ និងប្រជាពលរដ្ឋងាយរងគ្រោះតាមរយៈការធ្វើសម្បទានដីសង្គមកិច្ចផ្អែកលើឃុំ។ គោលបំណងរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺដើម្បីៈ

- បែងចែកដីរដ្ឋដែលសមស្របសម្រាប់ធ្វើកសិកម្ម រួមជាមួយនឹងសេវាគាំទ្រសមស្របមួយចំនួនដល់គ្រួសារគ្មានដី និងគ្រួសារមានដីតិចតួចពិតប្រាកដ និង
- ណែនាំ និងអនុវត្តដំណើរការប្រកបដោយតម្លាភាព និងមានបទដ្ឋានសម្រាប់ការអនុវត្តបន្ថែមលើសម្បទានដីសង្គមកិច្ចដែលបានចាប់ផ្តើមឡើងនៅតាមមូលដ្ឋាន។

ការអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិចុ្ច និងការអភិវឌ្ឍសេដ្ឋកិច្ចគោរពតាមគោលការណ៍ដូចខាងក្រោមៈ

- លើកកម្ពស់អភិបាលកិច្ចល្អ និងនីតិរដ្ឋ
- គាំទ្រ និងពង្រឹងរបៀបវារៈធ្វើកំណែទម្រង់ដីធ្លីរបស់រដ្ឋាភិបាល
- លើកទឹកចិត្តឲ្យមានការចូលរួមពីប្រជាពលរដ្ឋ
- ទប់ស្កាត់ការខូចខាតដល់បិរស្ថាន
- លើកកម្ពស់តម្លាភាព និងគណនេយ្យភាព និង
- ធានាឲ្យមានកំណើនប្រកបដោយនិរន្តរភាព

ភ្នាក់ងារប្រតិបត្តិសម្រាប់គម្រោងបែងចែកដីដើម្បីសង្គមសេដ្ឋកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺជាអគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច ដែលមានមូលដ្ឋាននៅក្នុងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ យោងតាមអនុសារណៈយោគយល់ដែលបានចុះហត្ថលេខារវាងក្រសួងរៀបចំ ដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងមហាផ្ទៃនៅថ្ងៃទី ២៤ ខែសីហា ឆ្នាំ ២០០៧ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ត្រូវទទួលខុសចំពោះរាល់ទិដ្ឋភាពប្រតិបត្តិការរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចនៅថ្នាក់ក្រោមជាតិ រួមទាំងការគ្រប់គ្រងកិច្ចសន្យា ការគ្រប់គ្រងហិរញ្ញវត្ថុ និងការត្រួតពិនិត្យតាមដាន និងការវាយតម្លៃ ក៏ដូចជាដើម្បីត្រួតពិនិត្យការអនុវត្តនៅក្នុងក្របខ័ណ្ឌនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) នឹងអនុវត្តការទទួលខុសត្រូវនេះ តាមរយៈគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត/គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត។

**អ្នកឯកទេសផ្នែកកសិកម្មរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច** គឺជាបុគ្គលិកមួយរូបនៅក្នុងមន្ទីរកសិកម្មខេត្ត ដែលទទួលខុសត្រូវជួយដល់អ្នកគ្រប់គ្រងថ្នាក់ខេត្តនៅក្នុងគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តក្នុងការគាំទ្រការអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។ បុគ្គលិករូបនេះនឹងធ្វើការដោយផ្ទាល់តាមរយៈការជួយការផ្តល់មតិយោបល់ និងការជួយជ្រោមជ្រែងដល់ក្រុមការងារថ្នាក់ស្រុក និងក្រុមប្រឹក្សាឃុំ។

## ការគ្រប់គ្រងមុខតំណែង

**អ្នកឯកទេសផ្នែកកសិកម្ម** គឺស្ថិតក្រោមការត្រួតពិនិត្យដោយផ្ទាល់ពីប្រធានគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត/គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត។

## ភារកិច្ចជាក់លាក់

ជាក់ស្តែង **ឯកទេសផ្នែកកសិកម្ម** នឹង:

- ជួយប្រធានគ្រប់គ្រងថ្នាក់ខេត្តដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងសេវាកសិកម្ម រួមមានក្សេត្រសាស្ត្រ ការផ្សព្វផ្សាយកសិកម្ម និងសេវាបសុពេទ្យ

- ផ្តល់ការវាយតម្លៃផ្នែកកសិកម្មលើសំណើធ្វើសម្បទានដីសង្គមកិច្ចរបស់ឃុំ ផែនការអនុគម្រោងសម្បទានដីសង្គមកិច្ចបណ្តោះអាសន្ន និងចុងក្រោយ ដើម្បីជាធនធានសម្រាប់ដំណើរការពិនិត្យឡើងវិញ និងការសម្រេចរបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ។
- កំណត់អត្តសញ្ញាណអ្នកផ្តល់សេវាកសិកម្មសាធារណៈ និងឯកជនសម្រាប់ការផ្សព្វផ្សាយស្រាវជ្រាវ ធនធាន និងការរកទីផ្សារ និងការកែច្នៃ
- នៅពេលចាំបាច់ ត្រូវធ្វើការសហការជាមួយគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ក្នុងការវាយតម្លៃលើបទដ្ឋានបច្ចេកទេស ដើម្បីគាំទ្រដល់លទ្ធកម្មទំនិញ និងសេវាកសិកម្មរបស់ឃុំ។
- ជួយប្រធានគ្រប់គ្រងថ្នាក់ខេត្តក្នុងការសម្របសម្រួលការគាំទ្រផ្នែកកសិកម្មពីភ្នាក់ងារថ្នាក់ខេត្ត និងថ្នាក់ជាតិ រួមទាំងប្រព័ន្ធក្សេត្របរិស្ថាន
- ផ្តល់ការបណ្តុះបណ្តាល និងសកម្មភាពកសាងសមត្ថភាពដល់ក្រុមការងារថ្នាក់ស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមអ្នកទទួលផលស្តីពីផលិតផលកសិកម្ម និងបញ្ហាទីផ្សារ
- ជួយប្រធានគ្រប់គ្រងថ្នាក់ខេត្តដោះស្រាយបញ្ហានានាទាក់ទងនឹងការប្រើប្រាស់ និងការគ្រប់គ្រងក្រោយពេលប្រមូលផល។ ជួយប្រធានគ្រប់គ្រងប្រចាំខេត្តផ្តល់ការគាំទ្រដល់អ្នកទទួលផល ស្តីអំពីវិធីសាស្ត្រផលិតកសិកម្មរួមបញ្ចូលគ្នា (ដែលរួមមានការបង្កើតធនាគារស្រូវ និងកម្មវិធីសន្សំប្រាក់ផ្អែកលើសហគមន៍ ដោយផ្តោតជាសំខាន់លើបញ្ហាកសិកម្ម) និង
- ធ្វើការសម្របសម្រួលជាមួយអ្នកជំនាញគ្រប់គ្រងដី និងអភិវឌ្ឍន៍ជនបទ ស្តីពីដំណើរការរៀបចំផែនការប្រើប្រាស់ដីដែលមានការចូលរួមសម្រាប់សម្បទានដីសង្គមកិច្ចនៅក្នុងតំបន់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។

## លក្ខណសម្បត្តិ និងបទពិសោធន៍

**អ្នកឯកទេសផ្នែកកសិកម្ម** ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម:

- មានសញ្ញាបត្រសិក្សាពាក់ព័ន្ធនឹងផ្នែកកសិកម្ម ឬ ជំនាញពាក់ព័ន្ធ និង/ឬ រួមផ្សំនឹងបទពិសោធន៍សមស្រប
- មានបទពិសោធន៍ច្រើនក្នុងការអភិវឌ្ឍសង្គម និងសហគមន៍ ការធ្វើផែនការដែលមានការចូលរួម និងការងារកសិកម្ម ឬ ក្នុងវិស័យពាក់ព័ន្ធ
- មានបទពិសោធន៍ក្នុងការជ្រើសរើសពូជ វិធីសាស្ត្រធ្វើកសិកម្ម ការវិភាគដី និងក្សេត្រសាស្ត្រ
- មានចំណេះដឹងការងារទាក់ទងនឹងបទបញ្ញត្តិ និងគោលនយោបាយសំខាន់ៗទាក់ទងនឹងច្បាប់ ធ្វើកសិកម្ម ដីធ្លី ព្រៃឈើ ទឹក និងច្បាប់បរិស្ថាន
- មានចំណេះដឹង និងបទពិសោធន៍អំពីព័ត៌មានទីផ្សារ និងដាក់តម្លៃទីផ្សារ

- មានបទពិសោធន៍ក្នុងការគ្រប់គ្រងក្រោយពេលប្រមូលផល
- មានបទពិសោធន៍ធ្វើផែនការប្រើប្រាស់ដីធ្លីដែលមានការចូលរួម
- មានបទពិសោធន៍ជាក់ស្តែងក្នុងការគ្រប់គ្រងកសិដ្ឋាន និងពូជ
- មានជំនាញរៀបចំផែនការ គ្រប់គ្រង និងធ្វើរបាយការណ៍កន្លងមក
- មានសមត្ថភាពជាក់ស្តែងអាចធ្វើការនៅក្នុងក្រុមការងារចម្រុះដែលមានជំនាញខុសៗគ្នា និងមានសមត្ថភាពអាចធ្វើការជាមួយភ្នាក់ងាររដ្ឋាភិបាល និងក្រៅរដ្ឋាភិបាលផ្សេងៗទៀត
- មានជំនាញកុំព្យូទ័រពាក់ព័ន្ធ មានជំនាញស្តាប់នៅក្នុងបរិបទមួយដែលមានអ្នកពាក់ព័ន្ធច្រើន
- មានជំនាញខ្លាំងខាងទំនាក់ទំនង និងសម្របសម្រួល អាចនិយាយ និងសរសេរភាសាខ្មែរ និងភាសាអង់គ្លេសបានល្អ

# លក្ខខណ្ឌការងារ

មុខតំណែង: អ្នកឯកទេសជ្រើសរើសអ្នកទទួលផលគម្រោងឡាសិតថ្នាក់ជាតិ
ឈ្មោះគម្រោង: គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច
ខ្ទង់ថវិកា:
ទីកន្លែងបំពេញការងារ: គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត /គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត
រយៈពេល: មួយឆ្នាំ (ដោយមានការត្រួតពិនិត្យការអនុវត្តប្រចាំឆ្នាំ)

**ទិដ្ឋភាពទូទៅ**

គោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺស្ថិតនៅក្រោមអំណាច និងការគ្រប់គ្រងទាំងស្រុងរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប)។ អង្គភាពគាំទ្រកម្មវិធីរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិទទួលខុសត្រូវក្នុងការអនុវត្តកម្មវិធី។ គណៈកម្មាធិការអភិវឌ្ឍន៍ជនបទថ្នាក់ខេត្តដែលដឹកនាំដោយអភិបាលខេត្តទទួលខុសត្រូវចំពោះការគ្រប់គ្រងកិច្ចការនេះនៅថ្នាក់ខេត្ត។

អភិបាលខេត្តបានបង្កើតគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត និងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត គឺដើម្បីអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ និងការងារប្រចាំថ្ងៃរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងគោលបំណងបំពេញការទទួលខុសត្រូវផ្នែកប្រតិបត្តិរបស់ខ្លួនក្នុងការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ។

គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកច្ចិ គឺជាគម្រោងមួយដែលគាំទ្រការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចរបស់រាជរដ្ឋាភិបាល ដើម្បីបែងចែកដីជូនប្រជាពលរដ្ឋដែលគ្មានដី និងមានដីតិចតួច តាមរយៈសម្បទានដីសង្គមកិច្ច ដើម្បីលើកកម្ពស់ជីវភាពរបស់គ្រួសារក្រីក្រ និងប្រជាពលរដ្ឋងាយរងគ្រោះតាមរយៈការធ្វើសម្បទានដីសង្គមកិច្ចផ្អែកលើឃុំ។ គោលបំណងរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺដើម្បី:

- បែងចែកដីរដ្ឋដែលសមស្របសម្រាប់ធ្វើកសិកម្ម រួមជាមួយនឹងសេវាគាំទ្រសមស្របមួយចំនួនដល់គ្រួសារគ្មានដី និងគ្រួសារមានដីតិចតួចពិតប្រាកដ និង
- ណែនាំ និងអនុវត្តដំណើរការប្រកបដោយតម្លាភាព និងមានបទដ្ឋានសម្រាប់ការអនុវត្តបន្ថែមលើសម្បទានដីសង្គមកិច្ចដែលបានចាប់ផ្តើមឡើងនៅតាមមូលដ្ឋាន។

ការអនុវត្តរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គោរព តាមគោលការណ៍ដូចខាងក្រោម:

- លើកកម្ពស់អភិបាលកិច្ចល្អ និងនីតិរដ្ឋ
- គាំទ្រ និងពង្រឹងរបៀបវារៈធ្វើកំណែទម្រង់ដីធ្លីរបស់រដ្ឋាភិបាល
- លើកទឹកចិត្តឲ្យមានការចូលរួមពីប្រជាពលរដ្ឋ
- ទប់ស្កាត់ការខូចខាតដល់បិរស្ថាន
- លើកកម្ពស់តម្លាភាព និងគណនេយ្យភាព និង
- ធានាឲ្យមានកំណើនប្រកបដោយនិរន្តរភាព

ភ្នាក់ងារប្រតិបត្តិសម្រាប់គម្រោងបែងចែកដីដើម្បីសង្គមសេដ្ឋកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺជាអគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច ដែលមានមូលដ្ឋាននៅក្នុងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ យោងតាមអនុស្សារណៈយោគយល់ដែលបានចុះហត្ថលេខារវាង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងមហាផ្ទៃនៅថ្ងៃទី ២៤ ខែសីហា ឆ្នាំ ២០០៧ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ត្រូវទទួលខុសចំពោះរាល់ទិដ្ឋភាពប្រតិបត្តិការរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចនៅថ្នាក់ក្រោមជាតិ រួមទាំងការគ្រប់គ្រងកិច្ចសន្យា ការគ្រប់គ្រងហិរញ្ញវត្ថុ និងការត្រួតពិនិត្យតាមដាន និងការវាយតម្លៃ ក៏ដូចជាដើម្បីត្រួតពិនិត្យការអនុវត្តនៅក្នុងក្របខ័ណ្ឌ នៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) នឹងអនុវត្តការទទួលខុសត្រូវនេះតាមរយៈគណៈកម្មាធិ ការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត/គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត។

**អ្នកឯកទេសជ្រើសរើសអ្នកទទួលផលពីគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចថ្នាក់ជាតិ** គឺជាបុគ្គលិកមួយរូបរបស់អគ្គលេខាធិការដ្ឋានថ្នាក់ខេត្តដែលមានតួនាទីជួយ ប្រធានគ្រប់គ្រងថ្នាក់ខេត្ត ដើម្បីគាំទ្រការអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍ សេដ្ឋកិច្ច ។ អ្នកឯកទេសជ្រើសរើសអ្នកទទួលផលពីគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការ អភិវឌ្ឍសេដ្ឋកិច្ចថ្នាក់ជាតិនឹងអនុវត្តការងារនេះដោយផ្ទាល់តាមរយៈការគាំទ្រ ការផ្តល់មតិយោបល់ និងការជួយជ្រោមជ្រែងក្រុមការងារថ្នាក់ស្រុក និងក្រុមប្រឹក្សាឃុំ។

## ការគ្រប់គ្រងមុខតំណែង

**អ្នកឯកទេសជ្រើសរើសអ្នកទទួលផល** គឺស្ថិតនៅក្រោមការត្រួតពិនិត្យដោយផ្ទាល់ពីប្រធាន គ្រប់គ្រងថ្នាក់ខេត្តនៅក្នុងគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត/គណៈកម្មាធិការ គ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត។

**ភារកិច្ចជាក់លាក់**

ជាក់ស្តែង **អ្នកឯកទេសជ្រើសរើសអ្នកទទួលផល នឹង:**

- ជួយប្រធានគ្រប់គ្រងថ្នាក់ខេត្តដោះស្រាយបញ្ហាទាក់ទងនឹងនីតិវិធីនៃការជ្រើសរើសអ្នកទទួលផល
- ទទួលអនុវត្តការត្រួតពិនិត្យបច្ចេកទេស និងផ្តល់ការណែនាំដល់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ទាក់ទិននឹងទិដ្ឋភាពនៃការជ្រើសរើសសំណើរបស់អ្នកទទួលផល ផែនការបណ្តោះអាសន្ន និងផែនការអនុគម្រោងសម្បទានដីសង្គមកិច្ចចុងក្រោយដែលដាក់ជូនដោយឃុំដើម្បីសុំការឯកភាពពីគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត។
- ជួយបណ្តុះបណ្តាល និងត្រួតពិនិត្យតាមដានដើម្បីធានាឲ្យមានតម្លាភាព គណនេយ្យភាព និងយុត្តិធម៌ក្នុងដំណើរការជ្រើសរើស
- ជួយបណ្តុះបណ្តាល និងពិនិត្យតាមដានដើម្បីធានាឲ្យមានការចូលរួមពីប្រជាពលរដ្ឋ និងបញ្ហាយេនឌ័រ
- ធានាថា គោលការណ៍ការបញ្ជ្រាបយេនឌ័រត្រូវបានដាក់ឲ្យអនុវត្តប្រកបដោយប្រសិទ្ធភាព
- ជួយក្រុមការងារថ្នាក់ស្រុកក្នុងការវាយតម្លៃសេចក្តីត្រូវការ ដើម្បីកំណត់លក្ខណវិនិច្ឆ័យនៃការជ្រើសរើសអ្នកទទួលផល ជាពិសេសនៅក្នុងបណ្តាឃុំដែលមានលក្ខណសម្បត្តិពិសេស។
- ជួយបណ្តុះបណ្តាល និងពិនិត្យតាមដានដើម្បីធានាឲ្យមានការចូលរួមពីសហគមន៍ និងធានាបាននូវតម្លាភាពស្របតាមក្របខ័ណ្ឌនៃការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច
- ជួយប្រធានគ្រប់គ្រងថ្នាក់ខេត្តត្រួតពិនិត្យពាក្យបណ្តឹង និងបណ្តឹងសាទុក្ខ និងរបាយការណ៍នានា និងធានាថាបានឆ្លើយតបទៅកាន់អ្នកទទួលផលទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព
- ជួយប្រធានគ្រប់គ្រងថ្នាក់ខេត្តក្នុងការប្រមូលទិន្នន័យ និងការគ្រប់គ្រងពាក់ព័ន្ធនឹងអ្នកទទួល ផល
- ជួយប្រធានគ្រប់គ្រងថ្នាក់ខេត្តក្នុងការផ្តល់ការបណ្តុះបណ្តាល និងសកម្មភាពកសាងសមត្ថភាពដល់ក្រុមការងារថ្នាក់ស្រុក ក្រុមប្រឹក្សាឃុំ ប្រធានភូមិ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល និង
- សម្របសម្រួលជាមួយអ្នកឯកទេសរៀបចំដែនដី កសិកម្ម និងអភិវឌ្ឍន៍ជនបទ ទាក់ទងនឹងដំណើរការរៀបចំផែនការប្រើប្រាស់ដីដែលមានការចូលរួមសម្រាប់សម្បទានដីសង្គមកិច្ចក្នុង តំបន់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។

**លក្ខណសម្បត្តិ និងបទពិសោធន៍**

**អ្នកឯកទេសជ្រើសរើសអ្នកទទួលផល** ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោមៈ

- មានបទពិសោធន៍ទូលំទូលាយក្នុងការអភិវឌ្ឍសង្គម ជនបទ និងសហគមន៍
- មានបទពិសោធន៍ក្នុងការធ្វើជំរឿនប្រជាពលរដ្ឋ និងវិធីសាស្ត្រធ្វើចំណាត់ថ្នាក់សង្គមកិច្ច
- មានចំណេះដឹងការងារអំពីបទបញ្ញត្តិ និងគោលនយោបាយសំខាន់ៗ ទាក់ទងនឹងច្បាប់កសិកម្ម ដីធ្លី ព្រៃឈើ ទឹក និងច្បាប់បរិស្ថាន
- មានបទពិសោធន៍ក្នុងសកម្មភាពបណ្តុះបណ្តាលនានា
- មានបទពិសោធន៍ក្នុងការរៀបចំផែនការប្រើប្រាស់ដីធ្លីដែលមានការចូលរួម
- មានសញ្ញាបត្រសិក្សាពាក់ព័ន្ធ និង/ឬ រួមផ្សំនឹងបទពិសោធន៍សមស្រប
- មានជំនាញក្នុងការធ្វើផែនការ គ្រប់គ្រង និងការធ្វើរបាយការណ៍
- មានជំនាញកុំព្យូទ័រដែលពាក់ព័ន្ធ និង
- មានជំនាញខ្លាំងខាងទំនាក់ទំនង និងសម្របសម្រួលល និងការឡើងបង្ហាញ អាចនិយាយ និងសរសេរបានយ៉ាងល្អ។

# <u>លក្ខខណ្ឌការងារ</u>

| | |
|---|---|
| មុខតំណែង: | មន្ត្រីសុរិយោដី និងការគ្រប់គ្រងដីគម្រោងឡាសិតថ្នាក់ជាតិ |
| ឈ្មោះគម្រោង: | គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច |
| ខ្ទង់ថវិកា: | |
| ទីកន្លែងបំពេញការងារ: | គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត /គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត |
| រយៈពេល: | មួយឆ្នាំ (ដោយមានការត្រួតពិនិត្យការអនុវត្តប្រចាំឆ្នាំ) |

**ទិដ្ឋភាពទូទៅ**

គោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺស្ថិតនៅក្រោមអំណាច និងការគ្រប់គ្រងទាំងស្រុងរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប)។ អង្គភាពគាំទ្រកម្មវិធីរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិទទួលខុសត្រូវក្នុងការអនុវត្តកម្មវិធី។ គណៈកម្មាធិការអភិវឌ្ឍន៍ជនបទថ្នាក់ខេត្តដែលដឹកនាំដោយអភិបាលខេត្តទទួលខុសត្រូវចំពោះការគ្រប់គ្រងកិច្ចការនេះនៅថ្នាក់ខេត្ត។

អភិបាលខេត្តបានបង្កើតគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត និងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត គឺដើម្បីអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ និងការងារប្រចាំថ្ងៃរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងគោលបំណងបំពេញការទទួលខុសត្រូវផ្នែកប្រតិបត្តិរបស់ខ្លួនក្នុងការអនុវត្តផែនការការសកម្មភាព និងថវិកាប្រចាំឆ្នាំ។

គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺជាគម្រោងមួយដែលគាំទ្រការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចរបស់រាជរដ្ឋាភិបាល ដើម្បីបែងចែកដីជូនប្រជាពលរដ្ឋដែលគ្មានដី និងមានដីតិចតួចតាមរយៈសម្បទានដីសង្គមកិច្ច ដើម្បីលើកកម្ពស់ជីវភាពរបស់គ្រួសារក្រីក្រ និងប្រជាពលរដ្ឋងាយរងគ្រោះតាមរយៈការធ្វើសម្បទានដីសង្គមកិច្ចផ្អែកលើឃុំ។ គោលបំណងរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺដើម្បី:

- បែងចែកដីរដ្ឋដែលសមស្របសម្រាប់ធ្វើកសិកម្ម រួមជាមួយនឹងសេវាគាំទ្រសមស្របមួយចំនួនដល់គ្រួសារគ្មានដី និងគ្រួសារមានដីតិចតួចពិតប្រាកដ និង
- ណែនាំ និងអនុវត្តដំណើរការប្រកបដោយតម្លាភាព និងមានបទដ្ឋានសម្រាប់ការអនុវត្តបន្ថែមលើសម្បទានដីសង្គមកិច្ចដែលបានចាប់ផ្តើមឡើងនៅតាមមូលដ្ឋាន។

ការអនុវត្តរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គោរពតាមគោលការណ៍ដូចខាងក្រោម:

- លើកកម្ពស់អភិបាលកិច្ចល្អ និងនីតិវិធី
- គាំទ្រ និងពង្រឹងរបៀបវារៈធ្វើកំណែទម្រង់ដីធ្លីរបស់រដ្ឋាភិបាល
- លើកទឹកចិត្តឲ្យមានការចូលរួមពីប្រជាពលរដ្ឋ
- ទប់ស្កាត់ការខូចខាតដល់បិរស្ថាន
- លើកកម្ពស់តម្លាភាព និងគណនេយ្យភាព និង
- ធានាឲ្យមានកំណើនប្រកបដោយនិរន្តរភាព

ភ្នាក់ងារប្រតិបត្តិសម្រាប់គម្រោងបែងចែកដីដើម្បីសង្គមសេដ្ឋកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺជាអគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច ដែលមានមូលដ្ឋាននៅក្នុងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ យោងតាមអនុសារណៈយោគយល់ដែលបានចុះហត្ថលេខារវាងក្រសួងរៀបចំ ដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងមហាផ្ទៃនៅថ្ងៃទី ២៤ ខែសីហា ឆ្នាំ ២០០៧ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ត្រូវទទួលខុសចំពោះរាល់ទិដ្ឋភាពប្រតិបត្តិការរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍ សេដ្ឋកិច្ចនៅថ្នាក់ក្រោមជាតិ រួមទាំងការគ្រប់គ្រងកិច្ចសន្យា ការគ្រប់គ្រងហិរញ្ញវត្ថុ និងការត្រួតពិនិត្យតាមដាន និងការវាយតម្លៃ ក៏ដូចជាដើម្បីត្រួតពិនិត្យការអនុវត្តនៅក្នុងក្របខ័ណ្ឌនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) នឹងអនុវត្តការទទួលខុសត្រូវនេះតាមរយៈគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត/គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត។

**មន្ត្រីសុរិយោដី និងការគ្រប់គ្រងដីថ្នាក់ជាតិនៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច** គឺជាបុគ្គលិកមួយរូបរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ដោយមានតួនាទីជួយប្រធានគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្នុងការ គាំទ្រការអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។ សុរិយោដី និងការ គ្រប់គ្រងដីថ្នាក់ជាតិនៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចនឹងអនុវត្តការងារ នេះដោយផ្ទាល់តាមរយៈការគាំទ្រ ការផ្តល់មតិយោបល់ និងការជួយជ្រោមជ្រែងក្រុមការងារថ្នាក់ស្រុក និងក្រុមប្រឹក្សាឃុំ។

## ការគ្រប់គ្រងមុខតំណែង

**មន្ត្រីសុរិយោដី និងការងារគ្រប់គ្រងដី** គឺស្ថិតនៅក្រោមការត្រួតពិនិត្យផ្ទាល់របស់ប្រធានគ្រប់គ្រងថ្នាក់ខេត្តនៅក្នុងគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត/គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត។

**ភារកិច្ចជាក់លាក់**

ជាក់ស្តែង **ការងារសុរិយោដី និងការគ្រប់គ្រងដី** នឹង:

- គាំទ្រគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត/គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ ខេត្ត ក្រុមការងារថ្នាក់ប្រចាំស្រុក និងក្រុមប្រឹក្សាឃុំ ទាក់ទងនឹងទិដ្ឋភាពបច្ចេកទេសទាំង ស្រុងស្តីពីការកំណត់អត្តសញ្ញាណកម្មដីឯកជនរបស់រដ្ឋ ការធ្វើផែនទី ការធ្វើចំណាត់ថ្នាក់ដី ការវាស់វែង និងការចុះបញ្ជីសម្រាប់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍ សេដ្ឋកិច្ច។
- ធានាឲ្យមានការចូលរួម និងធ្វើបច្ចុប្បន្នកម្មលើផែនទីទីតាំងសំខាន់ក្នុងខេត្ត និងការពិភាក្សាជាមួយសាធារណជនពាក់ព័ន្ធ សង្គមស៊ីវិល និងបណ្តាភាគីពាក់ព័ន្ធដទៃទៀត ក៏ដូចជាការផ្សព្វផ្សាយរបស់ខ្លួនទៅដល់បណ្តាស្រុក និងឃុំនានា
- ត្រួតពិនិត្យសំណើធ្វើសម្បទានដីសង្គមកិច្ច ផែនការអនុគម្រោងសម្បទានដីសង្គមកិច្ចបណ្តោះអាសន្ន និងចុងក្រោយរបស់ឃុំ ស្តីអំពីទិដ្ឋភាពនៃការរៀបចំដីធ្លីសម្រាប់ការពិនិត្យ និងការសម្រេចពីគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត
- ធានាថា កត្តាមជ្ឈដ្ឋានជុំវិញ និងសុវត្ថិភាពសង្គមនៅក្នុងតំបន់សម្បទានដីសង្គមកិច្ច ត្រូវបានដោះស្រាយប្រកបដោយប្រសិទ្ធភាព
- ធានាថា ការចូលរួមរបស់ប្រជាពលរដ្ឋ និងការបញ្ជ្រាបយេនឌ័រត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពនៅក្នុងដំណើរការគ្រប់គ្រងនេះ
- ផ្តល់ការគាំទ្របច្ចេកទេស និងការណែនាំស្តីអំពីបញ្ហាសុរិយោដីនៅថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សាឃុំ
- ជួយប្រធានគ្រប់គ្រងគម្រោងប្រចាំខេត្តក្នុងការផ្តល់នូវព័ត៌មានទាក់ទងនឹងភាពអាចទទួលបានដីធ្លីសម្រាប់គម្រោងបែងចែកដី ដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចនៅថ្នាក់ឃុំ
- ចូលរួមដោយផ្ទាល់ក្នុងការគ្រប់គ្រងទិន្នន័យ និងការវិភាគទាក់ទងទៅនឹងប្រព័ន្ធព័ត៌មានភូមិសាស្ត្រទាក់ទងនឹងតំបន់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចរួមមានការរៀបចំផែនទីតំបន់ដោយផ្អែកលើទិដ្ឋភាពតំបន់ជនបទសម្រាប់ប្រើប្រាស់ តាមរយៈបណ្តា ឃុំ និងស្រុកក្នុងការរៀបចំផែនការសម្បទានដីសង្គមកិច្ច
- ជួយប្រធានគ្រប់គ្រងប្រចាំខេត្ត បណ្តុះបណ្តាល និងគាំទ្រនៅថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សាឃុំ ស្តីពីការទទួលស្គាល់ដីឯកជនរបស់រដ្ឋ គូសផែនទី ការធ្វើចំណាត់ថ្នាក់ ការវាស់ស្ទង់ និងនីតិវិធីចុះបញ្ជី
- ជួយរៀបចំរបាយការណ៍ដែលពាក់ព័ន្ធនឹងការទទួលស្គាល់ដីឯកជនរបស់រដ្ឋ ការធ្វើផែនទី ការធ្វើចំណាត់ថ្នាក់ ការវាស់ស្ទង់ និងការចុះបញ្ជីសម្រាប់គម្រោង

- អនុវត្តការងារតាមមូលដ្ឋានពាក់ព័ន្ធដែលទាក់ទងដោយផ្ទាល់ទៅនឹងគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច តាមការណែនាំរបស់ប្រធានគ្រប់គ្រងប្រចាំខេត្ត និង
- ជួយក្នុងការអនុវត្តការត្រួតពិនិត្យ និងការវាយតម្លៃពាក់ព័ន្ធនឹងការអនុវត្តសកម្មភាពរបស់ថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សាឃុំដែលទាក់ទងនឹងដីឯកជនរបស់រដ្ឋ ការធ្វើផែនទី ការធ្វើចំណាត់ថ្នាក់ ធ្វើការវាស់ស្ទង់ និងការចុះបញ្ជីសម្រាប់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និង ការអភិវឌ្ឍសេដ្ឋកិច្ច
- ជួយក្នុងការអនុវត្តការត្រួតពិនិត្យ និងការវាយតម្លៃពាក់ព័ន្ធនឹងការអនុវត្តសកម្មភាពរបស់ថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សាឃុំ ទាក់ទងនឹងការអនុវត្តផែនការប្រើប្រាស់ដីរបស់សម្បទានដីសង្គមកិច្ចដែលបានអនុម័តហើយ និង
- សម្របសម្រួលជាមួយអ្នកឯកទេសកសិកម្ម និងអភិវឌ្ឍន៍ជនបទ អំពីដំណើរការរៀបចំផែនការប្រើប្រាស់ដីធ្លីដែលមានការចូលរួមសម្រាប់សម្បទានដីសង្គមកិច្ច នៅក្នុងតំបន់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។

## លក្ខណសម្បត្តិ និងបទពិសោធន៍

**មន្ត្រីសុរិយោដី និងការងារគ្រប់គ្រងដី** ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម:

- មានប្រវត្តិអប់រំពាក់ព័ន្ធក្នុងការគ្រប់គ្រងសុរិយោដី និងដីធ្លី ឬ វិស័យដែលពាក់ព័ន្ធ និង/ឬ ការរួមបញ្ចូលនូវបទពិសោធន៍សមស្រប
- មានបទពិសោធន៍ទូលំទូលាយក្នុងការកំណត់អត្តសញ្ញាណកម្មដី ការធ្វើផែនទី ការធ្វើចំណាត់ថ្នាក់ ធ្វើការវាស់ស្ទង់ និងនីតិវិធីចុះបញ្ជី
- ស្គាល់ Total ឧបករណ៍កំណត់ទីតាំងភូគោលសាស្ត្រ ឧបករណ៍ និងបច្ចេកទេសវាស់ស្ទង់ផ្សេងៗទៀត
- មានចំណេះដឹងការងារអំពីបទបញ្ញត្តិ និងគោលនយោបាយសំខាន់ៗទាក់ទងនឹងច្បាប់កសិកម្ម ដីធ្លី ព្រៃឈើ ទឹក និងច្បាប់បរិស្ថាន
- មានជំនាញខាងការឡើងបង្ហាញ ទំនាក់ទំនង និងការសម្របសម្រួល ជំនាញស្តាប់នៅក្នុងមជ្ឈដ្ឋានការងារដែលមានអ្នកពាក់ព័ន្ធចម្រុះ
- មានជំនាញរៀបចំផែនការ គ្រប់គ្រង និងធ្វើរបាយការណ៍
- មានសមត្ថភាពជាក់ស្តែងអាចធ្វើការនៅក្នុងក្រុមការងារដែលមានជំនាញចម្រុះ និងមានលទ្ធភាពធ្វើការជាមួយភ្នាក់ងាររដ្ឋាភិបាល និងក្រៅរដ្ឋាភិបាលផ្សេងៗទៀត
- មានចំណេះដឹងកុំព្យូទ័រ និងកម្មវិធី software ពាក់ព័ន្ធនឹងប្រព័ន្ធព័ត៌មានភូមិសាស្ត្រ។

# លក្ខខណ្ឌការងារ

| | |
|---|---|
| មុខតំណែង: | មន្ត្រីឯកទេសអភិវឌ្ឍជនបទគម្រោងឡាសិតថ្នាក់ជាតិ |
| ឈ្មោះគម្រោង: | គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច |
| ខ្ទង់ថវិកា: | |
| ទីកន្លែងបំពេញការងារ: | គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត /គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត |
| រយៈពេល: | មួយឆ្នាំ (ដោយមានការត្រួតពិនិត្យការអនុវត្តប្រចាំឆ្នាំ) |

**ទិដ្ឋភាពទូទៅ**

គោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺស្ថិតនៅក្រោមអំណាច និងការគ្រប់គ្រងទាំងស្រុងរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប)។ អង្គភាពគាំទ្រកម្មវិធីរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិទទួលខុសត្រូវក្នុងការអនុវត្តកម្មវិធី។ គណៈកម្មាធិការអភិវឌ្ឍន៍ជនបទថ្នាក់ខេត្តដែលដឹកនាំដោយអភិបាលខេត្តទទួលខុសត្រូវចំពោះការគ្រប់គ្រងកិច្ចការនេះនៅថ្នាក់ខេត្ត។

អភិបាលខេត្តបានបង្កើតគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត និងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត គឺដើម្បីអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ និងការងារប្រចាំថ្ងៃរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ក្នុងគោលបំណងបំពេញការទទួលខុសត្រូវផ្នែកប្រតិបត្តិរបស់ខ្លួនក្នុងការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ។

គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកច្ចិ គឺជាគម្រោងមួយដែលគាំទ្រការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចរបស់រាជរដ្ឋាភិបាល ដើម្បីបែងចែកដីជូនប្រជាពលរដ្ឋដែលគ្មានដី និងមានដីតិចតួចតាមរយៈសម្បទានដីសង្គមកិច្ច ដើម្បីលើកកម្ពស់ជីវភាពរបស់គ្រួសារក្រីក្រ និងប្រជាពលរដ្ឋងាយរងគ្រោះ តាមរយៈការធ្វើសម្បទានដីសង្គមកិច្ចផ្អែកលើឃុំ។ គោលបំណងរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺដើម្បី:

- បែងចែកដីរដ្ឋដែលសមស្របសម្រាប់ធ្វើកសិកម្ម រួមជាមួយនឹងសេវាគាំទ្រសមស្របមួយចំនួនដល់គ្រួសារគ្មានដី និងគ្រួសារមានដីតិចតួចពិតប្រាកដ និង
- ណែនាំ និងអនុវត្តដំណើរការប្រកបដោយតម្លាភាព និងមានបទដ្ឋានសម្រាប់ការអនុវត្តបន្ថែមលើសម្បទានដីសង្គមកិច្ចដែលបានចាប់ផ្តើមឡើងនៅតាមមូលដ្ឋាន។

ការអនុវត្តរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គោរពតាមគោលការណ៍ដូចខាងក្រោម:

- លើកកម្ពស់អភិបាលកិច្ចល្អ និងនីតិរដ្ឋ
- គាំទ្រ និងពង្រឹងរបៀបវារៈធ្វើកំណែទម្រង់ដីធ្លីរបស់រដ្ឋាភិបាល
- លើកទឹកចិត្តឲ្យមានការចូលរួមពីប្រជាពលរដ្ឋ
- ទប់ស្កាត់ការខូចខាតដល់បរិស្ថាន
- លើកកម្ពស់តម្លាភាព និងគណនេយ្យភាព និង
- ធានាឲ្យមានកំណើនប្រកបដោយនិរន្តរភាព

ភ្នាក់ងារប្រតិបត្តិសម្រាប់គម្រោងបែងចែកដីដើម្បីសង្គមសេដ្ឋកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺជាអគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច ដែលមានមូលដ្ឋាននៅក្នុងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ យោងតាមអនុសារណៈយោគយល់ដែលបានចុះហត្ថលេខារវាងក្រសួងរៀបចំ ដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងមហាផ្ទៃនៅថ្ងៃទី ២៥ ខែសីហា ឆ្នាំ ២០០៧ គណៈ កម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ត្រូវទទួល ខុសចំពោះរាល់ទិដ្ឋភាពប្រតិបត្តិការរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋ កិច្ចនៅថ្នាក់ក្រោមជាតិ រួមទាំងការគ្រប់គ្រងកិច្ចសន្យា ការគ្រប់គ្រងហិរញ្ញវត្ថុ និងការត្រួតពិនិត្យ តាមដាន និងការវាយតម្លៃ ក៏ដូចជាដើម្បីត្រួតពិនិត្យការអនុវត្តនៅក្នុងក្របខ័ណ្ឌនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) នឹងអនុវត្តការទទួលខុសត្រូវនេះតាមរយៈគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត/គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត។

**មន្ត្រីឯកទេសអភិវឌ្ឍន៍ជនបទរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចថ្នាក់ជាតិ** គឺជាបុគ្គលិកមួយរូបរបស់មន្ទីរអភិវឌ្ឍជនបទខេត្ត ដែលមានតួនាទីជួយប្រធានគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្នុងការគាំទ្រការអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។ អ្នកឯកទេសអភិវឌ្ឍន៍ជនបទថ្នាក់ជាតិរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចនឹងអនុវត្តការងារនេះដោយផ្ទាល់តាមរយៈការគាំទ្រ ការផ្តល់មតិយោបល់ និងការជួយជ្រោមជ្រែងក្រុមការងារថ្នាក់ស្រុក និងក្រុមប្រឹក្សាឃុំ។

## ការគ្រប់គ្រងមុខតំណែង

**មន្ត្រីឯកទេសអភិវឌ្ឍន៍ជនបទ** គឺស្ថិតនៅក្រោមការត្រួតពិនិត្យផ្ទាល់របស់ប្រធានគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត/គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត។

## ភារកិច្ចជាក់លាក់

ជាក់ស្តែង **មន្ត្រីឯកទេសអភិវឌ្ឍន៍ជនបទ** នឹង:

- ជួយប្រធានគ្រប់គ្រងប្រចាំខេត្តដោះស្រាយបញ្ហាទាក់ទងនឹងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ជនបទ
- អនុវត្តការត្រួតពិនិត្យបច្ចេកទេស និងផ្តល់ការណែនាំដល់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត នៃទិដ្ឋភាពអភិវឌ្ឍន៍ជនបទរបស់សំណើផែនការបណ្តោះអាសន្ន និងផែនការអនុគម្រោងសម្បទានដីសង្គមកិច្ចចុងក្រោយដែលបានដាក់ជូនដោយឃុំដើម្បីសុំការឯកភាព ពីគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត។
- ជួយប្រធានគ្រប់គ្រងប្រចាំខេត្តក្នុងការវាយតម្លៃសេចក្តីត្រូវការ ដើម្បីកំណត់អាទិភាពនានាសម្រាប់ផែនការអភិវឌ្ឍន៍ឃុំ
- ជួយប្រធានគ្រប់គ្រងប្រចាំខេត្ត និងធ្វើការសហការជាមួយគណៈកម្មាធិការប្រតិបត្តិ ក្នុងការផ្តល់សកម្មភាពបណ្តុះបណ្តាល និងការកសាងសមត្ថភាពដល់ក្រុមការងារប្រចាំស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមអ្នកទទួលផល
- ជួយប្រធានគ្រប់គ្រងប្រចាំខេត្តដោះស្រាយបញ្ហាទាក់ទងនឹងការគាំទ្ររចនាសម្ព័ន្ធរបស់បណ្តាសហគមន៍ក្នុងតំបន់ជនបទ
- ធានាបាននូវការចូលរួមពីប្រជាពលរដ្ឋ និងបញ្ហាយេនឌ័រ
- ប្រាកដថា ការណែនាំអំពីការបញ្ជ្រាបយេនឌ័រ ត្រូវបានអនុវត្តយ៉ាងមានប្រសិទ្ធភាព និង
- ធ្វើការសម្របសម្រួលជាមួយអ្នកជំនាញខាងគ្រប់គ្រងដីធ្លី និងកសិកម្ម អំពីការគាំទ្រដំណើរការរៀបចំផែនការប្រើប្រាស់ដីដែលមានការចូលរួមសម្រាប់សម្បទានដីសង្គមកិច្ចនៅក្នុងតំបន់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។

## លក្ខណសម្បត្តិ និងបទពិសោធន៍

**មន្ត្រីឯកទេសអភិវឌ្ឍន៍** ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម:

- មានសញ្ញាបត្រសិក្សាពាក់ព័ន្ធនឹងការអភិវឌ្ឍជនបទ ឬ វិស័យពាក់ព័ន្ធ និង/ឬ បូករួមនឹងបទពិសោធន៍សមស្រប
- មានបទពិសោធន៍ទូលំទូលាយក្នុងការអភិវឌ្ឍផ្តោតលើសង្គម សហគមន៍ និងការអភិវឌ្ឍជនបទ ឬ ក្នុងវិស័យពាក់ព័ន្ធ
- មានបទពិសោធន៍ពាក់ព័ន្ធនឹងបញ្ហាស្វែងរកទីផ្សារ ការផ្តល់សេវាសុខភាព និងអប់រំ និងការផ្តល់សេវាផ្សេងៗទៀត
- មានចំណេះដឹងការងារអំពីបទបញ្ញត្តិ និងគោលនយោបាយសំខាន់ៗ ទាក់ទងនឹងច្បាប់កសិកម្ម ដីធ្លី ព្រៃឈើ ទឹក និងច្បាប់បរិស្ថាន
- មានចំណេះដឹង និងបទពិសោធន៍ក្នុងការរៀបចំផែនការ និងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធ

- មានបទពិសោធន៍ក្នុងការរៀបចំផែនការប្រើប្រាស់ដីធ្លីដែលមានការចូលរួម
- មានជំនាញក្នុងការធ្វើផែនការ គ្រប់គ្រង និងធ្វើរបាយការណ៍
- មានសមត្ថភាពជាក់ស្តែង អាចធ្វើការនៅក្នុងក្រុមការងារដែលមានជំនាញចម្រុះ និងមានលទ្ធភាពអាចធ្វើការជាមួយភ្នាក់ងាររដ្ឋាភិបាល និងក្រៅរដ្ឋាភិបាលផ្សេងៗទៀត
- មានជំនាញកុំព្យូទ័រដែលពាក់ព័ន្ធ និង
- មានជំនាញខ្លាំងខាងទំនាក់ទំនង និងសម្របសម្រួល និយាយ និងសរសេរភាសាខ្មែរ និងភាសាអង់គ្លេសបានល្អ មានជំនាញស្តាប់នៅក្នុងមជ្ឈដ្ឋានការងារដែលមានអ្នកពាក់ព័ន្ធចម្រុះ។

**ឧបសម្ព័ន្ធទី ៧ - លក្ខខណ្ឌយោង:**

# មុខតំណែងនៅថ្នាក់គណៈកម្មាធិការប្រតិបត្តិ

## <u>លក្ខខណ្ឌការងារ</u>

| | |
|---|---|
| មុខតំណែង: | មន្ត្រីគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាលគម្រោងឡាសិត |
| ឈ្មោះគម្រោង: | គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច |
| ខ្ទង់ថវិកា: | |
| ទីកន្លែងបំពេញការងារ: | គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត ផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាល |
| រយៈពេល: | ១ ឆ្នាំ (ដោយមានការត្រួតពិនិត្យការអនុវត្តប្រចាំឆ្នាំ) |

**ទិដ្ឋភាពទូទៅ**

គោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺស្ថិតនៅក្រោមអំណាច និងការគ្រប់គ្រងទាំងស្រុងរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប)។ អង្គភាពគាំទ្រកម្មវិធីរបស់លេខាធិការដ្ឋាន គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ទទួលខុសត្រូវក្នុងការអនុវត្តកម្មវិធី។ គណៈកម្មាធិការអភិវឌ្ឍជនបទខេត្តដែលដឹកនាំដោយអភិបាលខេត្តទទួលខុសត្រូវចំពោះការគ្រប់គ្រងភារកិច្ចនេះនៅថ្នាក់ខេត្ត។

គណៈកម្មាធិការអភិវឌ្ឍជនបទខេត្តបង្កើតគណៈកម្មាធិការប្រតិបត្តិ (គ.ប្រនៃ គអជប) ដើម្បីអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ និងការងារប្រចាំថ្ងៃរបស់គណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត។ គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត បង្កើតផ្នែកគ្រប់គ្រងចំនួន ៤ ដើម្បីបំពេញការទទួលខុសត្រូវផ្នែកប្រតិបត្តិរបស់ខ្លួនក្នុងការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ។ ផ្នែកទាំង៤ នោះមាន៖ (១) ផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាល (២) ផ្នែករដ្ឋបាលមូល ដ្ឋាន (៣) ផ្នែកគាំទ្របច្ចេកទេស និង (៤) ផ្នែកហិរញ្ញវត្ថុ។

គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺជាគម្រោងមួយគាំទ្រដល់ការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចរបស់រាជរដ្ឋាភិបាល ដើម្បីបែងចែកដីទៅឲ្យប្រជាពលរដ្ឋដែលគ្មានដី និងអ្នកមានដីតិចតួចតាមរយៈសម្បទានដីសង្គមកិច្ច ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់គ្រួសារក្រីក្រ និងប្រជាពលរដ្ឋងាយរងគ្រោះតាមរយៈសម្បទានដីសង្គមកិច្ចផ្អែកលើឃុំ។ គោលបំណងនៃការបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺដើម្បី:

- បែងចែកដីរដ្ឋសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ រួមជាមួយនឹងការផ្ដល់សេវាគាំទ្រ ចំពោះគ្រួសារដែលមានលក្ខណៈសម្បត្តិសមស្របដែលក្រីក្រ គ្មានដី និងមានដីតិចតួច និង
- ណែនាំ និងអនុវត្តដំណើរការឲ្យមានតម្លាភាព និងស្របតាមបទដ្ឋានដើម្បីអនុវត្តឲ្យបាន ទូលំទូលាយនូវសម្បទានដីសង្គមកិច្ចដែលផ្ដួចផ្ដើមឡើងដោយមូលដ្ឋាន។

ការអនុវត្តគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចគោរពតាមគោលការណ៍ ដូចខាងក្រោម:

- លើកកម្ពស់អភិបាលកិច្ចល្អ និងនីតិរដ្ឋ
- គាំទ្រ និងពង្រឹងរបៀបវារៈសម្រាប់ការធ្វើកំណែទម្រង់ដីធ្លីរបស់រដ្ឋាភិបាល
- ជំរុញការចូលរួមពីប្រជាពលរដ្ឋ
- ទប់ស្កាត់ការខូចខាតបរិស្ថាន
- លើកកម្ពស់តម្លាភាព និងគណនេយ្យភាព និង
- ធានាឲ្យមានកំណើនប្រកបដោយនិរន្តរភាព

ភ្នាក់ងារប្រតិបត្តិគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺជាអគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ចដែលមានមូលដ្ឋាននៅក្នុងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ យោងតាមអនុសារណៈយោគយល់ដែលបានចុះហត្ថលេខារវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងមហាផ្ទៃនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៧ លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ទទួលខុសត្រូវចំពោះរាល់ទិដ្ឋភាពប្រតិបត្តិការរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចនៅថ្នាក់ក្រោមជាតិ រួមមាន ការគ្រប់គ្រងកិច្ចសន្យា ការគ្រប់គ្រងហិរញ្ញវត្ថុ និងការត្រួតពិនិត្យ និងការវាយតម្លៃប្រតិបត្តិការ រួមទាំងដើម្បីត្រួតពិនិត្យមើលការអនុវត្តនៅក្នុងក្របខ័ណ្ឌនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) អនុវត្តការទទួលខុសត្រូវនេះតាមរយៈគណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត ។

**មន្ត្រីគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាលគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច** គឺជាបុគ្គលិកនៃផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាលគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្តដែលទទួលខុសត្រូវជួយដល់ប្រធានផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាលគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្តក្នុងការបំពេញភារកិច្ចគ្រប់គ្រងកិច្ចសន្យាក្រោមគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។

## ការគ្រប់គ្រងមុខតំណែង

មន្ត្រីគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាលគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចធ្វើការស្ថិតក្រោមការត្រួតពិនិត្យផ្ទាល់ពីប្រធានផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាល។

## សហប្រតិបត្តិការបច្ចេកទេស

មន្ត្រីគ្រប់គ្រងកិច្ចសន្យានិងរដ្ឋបាលគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចត្រូវបានគាំទ្រដោយអ្នកផ្តល់ប្រឹក្សាប្រតិបត្តិនៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចថ្នាក់ខេត្ត។

## ភារកិច្ចជាក់លាក់

ភារកិច្ចជាក់លាក់របស់មន្ត្រីគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាលនៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចមានដូចខាងក្រោមៈ

១. ជួយដល់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុមការងារថ្នាក់ស្រុក ក្រុមប្រឹក្សាឃុំ និងភ្នាក់ងារផ្សេងៗទៀតក្នុងការរៀបចំការដាក់បញ្ជូនផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំសម្រាប់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។

២. ជួយដល់ប្រធានផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាលគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្តក្នុងការទទួល ពិនិត្យ និងសម្របសម្រួលឯកសារបញ្ជូនមកពីភ្នាក់ងារដែលបានលើកឡើងនៅក្នុងចំណុចទី (១) ខាងលើ ដើម្បីដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំថ្នាក់ខេត្តរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។

៣. ជួយដល់ប្រធានផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាលគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្តក្នុងការពិនិត្យសំណើកិច្ចសន្យា និងការកែសម្រួលមួយចំនួនដែលដាក់ជូនដោយភ្នាក់ងារអនុវត្តឲ្យត្រូវតាមពេលវេលាកំណត់។

៤. ធ្វើការសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយនឹងផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាលគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត/ស្ថាប័នត្រួតពិនិត្យតាមដាន និងវាយតម្លៃ និងមន្ត្រីផ្នែកផ្សេងៗទៀត និងដោយមានការចូលរួមពីបុគ្គលិកស្ទួលមកពីភ្នាក់ងារអនុវត្តមួយចំនួនដើម្បីត្រួតពិនិត្យតាមដានការអនុវត្តកិច្ចសន្យាដែលបានអនុម័តក្រោមគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយប្រសិទ្ធភាព និងរាយការណ៍ជូនគណៈកម្មាធិការប្រតិបត្តិ។

៥. ជួយដល់ប្រធានផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាលគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត ក្នុងការត្រួតពិនិត្យរបាយការណ៍វិវឌ្ឍន៍ដែលដាក់ជូនដោយភ្នាក់ងារអនុវត្ត និងបូកសរុបរបាយការណ៍ទាំងនេះដើម្បីត្រួតពិនិត្យ និងតាមដានបន្ត។

៦. ជួយក្នុងការថែរក្សាប្រព័ន្ធចុះបញ្ជីដើម្បីរក្សាសុវត្ថិភាពរាល់ទិន្នន័យ និងឯកសារកិច្ចសន្យាទាំងអស់ដែលធ្វើឡើងរវាងគណៈកម្មាធិការប្រតិបត្តិ និងភ្នាក់ងារអនុវត្ត។
៧. អនុវត្តភារកិច្ចផ្សេងៗទៀតតាមការស្នើរបស់ប្រធានផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាលគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត ។

**លក្ខណសម្បត្តិ**

១. ជាមន្ត្រីរាជការថ្នាក់ខេត្តដែលមានកម្រិតវប្បធម៌ចាប់ពីមធ្យមសិក្សា ឬ ខ្ពស់ជាងនេះបូករួមនឹងបទពិសោធន៍ការងារសមស្រប។
២. មានចំណេះដឹងល្អទាក់ទងនឹងលេខនព្វន្ត
៣. មានជំនាញល្អក្នុងការសរសេររបាយការណ៍ និងទំនាក់ទំនង
៤. ជាមន្ត្រីរាជការ
៥. អាចជាស្ត្រី ឬ បុរស

# លក្ខខណ្ឌការងារ

មុខតំណែង: មន្ត្រីហិរញ្ញវត្ថុគម្រោងឡាសិត

ឈ្មោះគម្រោង: គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច

ខ្ទង់ថវិកា:

ទីកន្លែងបំពេញការងារ: គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត ផ្នែកហិរញ្ញវត្ថុ

រយៈពេល: ១ ឆ្នាំ (ដោយមានការត្រួតពិនិត្យការអនុវត្តប្រចាំឆ្នាំ)

## ទិដ្ឋភាពទូទៅ

គោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការគឺស្ថិតនៅក្រោមអំណាច និងការគ្រប់គ្រងទាំងស្រុងរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប)។ អង្គភាពគាំទ្រកម្មវិធីរបស់លេខាធិការដ្ឋានគណៈកម្មាធិការ ជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ទទួលខុសត្រូវក្នុងការអនុវត្តកម្មវិធី។ គណៈកម្មាធិការអភិវឌ្ឍជនបទខេត្តដែលក្រោមការដឹកនាំដោយអភិបាលខេត្តទទួលខុសត្រូវចំពោះការគ្រប់គ្រង ភារកិច្ច ទាំងនេះនៅថ្នាក់ខេត្ត។

គណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត បានបង្កើតគណៈកម្មាធិការប្រតិបត្តិ (គណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត) ដើម្បីអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ និងការងារប្រចាំថ្ងៃរបស់គណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត។ គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្តបានបង្កើតផ្នែកគ្រប់គ្រងចំនួនបួនដើម្បីបំពេញការអនុវត្តការទទួលខុសត្រូវរបស់ខ្លួនក្នុងការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ។ ផ្នែកទាំងបួននោះមានៈ (១) ផ្នែកគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាល (២) ផ្នែករដ្ឋបាលមូលដ្ឋាន (៣) ផ្នែកគាំទ្របច្ចេកទេស និង(៤) ផ្នែកហិរញ្ញវត្ថុ។

គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច (ការបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច) គឺជាគម្រោងមួយសម្រាប់គាំទ្រការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចរបស់រាជរដ្ឋាភិបាលដើម្បីបែងចែកដីទៅឲ្យប្រជាពលរដ្ឋដែលគ្មានដីធ្លី និងអ្នកខ្វះខាតដីធ្លីតាមរយៈសម្បទានដីសង្គមកិច្ច ដើម្បីលើកកម្ពស់ជីវភាពគ្រួសារក្រីក្រ និងក្រុមអ្នកដែលងាយរងគ្រោះតាមរយៈសម្បទានដីសង្គមកិច្ចដែលមានមូលដ្ឋាននៅក្នុងឃុំ។ គោលបំណងនៃការបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺដើម្បី:

- បែងចែកដីរដ្ឋដែលសមស្របសម្រាប់កសិកម្ម រួមជាមួយនឹងសេវាគាំទ្រសមស្របដល់គ្រួសារគ្មានដី និងខ្វះខាតដីធ្លីពិតប្រាកដ និង

- ណែនាំ និងអនុវត្តនូវដំណើរការប្រកបដោយតម្លាភាព និងបទដ្ឋានសម្រាប់ការអនុវត្តដែលទូលំទូលាយលើសម្បទានដីសង្គមកិច្ចដែលបានចាប់ផ្តើមនៅតាមមូលដ្ឋាន។

ការអនុវត្តនៃការបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គោរពតាមគោលការណ៍ ដូចខាងក្រោម:

- លើកកម្ពស់អភិបាលកិច្ចល្អ និងនីតិរដ្ឋ
- គាំទ្រ និងពង្រឹងរបៀបវារៈកំណែទម្រង់ដីធ្លីរបស់រដ្ឋាភិបាល
- លើកទឹកចិត្តឲ្យមានការចូលរួមពីប្រជាពលរដ្ឋ
- បង្ការការខូចខាតដល់បរិស្ថាន
- លើកកម្ពស់នូវតម្លាភាព និងគណនេយ្យភាព និង
- ធានាបាននូវការរីកចម្រើនប្រកបដោយនិរន្តរភាព។

ភ្នាក់ងារប្រតិបត្តិសម្រាប់ការបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច គឺជាអគ្គលេខាធិការដ្ឋានសម្រាប់សម្បទានដីសង្គមកិច្ច (អគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ច ) ដែលមានមូលដ្ឋាននៅក្នុងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ យោងតាមអនុសារណៈយោគយល់គ្នា ដែលបានចុះហត្ថលេខារវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងមហាផ្ទៃនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៧ បានចែងថា លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ទទួលខុសត្រូវនូវរាល់ទិដ្ឋភាពប្រតិបត្តិការសម្រាប់ការបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចនៅថ្នាក់ក្រោមជាតិ រួមមានការគ្រប់គ្រងកិច្ចសន្យា ការគ្រប់គ្រងហិរញ្ញវត្ថុ និងការត្រួតពិនិត្យ និងការវាយតម្លៃប្រតិបត្តិ ក៏ដូចជាការទទួលខុសត្រូវ ចំពោះការត្រួតពិនិត្យលើការអនុវត្តនៅក្នុងក្របខ័ណ្ឌនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) អនុវត្តការទទួលខុសត្រូវនេះ តាមរយៈគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត ។

**មន្ត្រីហិរញ្ញវត្ថុនៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច** គឺជាបុគ្គលិកផ្នែកហិរញ្ញវត្ថុរបស់គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត ដែលទទួលខុសត្រូវជួយដល់ប្រធានផ្នែកហិរញ្ញវត្ថុក្នុងភារកិច្ចគ្រប់គ្រងកិច្ចសន្យាដែលស្ថិតក្រោមគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច។

## ការគ្រប់គ្រងមុខតំណែង

មន្ត្រីហិរញ្ញវត្ថុរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចធ្វើការងារស្ថិតក្រោមការត្រួតពិនិត្យផ្ទាល់របស់ប្រធានផ្នែកហិរញ្ញវត្ថុ។

## សហប្រតិបត្តិការបច្ចេកទេស

មន្ត្រីគ្រប់គ្រងកិច្ចសន្យា និងរដ្ឋបាលរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចទទួលបានការជួយពីសំណាក់អ្នកផ្តល់ប្រឹក្សាហិរញ្ញវត្ថុរបស់គម្រោងគាំទ្រការអភិវឌ្ឍតាមបែបវិមជ្ឈការ។

## ភារកិច្ចជាក់លាក់

ភារកិច្ចជាក់លាក់របស់បុគ្គលិកហិរញ្ញវត្ថុនៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច មានដូចខាងក្រោម :

១. ចូលរួមក្នុងការរៀបចំ និងត្រួតពិនិត្យផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដើម្បីធានានូវសង្គតភាពរវាងការបែងចែកថវិកា និងធនធាន

